# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បទល្មើសព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **តិត្ថ ធី ថាត**

**លោក ផាត ផានេត**

ណែនាំដោយ

សាស្ត្រាចារ្យ **ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២៤** (បង់ថ្លៃ)

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ក្រុមសិក្សាស្រាវជ្រាវអាត្មាភាព/ខ្ញុំបាទទាំងពីរអង្គ/នាក់ មានឈ្មោះ **ធី ថាត** និង **ផាត ផានេត** ជាសមណនិស្សិត/និស្សិត ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី ២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ជាដំបូងអាត្មាភាព/ខ្ញុំបាទទាំងពីរអង្គ/នាក់ សូមគោរពលំឱនកាយវាចាចិត្តសម្តែងនូវគារវកិច្ច និងមហាកតញ្ញូតាធម៌គោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ ៖

| | | | |
|---|---|---|---|
| លោកឪពុក | **ឈិត ធី** | អ្នកម្តាយ | **ម៉ោង សំអាត** |
| លោកឪពុក | **ស៊ឹម ផាត** | អ្នកម្តាយ | **ស៊ាន សារុំ** |

កូនទាំងទ្វេសូមអនុញ្ញាតសម្តែងនូវការដឹងគុណចំពោះ គុណូបការៈដ៏ធំធេងបំផុតមិនអាចកាត់ថ្លៃបានរបស់លោកឪពុក អ្នកម្តាយទាំងទ្វេ ដែលលោកទាំងទ្វេបានផ្តល់កំណើតដល់រូបយើងខ្ញុំ ហើយលោកបានចំណាយពេលវេលា និងខិតខំបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្តីដោយមិនគិតពីភាពនឿយហត់ឡើយ ។

សូមថ្លែងអំណរគុណជូនចំពោះ ឯកឧត្តមបណ្ឌិត **លុយ ចន្ធា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោកលោកស្រី សាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការអប់រំបណ្តុះបណ្តាលយ៉ាងយកចិត្តទុកដាក់ និងលើកទឹកចិត្តអាត្មាភាព/ខ្ញុំបាទ ទាំងពីរអង្គ/នាក់នៅក្នុងការសិក្សា ដើម្បីជាគ្រឹះ និងជាស្ពានចម្លងយើងខ្ញុំឱ្យទទួលបានពុទ្ធិច្បាស់លាស់។

ជាពិសេសសូមថ្លែងអំណរគុណជូនចំពោះលោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** ជាសាស្ត្រាចារ្យច្បាប់នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយក៏ជាសាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ដែលលោកបានយកចិត្តទុកដាក់ក្នុងការបង្ហាញ ការណែនាំ និងផ្តល់នូវយោបល់ ឬអនុសាសន៍ល្អៗ ដល់យើងខ្ញុំទាំងពីរក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ តាំងពីដើមរហូតដល់ចប់។

សូមថ្លែងអំណរគុណផងដែរចំពោះលោកមេធាវី **ខែត ស៊ីណាត** ដែលបានណែនាំចំណុចមួយចំនួនបន្ថែម ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងជាលំដាប់ ហើយជាពិសេសទៀតនោះគាត់បានលើកទឹកចិត្ត និងជម្រុញឱ្យបន្តព្យាយាមស្រាវជ្រាវចំណុចថ្មីៗបន្ថែមទៀតផងដែរ។

ជាទីបញ្ចប់នេះ អាត្មាភាព/ខ្ញុំបាទ ទាំងពីរអង្គ/នាក់ សូមការអនុញ្ញាត ដើម្បីបានគោរពបទន់កាយ លើកហត្ថាទាំងទ្វេ ប្រណម្យបួងសួង និងសូមប្រសិទ្ធពរជ័យ ព្រមទាំងសម្តែងនូវសេចក្តីដឹងគុណជូនចំពោះ អ្នកមានគុណទាំងពីរ និងថ្នាក់ដឹកនាំនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ស្ថិតនៅក្នុងបរិបទនៃសង្គមរស់នៅ មនុស្សគ្រប់រូបតែងតែប្រាថ្នាចង់បានសេចក្តីសុខសន្តិភាព សិទ្ធិសេរីភាព ហើយក៏ពុំដែលប្រាថ្នាឲ្យបុគ្គលដទៃមករំលោភបំពានលើខ្លួនឡើយ។ ដូចនេះហើយបានជា អាត្មាភាពឈ្មោះ **ធី ថារត** និងខ្ញុំបាទឈ្មោះ **ផាត ផានេត** ជាសមណនិស្សិត/និស្សិត ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី ២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០-២០២៤ មានសេចក្តីរីករាយជាពន់ពេក ក្នុងការទទួលបានឱកាសសរសេរសារណាបញ្ចប់ការសិក្សាទៅលើ **ប្រធានបទ បទល្មើសព្រហ្មទណ្ឌ** ដោយមានគោលបំណងចង់សិក្សាឈ្វេងយល់ឲ្យបានកាន់តែស៊ីជម្រៅបន្ថែមលើអំពើទាំងឡាយណាដែលបានបង្កព្យសកម្មដល់រូបរាងកាយ ឬបេតិកភណ្ឌរបស់អ្នកដទៃ ដែលអាចចាត់ជាបទល្មើសព្រហ្មទណ្ឌ ឬពុំមែនជាបទល្មើសព្រហ្មទណ្ឌ។ ព្រមទាំងការកំណត់ឲ្យបានជាក់លាក់ពីបុគ្គលដែលជា នីតិបុគ្គល ឬរូបវន្តបុគ្គលដែលបានប្រព្រឹត្តិ និងបង្កព្យសកម្មនោះ ថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះទង្វើរបស់ខ្លួន ឬមិនទទួលខុសត្រូវ។ លើសពីនេះទៀតនោះ យើងក៏បានស្រាវជ្រាវឈានដល់ការអនុវត្តទោសផងដែរ ព្រោះកាលណាបុគ្គល មិនថារូបវន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវបានចាត់ថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌគឺបុគ្គលនោះនឹងត្រូវទទួលទោសព្រហ្មទណ្ឌទៅតាមការកំណត់ដោយក្រមព្រហ្មទណ្ឌដែលនៅជាធរមានស្រាប់ ។

ការខិតខំប្រឹងប្រែងស្រាវជ្រាវមួយនេះ អាត្មាភាព/ខ្ញុំបាទមានជំនឿជឿជាក់ហើយសង្ឃឹមថានឹងក្លាយជាកត្តាលិករក្នុងការចូលរួមចំណែកមួយផ្នែក ដើម្បីជាពុទ្ធិថ្មីក្នុងការពង្រឹងវិស័យច្បាប់នៅកម្ពុជា ឲ្យរឹតតែបន្តមានភាពប្រសើរឡើង ពីមួយកម្រិតទៅមួយកម្រិតទៀត ព្រមទាំងបង្កើនការអភិវឌ្ឍធនធានមនុស្សក្នុងប្រទេស និងកាត់បន្ថយបទល្មើសនានាក្នុងសង្គម ដើម្បីអាចបង្កើនភាពសុខដុមរមនា សណ្តាប់ធ្នាប់ល្អ ក្នុងសង្គមផងដែរ។ ជាពិសេសនោះ ចំពោះនិស្សិតជំនាន់ក្រោយៗ ដែលចង់សិក្សាស្រាវជ្រាវ សៀវភៅនេះអាចចូលរួមចំណែកជាឯកសារជំនួយបន្ថែមបានផងដែរ។

ក្នុងការសរសេរអំពីប្រធានបទនេះពិតនឹងមានចំណុចខ្វះខាត ឬខ្វះចន្លោះមួយចំនួនដែលនេះជាការស្រាវជ្រាវបឋមនៃយើងខ្ញុំ ហេតុនេះសូមអធ្យាស្រ័យទុកជាមុនចំពោះសាស្ត្រាចារ្យដែលជាគណកម្មាការ សាស្ត្រាចារ្យនានា និងអ្នកសិក្សាស្រាវជ្រាវ ឬសាធារណៈទាំងអស់ដែលមានចំណេះដឹងជ្រៅជ្រះលើប្រធានបទនេះ ប្រសិនបើមានការខុសឆ្គងត្រង់ប្រការណាមួយក្នុងការសរសេរសារណានេះ។ ហើយយើងខ្ញុំទាំងពីររង់ចាំទទួលការរិះគន់ពីគ្រប់មជ្ឈដ្ឋាននានាដើម្បីកែសម្រួលលើសៀវភៅនេះឱ្យកាន់តែមានភាពប្រសើរឡើងមួយកម្រិតទៀត។

យើងខ្ញុំ សូមសំដែងទឹកចិត្តដ៏ស្មោះស្ម័គ្រនូវសេចក្តីគោរពជូនដល់ជនរួមជាតិទាំងអស់នៅគ្រប់ទិសទីដែលផ្តល់ការលើកទឹកចិត្ត ការណែនាំ និងការគាំទ្រមតិយោបល់យ៉ាងរីករាយកក់ក្តៅសម្រាប់យើងខ្ញុំក្នុងការចងក្រងសៀវភៅនេះឡើង។

# មាតិកា


**សេចក្ដីផ្ដើម** ........ ១

## ជំពូកទី ១ ៖ បទល្មើសព្រហ្មទណ្ឌ

**ផ្នែកទី ១៖ សញ្ញាណទូទៅនៃបទល្មើស** ........ ៤

១. និយមន័យនៃបទល្មើសព្រហ្មទណ្ឌ ........ ៤

២. លក្ខណៈវិនិច្ឆ័យអំពីបទល្មើស ........ ៤

២.១ អំពើគ្រោះថ្នាក់ដល់សង្គម ........ ៥

២.២ អំពើដែលមានកំហុស ........ ៥

២.៣ អំពើដែលផ្ទុយច្បាប់ព្រហ្មទណ្ឌ ........ ៥

២.៤ អំពើដែលត្រូវទទួលទោសព្រហ្មទណ្ឌ ........ ៦

៣. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងបទល្មើសដទៃ ........ ៦

៣.១ ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណី ........ ៦

៣.២ ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យ ........ ៨

**ផ្នែកទី ២៖ ធាតុផ្សំនៃបទល្មើស** ........ ១០

១. ធាតុនីត្យានុកូល ឬធាតុច្បាប់ ........ ១១

១.១ អត្ថន័យនៃធាតុនីត្យានុកូល ........ ១១

១.២ គោលការណ៍នីត្យានុកូលភាព ........ ១២

ក. នីត្យានុកូលភាពនៃបទល្មើស ........ ១២

ខ. នីត្យានុកូលភាពនៃទោស ........ ១២

គ. គោលបំណងនៃគោលការណ៍នីត្យានុកូលភាព ........ ១៣

គ.១ បទប្បញ្ញត្តិគ្រឹះដើម្បីការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ........ ១៣

គ.២ បទប្បញ្ញត្តិគ្រឹះដើម្បីបង្ការទុកជាមុននូវបទល្មើសព្រហ្មទណ្ឌ ........ ១៤

១.៣ ការអនុវត្តច្បាប់ព្រហ្មទណ្ឌទូទៅ ........ ១៤

ក. ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល ........ ១៤

ក.១ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង ........ ១៥

ក.២ គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ........ ១៦

ខ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហ ឬដែនដី ........ ១៨

ខ.១ បទល្មើសដែលបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅក្នុងដែនដីកម្ពុជា........................................១៨
ខ.២ ស្ថានភាពទាំងប្រាំនៃបទល្មើសដែលចាត់ថាបានប្រព្រឹត្តនៅក្នុងដែនដីកម្ពុជា ................................ ១៩
ខ.៣ បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីកម្ពុជា ...................................................................២១
១.៤ ការអនុវត្តច្បាប់ព្រហ្មទណ្ឌដោយតុលាការ.................................................................................... ២២
ក. ការវាយតម្លៃកំណត់បទល្មើស........................................................................................................២៣
ខ. ការបកស្រាយច្បាប់ព្រហ្មទណ្ឌ ......................................................................................................២៣
២. ធាតុសត្យានុម័ត ឬធាតុសម្ភារៈ.......................................................................................................... ២៤
២.១ អត្ថន័យនៃធាតុសត្យានុម័ត ............................................................................................................. ២៤
២.២ បទល្មើសបានសម្រេច ..................................................................................................................... ២៥
ក. បទល្មើសសកម្ម ឬអំពើវិជ្ជមាន ......................................................................................................២៥
ខ. បទល្មើសអកម្ម ឬអំពើអវិជ្ជមាន .....................................................................................................២៥
២.៣ បទល្មើសមិនបានសម្រេច ឬការប៉ុនប៉ង ............................................................................................. ២៥
ក. ដំណាក់កាលនៃការប្រព្រឹត្តបទល្មើស.................................................................................................២៦
ក.១ ដំណាក់កាលគិត និងការសម្រេចចិត្ត.....................................................................................២៦
ក.២ ដំណាក់កាលត្រៀមប្រព្រឹត្តបទល្មើស ......................................................................................២៦
ក.៣ ដំណាក់កាលចាប់ផ្តើមប្រព្រឹត្តបទល្មើស....................................................................................២៧
ក.៤ ដំណាក់កាលបទល្មើសបានសម្រេច ឬមិនបានសម្រេច......................................................................២៧
ខ. ការប៉ុនប៉ង ..................................................................................................................................២៨
ខ.១ លក្ខខណ្ឌនៃការប៉ុនប៉ង ........................................................................................................២៨
ខ.២ ទណ្ឌកម្មចំពោះការប៉ុនប៉ង.......................................................................................................៣០
៣. ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ....................................................................................................... ៣០
៣.១ អត្ថន័យនៃធាតុអត្តនោម័ត ...............................................................................................................៣១
៣.២ កំហុសព្រហ្មទណ្ឌ.............................................................................................................................៣១
ក. កំហុសដោយចេតនា........................................................................................................................ ៣១
ក.១ ចេតនាទុច្ចរិតទូទៅ ................................................................................................................ ៣១
ក.២ ចេតនាទុច្ចរិតពិសេស ............................................................................................................ ៣១
ក.៣ ចេតនាទុច្ចរិតធ្ងន់ធ្ងរ ឬចេតនាដោយការគ្រោងទុក ............................................................................ ៣២

ក.៤ ចេតនាទុច្ចរិតច្បាស់លាស់ និងមិនច្បាស់លាស់ ........ ៣២
ក.៥ ចេតនាទុច្ចរិតចំពោះ និងមិនចំពោះ ........ ៣២
ខ. កំហុសដោយអចេតនា ........ ៣៣
៣.៣ ការវាយតម្លៃអំពីកំហុសចេតនា និងអចេតនា ........ ៣៤
**ផ្នែកទី៣ ៖ ចំណាត់ថ្នាក់បទល្មើស** ........ ៣៥
១. ចំណាត់ថ្នាក់តាមក្រមព្រហ្មទណ្ឌ ........ ៣៥
១.១ លក្ខណៈវិនិច្ឆ័យនៃការបែងចែក ........ ៣៦
ក. បទឧក្រិដ្ឋ ........ ៣៦
ខ.បទមជ្ឈិម ........ ៣៦
គ.បទលហុ ........ ៣៧
១.២.ផលប្រយោជន៍នៃការបែងចែកចំណាត់ថ្នាក់ ........ ៣៨
ក. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល ........ ៣៨
ខ. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី ........ ៣៩
២. ចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទនៃបទល្មើស ........ ៣៩
២.១ បទល្មើសសាមញ្ញ និងបទល្មើសយោធា ........ ៣៩
២.២ បទល្មើសសាមញ្ញ និងបទល្មើសនយោបាយ ........ ៤០
២.៣ បទល្មើសសាមញ្ញ និងបទល្មើសគ្រឿងញៀន ........ ៤១
៣. ចំណាត់ថ្នាក់ដោយផ្អែកលើបែបបទនៃការប្រព្រឹត្តបទល្មើស ........ ៤២
៣.១ ចំណាត់ថ្នាក់បទល្មើសផ្អែកលើបែបបទទិដ្ឋភាពសត្យានុម័តនៃការប្រព្រឹត្តបទល្មើស ........ ៤២
ក. ការចាត់ថ្នាក់ទៅតាមអំពើសកម្ម និងអកម្ម ........ ៤២
ខ. ការចាត់ថ្នាក់ទៅតាមថេរៈវេលានៃការប្រព្រឹត្តបទល្មើស ........ ៤៣
គ. ចំណាត់ថ្នាក់ទៅតាមចំនួននៃអំពើនៅក្នុងបទល្មើស ........ ៤៥
ឃ. ចំណាត់ថ្នាក់ទៅតាមលទ្ធផលនៃបទល្មើស ........ ៤៧
ង. ការចាត់ថ្នាក់ទៅតាមបទល្មើសជាក់ស្តែង និងមិនជាក់ស្តែង ........ ៤៨
៣.២ ការចាត់ថ្នាក់ផ្អែកលើបែបបទជាអត្តនោម័ត ........ ៤៨
ក. បទល្មើសចេតនា ........ ៤៨
ខ. បទល្មើសអចេតនា ........ ៤៩

៤. បទល្មើសដែលគ្មានអាជ្ញាយុកាល ........ ៤៩

## ជំពូកទី ២ ៖ ការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

**ផ្នែកទី១ ៖ ជនល្មើស និងការទទួលខុសត្រូវព្រហ្មទណ្ឌ** ........ ៥០
១. ជនល្មើស ........ ៥០
១.១ សញ្ញាណនៃជនល្មើស ........ ៥០
ក. ជនល្មើសដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ (ចារី និងសហចារី) ........ ៥១
ក.១ ចារី ........ ៥១
ក.២ សហចារី ........ ៥២
ខ. ជនល្មើសដែលបានប្រព្រឹត្តបទល្មើសដោយប្រយោល ........ ៥៣
ខ.១ អ្នកផ្តើមគំនិត ........ ៥៣
ខ.២ អ្នកសមគំនិត ........ ៥៤
១.២ លក្ខខណ្ឌនៃជនល្មើស ........ ៥៦
ក. ជនល្មើសជាមនុស្ស ........ ៥៦
ខ. កំពុងរស់នៅមានជីវិត ........ ៥៦
គ. មានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ ........ ៥៧
ឃ. មានអាយុតាមការកំណត់របស់នីតិព្រហ្មទណ្ឌ ........ ៥៧
២. ការទទួលខុសត្រូវព្រហ្មទណ្ឌ ........ ៥៧
២.១ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនល្មើសជារូបវន្តបុគ្គល ........ ៥៨
ក. ជនល្មើសជានីតិជន ........ ៥៨
ខ. ជនល្មើសជាអនីតិជន ........ ៥៨
ខ.១ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ........ ៥៩
ខ.២ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ........ ៦០
២.២ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ........ ៦១
ក. នីតិបុគ្គលជារដ្ឋ ឬនីតិបុគ្គលសាធារណៈ ........ ៦១
ខ. នីតិបុគ្គលមិនមែនរដ្ឋ ឬនីតិបុគ្គលឯកជន ........ ៦២
ខ.១ មានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗចែងទុកជាមុន ........ ៦២
ខ.២ បទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់នីតិបុគ្គល ........ ៦៣

ខ.៣ ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គល ... ៦៣
**ផ្នែកទី២៖ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ** ... ៦៤
១. មូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ (ទាក់ទងនឹងចារីផ្ទាល់) ... ៦៤
១.១ មូលហេតុវិបល្លាសស្មារតី ... ៦៤
ក. ការបាត់បង់នូវការដឹងខុសត្រូវ ... ៦៥
ខ. ការបន្ថយការដឹងខុសត្រូវ ... ៦៥
គ. វិបល្លាសស្មារតីដោយសារគ្រឿងស្រវឹង ឬសារធាតុដែលច្បាប់ហាមឃាត់ ... ៦៥
១.២ មូលហេតុដោយអានុភាពនៃកម្លាំង ឬការបង្ខំ ... ៦៦
ក. ប្រភេទនៃកម្លាំង ឬការបង្ខំ ... ៦៦
ក.១ ការបង្ខំលើរូបកាយ ... ៦៦
ក.២ ការបង្ខំលើផ្លូវចិត្ត ... ៦៧
ខ. លក្ខណៈនៃកម្លាំង ឬការបង្ខំ ... ៦៧
ខ.១ កម្លាំង ឬការបង្ខំដែលមិនអាចមើលឃើញជាមុនបាន ... ៦៧
ខ.២ កម្លាំង ឬការបង្ខំត្រូវតែជៀសមិនបាន ... ៦៧
១.៣ មូលហេតុទាក់ទងនឹងអនីតិភាព ... ៦៨
២. មូលហេតុសត្យានុម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ (យុត្តិកម្មនៃបទល្មើស) ... ៦៩
២.១ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ... ៦៩
ក. ការអនុញ្ញាតដោយច្បាប់ ... ៦៩
ខ. ការអនុញ្ញាតដោយអាជ្ញាធរ ... ៧០
២.២ ការការពារស្របច្បាប់ ... ៧១
ក. លក្ខខណ្ឌនៃការការពារស្របច្បាប់ ... ៧១
ខ. ភស្តុតាងនៃការការពារស្របច្បាប់ ... ៧២
២.៣ ស្ថានភាពចាំបាច់ ... ៧៣
ក. គ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន ... ៧៤
ខ. ការការពារជាចាំបាច់ ... ៧៤
គ. ការការពារដែលគ្មានវិសមាមាត្រជាមួយនឹងទម្ងន់គ្រោះថ្នាក់ ... ៧៥
២.៤ មូលហេតុផ្សេងៗនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ... ៧៦

ក. អភ័យឯកសិទ្ធិគ្រួសារ ........ ៧៦
ខ. ករណីប្រធានសក្តិ ........ ៧៦

## ជំពូកទី ៣ ៖ ការអនុវត្តទោសព្រហ្មទណ្ឌ

**ផ្នែកទី១៖ សញ្ញាណនៃទោស** ........ ៧៧
១. និយមន័យនៃទោស ........ ៧៧
២. គោលបំណងនៃទោស ........ ៧៨
២.១ គោលបំណងនៃការការពារទុកជាមុន(បំភិតបំភ័យ) ........ ៧៨
២.២ គោលបំណងនៃការធ្វើសំណងជាប្រាក់ ........ ៧៨
២.៣ គោលបំណងនៃការអប់រំកែប្រែ ........ ៧៩
៣. ចរិតលក្ខណៈនៃទោសព្រហ្មទណ្ឌ ........ ៧៩
៣.១ ចរិតលក្ខណៈនីត្យានុកូលនៃទោស ........ ៧៩
៣.២ ចរិតលក្ខណៈសមភាពនៃទោស ........ ៨០
៣.៣ ចរិតលក្ខណៈឯកត្តជននៃទោស ........ ៨០
**ផ្នែកទី២៖ ទោសដែលត្រូវអនុវត្តចំពោះជនល្មើសជារូបវន្តបុគ្គល** ........ ៨១
១. មូលទោស ........ ៨២
១.១ មូលទោសដែលអនុវត្តចំពោះជនល្មើសជានីតិជន ........ ៨៥
១.២ មូលទោសដែលអនុវត្តចំពោះជនល្មើសជាអនីតិជន ........ ៨៥
២. ទោសបន្ថែម ........ ៨៦
២.១ ទោសបន្ថែមសម្រាប់អនុវត្តចំពោះជនល្មើសជានីតិជន ........ ៨៧
២.២ ទោសបន្ថែមសម្រាប់អនុវត្តចំពោះជនល្មើសជាអនីតិជន ........ ៨៨
៣. ទោសជំនួស ........ ៩០
៣.១ ទោសជំនួសដែលត្រូវអនុវត្តចំពោះជនល្មើសជានីតិជន ........ ៩១
ក. ទោសការងារសហគមន៍ ........ ៩១
ខ. ទោសស្តីបន្ទោស ........ ៩២
៣.២ ទោសជំនួសដែលត្រូវអនុវត្តចំពោះជនល្មើសជាអនីតិជន ........ ៩២
ក. ទោសការងារសហគមន៍ ........ ៩២
ខ. ទោសស្តីបន្ទោស ........ ៩៣

**ផ្នែកទី៣៖ ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល** ........................................ ៩៣
១. ទោសពិន័យក្នុងឋានៈជាមូលទោស........................................ ៩៣
២. ទោសបន្ថែមដែលអនុវត្តចំពោះនីតិបុគ្គល ........................................ ៩៤
**សេចក្តីសន្និដ្ឋាន** ........................................ ៩៥
**អនុសាសន៍** ........................................ ៩៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ជាការពិតណាស់នៅគ្រប់ប្រជាជាតិទាំងអស់ក្នុងពិភពលោកយើងនេះ តែងតែប្រាថ្នាចង់បានសន្តិភាព សុខសុវត្ថិភាព ស្ថេរភាពក្នុងសង្គម និងរបៀបរៀបរយល្អក្នុងប្រទេសរៀងៗខ្លួន។ ប៉ុន្តែក្នុងកាលៈទេសៈសង្គមមួយប្រមូលផ្តុំទៅដោយមនុស្សគ្រប់ទម្រង់បែបនេះ ច្បាស់ណាស់គឺមិនអាចគេចផុតពីបញ្ហាឡើយ ដែលបញ្ហានេះបានធ្វើឱ្យសង្គមមានភាពអសន្តិសុខ ឬគ្មានស្ថេរភាព បញ្ហាទាំងនោះបានកើតឡើងដោយសារអំពើនៃមនុស្ស ដែលអំពើនោះបានឈានដល់ការបង្កព្យសនកម្មដល់បុគ្គលដទៃ និងសង្គមជាតិថែមទៀតផង។

ជាក់ស្តែងនៅក្នុងទំនាក់ទំនងនៃការរស់នៅរបស់មនុស្សគ្រប់រូប គឺតែងតែមានការប្រកួតប្រជែង ដណ្តើមផលប្រយោជន៍គ្នាទៅវិញទៅមក ក្នុងគោលបំណងបំពេញសេចក្តីត្រូវការផ្ទាល់ខ្លួន ដោយកត្តានេះហើយបានធ្វើឱ្យមនុស្សហ៊ានប្រព្រឹត្តនូវអំពើដែលប្រាសចាកសីលធម៌ ហើយសង្គមបានហាមឃាត់ចំពោះអំពើនោះ។

ដោយមើលឃើញពីមូលហេតុដែលនាំឲ្យសង្គម ជួបភាពអសន្តិសុខ និងអមនុស្សធម៌ បែបនេះហើយបានជានៅក្នុងប្រទេសនីមួយៗបានបង្កើតច្បាប់មួយ ដើម្បីជាបន្ទាត់វាស់ និងខណ្ឌកំណត់នៃដែនសេរីភាពក្នុងការធ្វើសកម្មភាពរបស់បុគ្គលម្នាក់ៗមិនឱ្យលើស ឬផុតដែនកំណត់នៃសិទ្ធិសេរីភាពរបស់ខ្លួនឡើយ។ កាលណាជនណាម្នាក់ដែលបានធ្វើសកម្មភាពលើសពីសិទ្ធិសេរីភាពដែលខ្លួនមាន ហើយថែមបង្កឲ្យប៉ះពាល់សិទ្ធិរបស់បុគ្គលដទៃ ឬប៉ះពាល់ដល់សង្គមជាតិទៀតនោះ គេនឹងចាត់ទុកបុគ្គលនោះថាបានប្រព្រឹត្តបទល្មើស។

បទល្មើស គឺជាអំពើទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់បានហាមឃាត់ ប៉ុន្តែមុននិងកំណត់ជនណាម្នាក់ថាពិតជាបានប្រព្រឹត្តបទល្មើស ចាំបាច់ទាមទារឱ្យមានការកំណត់ធាតុផ្សំនៃបទល្មើស និងពិនិត្យមើលទៅលើស្ថានភាពនៃជននោះ ហើយថែមទាំងត្រូវត្រួតពិនិត្យមើលទៅលើកាលៈទេសៈដែលនាំឱ្យជននោះប្រព្រឹត្តបទល្មើសផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងបានដឹងហើយថា គ្រប់អំពើល្មើសដែលបុគ្គលណាម្នាក់បានប្រព្រឹត្ត ហើយបង្កព្យសនកម្មដល់បុគ្គលដទៃ ឬក៏សង្គមជាតិ ដោយព្យសនកម្ម ផ្លូវកាយក្តី ផ្លូវចិត្តក្តី និងសម្ភារៈក្តី ដែលធ្វើឱ្យប៉ះពាល់ធ្ងន់ក្តី ស្រាលក្តី គឺសុទ្ធសឹងតែចាត់ទុកជា បទល្មើស។ បើតាមក្រមព្រហ្មទណ្ឌ គឺចាត់ទុកបទល្មើស គឺជាអំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម គឺជាបទល្មើស ដូចនេះដោយផ្អែកតាមអត្ថន័យនៃក្រម បានចែងតែពីអំពើដែលបង្កចលាចលដល់សង្គម អាស្រ័យហេតុនេះ បង្កឱ្យមានចម្ងល់ចោទជាសំណួរថា៖

**ដើម្បីកំណត់អំពើណាមួយជាបទល្មើសបាន មានធាតុផ្សំតែអំពើមួយយ៉ាង តើគ្រប់គ្រាន់ដែរឬទេ? បើមិនគ្រប់គ្រាន់ទេ តើដើម្បីចាត់ទុកជាបទល្មើសបានត្រូវមានធាតុផ្សំអ្វីខ្លះចូលរួម?**

**បើក្នុងករណីកំណត់អំពើនោះបានជាបទល្មើសហើយ ថាតើត្រូវពិចារណាលើអ្វីខ្លះ? ដើម្បីធ្វើការសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់ ឱ្យត្រឹមត្រូវ ឬស្របតាមច្បាប់ជាធរមាន?**

**បើក្នុងករណីមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការសម្រេចចោទប្រកាន់ថាជាបទល្មើស ហើយត្រូវផ្តន្ទាទោស តើទោសដែលត្រូវអនុវត្តចំពោះជននោះមានលក្ខណៈបែបណាខ្លះ?**

## ៣.គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងក្នុងការសិក្សាស្រាវជ្រាវនៃប្រធានបទសារណានេះ គឺដើម្បីធ្វើការឈ្វេងយល់ឱ្យបានកាន់តែច្បាស់នូវភាពមិនច្បាស់មួយចំនួននៃការកំណត់ បទល្មើសព្រហ្មទណ្ឌ។ ជាពិសេសទៀតនោះ ក្នុងការសិក្សាស្រាវជ្រាវក្រុមយើងខ្ញុំបានមុជចូលជ្រៅដល់ជម្រៅនៃខ្លឹមសារអត្ថបទក្នុងការជួយពង្រឹង និងបង្កើនសមត្ថភាពលើកម្រិតនៃចំណេះដឹងដែលបានសិក្សាពីមុនខ្លះៗ ដើម្បីឱ្យបានកាន់តែល្អប្រសើរឡើង។

ហើយក៏ជាស្មារតីនៃការរួមចំណែកចូលរួមបញ្ចូលនូវស្នាដៃដែលជាសមិទ្ធផល ដែលបានពីការសិក្សាស្រាវជ្រាវដល់ អ្នកសិក្សាស្រាវជ្រាវ និងមហាជនទូទៅ ដែលមានបំណងចង់សិក្សាឈ្វេងយល់បន្ថែមក្នុង វិស័យច្បាប់នេះ ជាពិសេសទាក់ទងទៅនឹង **បទល្មើសព្រហ្មទណ្ឌ** ដែលជាប្រធានបទសារណានេះផងដែរ។

## ៤.ដែនកំណត់ និងវិសាលភាពនៃកិច្ចការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាដែលបានលើកឡើងខាងលើ ក្រុមយើងខ្ញុំបានខិតខំសិក្សាស្រាវជ្រាវទៅលើឯកសារសំខាន់ៗដូចជា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ និងឯកសារយោងដែលពាក់ព័ន្ធផ្សេងៗទៀត ដែលមានភ្ជាប់មកជាមួយ ដើម្បីសរសេរប្រធានបទសារណានេះឡើង។

យើងខ្ញុំបានសរសេរសារណានេះជា ៣ ជំពូក ពោលគឺជំពូកទី១ បទល្មើសព្រហ្មទណ្ឌ ជំពូកទី២ ការទទួលខុសត្រូវ និងមិនទទួលខុសត្រូវព្រហ្មទណ្ឌ និងជំពូកទី៣ ការអនុវត្តទោសព្រហ្មទណ្ឌ។

## ៥.វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវទៅប្រធានបទសារណាមួយនេះ ដោយយើងខ្ញុំបានអានសៀវភៅផ្នែកច្បាប់ ក៏ដូចជាស្វែងរកឯកសារនានាជាច្រើនដូចជា ច្បាប់ជាតិ ច្បាប់អន្តរជាតិ លិខិតបទដ្ឋានគតិយុត្ត និងសៀវភៅរបស់សាស្ត្រាចារ្យ ព្រមទាំងបណ្តាញផ្សព្វផ្សាយនានាជាច្រើនផ្សេងៗទៀត ដើម្បីធ្វើការសិក្សាឈ្វេងយល់ វិភាគ វិនិច្ឆ័យ ផ្ទៀងផ្ទាត់ក្នុងការជម្រេញចេញជាសៀវភៅសារណាមួយក្បាលនេះឡើង។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការបង្កឱ្យកាន់តែមានភាពងាយស្រួល និងច្បាស់លាស់ ក្នុងឈ្វេងយល់ពីប្រធានបទ សារណាបទល្មើសព្រហ្មទណ្ឌមួយនេះ ក្រុមយើងខ្ញុំសូមធ្វើការបែងចែករចនាសម្ព័ន្ធជា ៣ ជំពូកធំៗ ដូចនេះយើងខ្ញុំនឹងធ្វើការបកស្រាយខ្លះៗអំពីគោលគំនិតនៃជំពូកទាំងបីនេះ៖

**ជំពូកទី១ បទល្មើសព្រហ្មទណ្ឌ ៖** នៅត្រង់ជំពូកនេះ ក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយអំពី សញ្ញាណទូទៅនៃបទល្មើស ធាតុផ្សំនៃបទល្មើស និងចុងក្រោយនៃជំពូកនេះ គឺនឹងនិយាយអំពីចំណាត់ថ្នាក់នៃបទល្មើស។ ដូច្នេះត្រង់ជំពូកនេះ គឺនិយាយអំពីការកំណត់អំពើណាមួយជាបទល្មើស ឬក៏អាចហៅថាដំណាក់កាលដំបូង។

**ជំពូកទី២ ការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវ ៖** ត្រង់ជំពូកនេះវិញ ក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយអំពី **ផ្នែកទី១** ជនល្មើស និងការទទួលខុសត្រូវព្រហ្មទណ្ឌ និង**ផ្នែកទី២** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ ចំពោះជំពូកនេះ គឺនិយាយក្រោយពីបានកំណត់ថាជាបទល្មើសហើយ តុលាការត្រូវពិចារណាថាជននោះគួរទទួលខុសត្រូវ ឬក៏មិនទទួលខុសត្រូវ យើងអាចហៅថាដំណាក់កាលក្រោយពីបានកំណត់បទល្មើសរួចរាល់។

**ជំពូកទី៣ ការអនុវត្តទោសព្រហ្មទណ្ឌ ៖** ជំពូកចុងក្រោយនេះ គឺយើងនឹងបកស្រាយអំពី សញ្ញាណនៃទោស ទោសដែលត្រូវអនុវត្តចំពោះជនល្មើសជារូបវន្តបុគ្គល និងទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល ឬអាចនិយាយបានថា បើតុលាការសម្រេចចោទប្រកាន់ថាអំពើណាមួយជាបទល្មើសហើយ នោះតុលាការនឹងត្រូវកំណត់ទោស ដើម្បីផ្តន្ទាទោសជនដែលបានប្រព្រឹត្តនោះ។

# ជំពូកទី ១
# បទល្មើសព្រហ្មទណ្ឌ

# ជំពូកទី១
# បទល្មើសព្រហ្មទណ្ឌ

នៅក្នុងជំពូកនេះយើងនឹងធ្វើការសិក្សាទៅលើចំណុចសំខាន់ៗ ដែលទាក់ទងទៅនឹង បទល្មើសព្រហ្មទណ្ឌ ដែលចំណុចទាំងនោះមាន សញ្ញាណទូទៅនៃបទល្មើស (**ផ្នែកទី១**) ធាតុផ្សំនៃបទល្មើស (**ផ្នែកទី២**) និងចំណាត់ថ្នាក់នៃបទល្មើស (**ផ្នែកទី៣**)។ ដូចនេះ ថាតើការកំណត់អំពើណាមួយជាបទល្មើសបាន តើត្រូវឆ្លងកាត់ការវិនិច្ឆ័យបែបណាខ្លះ? ដើម្បីឱ្យកាន់តែច្បាស់សូមមកឈ្វេងយល់នៅចំណុចដូចបានបកស្រាយខាងក្រោម។

## ផ្នែកទី ១៖ សញ្ញាណទូទៅនៃបទល្មើស

ក្នុងផ្នែកទី១ ដែលនិយាយអំពីសញ្ញាណទូទៅនៃបទល្មើស យើងខ្ញុំនឹងនិយាយអំពីចំណុចសំខាន់ៗ ចំនួន ៣ ប្រភេទ ដែលចំណុចទាំងនោះរួមមានដូចជា៖ និយមន័យនៃបទល្មើស (**១**) លក្ខណៈវិនិច្ឆ័យអំពីបទល្មើស (**២**) និងភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ ជាមួយនឹងបទល្មើសដទៃ (**៣**)។ អាស្រ័យដូចនេះថាតើអ្វីជាបទល្មើសព្រហ្មទណ្ឌ? ហើយលក្ខណៈវិនិច្ឆ័យអំពីបទល្មើសព្រហ្មទណ្ឌមានអ្វីខ្លះ? ហើយថាតើបទល្មើសព្រហ្មទណ្ឌ និងបទល្មើសដទៃខុសគ្នាដូចម្តេច? ហេតុនេះហើយយើងនឹងធ្វើការបកស្រាយដូចតទៅ ៖

### ១. និយមន័យនៃបទល្មើសព្រហ្មទណ្ឌ

ដោយផ្អែកទៅតាមអត្ថន័យទូទៅយើងអាចនិយាយបានថា បទល្មើសព្រហ្មទណ្ឌគឺជា អំពើទាំងឡាយណាដែលប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌ ឬក៏គេអាចនិយាយម្យ៉ាងទៀតថាជាអំពើបំពានច្បាប់ព្រហ្មទណ្ឌ។ បទល្មើសព្រហ្មទណ្ឌគឺជាអំពើដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់ព្រោះថា អំពើទាំងនោះបង្កចលាចលដល់សង្គមធ្ងន់ធ្ងរ ឬប៉ះពាល់សេរីភាពរបស់ប្រជាពលរដ្ឋ ការប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌហាមឃាត់នេះត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ។ តាមអត្ថន័យទូទៅនេះយើងអាចពិនិត្យឃើញថា ជនណាដែលប្រព្រឹត្តផ្ទុយ ឬបំពានច្បាប់ព្រហ្មទណ្ឌ ជននោះនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

បើតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ បានឱ្យនិយមន័យបទល្មើសនៅត្រង់មាត្រា ២ ថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស មានន័យថា បទល្មើសជាអំពើទាំងឡាយណាដែលបានប្រព្រឹត្តដោយបុគ្គលណាម្នាក់ ឬច្រើននាក់ ហើយអំពើនោះបានបង្កចលាចលដល់សង្គមដូចជា ខូចខាតសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ បង្កអសន្តិសុខនៅក្នុងសង្គម ឬក៏ប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋជាដើម។

### ២. លក្ខណៈវិនិច្ឆ័យអំពីបទល្មើស

នៅក្នុងចំណុចនៃ លក្ខណៈវិនិច្ឆ័យអំពីបទល្មើស ឬអាចនិយាយបានថាចរិតនៃ បទល្មើស យើងខ្ញុំនឹង

ធ្វើការបង្ហាញនូវចំណុចមួយចំនួនដូចជា៖ អំពើគ្រោះថ្នាក់ដល់សង្គម (២.១) អំពើដែលមានកំហុស (២.២) អំពើដែលផ្ទុយច្បាប់ព្រហ្មទណ្ឌ (២.៣) និងអំពើដែលត្រូវទទួលទោសព្រហ្មទណ្ឌ (២.៤)។

**២.១ អំពើគ្រោះថ្នាក់ដល់សង្គម**

ចំពោះអំពើគ្រោះថ្នាក់ដល់សង្គមនៃបទល្មើសព្រហ្មទណ្ឌ គឺយើងបានដឹងហើយថាបទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលបង្កអន្តរាយដល់ទំនាក់ទំនងនៅក្នុងសង្គម ដែលទំនាក់ទំនងទាំងនោះមានដូចជា ប្រជាពលរដ្ឋ សិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ និងផលប្រយោជន៍ស្របច្បាប់ ទាំងផលប្រយោជន៍ឯកជន និងផលប្រយោជន៍សាធារណៈ ព្រមទាំងសន្តិសុខសុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងសង្គម។

ចំពោះបទល្មើសមួយចំនួនគឺ បានបង្កអន្តរាយដល់មនុស្សដូចជា រងរបួស ឬស្លាប់បាត់បង់ជីវិត ហើយបទល្មើសខ្លះធ្វើឱ្យប៉ះពាល់នូវសិទ្ធិ សេរីភាព និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ លើសពីនេះទៀត បទល្មើសខ្លះបានបង្កការប៉ះពាល់ដល់ផលប្រយោជន៍ទាំងឡាយដូចជា សម្ភារៈ ឧបករណ៍ប្រើប្រាស់ និងជាពិសេសនោះ បង្កផលប៉ះពាល់ដល់ស្ថិរភាពនយោបាយ សេដ្ឋកិច្ច សង្គម និងសន្តិសុខសង្គមផងដែរ។ យើងអាចពិនិត្យឃើញថារាល់បទល្មើសដែលកើតឡើងគឺ ធ្វើឱ្យមានការប្រែប្រួលនូវទំនាក់ទំនងសង្គម ដែលបង្ហាញពីការអន្តរាយ មិនថាអន្តរាយតិចតួច ឬច្រើន ដែលធ្វើឱ្យសង្គមចលាចល សង្គមរងនូវការប៉ះទង្គិច និងមានគ្រោះថ្នាក់ជាដើម។

ហេតុនេះហើយមិនថា ប្រជាពលរដ្ឋ ឬរដ្ឋនោះទេ ត្រូវរួមគ្នាប្រយុទ្ធប្រឆាំង ការពារ និងទប់ស្កាត់រាល់បទល្មើសដែលបានកើតឡើង ឬប្រុងនឹងកើតឡើង ហើយក្នុងការទប់ស្កាត់ដែលមានប្រសិទ្ធភាពបំផុត គឺស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នពាក់ព័ន្ធ ត្រូវស្រាវជ្រាវបន្ថែមក្នុងការអនុម័តច្បាប់ឱ្យទាន់ទៅតាមការរីកចម្រើនរបស់សង្គម។

**២.២ អំពើដែលមានកំហុស**

អំពើដែលមានកំហុស គឺជាអំពើប្រព្រឹត្តដោយចេតនា ឬអចេតនា ដែលបង្កការខូចខាតដល់អ្នកដទៃ។ កំហុសចេតនា ជាអំពើបំពានដោយព្យាករទុកជាមុនថានឹងមានលទ្ធផលកើតឡើង ហើយទទួលយកលទ្ធផលនោះ ចំណែកកំហុសអចេតនា គឺជាការបំពានលើករណីកិច្ចប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ហើយបណ្តាលឱ្យមានព្យសនកម្មកើតឡើង។ រាល់គ្រប់អំពើដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សង្គមគឺ កើតឡើងដោយមានកំហុស ដែលកំហុសទាំងនោះអាចមានទាំង កំហុសចេតនា និងកំហុសអចេតនា។

**២.៣ អំពើដែលផ្ទុយច្បាប់ព្រហ្មទណ្ឌ**

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់ព្រោះថា អំពើទាំងនោះបង្កចលាចលដល់សង្គមធ្ងន់ធ្ងរ ឬប៉ះពាល់សេរីភាពរបស់ប្រជាពលរដ្ឋ ការប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌហាមឃាត់នេះគឺជាបទល្មើស។ តាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា មានតែអំពើដែលបង្កើតជាបទល្មើស នៅ

ពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ ចំពោះ ទោសវិញក៏ដូចគ្នាគឺ មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន។ ដោយគោរពតាមគោលការណ៍ខាងលើនេះគឺថា ដើម្បីចោទប្រកាន់អំពើណាមួយជាបទល្មើសបានលុះត្រាតែច្បាប់មានចែងទុកជាមុនថាអំពើនោះជា បទល្មើស ទើបអាចចោទប្រកាន់បាន ទោសក៏ដូចដែរគ្នាដែរដើម្បីប្រកាសទោសបាន លុះត្រាតែទោសនោះមានចែងទុកជាមុនក្នុងច្បាប់ដែលនៅជាធរមានទើបអាចប្រកាសបាន នេះដោយផ្អែកតាមគោលការណ៍នីត្យានុកូលភាព។

**២.៤ អំពើដែលត្រូវទទួលទោសព្រហ្មទណ្ឌ**

បទល្មើសព្រហ្មទណ្ឌគឺជា អំពើដែលត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ។ ចំពោះការផ្តន្ទាទោសគឺជាការបង្ហាញឱ្យឃើញថា កាលណាមានអំពើមួយកើតឡើងដែលបំពារបំពាន ឬបានធ្វើឱ្យប៉ះពាល់ដល់សង្គម រដ្ឋគឺមានវិធានការចាប់បង្ខំជនដែលបានប្រព្រឹត្តនូវអំពើនោះ ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើរបស់ខ្លួនទៅតាមកម្រិតមួយដែលច្បាប់បានចែងទុកជាមុន។

តាមទស្សនៈខាងលើមានន័យថា ជនល្មើសត្រូវទទួលទោសព្រហ្មទណ្ឌកាលណាជននោះបានប្រព្រឹត្តអំពើដែលផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌ ប៉ុន្តែអំពើខ្លះមានរូបភាពជាបទល្មើសព្រហ្មទណ្ឌក៏ពិតមែន តែអំពើនោះមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌឡើយក្នុងករណីថា ផុតអាជ្ញាយុកាល ឬស្ថិតក្នុងករណីយុត្តិកម្មនៃបទល្មើស។

**៣. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងបទល្មើសដទៃ**

យើងបានដឹងមកហើយថា បទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលបំពានទៅនឹងច្បាប់ព្រហ្មទណ្ឌ ឬក៏ជាអំពើដែលផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌ ដែលអំពើនោះបង្កផលប៉ះពាល់ដល់បុគ្គល ឬក៏បង្កគ្រោះថ្នាក់ដល់សង្គម ហើយបុគ្គលដែលប្រព្រឹត្តនោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទៅតាមអំពើដែលរូបគេបានប្រព្រឹត្ត។ សូមរំលឹកផងដែរថាដើម្បីចោទប្រកាន់ និងផ្តន្ទាទោសបុគ្គលណាម្នាក់បាន លុះត្រាតែមានច្បាប់ចែងទុកជាមុនសិន។

បើតាមការពិនិត្យជាក់ស្តែង មានអំពើមួយចំនួនក៏ជាអំពើល្មើសដែរ ក៏ប៉ុន្តែមិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌទេ។ អាស្រ័យហេតុនេះ នៅក្នុងចំណុចនេះយើងនឹងសិក្សានូវភាពខុសគ្នារវាង បទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសដទៃផ្សេងៗទៀត។ នៅចំណុចនេះយើងនិងលើកយកអំពើចំនួន ២ ដែលពុំត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌមានដូចជា អំពើល្មើសផ្នែករដ្ឋប្បវេណី (៣.១) និងអំពើល្មើសផ្នែកវិន័យ (៣.២)។

**៣.១ ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណី**

ចំពោះបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណីមានភាពខុសគ្នាមួយចំនួនដូចខាងក្រោម៖

**ប្រភព** ៖ អំពើល្មើសផ្នែករដ្ឋប្បវេណី មានប្រភពមកពីក្រមរដ្ឋប្បវេណីនៃមាត្រា ៧៤៣ ដែលបានចែងថាបុគ្គលដែលបានបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬដោយ

កំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាតដែលកើតឡើងដោយអំពើនោះ បើក្រឡេកមកបទល្មើសព្រហ្មទណ្ឌវិញ គឺមានប្រភពមកពីច្បាប់ព្រហ្មទណ្ឌ ឬក្រមព្រហ្មទណ្ឌ ដែលបានចែងយ៉ាងច្បាស់ថាអំពើណាជាបទល្មើសព្រហ្មទណ្ឌ ឬអាចនិយាយបានថា គឺត្រូវតែចែងក្នុងច្បាប់យ៉ាងច្បាស់ថាជា បទល្មើសព្រហ្មទណ្ឌ នេះគឺផ្អែកទៅតាមមាត្រា ៣ ក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ឬអាចហៅថា គោលការណ៍នីត្យានុកូលភាពនៃបទល្មើស។

**លទ្ធផល** ៖ ចំពោះអំពើល្មើសផ្នែករដ្ឋប្បវេណីដើម្បីអាចឱ្យតុលាការដាក់ទណ្ឌកម្មទៅលើអ្នកប្រព្រឹត្តបាន គឺចាំបាច់ត្រូវពិនិត្យទៅមើលលើព្យសនកម្ម មានន័យថាតុលាការត្រូវពិនិត្យ និងវិនិច្ឆ័យទៅលើព្យសនកម្មក្នុងការកំណត់អំពីទណ្ឌកម្មទៅកាន់បុគ្គលដែលបានប្រព្រឹត្ត។ ចំណែកបទល្មើសព្រហ្មទណ្ឌផ្ទុយពីអំពើល្មើសផ្នែករដ្ឋប្បវេណីត្រង់ថា ការបង្កើតជាបទល្មើសព្រហ្មទណ្ឌ គឺពុំសុទ្ធតែទាមទារឱ្យមានព្យសនកម្មទេ ជាឧទាហរណ៍មានបទល្មើសមួយចំនួនដូចជា បទល្មើសជួញដូរគ្រឿងញៀន ការបើកបរក្នុងល្បឿនលឿន ឬការមិនគោរពផ្លាកសញ្ញាចរាចរណ៍ជាដើម។ ចំពោះមូលហេតុដែលអំពើមួយចំនួន ទោះបីជាមិនបានបង្កព្យសកម្មក៏ដោយ តែត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ គឺដើម្បីការពារ ឬបង្ការទុកជាមុន ព្រោះថាអំពើមួយចំនួនទោះបីពុំបង្កព្យសនកម្មក៏ដោយ តែបើមិនមានការគ្រប់គ្រងត្រឹមត្រូវទេ អំពើនោះអាចនឹងបង្កព្យសនកម្មនៅពេលក្រោយមិនខានឡើយ។

**ទណ្ឌកម្ម** ៖ ចំពោះទណ្ឌកម្មសម្រាប់អំពើល្មើសផ្នែករដ្ឋប្បវេណី គឺជាការបង់សំណងជម្ងឺចិត្ត នេះជាទណ្ឌកម្មដែលផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះនៃអំពើល្មើសនោះ សម្រាប់ជួសជុលការខូចខាតទាំង ផ្លូវកាយ ផ្លូវចិត្ត និងផ្លូវសេដ្ឋកិច្ចក្តី។ ចំពោះទណ្ឌកម្មព្រហ្មទណ្ឌវិញ មានគោលដៅចម្បងការពារទាំងសង្គមផង និងបុគ្គលផង ហើយចំពោះប្រាក់ពិន័យ គឺត្រូវបង់ចូលជាថវិការរដ្ឋ។

អំពើមួយអាចចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែពុំមែនជាអំពើល្មើសផ្នែករដ្ឋប្បវេណីទេ មានដូចជាការជួញដូរគ្រឿងញៀន ការជួញដូរអាវុធ និងការមិនគោរពភ្លើងស្តុបជាដើម។ យើងពិនិត្យឃើញថា អំពើល្មើសផ្នែករដ្ឋប្បវេណីខ្លះជាអំពើខុសឆ្គងក៏ពិតមែន ប៉ុន្តែមិនមែនជាបទល្មើសព្រហ្មទណ្ឌនោះទេ ដូចជាអំពើដែលធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃដោយអចេតនា ដែលអំពើនេះបានធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់អ្នកដទៃ។ ផ្ទុយពីនេះ អំពើមួយអាចចាត់ទុកជាបទល្មើសព្រហ្មទណ្ឌផង និងអំពើល្មើសផ្នែករដ្ឋប្បវេណីផងក៏បានដូចជាអំពើហិង្សាដោយចេតនា បទឃាតកម្ម ឬអំពើរំលោភសេពសន្ថវៈជាដើម។ ចំពោះករណីបែបនេះ អាចនឹងមានបណ្តឹងពីរប្រភេទបានកើតឡើងដូចជា បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី។ ដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃមាត្រា ២ បណ្តឹងទាំងពីរនេះមានទិដ្ឋភាពដូចតទៅ៖

**បណ្តឹងអាជ្ញា** មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះ តាមច្បាប់កំណត់។ តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ បានចែងត្រង់មាត្រា

១៣១ ថ្មីថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។

**បណ្តឹងរដ្ឋប្បវេណីវិញ** មានគោលបំណងធ្វើឱ្យទទួលបានការជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។ តាមមាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា បុគ្គលគ្រប់រូបដែលប្រកាសថាខ្លួនជាជនរងគ្រោះនៃបទល្មើសអាចដាក់ពាក្យប្តឹងបាន។

បណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើងក្នុងពេលជាមួយគ្នានឹងបណ្តឹងអាជ្ញា នៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌ។ បណ្តឹងរដ្ឋប្បវេណី ក៏អាចធ្វើបានដែរនៅចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណី។[1] ចំណុចនេះមានន័យថាបណ្តឹងទាំងពីរអាចធ្វើឡើងចំពោះមុខតុលាការព្រហ្មទណ្ឌតែមួយ ឬក៏ចំពោះមុខតុលាការព្រហ្មទណ្ឌផង និងតុលាការរដ្ឋប្បវេណីផងក៏បាន។ ហើយក្នុងករណីនេះបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានព្យួរសិន ដរាបណាមិនទាន់មានសេចក្តីសម្រេចជាស្ថាពរមួយ ត្រូវបានប្រកាសលើបណ្តឹងអាជ្ញា។[2] ត្រង់ចំណុចនេះមានន័យថាបណ្តឹងរដ្ឋប្បវេណី អាចយកមកសម្រេចបានលុះត្រាតែតុលាការព្រហ្មទណ្ឌបានដោះស្រាយរឿងក្តីព្រហ្មទណ្ឌចប់សព្វគ្រប់ជាមុនសិន។ ទោះក្នុងករណីតុលាការព្រហ្មទណ្ឌសម្រេចឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ ក៏ដោយប្រសិនបើតុលាការរកឃើញថាមានអំពើល្មើសផ្នែករដ្ឋប្បវេណី ដែលជាមូលហេតុបង្កព្យសនកម្មដល់ភាគីនៃជនរងគ្រោះ ក៏ប៉ុន្តែអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ក៏តុលាការរដ្ឋប្បវេណីអាចសម្រេចឱ្យជនដែលប្រព្រឹត្តសងជាសំណងរដ្ឋប្បវេណីបានដែរ។ ចំណុចនេះគឺជាការការពារដល់ជនរងគ្រោះដែលទទួលរងព្យសកម្មពីអំពើដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌ។

**ឧទាហរណ៍៖** ដូចករណីដែលជនម្នាក់បានចោលដុំដែកទៅក្រៅផ្ទះបណ្តាលឱ្យខូចខាតដល់រថយន្តអ្នកដទៃដោយអចេតនា ដូចនេះបើពិនិត្យទៅដោយសារតែកង្វះធាតុផ្សំនៃបទល្មើស តុលាការពុំអាចចោទប្រកាន់ជនបង្កបានទេ តែតុលាការរដ្ឋប្បវេណីនៅតែអាចដាក់ទណ្ឌកម្ម ដោយតម្រូវឱ្យជនដែលប្រព្រឹត្តបង់សំណងនៃការខូចខាតដល់ជូនរងគ្រោះបានដដែល ដោយផ្អែកលើកំហុសរដ្ឋប្បវេណី។

### ៣.២ ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យ

ចំពោះភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យមានទិដ្ឋភាពដូចខាងក្រោម៖

**ប្រភព** ៖ ចំពោះបទល្មើសព្រហ្មទណ្ឌ ទោះបីជាមានច្រើនយ៉ាងណាក៏ដោយបទល្មើសព្រហ្មទណ្ឌសុទ្ធសឹងតែជាអំពើដែលច្បាប់បានកំណត់ទុកយ៉ាងច្បាស់លាស់ជាមុនរួចទៅហើយ ចំណុចនេះគឺអនុលោមទៅតាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើស ពោលរាល់គ្រប់បទល្មើសគឺរមែងមានចែងទុកក្នុងច្បាប់យ៉ាងច្បាស់

[1] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២២។

[2] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២២។

លាស់ បើពុំមានចែងនោះទេ គឺតុលាការមិនអាចចោទប្រកាន់អំពើដែលពុំចែងនោះជាបទល្មើសបានទេ គឺមានន័យថា គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង។ ចំណែកអំពើល្មើសផ្នែកវិន័យវិញ គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ជា សមូលហភាពនៃក្រុម ឬសង្គមណាមួយ ដែលមានដូចជា មេធាវី ពេទ្យ និងនិស្សិតជាដើម ហើយអំពើនោះមិនត្រូវបានកំណត់ឱ្យច្បាស់លាស់ជាទូទៅ ដូចបទល្មើសព្រហ្មទណ្ឌនោះទេ។ **ឧទាហរណ៍** តាមមាត្រា ៥៤ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៤ បានបញ្ញត្តិកំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ ស្អាតស្អំ និងសេចក្តីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា នាំឱ្យមានទណ្ឌកម្មខាងវិន័យតាមបទបញ្ញត្តិនៃច្បាប់នេះ។ ការកំណត់ដូចនេះបានបង្ហាញឱ្យឃើញថា អំពើល្មើសផ្នែកវិន័យសម្រាប់វិជ្ជាជីវៈចៅក្រម មិនត្រូវបានបញ្ជាក់ច្បាស់ជាមុនដូចបទល្មើសព្រហ្មទណ្ឌនោះទេ ព្រោះអំពើដែលប៉ះពាល់ដល់សីលធម៌ ឬកិត្តិយស សេចក្តីថ្លៃចៅក្រម ជាសញ្ញាណមួយមានលក្ខណៈទូលំទូលាយណាស់។

**លទ្ធផល** ៖ បទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលប៉ះពាល់សង្គមទូទៅ ឬក៏ប៉ះពាល់ធំធេងជាងអំពើល្មើសផ្នែកវិន័យ មានន័យថា បទល្មើសព្រហ្មទណ្ឌ គឺមានព្យសនកម្មជាច្រើនដល់មនុស្ស និងសង្គមដូចជាប៉ះពាល់ដល់អាយុជីវិត ទ្រព្យសម្បត្តិ និងជាពិសេសនោះបង្កឱ្យមានអនាធិបតេយ្យ និងសង្គមគ្មានសណ្តាប់ធ្នាប់ជាដើម។ រីឯអំពើល្មើសផ្នែកវិន័យវិញ គឺគ្រាន់តែជាអំពើមួយដែលធ្វើឱ្យប៉ះពាល់ត្រឹមកម្រិតនៃក្រុម ឬផ្នែកណាមួយនៃសង្គមប៉ុណ្ណោះ ពោលត្រឹមសង្គមដែលជននោះប្រព្រឹត្តល្មើស។

**ទណ្ឌកម្ម** ៖ ចំពោះការដាក់ទណ្ឌកម្មទៅលើអំពើល្មើសផ្នែកវិន័យ គឺត្រូវធ្វើដោយស្ថាប័នពិសេសសម្រាប់ក្រុមសង្គមណាមួយ។ **ឧទាហរណ៍** នៅកម្ពុជាមាន ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រាប់ដាក់វិន័យទៅលើចៅក្រម និងព្រះរាជអាជ្ញា ឬក្រុមប្រឹក្សាគណៈមេធាវី សម្រាប់ដាក់វិន័យទៅលើមេធាវីជាដើម។ ទាក់ទងទៅនឹងបទល្មើសព្រហ្មទណ្ឌវិញ មានតែតុលាការ ឬសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជាទេ ដែលមានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មបាន ហើយបើយើងពិនិត្យមើលចំពោះទណ្ឌកម្មគឺអាចមានលក្ខណៈធ្ងន់ធ្ងរ រហូតដល់ការដាក់ទោសពន្ធនាគារអស់មួយជីវិតទៀតផង។

ការបែងចែករវាង អំពើល្មើសផ្នែករដ្ឋប្បវេណី និងបទល្មើសព្រហ្មទណ្ឌ ក៏ដូចជាការបែងចែករវាងអំពើល្មើសផ្នែកវិន័យ និងបទល្មើសព្រហ្មទណ្ឌដែរ ព្រោះបានឆ្លុះបញ្ចាំងឱ្យឃើញថា នៅក្នុងករណីខ្លះអំពើមួយត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែពុំមែនជាអំពើល្មើសផ្នែកវិន័យនោះទេ។ **ឧទាហរណ៍** បទល្មើសលួច(មាត្រា៣៥៣) បទល្មើសការឆបោក(មាត្រា៣៧៧) ឬបទល្មើសហិង្សាដោយចេតនា (មាត្រា២១៧)ជាដើម។

ផ្ទុយពីការបកស្រាយខាងលើ ពេលខ្លះអំពើមួយត្រូវបានចាត់ទុកថាជា អំពើល្មើសផ្នែកវិន័យ ក៏ប៉ុន្តែពុំត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនោះឡើយ។ **ឧទាហរណ៍** សិស្សនិស្សិតជាច្រើននាក់ មិនគោរពទៅតាមបទ

បញ្ញត្តដែលសាលាបានដាក់ចេញ ឬមិនគោរពវិន័យសាលាជាដើម និងឧទាហរណ៍មួយផ្សេងទៀតដូចជា មន្ត្រីរាជការម្នាក់មិនបានមកធ្វើការជាច្រើនថ្ងៃ ហើយការឈប់នោះដោយពុំមានច្បាប់អនុញ្ញាតត្រឹមត្រូវឡើយ ឬគ្រូពេទ្យបានធ្វើការរំលូតកូន ដោយមិនមានការអនុញ្ញាតតាមច្បាប់ស្តីពីការរំលូតកូនឱ្យបានត្រឹមត្រូវ ដែលទាំងនេះ ហើយគឺសុទ្ធតែជាការល្មើសផ្នែកវិន័យ តែពុំត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌឡើយ។

ហើយក៏មានអំពើមួយចំនួនដែលត្រូវចាត់ចូលជាបទល្មើសព្រហ្មទណ្ឌផង និងអំពើល្មើសផ្នែកវិន័យផង **ឧទាហរណ៍** ដូចខាងក្រោមនេះ

- នៅក្នុងពេលបំពេញការងារ មន្ត្រីរាជការម្នាក់បានទទួលសំណូក ដែលអំពើនេះគឺជាបទល្មើសព្រហ្មទណ្ឌ(បទស៊ីសំណូក) និងអំពើល្មើសផ្នែកវិន័យផងដែរ។
- ពេទ្យម្នាក់បានរំលូតកូនដោយល្មើសនឹងច្បាប់ស្តីពីការរំលូតកូន ហើយបណ្តាលឱ្យនារីមានគភ៌ស្លាប់។
- មេធាវីម្នាក់បានបង្ហាញព័ត៌មានដែលខ្លួនបានទទួល នៅក្នុងក្របខ័ណ្ឌនៃរឿងក្តីដែលខ្លួនការពារ ដោយបង្ហាញទៅកាន់បុគ្គលដែលគ្មានសមត្ថកិច្ចឱ្យដឹងព័ត៌មាន អំពើនេះបានរំលោភបំពានទៅលើកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈរបស់មេធាវី តាមមាត្រា ៣១៤ ក្រមព្រហ្មទណ្ឌ២០០៩ បានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ហើយមេធាវីនោះក៏ទទួលអំពើល្មើសផ្នែកវិន័យដែរ។

បន្ទាប់ពីបានបញ្ចប់ការបកស្រាយ **ផ្នែកទី១** ដែលនិយាយអំពីសញ្ញាណទូទៅនៃបទល្មើស យើងនឹងចូលទៅផ្នែកបន្ទាប់ទៀត នៅចំណុចបន្ទាប់យើងនឹងធ្វើការសិក្សាបន្តអំពីធាតុផ្សំនៃបទល្មើស(**ផ្នែកទី២**) វិញម្តង។

## ផ្នែកទី ២៖ ធាតុផ្សំនៃបទល្មើស

បន្ទាប់ពីបានសិក្សាអំពីសញ្ញាណទូទៅនៃបទល្មើសព្រហ្មទណ្ឌរួចមក យើងនឹងឈានដល់ចំណុចមួយទៀតដែលនិយាយអំពីធាតុផ្សំនៃបទល្មើស។ បន្ទាប់ពីបានឈ្វេងយល់រួចមកហើយថាអំពើបែបណាដែលចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ និងភាពខុសគ្នាខ្លះៗរវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសដទៃ ដែលបានលើកយកមកនិយាយនៅចំណុចនៃ (**ផ្នែកទី១**) ដូចនេះផ្នែកបន្ទាប់យើងនឹងនិយាយអំពីចំណុចសំខាន់មួយទៀតគឺធាតុផ្សំនៃបទល្មើស(**ផ្នែកទី២**)។ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ គឺជាផ្នែកមួយសំខាន់ណាស់ក្នុងការកំណត់អំពើណាមួយជាបទល្មើស ដើម្បីអាចចោទប្រកាន់ និងផ្តន្ទាទោសបុគ្គលដែលប្រព្រឹត្តអំពើនោះបាន។ អាស្រ័យហេតុនេះក្នុងករណីដែលធាតុណាមួយនៃធាតុផ្សំបទល្មើសមិនបានបំពេញទេ គឺតុលាការពុំអាចចោទប្រកាន់ និងផ្តន្ទាទោសបុគ្គលដែលប្រព្រឹត្តនោះបានឡើយ។ ចំពោះធាតុផ្សំនៃបទល្មើសត្រូវបានបែងចែកជាបីធាតុ ដែលរួមមានធាតុនីត្យានុកូល ឬធាតុច្បាប់ (១) ធាតុសត្យានុម័ត ឬធាតុសម្ភារៈ (២) និងធាតុអត្តនោម័ត ឬចិត្តសាស្ត្រ (៣)។

អាស្រ័យហេតុនេះ ដើម្បីដឹងថាធាតុផ្សំបទល្មើសទាំងបីមានអត្ថន័យបែបណា ហើយមានទិដ្ឋភាពបែបណាខ្លះ គប្បីយើងនឹងធ្វើការបកស្រាយនៅចំណុចខាងក្រោមនេះ។

## ១. ធាតុនីត្យានុកូល ឬធាតុច្បាប់

ធាតុផ្សំនីត្យានុកូល គឺជាធាតុផ្សំដែលចាំបាច់មួយក្នុងចំណោមធាតុផ្សំទាំងបី។ ក្នុងធាតុនីត្យានុកូលនេះ យើងនឹងលើកយកចំណុចមួយចំនួនមកធ្វើការបកស្រាយបង្ហាញដែលចំណុចទាំងនោះ មានដូចតទៅ អត្ថន័យនៃធាតុនីត្យានុកូល (១.១) គោលការណ៍នីត្យានុកូលភាព (១.២) អានុភាពនៃច្បាប់ព្រហ្មទណ្ឌ (១.៣) និងវិសាលភាពកំណត់បទល្មើសដោយតុលាការ (១.៤)។

### ១.១ អត្ថន័យនៃធាតុនីត្យានុកូល

ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្សសិទ្ធិនារី និងសិទ្ធិកុមារ។[3] ដោយគោរពតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានចែងថា ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ គ្មានជនណាម្នាក់ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។[4] ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិដាក់ពាក្យបណ្តឹងដើម្បីឱ្យតុលាការអាចសម្រេចដោយមិនពន្យារពេលអំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ឱ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់។[5] គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។[6] ហេតុផលមួយចំនួនខាងលើនេះហើយដែលបានបង្កើតឱ្យមានធាតុនីត្យានុកូល ព្រោះធាតុនេះមានសារៈប្រយោជន៍ជាច្រើន។ តាមរយៈការលើកឡើងនូវចំណុចមួយចំនួនខាងលើនេះហើយ យើងអាចកំណត់បានថាធាតុនីត្យានុកូល គឺជាធាតុដែលទាក់ទងនឹងច្បាប់ ព្រោះថាដើម្បីធ្វើការចោទប្រកាន់ និងផ្តន្ទាទោសបាន គឺត្រូវមានច្បាប់ចែងទុកជាមុនសិន។

អាស្រ័យហេតុនេះហើយទើបមានគោលការណ៍មួយបានលើកឡើងថា **គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង** ឬអាចនិយាយបានថា បើគ្មានច្បាប់ចែងថាអំពើនោះជាបទល្មើសនោះទេ គឺតុលាការមិនអាចចោទថាជាបទល្មើសបានឡើយ។

---

[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, ត្រង់មាត្រា ៣១ (កថាខណ្ឌទី ១)។

[4] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦, មាត្រា៩ (កថាខណ្ឌទី ១)។

[5] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦, មាត្រា៩ (កថាខណ្ឌទី ៤)។

[6] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦, មាត្រា១៥(កថាខណ្ឌទី១)។

## ១.២ គោលការណ៍នីត្យានុកូលភាព

គោលការណ៍នីត្យានុកូលភាពនេះគឺជាគោលការណ៍ដែលមានសារៈសំខាន់ណាស់ក្នុងច្បាប់ព្រហ្មទណ្ឌ ហើយជាពិសេសគោលការណ៍នេះគឺសំខាន់បំផុតសម្រាប់ការបំពេញសកម្មភាពរបស់មន្ត្រីមានសមត្ថកិច្ចក្នុងការអនុវត្តច្បាប់ ដែលជាទូទៅក្នុងរឿងព្រហ្មទណ្ឌ គឺតែងតែទាមទារឱ្យមាននូវគោលការណ៍នីត្យានុកូលភាពនេះ។

ដោយអនុលោមតាមមាត្រា ៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ បានបញ្ញត្តនូវគោលការណ៍នីត្យានុកូលនេះមានដូចជា គោលការណ៍នីត្យានុកូលភាពនៃបទល្មើស (ក) និងគោលការណ៍នីត្យានុកូលភាពនៃទោស (ខ) ដូចនេះយើងនឹងធ្វើការបកស្រាយគោលការណ៍នីមួយៗនៅចំណុចបន្ទាប់។ ហើយដើម្បីឈ្វេងយល់កាន់តែច្បាស់បន្ថែមអំពីគោលការណ៍នេះទៀតនោះ យើងក៏បានស្រាវជ្រាវបន្ថែមមួយចំណុចទៀតដែរ ដែលនិយាយអំពីគោលបំណងនៃគោលការណ៍នីត្យានុកូលភាព (គ)។

### ក. នីត្យានុកូលភាពនៃបទល្មើស

ដោយអនុលោមតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣ កថាខណ្ឌទី១ បានចែងថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។ នៅត្រង់ចំណុចនេះមានន័យថា ដើម្បីធ្វើការចោទប្រកាន់ ឬផ្តន្ទាទោសអំពើណាមួយបាន លុះត្រាតែអំពើនោះមានចែងក្នុងច្បាប់ជាធរមានយ៉ាងច្បាស់លាស់ បើពុំមានចែងក្នុងច្បាប់នោះទេ តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើការចោទប្រកាន់ ឬផ្តន្ទាទោសបាននោះទេ។ ចំពោះចំណុចនេះ យើងអាចនិយាយបានថាច្បាប់គឺបានចែងទុក ដើម្បីកំណត់បទល្មើស បើមិនចែងទុកមិនចាត់អំពើនោះជាបទល្មើសឡើយ នេះហើយជាគោលការណ៍ **នីត្យានុកូលភាពនៃបទល្មើស**។

### ខ. នីត្យានុកូលភាពនៃទោស

នៅត្រង់ចំណុចនេះមានលក្ខណៈដូចទៅនឹង នីត្យានុកូលភាពនៃបទល្មើសផងដែរ ព្រោះថាដើម្បីដាក់ទោសចំពោះអំពើណាមួយបានដាច់ខាតត្រូវមានច្បាប់កំណត់ទុកជាមុនសិន ការលើកឡើងនេះគឺអនុលោមតាមមាត្រា ៣ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលបានចែងថា មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន។

សរុបជារួមមកថា ដើម្បីធ្វើការចោទប្រកាន់ និងផ្តន្ទាទោសចំពោះអំពើណាមួយបាន គឺទាមទារឱ្យមានច្បាប់ចែងទុក ទើបអាចធ្វើការចោទប្រកាន់ និងដាក់ទោសចំពោះអំពើនោះបាន ជាឧទាហរណ៍ដូចជា៖

- បទឃាតកម្ម មាត្រា១៩៩ ក្នុងក្រមព្រហ្មទណ្ឌ២០០៩ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ ទៅ ១៥ ឆ្នាំ។
- បទល្មើសហិង្សា មាត្រា២១៧ ក្នុងក្រមព្រហ្មទណ្ឌ២០០៩ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ ទៅ ៦.០០០.០០០ រៀល។

- បទឆបោក មាត្រា៣៧៧ និងទោសដែលត្រូវអនុវត្ត មាត្រា៣៧៨ ក្នុងក្រមព្រហ្មទណ្ឌ២០០៩ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ ទៅ ៦.០០០.០០០ រៀល។

## គ. គោលបំណងនៃគោលការណ៍នីត្យានុកូលភាព

ចំពោះគោលការណ៍នីត្យានុកូលភាព គឺពិតជាមានសារៈសំខាន់ណាស់ក្នុងប្រព័ន្ធនីតិសាស្ត្រ ឬក្នុងប្រព័ន្ធច្បាប់ ដែលគោលការណ៍នេះមានចែងក្នុងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ និងមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយឆ្នាំ១៩៦៦។ អាស្រ័យហេតុនេះបើពិនិត្យមើលលើគោលការណ៍នីត្យានុកូលនេះនឹងឃើញមានគោលបំណងសំខាន់ៗចំនួន ២ មានដូចជា បទប្បញ្ញត្តិគ្រឹះដើម្បីការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ **(គ.១)** និងដើម្បីបង្ការទុកជាមុននូវបទល្មើសព្រហ្មទណ្ឌ **(គ.២)**។

### គ.១ បទប្បញ្ញត្តិគ្រឹះដើម្បីការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ

តើការការពារនេះធ្វើឡើងយ៉ាងដូចម្ដេច? បើតាមប្រសាសន៍របស់ឯកឧត្តម **កើត រិទ្ធ** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្ដីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ២០១០ បានបកស្រាយថា ប្រជាពលរដ្ឋ ឬមួយក៏សមាជិកសង្គមទាំងអស់ប្រមូលផ្ដុំគ្នារស់នៅក្នុងសង្គមតាមរយៈកិច្ចសន្យាសង្គម ។ កិច្ចសន្យាសង្គមនេះ គឺជាច្បាប់ ហើយច្បាប់នេះគឺជាការសម្ដែងនូវឆន្ទៈទូទៅរបស់សមាជិកសង្គមទាំងអស់ តាមរយៈអ្នកតំណាងរាស្ត្រនៅអង្គការនីតិប្បញ្ញត្តិ។ ច្បាប់នេះត្រូវបានចាត់ទុកថាជា ឆន្ទៈទូទៅរបស់ប្រជាពលរដ្ឋទាំងអស់ ដែលជាសមាជិកសង្គមទាំងមូល។ ដើម្បីអាចកំណត់ថាអំពើណាមួយគឺជាបទល្មើស ហើយអាចផ្ដន្ទាទោសអំពើនោះបាន លុះត្រាតែមានច្បាប់ចែងកំណត់ជាមុនប្រាប់ទៅដល់សមាជិកសង្គមទាំងអស់ថា អំពើនេះគឺជាបទល្មើស។ ច្បាប់ព្រហ្មទណ្ឌស្ដែងឡើងហាក់បីដូចជា បញ្ជីនៃការហាមឃាត់ បញ្ជីនៃបទល្មើសព្រហ្មទណ្ឌ ឬមួយបញ្ជីនៃទោស គឺមានន័យថាច្បាប់ព្រហ្មទណ្ឌនេះគឺកំណត់អំពីព្រំដែននៃសិទ្ធិសេរីភាព រហូតដល់មាន អ្នកច្បាប់មួយចំនួនគេបានកំណត់ថាច្បាប់ព្រហ្មទណ្ឌគឺជាព្រំដែននៃសិទ្ធិ មានន័យថាប្រាប់ទៅដល់ប្រជាពលរដ្ឋឱ្យដឹងថា តើអំពើណាខ្លះគឺជាអំពើហាមឃាត់ ហើយអ្វីដែលមិនបានហាមឃាត់ដោយច្បាប់ព្រហ្មទណ្ឌ យើងអាចចាត់ទុកថាអំពើនោះជាសេរីភាពរបស់បុគ្គល អាចប្រព្រឹត្តទៅបាន ឬអាចអនុវត្តន៍បាន។ ប៉ុន្តែអ្វីដែលបានចែងចូលទៅក្នុងបញ្ជីនៃបទប្បញ្ញត្តិព្រហ្មទណ្ឌ គឺគេត្រូវបានកំណត់ថាប្រសិនបើអ្នកណាប្រព្រឹត្តរំលោភទៅលើបញ្ជីនៃបទល្មើសនេះ អ្នកនោះនឹងត្រូវផ្ដន្ទាទោសទៅតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។ ប៉ុន្តែប្រសិនបើជាអ្វីដែលមិនមានចែងទេ យើងអាចចាត់ទុកថាបុគ្គលគ្រប់រូបអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនបាន លើកលែងតែករណីនោះវាប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃ ហើយដែលសិទ្ធិរបស់អ្នកដទៃ គឺគេអាចប្រើប្រាស់នូវសិទ្ធិតាមនីតិរដ្ឋប្បវេណី ដើម្បីទាមទារនូវសំណងផ្សេងៗ។ ជាឧទាហរណ៍ ការបរិហារកេរ្តិ៍ ឬការជេរប្រមាថ ក្រមព្រហ្មទណ្ឌបានចាត់ទុកថាអំពើទាំងនេះគឺស្ថិតនៅក្នុងបញ្ជីមួយនៃបទល្មើសព្រហ្មទណ្ឌ

ដោយហេតុថាសង្គមកម្ពុជាមិនចង់ទទួលស្គាល់ថា ការជេរប្រមាថ ឬការបរិហារកេរ្តិ៍ជាសិទ្ធិរបស់បុគ្គល។ ដូចនេះ ហើយបានជាក្រមព្រហ្មទណ្ឌនៅតែរក្សាបទប្បញ្ញត្តិនេះ ចាត់ទុកថាអំពើទាំងនេះ គឺជាបទល្មើសព្រហ្មទណ្ឌ ដើម្បីជៀសវាងមានការបកស្រាយថា បើសិនជាយើងមិនចែងពីបទល្មើសបរិហារកេរ្តិ៍ ក៏ដូចជាបទជេរប្រមាថអ្នកដទៃចូលទៅក្នុងក្រមព្រហ្មទណ្ឌដោយចាត់ទុកវាថាគឺជាបទល្មើសព្រហ្មទណ្ឌទេ អាចនឹងមានអ្នកដទៃគេយកទៅធ្វើការពិនិត្យ និងបកស្រាយថា ទាំងនោះគឺជាសិទ្ធិរបស់គេក្នុងការជេរប្រមាថ ឬបរិហារកេរ្តិ៍អ្នកដទៃ។ ដូចនេះ យើងមិនទទួលស្គាល់នៅក្នុងសង្គមកម្ពុជា ដែលមានទំនៀមទម្លាប់ ប្រពៃណីល្អ យើងមិនចាត់ទុក ជាសិទ្ធិនោះទេ។[7]

**គ.២ បទប្បញ្ញត្តិគ្រឹះដើម្បីបង្ការទុកជាមុននូវបទល្មើសព្រហ្មទណ្ឌ**

នៅក្នុងទ្រឹស្តីឧក្រិដ្ឋវិជ្ជា គេបានចាត់ទុកថាការដែលចែងទុកជាមុននៅក្នុងអត្ថបទច្បាប់ជាពិសេស ដើម្បីឱ្យប្រជាពលរដ្ឋដឹងថា តើអំពើណាខ្លះ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសនោះ ក៏ជាផ្នែកមួយដែលអាចចូលរួមបាននូវការកាត់បន្ថយបទល្មើសព្រហ្មទណ្ឌផងដែរ (តាមប្រសាសន៍របស់ឯកឧត្តម កើត រិទ្ធ បានពន្យល់)។

**ឧទាហរណ៍៖** ប្រសិនបើយើងមិនចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌដោយបញ្ជាក់ថា បទល្មើសណាមួយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីប៉ុណ្ណេះទៅប៉ុណ្ណោះទេ វានឹងនាំឱ្យបុគ្គលនោះគាត់អាចយល់ឃើញថានេះគឺជាសេរីភាពរបស់គាត់ ដូច្នេះគាត់អាចនឹងប្រព្រឹត្តបទល្មើស។ តែបើក្នុងករណីដែលច្បាប់ចែងយ៉ាងជាក់លាក់ថាអំពើដែលគាត់ប្រព្រឹត្តនោះ ជាបទល្មើសព្រហ្មទណ្ឌ ដូចនេះការចែងទុកជាមុននេះ អាចធ្វើឱ្យបុគ្គលនោះរាងចាល ឬមួយមិនហ៊ានប្រព្រឹត្តបទល្មើស។ អាស្រ័យហេតុនេះហើយបានជាគោលការណ៍នេះ យើងអាចចាត់ទុកថាជាគោលការណ៍មួយដែលចូលរួមនៅក្នុងការបង្ការបទល្មើសព្រហ្មទណ្ឌបានមួយផ្នែកផងដែរ។

## ១.៣ ការអនុវត្តច្បាប់ព្រហ្មទណ្ឌទូទៅ

ច្បាប់ព្រហ្មទណ្ឌ បានអនុវត្តតាមគោលការណ៍ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌដែលបានកំណត់ដូចជាការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល ឬពេលវេលា **(ក)** និងការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហ **(ខ)**។

### ក. ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល

ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល គឺចង់សំដៅទៅលើការចូលជាធរមាននៃច្បាប់ព្រហ្មទណ្ឌ។ ដោយគោរពតាមគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ ត្រូវបានយកទៅអនុវត្តនៅពេលដែលច្បាប់នេះចូលជាធរមាន ហើយបន្តរហូតដល់ពេលច្បាប់នេះត្រូវនិរាករណ៍ដោយច្បាប់ថ្មី។ ដូចនេះ អំពើមួយអាចចាត់ទុកថាជា បទល្មើស ហើយត្រូវផ្តន្ទាទោសបាន គឺលុះត្រាតែអំពើនោះបានប្រព្រឹត្តនៅក្នុងពេលដែលច្បាប់ព្រហ្មទណ្ឌមានអានុភាពគតិយុត្ត គឺមានន័យថាច្បាប់នោះនៅជាធរមាននៅឡើយ (សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ)។

[7] ប្រសាសន៍របស់ឯកឧត្តម **កើត រិទ្ធ** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ត្រង់មាត្រា ៩៣ បានចែងថា ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបាន ពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបាន ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេស ក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវ ចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ។

បើនិយាយអំពីដែនអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល ឬពេលវេលា គឺការអនុវត្តច្បាប់ព្រហ្មទណ្ឌត្រូវផ្អែកលើគោលការណ៍ចំនួនពីរ ពោលគឺគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង **(ក.១)** និង គោលការណ៍ប្រតិសកម្មច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង **(ក.២)**។

### ក.១ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង

គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌមានអត្ថន័យថា ច្បាប់ដែលចូលជាធរមាននៅថ្ងៃណាមួយជាកំណត់ គឺជាទូទៅពុំមាន អានុភាពគ្រប់គ្រងស្ថានភាពទាំងឡាយណា ដែលបានកើតឡើងមុនពេលច្បាប់ចូលជាធរមានឡើយ ។ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ មានគោលបំណងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើសកម្មភាពផ្សេងៗ ដែលច្បាប់នៅខណៈពេលនោះពុំបានចាត់ទុកជាបទល្មើសទេ។ ទោះបីជាថ្ងៃក្រោយមកទៀត ស្រាប់តែមានច្បាប់កំណត់ថា អំពើដដែលជាបទល្មើសក៏ដោយ ក៏ចារីដែលបានប្រព្រឹត្តអំពើល្មើសពុំចាំបាច់ភ័យខ្លាចឡើយ ពីព្រោះថាច្បាប់ដែលទើបតែបានចូលជាធរមានត្រូវមានអានុភាពអនុវត្តតែទៅលើសកម្មភាពដែលកើតឡើង ចាប់ពីថ្ងៃដែលច្បាប់ចូលជាធរមានតែប៉ុណ្ណោះ។[៨]

គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង មានបញ្ញត្តនៅក្នុងមាត្រា១០ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ(បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ) និងនៅក្នុងមាត្រា១១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តី ពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលបានចែងថា គ្មានជនណាម្នាក់ត្រូវជាប់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយ ចំពោះអំពើ ឬការធ្វេសប្រហែសណាមួយដែល ពុំមែនជាបទល្មើសព្រហ្មទណ្ឌដែលមាននៅក្រោមច្បាប់ជាតិ ច្បាប់អន្តរជាតិ នៅខណៈពេលដែលអំពើនោះបានប្រព្រឹត្ត ។[៩]

គោលការណ៍នេះមានន័យថា ច្បាប់ព្រហ្មទណ្ឌគឺមានអានុភាពអនុវត្តតែទៅអនាគត ហើយមិនមានអានុភាពអនុវត្តទៅអតីតកាលទេ ពោលគឺអនុវត្តតែទៅលើបទល្មើសណាដែលកើតក្រោយច្បាប់ព្រហ្មទណ្ឌចូលជាធរមានតែប៉ុណ្ណោះ។ ដូចនេះច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង មិនអនុវត្តទៅនឹងបទល្មើសដែលកើតមុនច្បាប់

[៨] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[៩] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

ព្រហ្មទណ្ឌនោះចូលជាធរមាននោះទេ ពោលគឺមិនប្រតិសកម្មនោះទេ។ គោលការណ៍នេះក៏ជួយដល់ការពារការសងសឹកគ្នារវាងគណបក្សនយោបាយដែលការពារមិនឱ្យអ្នកឡើងកាន់អំណាចក្រោយ សងសឹកទៅលើអ្នកកាន់អំណាចមុនដែលបាត់បង់អំណាច។ **ឧទាហរណ៍៖** ឈ្មោះ **ក** បានប្រព្រឹត្តអំពើមួយដែលច្បាប់ពីមុនមិនបានចែងថាអំពើនោះជាបទល្មើសទេ ស្រាប់តែក្រោយមក ទើបមានច្បាប់ថ្មីមួយបានចូលជាធរមាន ហើយបានកំណត់ថាអំពើនោះជាបទល្មើស។ ក្នុងករណីនេះ តុលាការមិនអាចធ្វើការចោទប្រកាន់ទៅលើឈ្មោះ **ក** បានទេ ពីព្រោះថាអំពើនោះជាអំពើដែលបានប្រព្រឹត្តមុនច្បាប់ថ្មីចូលជាធរមាន ហើយច្បាប់ចាស់មិនបានចែងថាជាបទល្មើសទេ។

**ក.២ គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង**

គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង គឺជាគោលការណ៍មួយដែលច្បាប់ព្រហ្មទណ្ឌអាចអនុវត្តទៅលើអំពើដែលប្រព្រឹត្តមុនច្បាប់នេះចូលជាធរមាន គោលការណ៍នេះគឺអនុវត្តដើម្បីផ្តល់ផលអនុគ្រោះដល់ជនល្មើស។ គោលការណ៍នេះរួមមានដូចជា៖

- **គោលការណ៍ដែលលុបចោលនូវបទល្មើស** ៖ ដោយយោងតាមមាត្រា ៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា បទប្បបញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម មានន័យថាអំពើប្រព្រឹត្តនៅមុនបទប្បបញ្ញត្តិនេះចូលជាធរមានមិនអាចត្រូវចោទប្រកាន់ទៀតទេ ហើយការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះត្រូវបានបញ្ចប់។ នៅត្រង់នេះមានន័យថា ច្បាប់បានផ្តល់ការអនុគ្រោះក្នុងគោលបំណងមនុស្សធម៌ ព្រោះថាអំពើមួយដែលត្រូវបានចាត់ទុកជាបទល្មើសនៅច្បាប់ចាស់ ហើយច្បាប់ថ្មីបានចែងថាមិនមែនជាបទល្មើស ដូចនេះអំពើនោះនឹងរួចផុតពីការចោទប្រកាន់ទោះបីជាការចោទប្រកាន់កំពុងដំណើរការក៏ដោយ គឺត្រូវបញ្ចប់ភ្លាម នេះបើយើងគោរពទៅតាមគោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង។ ហើយប្រសិនបើទោសនោះបានប្រកាសជាស្ថាពររួចមកហើយក៏ដោយ ទោសដែលចេញពីការផ្តន្ទាទោសនេះមិនត្រូវអនុវត្តទេ នេះបើផ្អែកតាមមាត្រា៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ២០០៩។

**ឧទាហរណ៍៖** បទល្មើសល្បែងស៊ីសង នៅច្បាប់ចាស់បានចែងអំពីអំពើល្បែងស៊ីសងនេះជាបទល្មើស ហើយបន្ទាប់មកក៏មានច្បាប់ថ្មីដែលចេញដោយរដ្ឋសភា និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្របានចាត់ទុកអំពើនេះមិនមែនជាបទល្មើសព្រហ្មទណ្ឌ អាស្រ័យដូចនេះបើក្នុងករណីបុគ្គលដែលបានផ្តន្ទាទោសតាមច្បាប់ចាស់កំពុងអនុវត្តទោស គឺទោសនោះត្រូវបញ្ឈប់ និងមិនត្រូវអនុវត្តទៀតនោះទេ។

**ឧទាហរណ៍៖** លោក **ក** បានប្រព្រឹត្តអំពើមួយដែលច្បាប់ព្រហ្មទណ្ឌចាត់ទុកជាមុនល្មើស ហើយពេលកំពុងអនុវត្តទោស រដ្ឋសភាបានអនុម័តច្បាប់ថ្មីដោយចាត់ទុកអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌនោះទេ ដូចនេះលោក **ក** ត្រូវបានរួចពីការចោទប្រកាន់ ហើយទោសដែលកំពុងអនុវត្តនោះមិនត្រូវអនុវត្តទៀតនោះទេ។

- **គោលការណ៍នៃច្បាប់ព្រហ្មទណ្ឌដែលកំណត់អំពីទោសស្រាលជាង** ៖ តាមមាត្រា១០ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌកម្ពុជាបានចែងថា បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម។ មានន័យថាកាលណាដែលច្បាប់ថ្មីបានចែងអំពីទោសដែលស្រាលជាងច្បាប់ចាស់ ដូចនេះតុលាការត្រូវយកបទប្បបញ្ញត្តិថ្មីដែលចែងអំពីទោសស្រាលជាងយកមកប្រើ ព្រោះដើម្បីអនុគ្រោះដល់ជនដែលបានប្រព្រឹត្ត អាចមានឱកាសកែខ្លួនជាថ្មីឡើងវិញ។

**ឧទាហរណ៍៖** អំពើលួចមួយ បានកើតឡើងនៅក្នុងច្បាប់សម័យអន្តរកាលឆ្នាំ១៩៩២-១៩៩៣ បានកំណត់ផ្តន្ទាទោសដាក់គុកចំនួន ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ហើយកំពុងតែធ្វើការចោទប្រកាន់រហូតមកដល់ក្រមព្រហ្មទណ្ឌថ្មីនេះចូលជាធរមាន ដោយក្រមថ្មីនេះបានកំណត់ត្រឹមតែ ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំតែប៉ុណ្ណោះ។ ដូច្នេះ នៅពេលដែលប្រកាសទោសចៅក្រមត្រូវយកទោសដែលកំណត់នៅក្នុងក្រមថ្មីនេះ គឺចន្លោះ ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ មកអនុវត្តទៅលើបទលួច ដែលប្រព្រឹត្តមុនកាលក្រមថ្មីនេះចូលជាធរមាន ដោយហេតុថាក្រមព្រហ្មទណ្ឌថ្មីបានកំណត់ទោសចំពោះអំពើលួចស្រាលជាង។[10]

ក៏ប៉ុន្តែបើយើងពិនិត្យមើលលើមាត្រា១០ កថាខណ្ឌទី១ ដដែលបានបន្ថែមថា ការផ្តន្ទាទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីជាទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ ចំពោះចំណុចនេះមានន័យថា ច្បាប់ថ្មីស្រាលជាងមានអានុភាពអនុវត្ត ចំពោះអំពើទាំងឡាយណាដែលបានកើតឡើងមុនពេលដែលច្បាប់ថ្មីចូលជាធរមាន ហើយពុំទាន់ត្រូវបានវិនិច្ឆ័យជាស្ថាពរនៅឡើយ ។ ប្រសិនបើមានសាលក្រម ឬសាលដីកាស្ថាពរ ហើយជាធម្មតាគេពុំអាចសើរើ ឬកែប្រែសេចក្តីសម្រេចទាំងនោះបានឡើយ លើកលែងតែទណ្ឌិតត្រូវបានដាក់ទោសដោយហេតុផលថា បានប្រព្រឹត្តអំពើណាមួយដែលជាក់ស្តែងច្បាប់ថ្មីឈប់ចាត់ទុកថាជាបទល្មើសទៀតហើយ។ ករណីបែបនេះ ត្រូវបានបញ្ញត្តដោះស្រាយដោយមាត្រា ៩ នៃក្រមព្រហ្មទណ្ឌ ដែលបានចែងថា បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។[11]

យោងតាមមាត្រា ១១ នៃក្រមព្រហ្មទណ្ឌ ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធីដែលបានបំពេញស្របតាមបទប្បញ្ញត្តិចាស់ឡើយ។ ត្រង់នេះមានន័យថាចំណាត់ការ ឬកិច្ចការផ្សេងៗ ដែលត្រូវបានអនុវត្តស្របតាមច្បាប់ស្តីពីនីតិវិធី ហើយដែលបានបំពេញស្របតាមវិធានគតិយុត្ត ដែលមានចែងនៅក្នុងមាត្រាច្បាប់ចាស់រួច និងមានតម្លៃស្របច្បាប់ ព្រមទាំងមានអានុភាពអនុវត្តបានគឺបទប្បញ្ញត្តិថ្មីដែលត្រូវអនុវត្តភ្លាមមិនមានអានុភាពទៅលើបទប្បញ្ញតិដែលមានចែងក្នុងមាត្រានៃច្បាប់ចាស់ឡើយ។

[10] ប្រសាសន៍របស់ឯកឧត្តម **ផូវ សំភី** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

[11] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

**ឧទាហរណ៍៖** ក្នុងបទល្មើសមួយដែលកំពុងចាត់ការតាមនីតិវិធីនៅក្នុងច្បាប់ចាស់ស្រាប់តែមានច្បាប់ថ្មីបានចូលជាធរមាន ហើយស្រាលជាងច្បាប់ចាស់។ ក្នុងករណីនេះនីតិវិធីដែលកំពុងចាត់ការនៅក្នុងច្បាប់ចាស់ គឺត្រូវយកមកអនុវត្តបន្ត ប៉ុន្តែទោសដែលត្រូវដាក់វិញគឺត្រូវយកទោសដែលស្រាលជាងមកអនុវត្តគឺតាមច្បាប់ថ្មី។[12]

**ខ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហ ឬដែនដី**

ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងដែនដីនេះ គឺជាសិទ្ធិអធិបតេយ្យមួយទាក់ទងនឹងរឿងព្រហ្មទណ្ឌ នៅក្នុងនេះគេចែកដែនដីដែលមានការប្រព្រឹត្តបទល្មើសជាពីរមានដូចជា បទល្មើសដែលបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅក្នុងដែនដីកម្ពុជា **(ខ.១)** និងបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីកម្ពុជា **(ខ.២)**។

**ខ.១ បទល្មើសដែលបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅក្នុងដែនដីកម្ពុជា**

ដោយអនុលោមតាមមាត្រា ២ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាឆ្នាំ១៩៩៣ បានចែងថា «បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាត ក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជា អន្តរជាតិនៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩»។

តាមស្មារតីនៃរដ្ឋធម្មនុញ្ញនេះ គឺគ្រប់បទល្មើសដែលកើតមានក្នុងរង្វង់ដែនដី ដូចបានកំណត់ខាងលើត្រូវយកច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាមកអនុវត្ត ឬអាចនិយាយបានថា ឱ្យតែមានបទល្មើសប្រព្រឹត្តនៅលើដែនដីកម្ពុជា តុលាការកម្ពុជាជាអ្នកមានសិទ្ធិ ឬសមត្ថកិច្ចដែលត្រូវយកច្បាប់របស់កម្ពុជាមកអនុវត្ត ទោះជនល្មើស ឬជនរងគ្រោះមានសញ្ជាតិអ្វីក៏ដោយ។

ការលើកឡើងខាងលើនេះគឺផ្អែកទៅតាមមាត្រា១២ ដែលចែងអំពីគោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា ត្រង់មាត្រានេះបានចែងថា «ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយណា ដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា» ត្រង់នេះមានន័យថាឱ្យតែមានបទល្មើសប្រព្រឹត្តនៅលើដែនដីកម្ពុជា គឺត្រូវយកច្បាប់ព្រហ្មទណ្ឌកម្ពុជាមកអនុវត្ត ដូចនេះគ្រប់ជនដែលបានប្រព្រឹត្តបទល្មើសនៅលើដែនដីកម្ពុជាគឺត្រូវតែទទួលទោសចំពោះមុខច្បាប់កម្ពុជា។ ចំពោះដែនដីនេះ មាត្រាដដែលក៏បានបញ្ជាក់ដែរថា «ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា»។ ការយកគោលការណ៍នេះមកអនុវត្ត គឺក្នុងគោលបំណង ដើម្បីការធានាសុវត្ថិភាព ការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងប្រទេស។

**ឧទាហរណ៍៖** លោក **ក** ដែលជាជនជាតិថៃ បានសម្លាប់ជនជាតិខ្មែរ ឬសម្លាប់ជនជាតិដទៃនៅលើដែន

[12] ណែនាំដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង**, ដកស្រង់ចេញពីសារណាបញ្ចប់ការសិក្សាប្រធានបទ បទល្មើសព្រហ្មទណ្ឌ ឆ្នាំ២០២២។

ដីកម្ពុជា ករណីនេះបើផ្អែកតាមគោលការណ៍ដែនដីនេះ គឺត្រូវយកច្បាប់កម្ពុជាមកអនុវត្ត ហើយនឹងត្រូវផ្តន្ទាទោសជនល្មើសដែលជាលោក **ក** នោះទៅតាមច្បាប់កម្ពុជា។

យោងតាមគោលការណ៍នៃប្រព័ន្ធដែនដី តម្រូវឱ្យមានការផ្តន្ទាទោសលើគ្រប់ជនល្មើសទាំងអស់ ទោះបីជននោះជាពលរដ្ឋកម្ពុជាក្តី ឬជាជនបរទេសក្តី។ ប្រសិនបើជនទាំងនោះបានប្រព្រឹត្តអំពើល្មើសលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលការផ្តន្ទាទោសចំពោះមុខតុលាការកម្ពុជា លើកលែងតែប្រភេទជនបរទេសមួយចំនួនដែលច្បាប់ផ្តល់អភ័យឯកសិទ្ធិដោយឡែកតាមអនុសញ្ញាអន្តរជាតិ។ ជនបរទេសទាំងនោះមានដូចជា៖

- ជនបរទេសដែលបម្រើការនៅស្ថានទូត ដូចជា ឯកអគ្គរដ្ឋទូត, អគ្គរដ្ឋទូត, ប្រេសិត, ភារៈមេធាវី ព្រមទាំងក្រុមគ្រួសារ និងបុគ្គលិកស្ថានទូត ក្នុងរយៈពេលដែលបំពេញបេសកកម្មការទូត។
- ជនបរទេសដែលបម្រើការងារនៅស្ថានកុងស៊ុល ដូចជា អគ្គកុងស៊ុល, កុងស៊ុល និងបុគ្គលិក កុងស៊ុល ព្រមទាំងក្រុមគ្រួសាររបស់គេក្នុងពេលបំពេញបេសកកម្មការទូត។
- ជនបរទេសដទៃទៀត ដូចជា តំណាងអង្គការសហប្រជាជាតិ, តំណាងរដ្ឋាភិបាល, តំណាងអង្គការ ក្រៅរដ្ឋាភិបាល ក្នុងដំណើរទស្សនៈកិច្ចជាផ្លូវការក្តី ក្រៅផ្លូវការក្តី ឬមានបេសកកម្មពិសេសនៅកម្ពុជាក្តី ដោយផ្អែកលើសន្ធិសញ្ញាអន្តរជាតិ ឬអនុសញ្ញាអន្តរជាតិ។[13]

**ខ.២ ស្ថានភាពទាំងប្រាំនៃបទល្មើសដែលចាត់ថាបានប្រព្រឹត្តនៅក្នុងដែនដីកម្ពុជា**

ចំពោះបទល្មើសមួយចំនួន អាចប្រព្រឹត្តមិនមែននៅក្នុងដែនដីកម្ពុជាទាំងស្រុងនោះទេ ក៏ប៉ុន្តែច្បាប់ព្រហ្មទណ្ឌកម្ពុជាក៏ចាត់ទុកថាបានប្រព្រឹត្តនៅក្នុងដែនដីកម្ពុជាផងដែរ ដែលស្ថានភាពទាំងនោះមានដូចជា៖

❖ **ទីកន្លែងប្រព្រឹត្តបទល្មើស៖** តាមរយៈមាត្រា១៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ បានចែងថា «បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅ ពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា»[14] ផ្អែកតាមមាត្រានេះមានន័យថា ឱ្យតែអំពើណាមួយ ឬផ្នែកណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅក្នុងដែនដីកម្ពុជា បទល្មើសនោះនឹងត្រូវចាត់ថាបានប្រព្រឹត្តនៅក្នុងដែនដីកម្ពុជា។ **ឧទាហរណ៍៖** បទល្មើសឆបោក ជនល្មើសបានប្រើប្រាស់វិធីឆបោកនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែការប្រគល់ទ្រព្យដែលបានឆបោកនោះ នៅលើទឹកដីបរទេស ក្នុងករណីនេះច្បាប់កម្ពុជាបានចាត់ទុកថាបទល្មើសបានប្រព្រឹត្តក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា នេះបើផ្អែកតាមមាត្រា ១៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩។

---

[13] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ សម្រាប់និស្សិតឆ្នាំទី២។

[14] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៣។

❖ **បទល្មើសដែលបានប្រព្រឹត្តក្នុងនាវាកម្ពុជា៖** តាមរយៈមាត្រា ១៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ បានចែងថា « ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែល ប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ » គឺមានន័យថានាវាដែលបានចុះបញ្ជីនៅកម្ពុជា ហើយនាវានោះបានចេញទៅលើដែនដីនៃរដ្ឋបរទេស។ **ឧទាហរណ៍៖** នាវាដែលមានសញ្ជាតិខ្មែរ បានធ្វើដំណើរទៅលើដែនដីនៃរដ្ឋបរទេស ហើយក៏មានបទល្មើសកើតឡើងនៅលើនាវានោះ។ ដូចនេះច្បាប់កម្ពុជាយើងក៏បានចែងយ៉ាងច្បាស់ថា គឺជាសមត្ថកិច្ចរបស់ច្បាប់ព្រហ្មទណ្ឌកម្ពុជា នេះបើផ្អែកតាមមាត្រា ១៤ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩។

❖ **បទល្មើសដែលបានប្រព្រឹត្តក្នុងនាវាបរទេស៖** តាមរយៈមាត្រា ១៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ បានចែងថា «ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែល ប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ»។[15]ត្រង់ចំណុចនេះមានន័យថា តាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ យើងអាចមានសិទ្ធិចូលទៅត្រួតពិនិត្យមើល ឬអាចត្រូវបានគេស្នើសុំឱ្យជួយអន្តរាគមន៍នូវបទល្មើសមួយចំនួនដែលបានប្រព្រឹត្តក្នុងនាវាបរទេស។ ក្នុងករណីនេះច្បាប់ព្រហ្មទណ្ឌកម្ពុជាមានសមត្ថកិច្ចទៅលើបទល្មើសនោះ នេះបើផ្អែកតាមមាត្រា ១៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩។

❖ **បទល្មើសដែលបានប្រព្រឹត្តក្នុងអាកាសយានកម្ពុជា ៖** តាមរយៈមាត្រា ១៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ បានចែងថា ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្ត នៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ។[16] អាកាសយាន សំដៅលើយន្តហោះដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជារួចរាល់។ **ឧទាហរណ៍៖** នៅពេលដែលយន្តហោះដែលបានចុះបញ្ជីនៅកម្ពុជា ឬយន្តហោះដែលមានសញ្ជាតិខ្មែរមានបទល្មើសកើតឡើងក្នុងនោះ ករណីនេះច្បាប់កម្ពុជាមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ និងមានសិទ្ធិដោះស្រាយ ឬធ្វើការផ្តន្ទាទោសចំពោះករណីនោះ ផ្អែកតាមមាត្រា ១៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា។

❖ **បទល្មើសដែលមានអ្នកផ្តើមគំនិត ឬសមគំនិតនៅលើដែនដីកម្ពុជា ៖** តាមរយៈមាត្រា ១៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ បានចែងថា ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមនេះត្រូវបានបំពេញ ៖

[15] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៥។

[16] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦។

1. បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង និង
2. អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស។[17]

ក្នុងករណីបទល្មើសជាបទលហុ អ្នកផ្តើមគំនិត ឬអ្នកសមគំនិត មិនត្រូវបានផ្តន្ទាទោសឡើយ ផ្អែកតាមមាត្រា ១៧ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩។

**ខ.៣ បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីកម្ពុជា**

យើងបានដឹងមកហើយថា កាលណាមានបទល្មើសកើតឡើងនៅលើដែនដីនៃប្រទេសកម្ពុជា គឺត្រូវតែយកច្បាប់កម្ពុជាមកអនុវត្ត នេះបើផ្អែកតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ដែលចែងអំពីគោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា។ អាស្រ័យដូចនេះក្នុងករណីដែលមានបទល្មើសបានកើតឡើងនៅក្រៅដែនដីនៃប្រទេសកម្ពុជា តើច្បាប់កម្ពុជាអាចយកទៅអនុវត្តនៅក្រៅដែនដីបានដែរឬទេ? បើពិនិត្យមើលក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ក៏បានចែងអំពីសមត្ថកិច្ចរបស់ច្បាប់ព្រហ្មទណ្ឌកម្ពុជាទៅលើបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីកម្ពុជាផងដែរ។ ច្បាប់ព្រហ្មទណ្ឌដែលមានអានុភាពអនុវត្តនេះ គឺផ្អែកទៅតាមគោលការណ៍នៃសញ្ជាតិ មានន័យថា ទោះបុគ្គលប្រព្រឹត្តបទល្មើសបានប្រព្រឹត្តនៅក្រៅដែនដីនោះមានសញ្ជាតិខ្មែរ ឬជនបរទេសក៏ដោយ ឱ្យតែជនរងគ្រោះជាជនជាតិខ្មែរ គឺត្រូវអនុវត្តទៅតាមច្បាប់កម្ពុជា។

- **ករណីសញ្ជាតិរបស់ជនល្មើស** ៖ ក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ត្រង់មាត្រា ១៩ អំពីជនល្មើសដែលជាពលរដ្ឋខ្មែរ បានប្រព្រឹត្តបទល្មើសនៅក្រៅដែនដីកម្ពុជា។[18] បទល្មើសត្រូវបានបែងចែកជាពីរគឺ ៖

1. **ចំពោះបទឧក្រិដ្ឋ** ជនល្មើសដែលជាពលរដ្ឋខ្មែរប្រព្រឹត្តបទល្មើសនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ព្រហ្មទណ្ឌកម្ពុជាមានអានុភាពអនុវត្តទៅលើជនល្មើសដែលប្រព្រឹត្តបទល្មើសនេះតែម្តង គឺមានន័យថា ច្បាប់ព្រហ្មទណ្ឌកម្ពុជាអាចធ្វើការផ្តន្ទាទោសទៅលើជនល្មើសនោះបាន (មាត្រា១៩ កថាខណ្ឌទី១ )។
2. **ចំពោះបទមជ្ឈិម** ជនល្មើសដែលជាពលរដ្ឋខ្មែរប្រព្រឹត្តបទល្មើសនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា អាចនឹងត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជាបាន លុះត្រាតែបទល្មើសដែលប្រព្រឹត្តនោះ ត្រូវបានប្រទេសក្រៅនោះបានកំណត់ថាគឺជាបទល្មើសដែលត្រូវផ្តន្ទាទោសផងដែរ(មាត្រា១៩ កថាខណ្ឌទី១)។ ឧទាហរណ៍៖ ករណីជនម្នាក់ប្រព្រឹត្តអំពើលួចនៅប្រទេសក្រៅ ប្រសិនបើប្រទេសនោះចាត់ទុកអំពើនោះជាបទល្មើសដែលត្រូវផ្តន្ទាទោសដែរនោះ គឺច្បាប់ព្រហ្មទណ្ឌកម្ពុជាមានអនុភាពអនុវត្តទៅលើអំពើនោះផងដែរ។ ប៉ុន្តែប្រសិនបើប្រទេសក្រៅនោះ មិនបានចែងថាអំពើនោះជាបទល្មើសទេ ករណីនេះច្បាប់ព្រហ្មទណ្ឌកម្ពុជាមិនអាចអនុវត្តចំពោះបទល្មើសនោះបានទេ។

[17] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៧។

[18] សូមអានមាត្រា ១៩ ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

- **ករណីសញ្ជាតិរបស់ជនរងគ្រោះ** ៖ ដោយផ្អែកតាមមាត្រា ២០ នៃក្រមព្រហ្មទណ្ឌកម្ពុជា២០០៩ បានចែងថា ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត។ តាមរយៈមាត្រានេះមានន័យថា កាលណាជនរងគ្រោះជាជនជាតិខ្មែរដែលរស់នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានគេប្រព្រឹត្តបទឧក្រិដ្ឋមកលើខ្លួន ដូចនេះមិនថាពលរដ្ឋខ្មែរជាប្រព្រឹត្ត ឬជនបរទេសជាអ្នកប្រព្រឹត្តនោះទេ នោះច្បាប់ព្រហ្មទណ្ឌកម្ពុជាមានអានុភាពអនុវត្តទៅលើអំពើនោះ។ ច្បាប់ព្រហ្មទណ្ឌអាចអនុវត្តបានចំពោះតែបទឧក្រិដ្ឋតែប៉ុណ្ណោះ។[19]

តាមរយៈមាត្រា ២១ នៃក្រមព្រហ្មទណ្ឌកម្ពុជា២០០៩ បានចែងអំពីការធ្វើបណ្តឹងចោទប្រកាន់ ដែលត្រង់មាត្រានោះបានចែងថា នៅក្នុងករណីដែលមានចែងនៅក្នុងមាត្រា ១៩ (បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ) និងមាត្រា ២០ (ជនរងគ្រោះជាជនជាតិខ្មែរ) នៃក្រមនេះ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អយ្យការតែប៉ុណ្ណោះ។ ការចោទប្រកាន់ត្រូវតែមានបណ្តឹងពីជនរងគ្រោះ ឬពីសិទ្ធិវន្ត ឬបណ្តឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត ។[20]

- **បទល្មើសដែលប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា** ៖ ក្រៅពីសញ្ជាតិរបស់ជនល្មើស និងសញ្ជាតិរបស់ជនរងគ្រោះ ច្បាប់ព្រហ្មទណ្ឌកម្ពុជា មានអានុភាពអនុវត្តទៅលើបទល្មើសដែលប្រឆាំងនឹងកម្ពុជាផងដែរ ។ ក្នុងនោះអាចពិនិត្យឃើញមានបទល្មើសចំនួន ៥ ប្រភេទដែលមានដូចជា៖

  1. បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ។
  2. បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ។
  3. បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិដែលមានតម្លៃស្របច្បាប់នៅកម្ពុជា។
  4. បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។
  5. បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។[21]

### ១.៤ ការអនុវត្តច្បាប់ព្រហ្មទណ្ឌដោយតុលាការ

តាមរយៈគោលការណ៍នីត្យានុកូលខាងលើ គេសង្កេតឃើញថាមានបញ្ហាពិសេសមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌដោយតុលាការ ដែលសរុបមកមានចំនួន ២ សំខាន់ៗដូចជា ការវាយតម្លៃកំណត់បទល្មើស **(ក)** និងការបកស្រាយច្បាប់ព្រហ្មទណ្ឌ **(ខ)**។

[19] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២០។
[20] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២១។
[21] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២២។

## ក. ការវាយតម្លៃកំណត់បទល្មើស

នៅពេលដែលមានបទល្មើសមួយកើតឡើង ចៅក្រមត្រូវស្វែងរកអត្ថបទច្បាប់ដែលកំណត់ថាអំពើពាក់ព័ន្ធនោះគឺជាបទល្មើស និងត្រូវយកច្បាប់នោះមកអនុវត្តលើបទល្មើស ។ ប្រតិបត្តិការបែបនេះ ត្រូវគេឱ្យឈ្មោះថាជាការវាយតម្លៃកំណត់បទល្មើស ។ ជាការពិតនៅក្នុងនីតិព្រហ្មទណ្ឌ ការវាយតម្លៃកំណត់បទល្មើសគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដោយសារតែគោលការណ៍នីត្យានុកូលភាពបានកំណត់ថា **គ្មានច្បាប់ គ្មានបទល្មើស**។ ដូច្នេះ ចៅក្រមត្រូវតែកំណត់ឱ្យបានច្បាស់នូវច្បាប់ណាដែលត្រូវយកមកអនុវត្ត ចំពោះអំពើណាមួយជាកំណត់ឱ្យបានយ៉ាងត្រឹមត្រូវតាមផ្លូវច្បាប់ ។[22]

ចំពោះការវាយតម្លៃកំណត់បទល្មើសនេះ យើងអាចនិយាយបានថាជាការកំណត់ឈ្មោះនៃបទល្មើស ឬការកំណត់បទល្មើសដើម្បីធ្វើការចោទប្រកាន់។ ដើម្បីអាចកំណត់បទល្មើសបានទាមទារមានការសិក្សាអំពីបទល្មើសឱ្យបានច្បាស់លាស់ជាមុនសិន ពោលទាំងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ និងបទល្មើសដែលមានចែងក្នុងច្បាប់ពិសេសផ្សេងៗទាក់ទងនឹងវិស័យព្រហ្មទណ្ឌ។ ឧទាហរណ៍ករណីខាងក្រោមនេះ៖

**១.** បុរសម្នាក់បានដកយកទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការព្រមព្រៀង នេះជាបទល្មើសលួច តាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។ **២.** លោក **ក** បានយកដុំថ្មវាយទៅលើលោក **ខ** ដោយមូលហេតុមានជម្លោះជាមួយគ្នា នេះជាបទល្មើសហិង្សាដោយចេតនា ( តាមមាត្រា ២១៧ )។

## ខ. ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌ ចៅក្រមមានករណីកិច្ចត្រូវតែធ្វើការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹង និងមានភាពច្បាស់លាស់។ ការបកស្រាយច្បាប់ គឺជាការស្វែងរកអត្ថន័យពិតប្រាកដរបស់ច្បាប់ ដើម្បីអាចអនុវត្តច្បាប់ឱ្យបានច្បាស់លាស់ និងបានត្រឹមត្រូវ។[23]

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ។[24] សទិសភាព មានន័យថាស្រដៀងគ្នា ដកស្រង់ពីវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត។ ត្រង់មាត្រា ៥ អំពីគោលការណ៍ការបកស្រាយច្បាប់ព្រហ្មទណ្ឌ សំដៅទៅលើការបកស្រាយច្បាប់ព្រហ្មទណ្ឌដែលមានចែងអំពីបទល្មើស នឹងទោស ដោយគោរពទៅតាមគោលបំណងនៃអ្នកនីតិកម្ម ឬការបកស្រាយដោយគោរពតាមអត្ថន័យមួយយ៉ាងតឹងរ៉ឹង ដើម្បីកុំឱ្យឃ្លាតចាកពីគោលការណ៍នីត្យានុកូល។ គោលការណ៍នៃការបកស្រាយច្បាប់ព្រហ្មទណ្ឌបានហាមដាច់ខាត មិនឱ្យចៅក្រមពង្រីកវិសាលភាពអនុវត្ត ឬ

---

[22] សាស្ត្រាចារ្យ **នុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[23] សាស្ត្រាចារ្យ **នុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[24] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥។

ការប្រព្រឹត្តតាមសទិសភាពឡើយ មានន័យថាចៅក្រមមិនអាចបកស្រាយតាមន័យ ប្រដូច ឬប្រៀបធៀប ឬប្រហាក់ប្រហែលនោះឡើយ។ **ឧទាហរណ៍៖** ក្រមព្រហ្មទណ្ឌបានកំណត់ថា ការជិះឡានក្រុងមិនឱ្យលុយជាអំពើខុសច្បាប់ព្រហ្មទណ្ឌ និងត្រូវទទួលទោសព្រហ្មទណ្ឌ។ ពេលនោះមានអំពើមួយបានកើតឡើង ដោយលោក ក បានចូលទៅហាងអាហារមួយ ពេលរួចរាល់គាត់(ក) មិនមានលុយសម្រាប់ការទូទាត់ថ្លៃអាហារ។ ករណីនេះបើយើងពិនិត្យមើលទៅវាមានភាពប្រហាក់ប្រហែលគ្នា ឬស្រដៀងគ្នា ប៉ុន្តែផ្អែកតាមគោលការណ៍នៃការបកស្រាយច្បាប់ព្រហ្មទណ្ឌហាមមិនឱ្យបកស្រាយក្នុងន័យប្រដូចបែបនេះឡើយ។ ដូចនេះចៅក្រមមិនអាចយកអំពើដែលចូលហាងអាហារមិនឱ្យលុយ ទៅផ្តន្ទាទោសចូលក្នុងបទល្មើស ការជិះឡានក្រុងមិនឱ្យលុយនោះឡើយ។

## ២. ធាតុសត្យានុម័ត ឬធាតុសម្ភារៈ

ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ សំដៅទៅលើអំពើដែលជនល្មើសបានប្រព្រឹត្តស្តែងចេញមកខាងក្រៅ ឬហេតុការណ៍ណាមួយដែលនាំឱ្យមានអំពើស្តែងចេញមកខាងក្រៅ។ ដូចនេះដើម្បីឈ្វេងយល់ឱ្យកាន់តែច្បាស់អំពីធាតុសត្យានុម័តនេះ យើងខ្ញុំនឹងលើកយកចំណុចមួយចំនួនមកធ្វើការបកស្រាយបង្ហាញក្នុងធាតុនេះ ដែលចំណុចទាំងនោះមានដូចតទៅ៖ អត្ថន័យនៃធាតុសត្យានុម័ត **(២.១)** បទល្មើសបានសម្រេច **(២.២)** និងបទល្មើសមិនបានសម្រេច ឬការប៉ុនប៉ង **(២.៣)**។

### ២.១ អត្ថន័យនៃធាតុសត្យានុម័ត

ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ សំដៅទៅលើអំពើដែលជនល្មើសបានប្រព្រឹត្តស្តែងចេញមកខាងក្រៅ មិនថាដោយអំពើសកម្ម ឬអកម្មក្តី ដែលអំពើនោះធ្វើឱ្យមានព្យសនកម្ម ដែលព្យសនកម្មនោះមានដូចជា ការប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពបុគ្គល ទ្រព្យសម្បត្តិសាធារណៈ ឬឯកជនជាដើម។ ដូចនេះទោះបីជាមានអំពើក៏ដោយ បើពុំមានព្យសនកម្មនោះទេ ក៏មិនអាចធ្វើការដាក់ទណ្ឌកម្មដល់ជននោះដែរ នេះទាក់ទងទៅនឹងទំនាក់ទំនងហេតុផលរវាងអំពើ និងព្យសនកម្ម។ សូមបញ្ជាក់៖ ព្យសនកម្មពុំមែនជាលក្ខខណ្ឌចាំបាច់ដើម្បីកំណត់បទល្មើសទេ ករណីមួយចំនួនដូចជា បទល្មើសជួញដូរអាវុធខុសច្បាប់ បទល្មើសគ្រឿងញៀនជាដើម។

ចំពោះទំនាក់ទំនងហេតុផលរវាងអំពើ និងព្យសនកម្មនេះ មានន័យថា ត្រូវមានចំណងទាក់ទងរវាងការខូតខាត ជាមួយនឹងអំពើ គឺបើសិនអំពើមួយផ្សេង ហើយការខូចខាតកើតឡើងមួយផ្សេងចេញក្រៅពីអំពើនេះ ក៏យើងមិនអាចយកអំពើរបស់បុគ្គលម្នាក់ដែលមិនបានធ្វើឱ្យមានការខូចខាតនេះ មកដាក់ទណ្ឌកម្ម ឬឱ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។[25]

[25] ប្រសាសន៍របស់ឯកឧត្តម **ប៊ុន ហុន** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធី ផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

ជាធម្មតា បទល្មើសត្រូវតែស្តែងឡើងដោយអំពើជាសម្ភារៈដែលគេអាចពិនិត្យមើលឃើញបាន បទល្មើសដែលស្តែងចេញជាសម្ភារៈមកខាងក្រៅនេះគេបែងចែកជាពីរគឺ បទល្មើសបានសម្រេច **(២.២)** និងបទល្មើសមិនបានសម្រេច ឬការប៉ុនប៉ង**(២.៣)**។ នៅពេលបទល្មើសបានសម្រេច មានន័យថា បទល្មើសបានឈានដល់គោលដៅចប់សព្វគ្រប់ហើយ ចារីដាច់ខាតត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែអ្វីដែលចោទជាការលំបាក គឺថាអំពើដែលពុំទាន់ចប់សព្វគ្រប់ ត្រូវមានកម្រិតត្រឹមណា ទើបតុលាការអាចចោទប្រកាន់ ឬផ្តន្ទាទោសបាន?[26] ដូចនេះយើងនឹងបកស្រាយចំណុចនីមួយៗជាបន្តបន្ទាប់នៅខាងក្រោមនេះ។

## ២.២ បទល្មើសបានសម្រេច

បទល្មើសបានសម្រេចត្រូវបានស្តែងចេញជាអំពើ ឬបទល្មើស ២ ប្រភេទដូចជា បទល្មើសសកម្ម ឬអំពើវិជ្ជមាន **(ក)** និងបទល្មើសអកម្ម ឬអំពើអវិជ្ជមាន **(ខ)**។

### ក. បទល្មើសសកម្ម ឬអំពើវិជ្ជមាន

បទល្មើសសកម្ម ឬអំពើវិជ្ជមាន គឺមានន័យថាបទល្មើសដែលជនល្មើសប្រព្រឹត្តបានបំពានលើការហាមឃាត់របស់ច្បាប់ព្រហ្មទណ្ឌ។ **ឧទាហរណ៍ ១**. បទឃាតកម្ម ដោយជនល្មើសបានយកកាំបិតចាក់ទៅលើជនម្នាក់បណ្តាលឱ្យស្លាប់បាត់បង់ជីវិត អំពើនេះត្រូវបានចាត់ទុកជាបទល្មើសសកម្មព្រោះវាជាបទល្មើសដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់។ **២**. អំពើជាសត្យានុម័តនៃអំពើលួច គឺជាអំពើដែលដកហូតយកទ្រព្យសម្បត្តិរបស់អ្នកដទៃ។

### ខ. បទល្មើសអកម្ម ឬអំពើអវិជ្ជមាន

បទល្មើសអកម្ម ឬអំពើអវិជ្ជមាន គឺមានន័យថាបទល្មើសដែលជនល្មើសមិនព្រមបំពេញកាតព្វកិច្ចអ្វីមួយទៅតាមច្បាប់តម្រូវឱ្យធ្វើ ឬអាចនិយាយថា ជនល្មើសមិនបានធ្វើអំពើដែលច្បាប់តម្រូវឱ្យធ្វើ។ **ឧទាហរណ៍** បទមិនប្តឹងបរិហារបទឧក្រិដ្ឋ មាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌបានចែងថា រាល់បុគ្គលណាដែលបានដឹងពីបទឧក្រិដ្ឋ ដែលអាចនឹងបង្ការ ឬ បន្ថយអានុភាព របស់បទល្មើសបាន ហើយមិនប្តឹងបរិហារដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។ **ឧទាហរណ៍** បទមិនប្តឹងបរិហារការធ្វើបាបអនីតិជន មាត្រា ៥៣០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

## ២.៣ បទល្មើសមិនបានសម្រេច ឬការប៉ុនប៉ង

ក្នុងការផ្តន្ទាទោសបទល្មើស ដើម្បីឱ្យអំពើល្មើសមួយអាចត្រូវផ្តន្ទាទោសបាន ច្បាប់មិនបានតម្រូវឱ្យចាំរហូតដល់លទ្ធផលបានសម្រេចនោះទេ។ ដូច្នេះនៅត្រង់នេះយើងខ្ញុំនឹងលើកយកចំណុច ២ មកធ្វើការបកស្រាយ

[26] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

ដែលមានដូចជា៖ ដំណាក់កាលនៃការប្រព្រឹត្តបទល្មើស (ក) និងការប៉ុនប៉ង (ខ)។ ថាតើលក្ខខណ្ឌ ឬដំណាក់កាលណាខ្លះ ដែលដំណាក់កាលនៃការប្រព្រឹត្តបទល្មើស និងការប៉ុនប៉ង ដែលច្បាប់អាចត្រូវផ្តន្ទាទោសបាន?

### ក. ដំណាក់កាលនៃការប្រព្រឹត្តបទល្មើស

មុនឈានដល់ការបកស្រាយអំពីការប៉ុនប៉ង ចំណុចដំបូងគប្បីយើងឈ្វេងយល់អំពីដំណាក់កាលនៃការប្រព្រឹត្តបទល្មើសជាមុនសិន។ បទល្មើសនីមួយៗតែងតែឆ្លងកាត់នូវស្ថានភាព ៤ ដំណាក់កាល ដូចបានរៀបរាប់នេះ ដំណាក់កាលគិត និងការសម្រេចចិត្ត **(ក.១)** ដំណាក់កាលត្រៀមប្រព្រឹត្តបទល្មើស **(ក.២)** ដំណាក់កាលចាប់ផ្តើមប្រព្រឹត្តបទល្មើស **(ក.៣)** និងដំណាក់កាលបទល្មើសបានសម្រេច ឬមិនបានសម្រេច **(ក.៤)** ។

#### ក.១ ដំណាក់កាលគិត និងការសម្រេចចិត្ត

ដំណាក់កាលនេះ ជាដំណាក់កាលដំបូង ដែលជនល្មើសបានគិតពិចារណាយ៉ាងច្បាស់លាស់មុននឹងសម្រេចចិត្តប្រព្រឹត្តបទល្មើសមួយទៅលើអ្នកដទៃ។ នៅក្នុងដំណាក់កាលនេះ ប្រសិនបើជនល្មើសបានត្រឹមតែគិតពិចារណា និងបានសម្រេចចិត្តថានឹងប្រព្រឹត្តបទល្មើសណាមួយក៏ដោយ ក៏ការគិត និងការសម្រេចចិត្តរបស់គាត់មិនត្រូវបានផ្តន្ទាទោសនោះទេ។ ដោយមូលហេតុថា មនុស្សម្នាក់ៗមានសិទ្ធិរបស់ខ្លួនក្នុងការគិតពិចារណា ទោះបីជាការគិតនោះស្តែងឡើងក្នុងន័យប្រព្រឹត្តបទល្មើសក៏ដោយ។ ហើយច្បាប់ក៏ពុំបានចែងថា ការគិត និងការសម្រេចចិត្តបែបនេះត្រូវផ្តន្ទាទោសនោះដែរ ព្រោះថាគ្រាន់តែគិត និងសម្រេចចិត្តបែបនេះ មិនទាន់ធ្វើអោយជនណាម្នាក់ ឬក៏សង្គមណាមួយទទួលរងនូវព្យសនកម្មពីជននោះដែរ ហើយក៏ពុំមានអំពើណាមួយស្តែងចេញមកក្រៅជាសម្ភារៈដើម្បីកំណត់បទល្មើសនោះដែរ។

#### ក.២ ដំណាក់កាលត្រៀមប្រព្រឹត្តបទល្មើស

ចំពោះក្នុងដំណាក់កាលនៃការត្រៀមនេះ គឺជាដំណាក់កាលមួយដែលជនល្មើសរៀបចំគម្រោងប្រព្រឹត្តសកម្មភាពរបស់ខ្លួន ដែលគេបានគិត និងបានសម្រេចចិត្តរួចហើយពីមុនមកនោះ។ មានន័យថា មុនឈានដល់ការប្រព្រឹត្តបទល្មើស ជននោះបានរៀបគម្រោងគ្រប់មធ្យោបាយដើម្បីសម្រេចនូវបំណងដែលគេចង់បាន។

**ឧទាហរណ៍៖** លោក **ក** បានខឹងនឹងលោក **ខ** ដែលមើលងាយ និងជេរប្រមាថខ្លួន ពេលនោះលោក **ក** បានសម្រេចចិត្តថានឹងសងសឹកលើលោក **ខ** ដោយគាត់បានទៅទិញកាំបិតមកដាក់តាមខ្លួន ហើយគាត់បានទៅពិនិត្យមើលសកម្មភាពរបស់លោក **ខ** ថាតើលោក **ខ** ទៅណាមកណាខ្លះក្នុងមួយថ្ងៃៗ។ ចំពោះសកម្មភាពខាងលើនេះគឺជាការត្រៀមប្រព្រឹត្តបទល្មើស ព្រោះគាត់បានត្រៀមដោយទិញកាំបិតដើម្បីយកទៅសងសឹងលោក **ខ**។

នៅក្នុងដំណាក់កាលនេះ គឺពុំទាន់បង្កើតបានជាបទល្មើសដែលត្រូវផ្តន្ទាទោសនៅឡើយនោះទេ ព្រោះថា មិនទាន់ធ្វើអោយជនណាម្នាក់ ឬក៏សង្គមណាមួយទទួលរងនូវព្យសនកម្ម ពីអំពើត្រៀមនោះនៅឡើយទេ។

ហើយក៏ពុំមានអំពើណាមួយស្តែងចេញមកក្រៅជាសម្ភារៈដើម្បីកំណត់ជាបទល្មើសនោះដែរ មានន័យថា **ក** អាចផ្លាស់ប្តូរគំនិតមិនចង់សងសឹកលោក **ខ** តែបែរជាយកកាំបិតនោះទៅធ្វើកសិកម្មវិញ។

ប៉ុន្តែអំពើត្រៀមមួយចំនួនត្រូវបានបទប្បញ្ញត្តិច្បាប់បញ្ញត្តថាជាបទល្មើស ទោះមិនទាន់បង្កព្យសនកម្មក៏ដោយ ជាពិសេសបទល្មើសដែលពាក់ព័ន្ធដល់សន្តិសុខជាតិជាដើម ព្រោះថាបទល្មើសទាំងនោះមានចរិតគ្រោះថ្នាក់ធ្ងន់ធ្ងរ។ បទល្មើសទាំងនោះមានដូចជា៖ បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋសង្គ្រាមជាដើម។ ក្នុងករណីមួយទៀត ដូចជាបុគ្គលម្នាក់បានទិញអាវុធ គ្រាប់រំសេវ សម្រាប់សម្លាប់មនុស្សដែលជាសត្រូវ ហើយត្រូវអាជ្ញាធរមានសមត្ថកិច្ចចាប់ខ្លួនបាន។ ករណីនេះទោះបីបទល្មើសសម្លាប់មនុស្សមិនទាន់បានប្រព្រឹត្តក៏ដោយ ក៏ត្រូវចោទប្រកាន់បានដែរពីបទប្រើប្រាស់អាវុធខុសច្បាប់។[27]

**ក.៣ ដំណាក់កាលចាប់ផ្តើមប្រព្រឹត្តបទល្មើស**

នៅក្នុងដំណាក់កាលនេះ គឺជនល្មើសចាប់ផ្តើមប្រព្រឹត្តសកម្មភាពរបស់ខ្លួន ដើម្បីសម្រេចនូវបំណងដែលគេបានគិតប៉ងទុកជាមុននោះ មានន័យថាជនល្មើសបានចាប់ផ្តើមធ្វើសកម្មភាពដើម្បីសម្រេចបទល្មើស។

**ឧទាហរណ៍៖** លោក **ក** យកកាំបិតដែលគាត់សំលៀងរួចមកតាមខ្លួន ហើយលោកបានពួនស្ទាក់ដើម្បីធ្វើការវាយប្រហារទៅលើបុគ្គលដែលគាត់ចង់សងសឹក។ ក្នុងស្ថានភាពនេះគឺឈានចូលដល់ដំណាក់កាលមួយដែលគេឱ្យឈ្មោះថា ការចាប់ផ្តើមប្រព្រឹត្តបទល្មើស មានន័យថាពេលជនរងគ្រោះមកដល់កន្លែងដែលគាត់ពួនស្ទាក់នោះ គាត់នឹងយកកាំបិតកាប់ទៅលើជនរងគ្រោះនោះ។ ក្នុងដំណាក់កាលនេះ បើសិនលោក **ក** បានបញ្ឈប់អំពើរបស់ខ្លួនដោយចេតនា នោះមិនមានទោសទេ ប៉ុន្តែបើគាត់មិនបញ្ឈប់អំពើរបស់ខ្លួនដោយចេតនានោះទេ គាត់នឹងមានទោស ដោយផ្អែកតាមលក្ខខណ្ឌទី២ នៃមាត្រា ២៧ ចែងអំពីការប៉ុនប៉ង។

**ក.៤ ដំណាក់កាលបទល្មើសបានសម្រេច ឬមិនបានសម្រេច**

ក្នុងដំណាក់កាលនេះ មានពីរករណីដែលត្រូវយកមកធ្វើការសិក្សា ដែលករណីទាំងពីរនោះមានដូចជា ៖

**បទល្មើសបានសម្រេច** ៖ គឺជាបទល្មើសទាំងឡាយណាដែលផលវិបាក ឬលទ្ធផលចុងក្រោយបានបំពេញតាមគោលបំណង ឬគោលដៅដែលជនល្មើសចង់បាន។[28] នៅត្រង់នេះមានន័យថាជនល្មើសបានសម្រេចគោលដៅដែលខ្លួនចង់បានហើយ ពោលគឺបានសម្រេចបទល្មើស។

**ឧទាហរណ៍៖** លោក **ក** បន្ទាប់រងចាំសងសឹកលោក **ខ** ពេលនោះលោក **ខ** ដែលជាជនរងគ្រោះត្រូវបានលោក **ក** ចាក់សម្លាប់ បន្ទាប់មកលោក **ខ** ដែលជាជនរងគ្រោះបានស្លាប់។ បញ្ជាក់ករណីនេះ គឺជាបទល្មើសបាន

[27] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៨៨ ដល់មាត្រា ៤៩០ ។

[28] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់ឆ្នាំទី២។

សម្រេច ក៏ប៉ុន្តែផ្ទុយទៅវិញ បើលោក **ក** ចាក់លោក **ខ** ហើយតែលោក **ខ** មិនស្លាប់ បទល្មើសនេះគឺជាបទល្មើសមិនបានសម្រេច។

**បទល្មើសមិនបានសម្រេច ៖** ជាអំពើប្រព្រឹត្តឡើងដោយចេតនា ក៏ប៉ុន្តែអំពើនោះ មិនទាន់ប្រព្រឹត្តចប់នៅឡើយ ដោយសារមានមូលហេតុផ្សេងៗមកបង្អាក់សកម្មភាពនេះ ហើយក្រៅពីឆន្ទៈរបស់ជនល្មើស។ ត្រង់ការចំណុចនេះគឺមានន័យថា ជនល្មើសមានចេតនាប្រព្រឹត្តបទល្មើសហើយ ក៏ប៉ុន្តែមិនបានសម្រេចដូចបំណងដែលគេចង់បាន ដោយសារមានសកម្មភាពខាងក្រៅរារាំង ធ្វើឱ្យជនល្មើសមិនអាចបញ្ចប់បទល្មើសបានតាមដូចបំណងខ្លួន។ បទល្មើសមិនបានសម្រេច នាំឱ្យមានការចោទប្រកាន់ពីការប៉ុនប៉ង។ តើអ្វីទៅជាការប៉ុនប៉ង?

### ខ. ការប៉ុនប៉ង

ការប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស ប៉ុន្តែត្រូវបានរាំងស្ទះ ឬ អាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ចារី ត្រូវចាត់ទុកជាការប៉ុនប៉ង។[29] ប្រសិនបើការប្រព្រឹត្តបទល្មើសឈានដល់ដំណាក់កាលចុងក្រោយ បទល្មើសជាបទល្មើសសម្រេចផល (ច្បាប់អាចត្រូវផ្តន្ទាទោសបាន) ប៉ុន្តែប្រសិនបើការប្រព្រឹត្តត្រូវអាក់ខានទៅវិញនោះគឺជាការប៉ុនប៉ង។ ហេតុនេះសូមឈ្វេងយល់ពីចំណុចមួយចំនួនដែលទាក់ទងនឹងការប៉ុនប៉ងដូចជា លក្ខខណ្ឌនៃការប៉ុនប៉ង(**ខ.១**) និងទណ្ឌកម្មចំពោះការប៉ុនប៉ង (**ខ.២**)។

#### ខ.១ លក្ខខណ្ឌនៃការប៉ុនប៉ង

តាមរយៈមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់លក្ខខណ្ឌពីរយ៉ាងដើម្បីឱ្យការប៉ុនប៉ងមានទោសគឺ លក្ខខណ្ឌទាំងនោះមានដូចខាងក្រោមនេះ៖

**ការចាប់ផ្តើមអនុវត្តបទល្មើស៖** មានន័យថាចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស។[30] នៅក្នុងករណីនេះ ចារី ឬជនល្មើសបានចាប់ផ្តើមប្រព្រឹត្តបទល្មើសរបស់ខ្លួន ដោយប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីឱ្យបានសម្រេចបទល្មើសនោះ។ ដំណាក់កាលនេះ មិនទាន់អាចចាត់ទុកជាបទល្មើសប៉ុនប៉ងមានទោសនោះទេ ពោលគឺទាមទារឱ្យបំពេញលក្ខខណ្ឌទីពីរមួយទៀត។

**ការអាក់ខានទៅវិញដោយអឆន្ទៈ៖** មានន័យថាចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្តតែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយសារឥទ្ធិពលនៃកាលៈទេសៈខាងក្រៅឆន្ទៈរបស់ខ្លួន។[31]មានន័យថា ជនល្មើសមិនបានបញ្ឈប់អំពើល្មើសរបស់ខ្លួនដោយស្ម័គ្រចិត្ត ឬដោយចេតនាទេ គ្រាន់តែអំពើនោះត្រូវបានបញ្ឈប់ដោយកាលៈទេសៈផ្សេងតែប៉ុណ្ណោះ។ ក្នុងករណីនេះ ជនល្មើសត្រូវតែទទួលទោសព្រហ្មទណ្ឌ។ ផ្ទុយទៅវិញ

---

[29] ដកស្រង់ចេញពីគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកការអនុម័តពាក្យច្បាប់ (ឆ្នាំ២០១១)

[30] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៧ កថាខណ្ឌទី១។

[31] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៧ កថាខណ្ឌទី២។

ប្រសិនបើជនល្មើសសុខចិត្តបោះបង់ចោលអំពើល្មើសរបស់ខ្លួនដោយស្ម័គ្រចិត្ត ឬដោយចេតនានោះ ជននោះមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ការបញ្ឈប់ដោយចេតនា ឬដោយស្ម័គ្រចិត្តនេះ ត្រូវគោរពតាមលក្ខខណ្ឌពីរគឺ៖

**១. ការបញ្ឈប់ត្រូវធ្វើដោយចេតនា៖** ពោលគឺត្រូវកើតឡើងដោយឆន្ទៈរបស់ជនល្មើស មិនមែនកើតឡើងដោយការគាបសង្កត់ ឬបង្ខំពីមជ្ឈដ្ឋានខាងក្រៅទេ។ **ឧទាហរណ៍៖** ក្នុងកំឡុងពេលដែលជនល្មើសបានត្រៀមលក្ខណៈថានឹងប្រព្រឹត្ត និងមុនពេលប្រព្រឹត្តអំពើរបស់ខ្លួនទៅលើជនរងគ្រោះ ជនល្មើសបានគិតឡើងវិញថា ប្រសិនបើខ្លួនប្រព្រឹត្តអំពើដូចជាការសម្លាប់មនុស្ស វាជាអំពើអមនុស្សធម៌ ហើយខ្លួននឹងទទួលទោសចំពោះអំពើនេះទៀត។ ហេតុនេះហើយគាត់ក៏បានសម្រេចចិត្តថា នឹងបញ្ឈប់អំពើរបស់ខ្លួនទៅលើជនរងគ្រោះ នៅក្នុងស្ថានភាពបែបនេះ ច្បាប់កំណត់ថាមិនធ្វើការផ្តន្ទាទោសដល់ជននោះទេ។

**២. ការបញ្ឈប់នេះត្រូវកើតឡើងមុនបទល្មើសបានសម្រេចផល៖** គឺមានន័យថា ការបញ្ឈប់នេះត្រូវកើតឡើងមុនអំពើគ្រោះថ្នាក់ដល់សង្គមកើតមានឡើង។ បើមិនដូចនេះទេ ការបញ្ឈប់នេះពុំមែនជាការបញ្ឈប់ដោយចេតនា ឬដោយស្ម័គ្រចិត្តទេ គឺជាការស្តាយក្រោយដោយសកម្ម (ព្រោះថាបទល្មើសបានសម្រេចហើយ ព្យសនកម្មក៏មានដែរ) ។ ការស្តាយក្រោយនេះ គ្មានអានុភាពលុបលាងបទល្មើសបានឡើយ ប៉ុន្តែអាចត្រូវបានទទួលរងនូវស្ថានសម្រាលទោស (មាត្រា៩៣)។ **ឧទាហរណ៍៖** ការលួចម៉ូតូរបស់គេនៅពេលយប់ បន្ទាប់ពីបានរយៈពេលមួយថ្ងៃក្រោយមក ដោយមូលហេតុអាណិតទៅដល់ជនរងគ្រោះ ជនល្មើសក៏បានយកម៉ូតូនោះទៅសងគេវិញ។

ផ្ទុយទៅវិញ ប្រសិនបើការបញ្ឈប់របស់ជនល្មើសដោយស្ថានភាពក្រៅឆន្ទៈ ឬមានការអាក់ខានដោយសារតែមានកាលៈទេសៈពីខាងក្រៅបានទៅបង្អាក់មិនឱ្យប្រព្រឹត្តបទល្មើសកើត ជនល្មើសត្រូវទទួលការចោទប្រកាន់ពីបទប៉ុនប៉ង។[32] ការបញ្ឈប់របស់ជនល្មើសដោយស្ថានភាពក្រៅឆន្ទៈ កើតមានឡើងក្នុងរូបភាពដូចជា ៖

***ការអាក់ខានដោយមូលហេតុព្រឹត្តិការណ៍ខាងក្រៅ*** ៖ ការអាក់ខានទៅវិញដោយអឆន្ទៈ ឬដោយស្ថានភាពខាងក្រៅ នោះជនល្មើសត្រូវទទួលការចោទប្រកាន់ពីបទប៉ុនប៉ង។ **ឧទាហរណ៍៖** ការខិតខំតបតរបស់ជនរងគ្រោះ សមត្ថកិច្ច ឬតតិយជនបានមកជួយទាន់ ឬសហការណ៍ជាមួយអ្នកសមគំនិតមិនបានល្អ។

***បរាជ័យនៃបទល្មើស*** ៖ គឺភាពឆ្គាំឆ្គងនៃជនល្មើស ឬភាពមិនប៉ិនប្រសប់របស់ជនល្មើស។ **ឧទាហរណ៍៖** ជនល្មើសបានយកកាំបិតទៅកាប់ជនរងគ្រោះតែទៅត្រូវម៉ូតូជនរងគ្រោះវិញ ឬ យកកាំភ្លើងទៅបាញ់តែមិនត្រូវ។

***បទល្មើសដែលពុំអាចកើតបាន*** ៖ គឺមានន័យថាអវត្តមាននៃកម្មវត្ថុបទល្មើស ឬក៏ឧបករណ៍ប្រើប្រាស់ពុំមានប្រសិទ្ធិភាព នៅពេលដែលជនល្មើសបានប្រព្រឹត្តបទល្មើស។ **ឧទាហរណ៍៖** ជនល្មើសបានលួចប្រាក់ក្នុងហោប៉ៅដែលគ្មានប្រាក់ ឬជនល្មើសបានបាញ់សម្លាប់មនុស្សដោយកាំភ្លើងគ្មានគ្រាប់។

---

[32] ណែនាំដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង**, ដកស្រង់ចេញពីសារណាបញ្ចប់ការសិក្សាប្រធានបទ បទល្មើសព្រហ្មទណ្ឌ ឆ្នាំ២០២២។

នៅក្នុងករណីនៃការប៉ុនប៉ងប្រព្រឹត្តបទល្មើស ទោះបីជាលទ្ធផលពុំទាន់ទទួលតាមបំណងរបស់ជនល្មើស ឬមានព្យសនកម្មក៏ដោយ ក៏ច្បាប់នៅតែតម្រូវឱ្យដាក់ទណ្ឌកម្មដែរ ដោយយោងទៅលើភាពគ្រោះថ្នាក់នៃអំពើនោះចំពោះសង្គមជាតិ។ ការដាក់ទណ្ឌកម្មនេះ គឺដើម្បីបញ្ចៀសនូវអំពើដែលអាចបង្កគ្រោះថ្នាក់ដល់សង្គមជាតិ កាលបើជនល្មើសប្រព្រឹត្តបានដូចបំណង។ តើការប៉ុនប៉ងត្រូវទទួលទណ្ឌកម្មបែបណា?

**ខ.២ ទណ្ឌកម្មចំពោះការប៉ុនប៉ង**

ដោយយោងតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា ២៥ និងមាត្រា ២៧ ការផ្តន្ទាទោសលើការប៉ុនប៉ងមិនខុសគ្នាពីការផ្តន្ទាទោសលើបទល្មើសបានសម្រេចឡើយ កាលបើលក្ខខណ្ឌនៃការប៉ុនប៉ងមានទោសត្រូវបានបំពេញគ្រប់គ្រាន់។ គ្រប់ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ត្រូវតែទទួលរងនូវការផ្តន្ទាទោសដូចគ្នាទៅនឹងបទឧក្រិដ្ឋដែរ។

ប៉ុន្តែចំពោះបទមជ្ឈិមវិញ ដើម្បីអាចផ្តន្ទាទោសលើករណីប៉ុនប៉ងក្នុងបទមជ្ឈិមបាន លុះត្រាតែមានច្បាប់ចែងចង្អុលច្បាស់លាស់ថា ការប៉ុនប៉ងនោះគឺត្រូវផ្តន្ទាទោស។ ត្រង់ចំណុចនេះមានន័យថា ដើម្បីផ្តន្ទាទោសករណីប៉ុនប៉ងក្នុងបទមជ្ឈិមបាន លុះត្រាតែមានច្បាប់កំណត់ទុកជាមុន ឬមានច្បាប់ចង្អុលទុកជាមុនថា ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមត្រូវផ្តន្ទាទោស។ **ឧទាហរណ៍៖** ក្នុងបទល្មើសលួច គឺជាប្រភេទនៃបទល្មើសមជ្ឈិម ដូច្នេះដើម្បីឱ្យការប៉ុនប៉ងក្នុងបទលួចត្រូវផ្តន្ទាទោសបាន លុះត្រាតែច្បាប់បានចែងយ៉ាងជាក់ច្បាស់ ដូចមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌបានបញ្ជាក់ថា ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ។ សូមបញ្ជាក់ថា ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ (មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩)។ ចំពោះការដាក់ទោសទៅលើការប៉ុនប៉ង ដោយមូលហេតុអំពើប៉ុនប៉ងនៅពុំទាន់បានបង្កព្យសនកម្មនៅឡើយ ជាទូទៅ ចៅក្រមមិនដាក់ទោសឱ្យធ្ងន់ធ្ងរដូចបទល្មើសបានសម្រេចឡើយ បើទោះបីជាច្បាប់តម្រូវឱ្យផ្តន្ទាទោសដូចគ្នាក៏ដោយ។[33]

## ៣. ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ

ក្នុងការកំណត់បទល្មើស ទោះបីជាមានធាតុនីត្យានុកូល និងធាតុសត្យានុម័ត ក៏ពុំទាន់មានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្កើតជាបទល្មើសដែរ ព្រោះថាលុះត្រាតែមានធាតុមួយទៀតទើបអាចកំណត់ជាបទល្មើសបាន ដែលធាតុនោះគឺ ធាតុអត្តនោម័ត **(៣.១)**។ ក្នុងការកំណត់បទល្មើស តែងតែផ្អែកទៅលើកំហុសរបស់ចារី ដូច្នេះដើម្បីបង្កើតបានជាបទល្មើស ចារីត្រូវតែប្រព្រឹត្តអំពើដោយមានកំហុស គេហៅថា កំហុសព្រហ្មទណ្ឌ **(៣.២)**។

[33] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

### ៣.១ អត្ថន័យនៃធាតុអត្តនោម័ត

ធាតុអត្តនោម័ត គឺជាចិត្តគំនិតខាងក្នុងរបស់ជនល្មើស ដែលស្តែងមកខាងក្រៅតាមរយៈ ធាតុសត្យានុម័ត ឬធាតុសម្ភារៈ ដូចជាកាយវិការ ឬអំពើប្រព្រឹត្តរបស់ជនល្មើស។ គេអាចនិយាយម្យ៉ាងទៀតបានថា ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រនេះ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និតជាមួយនឹងធាតុសត្យានុម័ត ឬធាតុសម្ភារៈ។[34]

### ៣.២ កំហុសព្រហ្មទណ្ឌ

កំហុស គឺជាអំពើ ឬសកម្មភាពរបស់មនុស្ស ហើយអំពើ ឬសកម្មភាពនោះ ធ្វើឱ្យមានគ្រោះថ្នាក់ដល់សង្គម ឬមានផលវិបាកកើតឡើង។ កំហុសដែលមានគោលដៅច្បាស់លាស់ ឬមានឆន្ទៈច្បាស់លាស់ គេហៅថា កំហុសដោយចេតនា (ក) រីឯកំហុសដែលគ្មានគោលបំណង ឬគ្មានឆន្ទៈ គេហៅថា កំហុសដោយអចេតនា(ខ)។

#### ក. កំហុសដោយចេតនា

កំហុសដោយចេតនា គឺកំហុសដែលកើតឡើងដោយបុគ្គលម្នាក់ ហើយបុគ្គលម្នាក់នោះអាចវាយតម្លៃនូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់បាន បើទោះបីជាបុគ្គលនោះដឹងថាអំពើរបស់ខ្លួនខុសច្បាប់ក៏នៅតែចង់ប្រព្រឹត្ត ឬចង់សម្រេចអំពើនោះ។ **ឧទាហរណ៍** លោក **គ** បានសម្លាប់លោក **ក** ក្នុងពេលសម្លាប់នោះគាត់បានដឹងថាអំពើរបស់គាត់នោះនឹងត្រូវទទួលទោស ប៉ុន្តែគាត់នៅតែប្រព្រឹត្ត ដើម្បីសម្រេចបទល្មើសដដែល។ ដូច្នេះ ខាងក្រោមនេះគឺជាប្រភេទនៃចេតនាប្រព្រឹត្តបទល្មើស ឬចេតនាទុច្ចរិត ដែលមានដូចជា៖

#### ក.១ ចេតនាទុច្ចរិតទូទៅ

ចេតនាទុច្ចរិតទូទៅ គឺជាចេតនារបស់ចារីក្នុងការប្រព្រឹត្តអំពើដែលខ្លួនបានដឹងថាច្បាប់ព្រហ្មទណ្ឌបានហាមឃាត់។ ចេតនានេះ សំដៅលើចេតនាបំពានច្បាប់ព្រហ្មទណ្ឌ ឬបំពានលើការហាមឃាត់ផ្នែកព្រហ្មទណ្ឌ។[35] **ឧទាហរណ៍៖** ចារី ចង់ ប្រព្រឹត្តអំពើដែលខ្លួន ដឹងថាខុសច្បាប់ព្រហ្មទណ្ឌ។

#### ក.២ ចេតនាទុច្ចរិតពិសេស

នៅក្នុងករណីចេតនាទុច្ចរិតពិសេស ជនល្មើសមានចេតនាចង់ឱ្យបទល្មើសដែលខ្លួនប្រព្រឹត្ត (ចេតនាទុច្ចរិតទូទៅ) នោះ ផ្តល់ផលពិសេស(ចេតនាទុច្ចរិតពិសេស)។ ចេតនាទុច្ចរិតពិសេសនេះ អាចកើតចេញមកពីអំពើមួយទៀត ដែលជនល្មើសបានគ្រោងទុកជាមុន។ **ឧទាហរណ៍៖** ការផ្សាយពត៌មានមិនពិត ឬពត៌មានក្លែងក្លាយក្នុងគោលបំណងបំផ្លិចបំផ្លាញកិត្តិយសជនរងគ្រោះ។[36]

---

[34] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់ឆ្នាំទី២។

[35] សាស្ត្រាចារ្យ **នុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[36] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់ឆ្នាំទី២។

**ក.៣ ចេតនាទុច្ចរិតធ្ងន់ធ្ងរ ឬចេតនាដោយការគ្រោងទុក**

ចេតនាទុច្ចរិតធ្ងន់ធ្ងរ សំដៅលើចេតនារបស់ចារីប្រព្រឹត្តបទល្មើស ដោយមានចេតនាបង្កនូវគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់សង្គមជាតិ។ ឧទាហរណ៍៖ ការគិតទុកជាមុនបានស្តែងមកក្រៅ ឱ្យឃើញចេតនាទុច្ចរិតធ្ងន់ធ្ងរមួយកើតឡើង។ ដោយយោងតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានឱ្យនិយមន័យថា ការគិតទុកជាមុនគឺជា គម្រោងដែលបង្កើតឡើង មុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។ ការសម្លាប់មនុស្សដោយគិតទុកជាមុន ត្រូវទទួលទោសធ្ងន់ជាងការសម្លាប់មនុស្សដោយចេតនា ដែលជាបទឃាតកម្ម ពោលឃាតកម្មធ្វើឡើងដោយការគិតទុកជាមុនត្រូវដាក់ពន្ធនាគារអស់មួយជីវិត។ ក្នុងការសម្លាប់មនុស្សដោយចេតនា ចេតនាទុច្ចរិតរបស់ចារីកើតឡើងភ្លាមៗ[37] ដែលពុំមានការត្រៀមទុកជាមុនឡើយ។

**ក.៤ ចេតនាទុច្ចរិតច្បាស់លាស់ និងមិនច្បាស់លាស់**

**ចេតនាទុច្ចរិតច្បាស់លាស់** គឺជាចេតនារបស់ចារីប្រព្រឹត្តបទល្មើស ដែលគោលបំណងរបស់ចារីប្រព្រឹត្តនោះ មានលក្ខណៈដូចគ្នាទៅនឹងលទ្ធផលនៃអំពើ ឬចារីកំណត់បានច្បាស់លាស់អំពីកម្រិត ឬទំហំនៃការអន្តរាយដែលកើតឡើងដោយសារការប្រព្រឹត្តបទល្មើសរបស់ខ្លួន។ **ឧទាហរណ៍៖** នៅពេលដែលចារីចង់សម្លាប់លោក ក ចារីបានធ្វើឱ្យលោក ក ទទួលមរណភាពដោយស្នាដៃរបស់ខ្លួនផ្ទាល់។

**ចេតនាទុច្ចរិតមិនច្បាស់លាស់** គឺចារីអាចវាយតម្លៃបានជាមុននូវព្យសនកម្មដែលនឹងកើតឡើង ប៉ុន្តែចារីពុំបានដឹងច្បាស់ថាកម្រិត ឬទំហំ នៃគ្រោះថ្នាក់ដែលបង្កឡើងពីបទល្មើសនោះ មានលក្ខណៈបែបណាទេ។ **ឧទាហរណ៍៖** ចារីបានយកដុំថ្មគប់ទៅលើជនរងគ្រោះ ប៉ុន្តែគាត់មិនដឹងថាតើការគប់នោះ បានបង្កព្យសកម្មទៅលើជនរងគ្រោះបែបណានោះទេ។ ឧបមាថា ចេតនារបស់ចារីគ្រាន់តែចង់ឱ្យជនរងគ្រោះទទួលរងនូវរបួសស្នាមបន្តិចបន្តួចតែប៉ុណ្ណោះ ក៏ប៉ុន្តែជនរងគ្រោះបែរជាស្លាប់បាត់បង់ជីវិតទៅវិញ។ ក្នុងករណីនេះ ចារីត្រូវតែទទួលនូវការផ្តន្ទាទោសតាមច្បាប់កំណត់។[38]

**ក.៥ ចេតនាទុច្ចរិតចំពោះ និងមិនចំពោះ**

**ចេតនាទុច្ចរិតចំពោះ** គឺជាកំហុសរបស់បុគ្គលម្នាក់ ដោយសារក្នុងពេលប្រព្រឹត្តអំពើដែលបង្កគ្រោះថ្នាក់ដល់សង្គម ជននោះបានដឹងយ៉ាងច្បាស់ថាអំពើរបស់ខ្លួនមានចរិតគ្រោះថ្នាក់ ហើយមើលឃើញច្បាស់ពិតប្រាកដនូវបច្ច័យ គ្រោះថ្នាក់នៃអំពើរបស់ខ្លួន ហើយចារីនៅតែចង់ឱ្យបច្ច័យនោះកើតឡើងទៀត។ **ឧទាហរណ៍៖** ចារីបានវាយរថយន្តរបស់ជនរងគ្រោះឱ្យខូចខាត ដោយសារតែចារីមានទំនាស់ពាក្យសម្តីជាមួយនឹងម្ចាស់រថយន្តក្នុងករណីនេះ ចារីមានចេតនាទុច្ចរិតចំពោះ។

---

[37] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[38] ណែនាំដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង**, ដកស្រង់ចេញពីសារណាបញ្ចប់ការសិក្សាប្រធានបទ បទល្មើសព្រហ្មទណ្ឌ ឆ្នាំ២០២២។

**ចេតនាទុច្ចរិតមិនចំពោះ** គឺជាកំហុសរបស់ជនម្នាក់ ដែលពេលប្រព្រឹត្តបទល្មើស ជននោះបានយល់ដឹងពីចរិតគ្រោះថ្នាក់ដល់សង្គមនៃអំពើរបស់ខ្លួនដែរ តែខ្លួនពុំបានប៉ងប្រាថ្នាឱ្យបច្ច័យនោះកើតឡើងនោះទ ប៉ុន្តែអំពើនោះបានធ្វើឱ្យបច្ច័យណាមួយកើតឡើងទៅវិញ។[39] **ឧទាហរណ៍** បុរស ក បានកាន់ជំពាមមួយដើម ដើម្បីយកទៅបាញ់ចាប ក្នុងពេលដែលបាញ់នោះ ជំពាមក៏បានភ្លាត់បែរជាបាញ់ចំជនរងគ្រោះបែកក្បាល។ អំពើរបស់ចារីខាងលើបានដឹងថាការបាញ់របស់ខ្លួនអាចនឹងមានចរិតគ្រោះថ្នាក់ ឬបង្កព្យសនកម្មដល់អ្នកដទៃបាន ប៉ុន្តែគោលបំណងរបស់ចារីគឺចង់បាញ់ចាបតែប៉ុណ្ណោះ។[40] ករណីនេះ ចារីត្រូវតែទទួលនូវការផ្តន្ទាទោសតាមច្បាប់កំណត់។

**ខ. កំហុសដោយអចេតនា**

កំហុសអចេតនា គឺមានន័យថាជាការបំពានលើករណីយកិច្ចប្រុងប្រយ័ត្នដែលច្បាប់បានកំណត់ ការបំពាននេះក៏ត្រូវទទួលការផ្តន្ទាទោសផងដែរ។ សម្រាប់បទល្មើសអចេតនា ធាតុផ្សំអត្តនោម័តសំដៅទៅលើកំហុសអចេតនាដែលពុំមែនជាចេតនាប្រព្រឹត្តបទល្មើសទេ តែចារីបានប្រព្រឹត្តខុសនឹងវិធានណាមួយដែលគ្រប់គ្រាន់បង្កើតបានជាបទល្មើស ។[41] មាត្រា ៤ នៃក្រមព្រហ្មទណ្ឌចែងថា ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។ កំហុសអចេតនារួមមានដូចតទៅ៖

**ខ.១ ការមិនប្រុងប្រយ័ត្ន៖** សំដៅទៅលើអំពើទាំងឡាយណាដែលខ្វះការប្រយ័ត្ន ឬមិនបានប្រុងប្រៀបស្មារតីទុកជាមុន។ **ឧទាហរណ៍** ការបើកបរដោយមិនយកចិត្តទុកដាក់ រវល់តែងាកឆ្វេងស្តាំ។

**ខ.២ ការខ្ជីខ្ជា៖** សំដៅទៅលើអំពើទាំងឡាយណាដែលធ្វើឱ្យតែរួចពីដៃ ឬធ្វើមិនហ្មត់ចត់។ **ឧទាហរណ៍** ការដាក់ចូផ្កានៅលើដំបូល ដោយមិនបានចងឱ្យជាប់ល្អ ធ្វើឱ្យធ្លាក់មកក្រោមបណ្តាលឱ្យអ្នកដទៃស្លាប់។

**ខ.៣ ការធ្វេសប្រហែស៖**គឺជាការភ្លេចភ្លាំង ឬការមាក់ងាយការងារដែលបង្ក ឬធ្វើឱ្យគ្រោះថ្នាក់កើតឡើង។

**ខ.៤ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ៖** សំដៅទៅលើការមិនគោរពតាមកាតព្វកិច្ចដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តតម្រូវឱ្យមាន ដូចជាការមិនគោរពភ្លើងសញ្ញាចរាចរណ៍នៅតាមដងផ្លូវសាធារណៈ។

សរុបជារួមមក ប្រភេទនៃចេតនាប្រព្រឹត្តបទល្មើស ឬចេតនាទុច្ចរិតដែលបានលើកឡើងខាងលើនេះ គឺសុទ្ធតែជាកំហុសដោយចេតនា ដែលត្រូវមានការទទួលខុសត្រូវព្រហ្មទណ្ឌ។

---

[39] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[40] ណែនាំដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង**, ដកស្រង់ចេញពីសារណាបញ្ចប់ការសិក្សាប្រធានបទ បទល្មើសព្រហ្មទណ្ឌ ឆ្នាំ២០២២។

[41] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

### ៣.៣ ការវាយតម្លៃអំពីកំហុសចេតនា និងអចេតនា

កំហុសចេតនា និងអចេតនាដែលជាធាតុផ្សំអត្តនោម័តនៃបទល្មើសនឹងត្រូវវាយតម្លៃ ដោយផ្អែកតាមធាតុផ្សំសត្យានុម័តដែលបានកើតឡើងជាក់ស្តែង មានន័យថាតាមរយៈសកម្មភាពប្រព្រឹត្តរបស់ចារី អាចទាញសេចក្តីសន្និដ្ឋានពីអត្ថិភាពនៃធាតុផ្សំអត្តនោម័តរបស់ចារីបាន។[42] ដើម្បីអាចវាយតម្លៃថា អំពើណាមួយជាអំពើប្រព្រឹត្តដោយចេតនា ឬអចេតនានោះ យើងអាចកំណត់អំពើទាំងនោះតាមរយៈប្រភេទនៃបទល្មើសនីមួយៗ។

**បទឧក្រិដ្ឋ៖** ចំពោះបទឧក្រិដ្ឋ ជាបទល្មើសដែលប្រព្រឹត្តដោយចេតនា។ ក្នុងករណីដែលចារីបានប្រព្រឹត្តបទល្មើសដែលជាបទឧក្រិដ្ឋនោះ គេចាត់ទុកថាចារីមានចេតនាពិតប្រាកដ ក្នុងការបង្កនូវព្យសនកម្មដល់សង្គម និងបានដឹងយ៉ាងច្បាស់ថាអំពើរបស់ខ្លួនជាបទល្មើសដែលច្បាប់ហាមឃាត់។**ឧទាហរណ៍៖** បុរស ក បានចាប់រំលោភនារី ខ នៅកន្លែងស្ងាត់មួយបានសម្រេច។ អំពើដែលជាបទរំលោភសេពសន្ថវៈខាងលើនេះ ច្បាប់ចាត់ទុកថា ជាបទល្មើសឧក្រិដ្ឋ ព្រោះចារីមានចេតនាយ៉ាងពេញលេញ ក្នុងការប្រព្រឹត្តអំពើរបស់ខ្លួនទៅលើជនរងគ្រោះដើម្បីសម្រេចបំណងរបស់ចារីនោះគឺ ការរួមភេទ។

**បទលហុ៖** ចំពោះបទលហុ គឺផ្ទុយទៅនឹងបទឧក្រិដ្ឋ មានន័យថា បទលហុជាបទល្មើសដែលប្រព្រឹត្តដោយអចេតនា។ លើកលែងតែច្បាប់ចែងថាជាអំពើប្រព្រឹត្តដោយចេតនាដូចជា បទបរិហារកេរ្តិ៍ជាសាធារណៈ គឺជាបទលហុដែលច្បាប់បានចែងផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់តែប៉ុណ្ណោះ។ គ្រប់អំពើអះអាងបំផ្លើស ឬទម្លាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គល ឬនៃស្ថាប័ន គឺគេចាត់ទុកថាជាអំពើប្រព្រឹត្តដោយចេតនាយ៉ាងពិតប្រាកដ ព្រោះថាចារីមានបំណងចង់ឱ្យលទ្ធផលនៃអំពើរបស់ខ្លួនកើតឡើងដោយធ្វើឱ្យខូចឈ្មោះ ឬកិត្តិយសរបស់ជនរងគ្រោះ។

**បទមជ្ឈិម៖**ចំពោះបទមជ្ឈិមវិញ ជាបទល្មើសប្រព្រឹត្តដោយចេតនា លើកលែងតែច្បាប់ចែងច្បាស់លាស់ផ្ទុយពីនេះ។ គឺថា ករណីដែលបទល្មើសជាបទមជ្ឈិមច្បាប់ក៏បានកំណត់ថាជាអំពើប្រព្រឹត្តដោយចេតនារបស់ជនល្មើសដូចទៅនឹងបទឧក្រិដ្ឋដែរ ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងយ៉ាងច្បាស់លាស់ថាអំពើនោះជាអំពើប្រព្រឹត្តដោយអចេតនា ជនល្មើសដែលប្រព្រឹត្តអំពើដោយអចេតនា ត្រូវទទួលទោសតាមបញ្ញត្តច្បាប់ដែលបានកំណត់ចំពោះបទល្មើសដែលប្រព្រឹត្តដោយអចេតនានោះ។ **ឧទាហរណ៍៖** អំពើហិង្សាដែលប្រព្រឹត្តដោយចេតនាលើអ្នកដទៃ ត្រូវផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។ ផ្ទុយទៅវិញ បើសិនជាអំពើរបស់ចារីប្រព្រឹត្តដោយអចេតនា ច្បាប់បានកំណត់ថាជាបទល្មើសបង្ករបួសស្នាមដោយអចេតនា និងត្រូវផ្តន្ទាទោសតាមមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌប៉ុណ្ណោះ។[43]

[42] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[43] ណែនាំដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង**, ដកស្រង់ចេញពីសារណាបញ្ចប់ការសិក្សាប្រធានបទ បទល្មើសព្រហ្មទណ្ឌ ឆ្នាំ២០២២។

## ផ្នែកទី៣ ៖ ចំណាត់ថ្នាក់បទល្មើស

សម្រាប់ក្នុងជីវិតរស់នៅប្រចាំថ្ងៃក្នុងសង្គមមនុស្ស ជាបរិបទទូទៅគេតែងសង្កេតឃើញមានបទល្មើសជាច្រើនផ្សេងៗគ្នា។ ហើយជាក់ស្តែង ច្បាប់ដែលកំណត់ពីបទល្មើសនីមួយៗក៏មានច្រើនផងដែរ ។ ដោយហេតុនេះ ដើម្បីជាប្រទីបក្នុងការស្គាល់ឱ្យបានច្បាស់លាស់អំពីប្រភេទនៃបទល្មើសនីមួយៗទាំងអស់នោះ ចាំបាច់ណាស់ ដែលយើងត្រូវតែធ្វើចំណាត់ថ្នាក់នៃបទល្មើសទាំងអស់ ក្នុងគោលដៅសម្រួលដល់ការកំណត់ ហើយដើម្បីបានស្គាល់នូវរបបគតិយុត្ត ដើម្បីអនុវត្តចំពោះបទល្មើសណាមួយ។ ជាការពិតក្រមព្រហ្មទណ្ឌត្រង់មាត្រា ២ បានផ្តល់នូវចំណាត់ថ្នាក់រវាងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។[44]

ដោយជាក់ស្តែង ការធ្វើចំណាត់ថ្នាក់នៃបទល្មើសដែលសំខាន់ជាងគេបំផុត គឺការបែងចែករវាង បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ឬចំណាត់ថ្នាក់តាមក្រមព្រហ្មទណ្ឌ (១) ។ ជាក់ស្តែងមិនមែនមានតែការបែងចែកប្រភេទបទល្មើសមួយប្រភេទនោះទេ ក៏ប៉ុន្តែអ្វីដែលត្រូវលើកយកមកធ្វើការសិក្សា គឺមានរបៀបធ្វើចំណាត់ថ្នាក់បទល្មើសជាច្រើនផ្សេងទៀត ដែលចំណាត់ថ្នាក់នីមួយៗកំណត់នូវរបបគតិយុត្តដោយឡែកៗ សម្រាប់បទល្មើសក្នុងចំណាត់ថ្នាក់នោះផងដែរ។ ដូចជាការបែងចែករវាងបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ជាមួយនឹងបណ្តាបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងច្បាប់ពិសេសដោយឡែក។ ចំណាត់ថ្នាក់បែបនេះ គេហៅថា ចំណាត់ថ្នាក់ដោយផ្អែកលើបទល្មើសសាមញ្ញ និងបទល្មើសពិសេស (២) ។ លើសពីនេះទៀត បទល្មើសក៏ត្រូវបែងចែកដោយផ្អែកលើបែបបទប្រព្រឹត្តបទល្មើស(៣) ពោលគឺសំដៅដល់ការធ្វើចំណាត់ថ្នាក់ដោយអនុលោមទៅលើរបៀបរបបដែលជនល្មើសប្រព្រឹត្តបទល្មើសជាលក្ខណៈសត្យានុម័ត មានដូចជា ការបែងចែករវាង បទល្មើសសកម្ម និងបទល្មើសអកម្ម ឬក៏ការធ្វើចំណាត់ថ្នាក់ដោយផ្អែកទៅលើបែបបទនៃការប្រព្រឹត្តបទល្មើសជាលក្ខណៈអត្តនោម័ត ដែលមានដូចជាការបែង ចែករវាងបទល្មើសចេតនា និងបទល្មើសអចេតនា។[45]

### ១. ចំណាត់ថ្នាក់តាមក្រមព្រហ្មទណ្ឌ

ដោយអនុលោមតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ បទល្មើសត្រូវបានបែងចែក ស្របទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើសនីមួយៗ ។ ក្នុងន័យនេះ មាត្រា ២ វាក្យខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌចែងថា បទល្មើសត្រូវចាត់ ថ្នាក់ជាបទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ ទៅតាមទម្ងន់នៃបទល្មើស ។ ដោយមើលឃើញថាការបែងចែកបទល្មើសជាបីប្រភេទ អាស្រ័យទៅតាមទម្ងន់នៃបទល្មើសនេះ មានសារៈសំខាន់ណាស់នៅក្នុងនីតិព្រហ្មទណ្ឌ ពីព្រោះថា ការបែងចែកនេះបាននាំមកនូវផលប្រយោជន៍ទាក់ទងនឹងរបបគតិយុត្ត ដែលច្បាប់មែងផ្សារភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃបទល្មើសយ៉ាងជាក់ច្បាស់។

---

[44] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ០២។

[45] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង សាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០២២។

## ១.១ លក្ខណៈវិនិច្ឆ័យនៃការបែងចែក

បទល្មើសត្រូវបានចែងយ៉ាងច្បាស់លាស់ក្នុងក្រមព្រហ្មទណ្ឌដែលបាននឹងកំពុងអនុវត្ត និងមានអានុភាពបច្ចុប្បន្ននេះ។ ក្រមព្រហ្មទណ្ឌបានបញ្ញត្ត អំពីលក្ខណៈវិនិច្ឆ័យនៃការកំណត់ប្រភេទនៃបទល្មើសទៅតាមទម្ងន់នៃបទល្មើស មានន័យថា ទៅតាមព្យសនកម្មរបស់ជនល្មើសដែលបានប្រព្រឹត្ត។ លើសពីនេះ ក្រមព្រហ្មទណ្ឌបានកំណត់យកអតិបរមានៃទោសដែលច្បាប់តម្រូវឱ្យផ្តន្ទាទោស ដើម្បីធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យក្នុងបទល្មើសផងដែរ។ ដោយយោងតាមអត្ថន័យនៃ មាត្រា ៤៦ និងមាត្រា ៤៧ ព្រមទាំង មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌដែលបានកំណត់ពីចំណាត់ថ្នាក់បទល្មើស បានចង្អុលបង្ហាញឱ្យ ឃើញដូចខាងក្រោមនេះ៖

### ក. បទឧក្រិដ្ឋ

បទឧក្រិដ្ឋ គឺជាបទល្មើសទាំងឡាយណាដែលជនល្មើសបានប្រព្រឹត្តនឹងបង្កព្យសនកម្មដ៏គ្រោះថ្នាក់ដល់សង្គមយ៉ាងធ្ងន់ធ្ងរ ហើយទោសដែលត្រូវទទួលក៏មានលក្ខណៈជាស្ថានទម្ងន់ផងដែរ។ យោងតាមមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌខ្មែរឆ្នាំ ២០០៩ ក្នុងបទឧក្រិដ្ឋត្រូវបានកំណត់ជាពីរគឺ៖

- ទោសដាក់ពន្ធនាគារអស់មួយជីវិត និង
- ទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ឆ្នាំ។ បញ្ជាក់៖ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។ **ឧទាហរណ៍៖**

- **បទឃាតកម្មគិតទុកជាមុន** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត (មាត្រា២០០ នៃក្រមព្រហ្មទណ្ឌ)។
- **បទរំលោភសេពសន្ថវៈ** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ (មាត្រា ២៣៩)។
- **បទឧបឃាត** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ទៅ ៣០ឆ្នាំ (មាត្រា ៤៥១ នៃក្រមព្រហ្មទណ្ឌ)។

### ខ.បទមជ្ឈិម

បទមជ្ឈិម គឺជាបទល្មើសទាំងឡាយណាដែលពុំសូវបង្កព្យសនកម្មខ្លាំងខ្លាពេកទេ វាស្ថិតនៅចន្លោះបទឧក្រិដ្ឋ និងបទលហុ ហើយកម្រិតគ្រោះថ្នាក់ដល់សង្គមនោះមិនធ្ងន់ធ្ងរពេក ក៏មិនស្រាលដែរ ចំណែកទោសដែលត្រូវទទួលក៏មានកម្រិតមធ្យម និងមិនស្រាលពេកដែរ ។ ក្នុងមាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ បទមជ្ឈិមត្រូវបានកំណត់អតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៦ថ្ងៃ និងក្រោម ឬស្មើនឹង ៥ឆ្នាំ ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ **ឧទាហរណ៍** ដូចបទល្មើសមួយចំនួននៅខាងក្រោមនេះ៖

- **អំពើលួច** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ ដូច្នេះអតិបរមានៃទោសដាក់ពន្ធនាគារដែលកំណត់ ៣ឆ្នាំ គឺក្រោម ៥ឆ្នាំ ដូច្នេះជាបទមជ្ឈិម (មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ)។
- **បទគំរាមកំហែងហែកកេរ្តិ៍** ត្រូវតែផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល (មាត្រា ៣៧២ និងមាត្រា ៣៧៣ នៃក្រមព្រហ្មទណ្ឌ)។

- **បទកំហែងយក** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល (មាត្រា ៣៦៣ និង មាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ)។
- **បទឆបោក** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និង ពិន័យជាប្រាក់ពី ១លានរៀល ទៅ ៤លានរៀល (មាត្រា ៣៧៧ និង មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ)។

**គ.បទលហុ**

បទលហុ គឺជាបទល្មើសដែលជនល្មើសបានប្រព្រឹត្តអំពើដែលនាំឱ្យប៉ះពាល់ដល់ សិទ្ធិសេរីភាពបុគ្គល ឬសណ្តាប់ធ្នាប់សាធារណៈយ៉ាងតិចតួច ហើយទណ្ឌកម្មដែលត្រូវផ្តន្ទាទោសទៅលើជនល្មើស ក៏មិនមានស្ថានទម្ងន់ផងដែរ។

មាត្រា ៤៨ ជាបទលហុ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើនឹង ៦ថ្ងៃ ដោយទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ មួយវិញទៀត គឺជាបទលហុដែរ កាលបើបទល្មើសនោះត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់(ប៉ុន្មានក៏នៅតែជាលហុ)។

**ឧទាហរណ៍**

- **បទបរិហារកេរ្តិ៍ជាសាធារណៈ** ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១សែនរៀល ទៅ ១០លានរៀល (មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ) ។
- **បទជេរប្រមាថជាសាធារណៈ** ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១សែនរៀល ទៅ ១០លានរៀល (មាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ)។
- **បទធ្វើឱ្យខូចខាតស្រាល** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ថ្ងៃ ទៅ ៦ថ្ងៃ និងត្រូវពិន័យជាប្រាក់ពី ១ពាន់រៀល ទៅ ១សែនរៀល (មាត្រា ៤១៨ នៃក្រមព្រហ្មទណ្ឌ)។
- **បទប្រមាថចំពោះព្រះសង្ឃ ដូនជី និងតាជី** ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ១ថ្ងៃ ទៅ ៦ថ្ងៃ និងពិន័យជាប្រាក់ពី ១ពាន់រៀល ទៅ ១សែនរៀល (មាត្រា ៥១៦ នៃក្រមព្រហ្មទណ្ឌ)។
- **បទស្រវឹងជាក់ស្តែង** ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ប្រាំពាន់រៀល ទៅ ១ម៉ឺនរៀល គឺពិន័យត្រឹមតែជាប្រាក់ប៉ុណ្ណោះ (មាត្រា ២៩៧ នៃក្រមព្រហ្មទណ្ឌ) ។

ផ្អែកតាមច្បាប់បទប្បញ្ញត្តិនៃមាត្រាខាងលើនេះ វាបានជួយសម្រួលព្រមបង្កឱ្យមានភាពងាយស្រួល ក្នុងគោលដៅដើម្បីធ្វើការកំណត់ថាបទល្មើសណាមួយ គឺជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។

កំណត់សម្គាល់៖ ការមើលអំពីចំណាត់ថ្នាក់នៃបទល្មើស គឺត្រូវមើលទៅលើអតិបរមានៃទោសដាក់ពន្ធនាគារ ដែលចែងនៅក្នុងច្បាប់ ឬមានចែងនៅក្នុងមាត្រានីមួយៗនៃច្បាប់ជាក់ស្តែងដែលយើងឃើញតែប៉ុណ្ណោះ ផ្ទុយទៅវិញ មិនត្រូវមើលទៅលើអប្បបរមានៃទោសដាក់ពន្ធនាគារឡើយ។

ចំពោះការធ្វើបំណែងចែកនៃបទល្មើសស្របទៅតាមទម្ងន់នៃបទល្មើស បានផ្តល់នូវផលប្រយោជន៍ជាច្រើនពាក់ព័ន្ធនឹងវិធានច្បាប់ដែលត្រូវយកមកអនុវត្ត ទៅលើបទល្មើសនីមួយៗ អាស្រ័យទៅតាមប្រភេទនៃបទល្មើសនោះ។ តើមានផលប្រយោជន៍អ្វីខ្លះ ដែលបានមកពីការចាត់ថ្នាក់នេះ?

## ១.២.ផលប្រយោជន៍នៃការបែងចែកចំណាត់ថ្នាក់

ការបែងចែកជាបទល្មើសទាំងបីប្រភេទខាងលើ មានផលប្រយោជន៍ជាច្រើនដែលច្បាប់បានកំណត់យក ហើយផលប្រយោជន៍សំខាន់ៗមាន ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល **(ក)** និងផលប្រយោជន៍ទាក់ទងនឹងនីតិវិធី **(ខ)**។

### ក. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល

អាជ្ញាយុកាល ជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះបុគ្គលម្នាក់អាចបាត់បង់សិទ្ធិណាមួយរបស់ខ្លួន ឬអាចទាមទារសិទ្ធិណាមួយជាប្រយោជន៍ផ្ទាល់របស់ខ្លួន។ នៅក្នុងច្បាប់ព្រហ្មទណ្ឌ អាជ្ញាយុកាលមានចំនួន ២ ប្រភេទមានដូចជា៖

❖ **អាជ្ញាយុកាលនៃបទល្មើស ឬ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា៖** ជារយៈពេលមួយកំណត់ដោយច្បាប់ដែលនៅពេលផុតចិរវេលានេះ ព្រះរាជអាជ្ញាពុំអាចនឹងធ្វើការចោទប្រកាន់បានទេ ឬនិយាយម្យ៉ាងទៀ ព្រះរាជអាជ្ញាពុំអាចដាក់បណ្តឹងអាជ្ញាឱ្យមានចលនាបានឡើយ។ ចំពោះចិរវេលានៃអាជ្ញាយុកាល គឺប្រែប្រួលទៅតាមប្រភេទនីមួយៗនៃបទល្មើស។ មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនេះ ចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ៖

- ១៥ ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ ឆ្នាំ ចំពោះបទមជ្ឈិម
- ១ ឆ្នាំ ចំពោះបទលហុ។

ជាគោលការណ៍ អាជ្ញាយុកាលនៃបទល្មើស ចាប់ផ្តើមរាប់ពីពេលប្រព្រឹត្តបទល្មើសតទៅ។[46]

❖ **អាជ្ញាយុកាលនៃទោស៖** គឺជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ទោសពុំអាចអនុវត្តបានទៀតទេ។ ក្រមព្រហ្មទណ្ឌកម្ពុជា បានកំណត់ចិរវេលានៃអាជ្ញាយុកាលនៃទោសដូចតទៅ៖

- ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ ឆ្នាំ។
- ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ ឆ្នាំ។

[46] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង សាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០២២។

- ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ ឆ្នាំ ។

ចិរវេលាខាងលើនេះ ត្រូវចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសបានចូលជាស្ថាពរ។

**ខ. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី**

ចំពោះការអនុវត្តនីតិវិធីព្រហ្មទណ្ឌ អ្នកនីតិបញ្ញត្តិកំណត់គោលការណ៍ មួយចំនួនដោយផ្អែកទៅលើស្ថានទម្ងន់នៃបទល្មើសថាជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិម ឬក៏ជាបទលហុ ។ ឧទាហរណ៍ក្នុងករណីបទល្មើសជា ៖

**បទឧក្រិដ្ឋ** ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរដោយធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ តាមមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ករណីបទឧក្រិដ្ឋ ការជំនុំជម្រះត្រូវធ្វើឡើងដោយចៅក្រម ៣រូប ដែលសម្រេចជាសមូហភាព ឬដែលហៅថា ក្រុមប្រឹក្សាជំនុំជម្រះ ដោយមានការចូលរួមពីតំណាងអយ្យការមួយរូប។

**បទមជ្ឈិម** ព្រះរាជអាជ្ញាមានសិទ្ធិជ្រើសរើសក្នុងការបើកការស៊ើបសួរ ឬ បញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬក៏ប្រើប្រាស់នីតិវិធីនៃការបង្ហាញខ្លួនភ្លាមបាន កាលបើលក្ខខណ្ឌដែលបានចែងនៅមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានបំពេញយ៉ាងគ្រប់គ្រាន់ ។

**បទលហុ** ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឲ្យចូលខ្លួនទៅចំពោះមុខតុលាការ ជំនុំជម្រះដោយផ្ទាល់ ដោយអនុលោមតាមមាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ចំពោះបទមជ្ឈិម និងបទលហុ សាលាដំបូងជំនុំជម្រះដោយចៅក្រមទោល ដោយអនុលោមតាមមាត្រា ២៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ចំពោះផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី គឺមានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តនីតិវិធីព្រហ្មទណ្ឌឱ្យត្រឹមត្រូវតាមច្បាប់។ យើងឃើញថា ការចាត់ថ្នាក់តាមក្រម បានផ្តល់ផលប្រយោជន៍ដល់ការអនុវត្តនីតិវិធីជាច្រើនដូចជា៖ ផលប្រយោជន៍ដល់ការកំណត់បទល្មើសប៉ុនប៉ងមានទោស ឬមិនមានទោស ផលប្រយោជន៍ទាក់ទងនឹងការឃុំខ្លួន ឬការឃាត់ខ្លួន និងផលប្រយោជន៍ផ្សេងៗជាច្រើនទៀត។

**២. ចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទនៃបទល្មើស**

ការចាត់ថ្នាក់តាមប្រភេទនៃបទល្មើស អាចធ្វើបានរវាងបទល្មើសសាមញ្ញ បទល្មើសយោធា បទល្មើសនយោបាយ និងបទល្មើសគ្រឿងញៀន។ ដូច្នេះសូមពិនិត្យទៅលើបទល្មើសសាមញ្ញ និងបទល្មើសយោធា **(២.១)** បទល្មើសសាមញ្ញ និងបទល្មើសនយោបាយ **(២.២)** និងបទល្មើសសាមញ្ញ និងបទល្មើសគ្រឿងញៀន **(២.៣)**។

**២.១ បទល្មើសសាមញ្ញ និងបទល្មើសយោធា**

បទល្មើសភាគច្រើនត្រូវបានចាត់ទុកជាបទល្មើសសាមញ្ញ ដោយហេតុថា បទល្មើសទាំងនោះស្ថិតក្រោមច្បាប់ព្រហ្មទណ្ឌទូទៅ ទាំងវិធានជាគ្រឹះ (ច្បាប់សារធាតុ) និងទាំងវិធានជាទម្រង់ (ច្បាប់នីតិវិធី) ។

បទល្មើសយោធាគឺជាបទល្មើសពិសេស ហើយត្រូវបានច្បាប់ឱ្យនិយមន័យដោយឡែក ។ ច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣ ត្រង់មាត្រា ៩ កំណត់ឱ្យ

និយមន័យបទល្មើសយោធា ថាជាបទល្មើសដែលប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ព ហើយដែលពាក់ព័ន្ធនឹងវិន័យកងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ។ ច្បាប់ព្រហ្មទណ្ឌអន្តរកាលត្រង់មាត្រា ១១ នៃក្រមនេះ ក៏បានផ្តល់អត្ថន័យស្រដៀងនេះដែរ ចំពោះបទប្បញ្ញត្តិខាងលើបានចែងថា បទល្មើសយោធាជាបទល្មើស ដែលទាក់ទិនដល់យោធិន ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ហើយដែលពាក់ព័ន្ធដល់បទវិន័យយោធា ឬ ការខូចខាតទ្រព្យសម្បត្តិយោធា។

ផ្អែកតាមអត្ថន័យខាងលើបានបង្ហាញឱ្យយើងឃើញថា គឺមានតែយោធិនទេដែលអាចប្រព្រឹត្តបទល្មើសយោធាបាន ជនស៊ីវិលពុំអាចប្រព្រឹត្តបទល្មើសយោធាបានឡើយ។ ម្យ៉ាងវិញទៀត រាល់បទល្មើសទាំងឡាយដែលប្រព្រឹត្តដោយយោធិន ពុំសុទ្ធសឹងតែជាបទល្មើសយោធាទេ ព្រោះតាមមាត្រា ១១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលបានកំណត់ថា អំពើល្មើសនឹងច្បាប់សាមញ្ញប្រព្រឹត្តដោយយោធិនពុំត្រូវចាត់ចូលជាបទល្មើសយោធាទេ។ **ឧទាហរណ៍៖** យោធិនម្នាក់បានបានលួចទ្រព្យរបស់ប្រជាពលរដ្ឋ តាមអំពើនេះគឺល្មើសទៅនឹងបទល្មើសសាមញ្ញគឺពុំមែនជាបទល្មើសយោធាទេ ដោយហេតុទ្រព្យនោះពុំមែនជាទ្រព្យរបស់កងកម្លាំង ឬទ្រព្យយោធា។

ពិតណាស់ ការបែងចែករវាងបទល្មើសសាមញ្ញ និងបទល្មើសយោធាមានសារៈប្រយោជន៍នៅត្រង់ថាបទល្មើសទាំងពីរមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដូចគ្នាទេ។ចំពោះបទល្មើសយោធាតុលាការយោធាជាតុលាការមានសមត្ថកិច្ចក្នុងការជំនុំជម្រះ រីឯបទល្មើសសាមញ្ញវិញត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងរាជធានីខេត្ត។[47]

## **២.២ បទល្មើសសាមញ្ញ និងបទល្មើសនយោបាយ**

សញ្ញាណនៃបទល្មើសនយោបាយត្រូវបានច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងយកមកប្រើប្រាស់ផងដែរ។ ជាក់ស្តែងមាត្រា ១១៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានប្រើប្រាស់ពាក្យ "បទល្មើសនយោបាយ" ដើម្បីកំណត់ជាលក្ខខណ្ឌនៃការឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយ បុគ្គលដែលស្ថិតក្នុងក្របខ័ណ្ឌនៃនីតិវិធីបត្យាប័ន។ ម្យ៉ាងវិញទៀត មាត្រា ៥៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងពីអំពើដែលមានលក្ខណៈនយោបាយផង និងបទល្មើសនយោបាយផង។ ក៏ប៉ុន្តែបទប្បញ្ញត្តិទាំងនេះពុំបានឱ្យនិយមន័យជាក់លាក់ស្តីពីបទល្មើសនយោបាយឡើយ ពោលគឺគ្រាន់តែបានផ្តល់ជាឧទាហរណ៍ពីបទល្មើសមួយចំនួនដែលមិនត្រូវបានចាត់ទុកថាជា បទល្មើសនយោបាយតែប៉ុណ្ណោះ ។

បើសិនជាពិនិត្យទៅលើសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងស្តីពីបត្យាប័ន ដែលព្រះរាជាណាចក្រកម្ពុជាបានព្រមព្រៀងជាមួយនឹង ព្រះរាជាណាចក្រថៃ សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិប

[47] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង សាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០២២។

តេយ្យប្រជាមានិតឡាវ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋបារាំង ក៏ពុំមាននិយមន័យនៃបទល្មើសនយោបាយដែរ។ ប៉ុន្តែមិនត្រូវចាត់ទុកជាបទល្មើសនយោបាយឡើយ ចំពោះការធ្វើឃាត ឬការបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ឬសមាជិកគ្រួសារនៃវរជនទាំងនោះ។ ក្នុងឆ្នាំ ១៨៩២ ប្រទេសស្វីសបានអនុម័តច្បាប់មួយដែលចែងថា បទល្មើសមួយ មិនត្រូវចាត់ទុកជាបទល្មើសនយោបាយទេ ប្រសិនបើជាបទល្មើសនៃនីតិរួម (បទល្មើសព្រហ្មទណ្ឌសាមញ្ញ) ទោះបីជាអំពើនោះមានមូលហេតុ ឬមានគោលបំណងចេញពីបញ្ហានយោបាយក៏ដោយ។ យោងតាមវចនានុក្រមច្បាប់អង់គ្លេស - ខ្មែរ បោះពុម្ពផ្សាយនៅឆ្នាំ ១៩៩៧ ដោយអង្គការមូលនិធិអាស៊ី បានឱ្យនិយមន័យបទល្មើសនយោបាយថា ជាអំពើមួយដែលធ្វើឡើងក្នុងគោលបំណងនយោបាយ ឬមកពីមូល ហេតុនយោបាយ។ តាមសទ្ទានុក្រមច្បាប់បារាំង-ខ្មែរ បានឱ្យនិយមន័យបទល្មើសនយោបាយតាមទស្សនៈសត្យានុម័តថា បទល្មើសនយោបាយសំដៅលើរាល់អំពើប្រព្រឹត្តទាំងឡាយណាដែលប៉ះពាល់ដោយផ្ទាល់ដល់ផលប្រយោជន៍ ឬបុព្វសិទ្ធិដែលមានលក្ខណៈនយោបាយ ដូចជាការប៉ះពាល់ដល់អត្ថិភាព ឬដល់ស្ថាប័នរដ្ឋ។ **ឧទាហរណ៍៖** ការប៉ះពាល់ដល់ដំណើរការនៃអំណាចរដ្ឋធម្មនុញ្ញ។

ការបែងចែករវាងបទល្មើសសាមញ្ញ និងបទល្មើសនយោបាយមានផលប្រយោជន៍ជាពិសេសពាក់ព័ន្ធនឹងរឿងធ្វើបត្យាប័ន។ បត្យាប័ន គឺជានីតិវិធីដែលរដ្ឋមួយហៅថា រដ្ឋធ្វើសំណើស្នើសុំទៅរដ្ឋមួយទៀតហៅថា រដ្ឋទទួលសំណើឱ្យប្រគល់ជនល្មើសដែលកំពុងតែស្ថិតនៅលើទឹកដីរបស់រដ្ឋទទួលសំណើ មកឱ្យរដ្ឋធ្វើសំណើ ដើម្បីធ្វើការចោទប្រកាន់ ជំនុំជម្រះ ឬអនុវត្តទោសនៅលើទឹកដីរបស់ រដ្ឋធ្វើសំណើ។ ជាគោលការណ៍បត្យាប័នមិនអាចត្រូវបានអនុញ្ញាតឡើយចំពោះ បទល្មើសនយោបាយ។[48]

## ២.៣ បទល្មើសសាមញ្ញ និងបទល្មើសគ្រឿងញៀន

ពាក្យបទល្មើសគ្រឿងញៀន ជាពាក្យដែលមានន័យទូលំទូលាយដែលគ្រប់ដណ្តប់លើគ្រប់បទល្មើសទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងគ្រឿងញៀន ហើយមានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ឧទាហរណ៍៖** ការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ឬការចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ឬការសម្រួលឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

ចំពោះបទល្មើសគ្រឿងញៀនដូចបានរៀបរាប់ខាងលើច្បាប់បានបញ្ញត្តនូវវិធានពិសេសសម្រាប់គ្រប់គ្រង និងផ្តន្ទាទោសជនដែលប្រព្រឹត្តបទល្មើសទាំងនេះ។ ម្យ៉ាងវិញទៀត ចំពោះបទល្មើសខាងលើនេះ ព្រះរាជអាជ្ញា ឬចៅក្រម ស៊ើបសួរ ត្រូវចាត់គ្រូពេទ្យឱ្យមកពិនិត្យជនឃាត់ខ្លួន ២៤ ម៉ោងម្តង ចំណែកឯចំពោះបទល្មើសសាមញ្ញវិញ នីតិវិធីបែបនេះពុំឃើញមានចែងឡើយ។[49]

---

[48] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង សាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០២២។

[49] ណែនាំដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង**, ដកស្រង់ចេញពីសារណាបញ្ចប់ការសិក្សាប្រធានបទ បទល្មើសព្រហ្មទណ្ឌ ឆ្នាំ២០២២។

## ៣. ចំណាត់ថ្នាក់ដោយផ្អែកលើបែបបទនៃការប្រព្រឹត្តបទល្មើស

បុគ្គលគ្រប់រូបកាលប្រព្រឹត្តធ្វើអ្វីមួយតែងត្រូវបានវិច្ឆិន័យតាមរយៈចិត្ត និងសម្ភារៈដែលបុគ្គលនោះបានប្រព្រឹត្ត ជាហេតុធ្វើឲ្យច្បាប់បានកំណត់បទល្មើសអាចត្រូវបានធ្វើការបែងចែក ដោយយោងតាមទិដ្ឋភាពសត្យានុម័ត (១) និងទិដ្ឋភាពអត្តនោម័ត (២) នៃបែបបទប្រព្រឹត្តបទល្មើស។

### ៣.១ ចំណាត់ថ្នាក់បទល្មើសផ្អែកលើបែបបទទិដ្ឋភាពសត្យានុម័តនៃការប្រព្រឹត្តបទល្មើស

ដោយយោងទៅតាមអំពើ ជាសត្យានុម័តនៃបទល្មើសនីមួយៗ គេអាចធ្វើការបែងចែកបទល្មើសទៅតាមប្រភេទនៃអំពើជាសម្ភារៈរបស់បទល្មើស (**ក**) ទៅតាមរយៈពេលសម្រេចបទល្មើស (**ខ**) និងទៅតាមប្រភេទនៃលទ្ធផលបទល្មើស (**គ**) ព្រមទាំងការបែងចែកទៅតាមចំនួននៃអំពើជាសម្ភារៈក្នុងបទល្មើសណាមួយ (**ឃ**) ។

### ក. ការចាត់ថ្នាក់ទៅតាមអំពើសកម្ម និងអកម្ម

ប្រភេទនៃអំពើជាសម្ភារៈនៃបទល្មើសមួយ អាចជាការប្រព្រឹត្តសកម្មភាពណាមួយ ឬការមិនប្រព្រឹត្តសកម្មភាពណាមួយ។ បើសិនអំពើជាសម្ភារៈជាការប្រព្រឹត្តសកម្មភាព គេហៅថាបទល្មើសសកម្ម (**ក.១**)។ ផ្ទុយទៅវិញ បើសិនអំពើជាសម្ភារៈជាការមិនប្រព្រឹត្តសកម្មភាព ឬអនុប្បវាទ គេហៅថាបទល្មើសអកម្ម (**ក.២**)។

### ក.១ បទល្មើសសកម្ម

បទល្មើសសកម្ម ឬអំពើវិជ្ជមាន គឺមានន័យថាបទល្មើសដែលជនល្មើសប្រព្រឹត្តបានបំពានលើការហាមឃាត់របស់ច្បាប់ព្រហ្មទណ្ឌ។ **ឧទាហរណ៍** ១. បទឃាតកម្ម ដោយជនល្មើសបានយកកាំបិតចាក់ទៅលើជនម្នាក់បណ្តាលឱ្យស្លាប់បាត់បង់ជីវិត អំពើនេះត្រូវបានចាត់ទុកជាបទល្មើសសកម្មព្រោះវាជាបទល្មើសដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់។ ២. អំពើជាសត្យានុម័តនៃអំពើលួច គឺជាអំពើដែលដកហូតយកទ្រព្យសម្បត្តិរបស់អ្នកដទៃ។

អំពើវិជ្ជមានដែលជាធាតុផ្សំសត្យានុម័តនៃបទល្មើសអាចជាកាយវិការណាមួយដូចជា ការសម្លាប់ ការធ្វើឱ្យរបួសដោយការកេះកៃកាំភ្លើង ការលួចដោយដកហូតយកទ្រព្យសម្បត្តិរបស់អ្នកដទៃ។ល។ អំពើក៏អាចជាពាក្យសម្តី ឬជាសំណេរណាមួយដែរដូចជា អំពើនៅក្នុងបទបរិហារកេរ្តិ៍ជាសាធារណៈ បទជេរប្រមាថ ឬបទក្លែងបន្លំឯកសារជាដើម ។

### ក.២ បទល្មើសអកម្ម

បទល្មើសអកម្ម ឬអំពើអវិជ្ជមាន គឺមានន័យថាបទល្មើសដែលជនល្មើសមិនព្រមបំពេញកាតព្វកិច្ចអ្វីមួយទៅតាមច្បាប់តម្រូវឱ្យធ្វើ ឬអាចនិយាយថា ជនល្មើសមិនបានធ្វើអំពើដែលច្បាប់តម្រូវឱ្យធ្វើ។ **ឧទាហរណ៍** បទមិនប្តឹងបរិហារបទឧក្រិដ្ឋ មាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌបានចែងថា រាល់បុគ្គលណាដែលបានដឹងពីបទឧក្រិដ្ឋដែលអាចនឹងបង្ការ ឬបន្ថយអានុភាពរបស់បទល្មើសបាន ហើយមិនប្តឹងបរិហារដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជា

ប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។ **ឧទាហរណ៍** បទមិនប្តឹងបរិហារការធ្វើបាបអនីតិជន មាត្រា ៥៣០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

**ខ. ការចាត់ថ្នាក់ទៅតាមថេរៈវេលានៃការប្រព្រឹត្តបទល្មើស**

ក្នុងបទល្មើសនីមួយៗ ជនល្មើសតែងតែប្រើប្រាស់នូវពេលវេលាសម្រាប់ធ្វើសកម្មភាពល្មើស ហើយរយៈពេលនោះមិនដូចគ្នាឡើយ បទល្មើសមួយចំនួនកើតឡើងភ្លាមៗ **(ខ.១)** បទល្មើសខ្លះបន្តសកម្មភាពជាហូរហែរ **(ខ.២)** និងបទល្មើសខ្លះទៀតអូសបន្លាយពេលវេលា**(ខ.៣)**។ ដូចនេះយើងនឹងត្រូវសិក្សាពីពេលវេលាចំពោះបទល្មើសនីមួយៗ ហើយនឹងផលប្រយោជន៍ដែលបានមកពីការចាត់ថ្នាក់ទៅតាមថេរៈវេលានេះ។

**ខ.១ បទល្មើសភ្លាមៗ**

នៅពេលដែលបទល្មើសអាចសម្រេចបានក្នុងពេលតែមួយភ្លែត មានន័យថាបទល្មើសដែលកើតឡើងក្នុងពេលតែមួយជាមួយនឹងអំពើប្រព្រឹត្ត គឺបទល្មើសនោះត្រូវចាត់ទុកថាជាបទល្មើសភ្លាមៗ។ បទល្មើសភ្លាមៗជាបទល្មើសដែលការប្រព្រឹត្តរបស់វាបានកើតឡើងភ្លាមៗមិនអូសបន្លាយពេលវេលា ហើយចំពោះការប្រព្រឹត្តបទល្មើសត្រូវប្រើសកម្មភាពក្នុងពេលយ៉ាងខ្លីបំផុត គឺថាបទល្មើសអាចសម្រេចផលក្នុងពេលតែមួយជាមួយនឹងការប្រព្រឹត្តបទល្មើស។ **ឧទាហរណ៍៖**

**អំពើលួច៖** បានសម្រេចនៅពេលដែលជនល្មើសបានដកហូតយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត។ គួរបញ្ជាក់ផងដែរថា បើទោះបីជាពេលខ្លះ ជនល្មើសត្រូវប្រើពេលវេលាវែងដូចជា ២ម៉ោង ឬ ៣ម៉ោង ដើម្បីគាស់ទម្លុះទម្លាយទូដែក យកទ្រព្យសម្បត្តិក៏ដោយ ក៏អំពើលួចនៅតែជាបទល្មើសភ្លាមៗដដែល ពីព្រោះថានៅពេលដែលជនល្មើសកំពុងតែគាស់ទូដែក អំពើលួចពុំទាន់បានសម្រេចផលនៅឡើយនោះទេដោយហេតុថាជនល្មើសនៅមិនទាន់បានដកហូតយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះនៅឡើយទេ។[50]

**បទឃាតកម្ម៖** សម្រេចបានភ្លាមៗ នៅខណៈដែលជនរងគ្រោះបានស្លាប់បាត់បង់ជីវិតដូចជា នៅពេលកំពុងរាំធុងបាស់ ដោយសារកំហឹង ស្រាប់តែមានយុវជនម្នាក់បានយកកាំបិតទៅចាក់លើយុវជនម្នាក់ទៀតបណ្តាលឱ្យស្លាប់បាត់បង់ជីវិតទៅ។

**ខ.២ បទល្មើសបន្តរៀងហូរហែ**

បទល្មើសបន្តរៀងហូរហែ ជាបទល្មើសដែលអំពើជាសម្ភារៈប្រព្រឹត្តឡើងបន្តគ្នាជាហូរហែ និងដោយស៊ីសង្វាក់គ្នានៅក្នុងពេលវេលា។ និយាយម្យ៉ាងទៀតថា ផ្ទុយពីបទល្មើសភ្លាមៗ បទល្មើសបន្តរៀងហូរហែ គឺជាបទល្មើស ដែលត្រូវអនុវត្តជាបន្តបន្ទាប់គ្នាក្នុងរយៈពេលមួយ ដែលបានបង្ហាញឱ្យឃើញពីចេតនាទុច្ចរិតដែលស្ថិត

[50] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង សាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០២២។

នៅជាដរាប។ សម្រាប់បទល្មើសបន្តរៀងហូរហែ អ្នកនីតិបញ្ញត្តិបានចាត់ទុកថា ជាអំពើប្រព្រឹត្តនូវបទល្មើសណាមួយដែលកើតឡើងក្នុងពេលវេលាណាមួយ។

ដើម្បីអាចចាត់ទុកថាបទល្មើសណាមួយគឺ ជាបទល្មើសបន្តរៀងហូរហែ គេចាំបាច់ត្រូវពិនិត្យទៅលើសកម្មភាពដែលអ្នកនីតិបញ្ញត្តិចាត់ទុកជាបទល្មើស ពោលគឺត្រូវពិនិត្យមើលថាតើសកម្មភាពនោះកើតឡើងដោយទាមទារឱ្យមានរយៈពេលណាមួយ ឬក៏កើតឡើងភ្លាមៗ។ ប្រសិនបើសកម្មភាពនោះកើតឡើងដោយទាមទារ ឱ្យមានរយៈពេលណាមួយ នោះគឺជាបទល្មើសបន្តរៀងហូរហែ ។

**ឧទាហរណ៍៖** បទទទួលផលចោរកម្ម ត្រូវបានបង្កើតឡើងចាប់ពីពេលដែលបុគ្គលម្នាក់ទទួលទិញវត្ថុណាមួយ ដោយដឹងជាក់ច្បាស់ថាវត្ថុនោះបានមកដោយសារតែការប្រព្រឹត្តបទល្មើស (ដូចជាអំពើលួចជាដើម) ។ ដរាបណា ជនទទួលផលចោរកម្មបន្តកាន់កាប់វត្ថុទិញនោះ បទល្មើសត្រូវបានចាត់ទុកថានៅតែបន្តប្រព្រឹត្តតទៅទៀតពុំទាន់បានចប់សព្វគ្រប់នៅឡើយ។ បទទទួលផលចោរកម្ម ត្រូវបានបញ្ចប់នៅពេលណាដែលជនទទួលផលចោរកម្មយកវត្ថុល្មើសចេញពីរូបខ្លួនដោយលក់ចេញទៅឱ្យតតិយជនជាដើម ។[51]

## ខ.៣ បទល្មើសអូសបន្លាយ

បទល្មើសអូសបន្លាយ គឺជាបទល្មើសដែលអំពើបង្កគ្រោះថ្នាក់ដល់សង្គមស្តែងឡើងជាប់ជាហូរហែគ្មានអាក់ខានក្នុងរយៈពេលណាមួយឡើយ។ និយាយម្យ៉ាងទៀតថា បទល្មើសអូសបន្លាយ សំដៅលើបទល្មើសដែលបង្កើតឡើងដោយបណ្តាអំពើជាច្រើនប្រហាក់ប្រហែលគ្នា ដោយអំពើនីមួយៗក៏ត្រូវចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌដែរ ក៏ប៉ុន្តែដោយសារឯកភាពនៃសេចក្តីសម្រេចចិត្ត(គោលដៅរបស់ជនល្មើស) និងភាពដូចគ្នានៃច្បាប់ដែលជនល្មើសបានបំពានអំពើច្រើនប្រហាក់ប្រហែលគ្នានោះ គួរតែចាត់ទុកថាជាបទល្មើសតែមួយប៉ុណ្ណោះ ។

**ឧទាហរណ៍៖ បទផិត** ត្រូវកើតឡើងនៅពេលដែលបុរស ឬស្ត្រីដែលមានសហព័ទ្ធត្រឹមត្រូវតាមច្បាប់រួច ហើយបែរជាទៅរួមសេវនកិច្ចជាមួយនឹងស្ត្រី ឬបុរសផ្សេងទៀត ។ ឧបមាថា ជនល្មើសបានរួមសេវនកិច្ច ៥ ដងជាមួយនឹងបុរស ឬស្ត្រីដទៃទៀតដែលមិនមែនជាសហព័ទ្ធរបស់ខ្លួន។ ប្រសិនបើបទល្មើសបានកើតឡើងចំនួន ៥ដង គួរចាត់ទុកថាមានបទល្មើសតែមួយប៉ុណ្ណោះដែលកើតឡើង មិនមែនមានបទល្មើសចំនួន ៥ ទេ ដោយហេតុថាគោលដៅរបស់ជនល្មើសមានតែមួយប៉ុណ្ណោះ ហើយច្បាប់ត្រូវផ្តន្ទាទោសលើអំពើនេះ ក៏ជាច្បាប់តែមួយដែរ។

## ខ.៤ ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល

យោងតាមមាត្រា ១១ វាក្យខ័ណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចិរវេលារបស់អាជ្ញាយុកាលនៃបទល្មើសត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស។ ការចាប់ផ្តើមគិតបែបនេះ ត្រូវយកមកអនុវត្តសម្រាប់បទល្មើស

[51] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង សាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០២២។

ភ្លាមៗ។ **ឧទាហរណ៍៖** ចំពោះបទល្មើសឃាតកម្មដែលជាបទល្មើសភ្លាមៗ ចិរវេលានៃអាជ្ញាយុកាលត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស បានន័យថា ចាប់ពីពេលដែលជនរងគ្រោះបានស្លាប់បាត់បង់ជីវិត ។

ចំណែកឯចិរវេលានៃអាជ្ញាយុកាលសម្រាប់បទល្មើសបន្តរៀងហូរហែ និងបទល្មើសអូសបន្លាយ ត្រូវចាប់ផ្តើមគិតពីពេលដែលអំពើល្មើសបានបញ្ចប់ តែមិនមែនចាប់ផ្តើមគិតពីពេលដែលអំពើល្មើសបានចាប់ផ្តើមទេ។

**ឧទាហរណ៍៖** ចំពោះបទទទួលផលចោរកម្មដែលជាបទល្មើសបន្តរៀងហូរហែ ចិរវេលារបស់អាជ្ញាយុកាលនៃ បទល្មើស ត្រូវចាប់ផ្តើមគិតពីថ្ងៃដែលជនល្មើស លែងរក្សាទុកវត្ថុនៅនឹងខ្លួនតទៅទៀត ដូចជាថ្ងៃដែលជនល្មើសបាន យកកម្មវត្ថុនៃបទល្មើសទៅលក់ចេញជាដើម។ រីឯបទជិតវិញ (បទល្មើសអូសបន្លាយ) ចិរវេលានៃអាជ្ញាយុកាលនៃបទល្មើស ត្រូវគិតចាប់ពីថ្ងៃដែលអំពើប្រព្រឹត្តរបស់ជនល្មើសចុងក្រោយបង្អស់ មិនមែនគិតចាប់ពីពេលប្រព្រឹត្តបទល្មើសដំបូងនោះទេ។

### ខ.៥ ផលប្រយោជន៍ទាក់ទងនឹងតុលាការមានសមត្ថកិច្ច

តុលាការមានសមត្ថកិច្ចក្នុងការជំនុំជម្រះបទល្មើស គឺជាតុលាការនៃទីកន្លែងប្រព្រឹត្តបទល្មើស។[52] ដូច្នេះ សម្រាប់បទល្មើសភ្លាមៗ តុលាការមានសមត្ថកិច្ចអាចមានតែមួយប៉ុណ្ណោះ បើយោងតាមគោលការណ៍ខាងលើ ផ្ទុយទៅវិញ ចំពោះបទល្មើសអូសបន្លាយ និងបទល្មើសបន្តរៀងហូរហែវិញ អំពើល្មើសអាចប្រព្រឹត្តនៅទីកន្លែងខុសៗ គ្នា ពោលគឺតុលាការនៃទីកន្លែងផ្សេងៗគ្នាសុទ្ធតែអាចជាតុលាការមានសមត្ថកិច្ចទាំងអស់ ។

### គ. ចំណាត់ថ្នាក់ទៅតាមចំនួននៃអំពើនៅក្នុងបទល្មើស

ដោយផ្អែកទៅលើចំនួននៃអំពើនៅក្នុងបទល្មើសមួយ គេអាចធ្វើការបែងចែកបទល្មើសជា បទល្មើសធម្មតា បទល្មើសស្មុគស្មាញ និង បទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់ ហើយការបែងចែកនេះបានផ្តល់នូវផល ប្រយោជន៍ផ្នែកគតិយុត្តមួយចំនួនផងដែរ។

### គ.១ លក្ខណៈវិនិច្ឆ័យនៃការបែងចែក

ដើម្បីកំណត់បទល្មើសទាំងនេះ គឺអាស្រ័យទៅតាមចំនួន ព្រមទាំងលក្ខណៈនៃអំពើ ដែលជាធាតុផ្សំសត្យានុម័តនៃបទល្មើសនោះ។

### ១. បទល្មើសធម្មតា ឬបទល្មើសសាមញ្ញ

បទល្មើសធម្មតា គឺជាបទល្មើសដែលត្រូវបានសម្រេចឡើងដោយ អំពើជាសត្យានុម័តតែមួយគត់ប៉ុណ្ណោះ ។ **ឧទាហរណ៍៖** មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា អំពើលួច គឺជាអំពើដក ហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណង

[52] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា /១០.សីហា.២០០៧/ មាត្រា ២៩០។

យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ ហេតុដូចនេះ អំពើជាសត្យានុម័តដែលជាធាតុផ្សំនៃអំពើលួចមានតែមួយគត់ គឺជាការដកហូតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ ។

**២. បទល្មើសស្មុគស្មាញ ឬបទល្មើសសាំញ៉ាំ**

បទល្មើសស្មុគស្មាញ គឺជាបទល្មើសដែលបានសម្រេចឡើងដោយមានអំពើជាសត្យានុម័តច្រើនគួបផ្សំគ្នា។ បទល្មើសស្មុគស្មាញ ជាបទល្មើសដែលត្រូវអនុវត្តជាបន្តបន្ទាប់ ប៉ុន្តែគឺជាបទល្មើសដែលកើតឡើងភ្លាមៗ។ **ឧទាហរណ៍៖** មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា អំពើលួចដោយប្រព្រឹត្តអំពើហិង្សា មានធាតុសត្យានុម័តចំនួនពីរគឺ៖

- ការប្រើប្រាស់ហិង្សាបំពារបំពានរូបរាងកាយ ឬអាយុជីវិតអ្នកដទៃ និង
- ការដណ្តើមយកទ្រព្យសម្បត្តិដែលមិនមែនជារបស់ខ្លួន។

**៣. បទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់**

បទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់ គឺជាបទល្មើសដែលកើតឡើងដោយសារអំពើដែលកើតឡើងពីការប្រព្រឹត្តអំពើដដែលៗម្តងហើយម្តងទៀត គឺបង្កើតបានជាបទល្មើសដែលត្រូវផ្តន្ទាទោស ។ ក្នុងន័យនេះ បទល្មើស កើតចេញពីអំពើប្រព្រឹត្តជាទម្លាប់ គឺជាបទល្មើសដែលត្រូវអនុវត្តជាបន្តបន្ទាប់ ។ ថ្វីត្បិតតែជាបទល្មើសដែលត្រូវអនុវត្តជាបន្តបន្ទាប់ក្តី បទល្មើសនេះត្រូវកើតឡើងភ្លាមៗ នៅពេលដែលមានអំពើចុងក្រោយដែលជាធាតុផ្សំនៃបទល្មើស(ទម្លាប់)។ **ឧទាហរណ៍៖** អំពើគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រឆាំងនឹងបុគ្គលដែលធ្វើដោយផ្ទាល់ មាត់ ឬតាមលិខិត រូបភាព ឬវត្ថុអ្វីមួយ គឺជាបទល្មើស និងត្រូវផ្តន្ទាទោសតាមមាត្រា ២៣១ នៃក្រមព្រហ្មទណ្ឌ កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត។ ក្នុងន័យនេះ បើអំពើគំរាមកំហែងធ្វើឡើងតែម្តងគត់ មិនត្រូវបានចាត់ទុកជាបទល្មើសទេ ។[53]

**គ.២ ផលប្រយោជន៍នៃការបែងចែក**

**១. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល**

សម្រាប់បទល្មើសស្មុគស្មាញ និងបទល្មើសដែលកើតចេញមកពីអំពើប្រព្រឹត្តជាទម្លាប់ អាជ្ញាយុកាលនៃបទ ល្មើសត្រូវចាប់រាប់ពីការសម្រេចអំពើចុងក្រោយនៃបទល្មើស ពីព្រោះថា បទល្មើសនឹងសម្រេចទាំងស្រុងចាប់ពីពេល សម្រេចអំពើចុងក្រោយនៃបទល្មើស តែមិនមែនចាប់ពីអំពើទីមួយនៃបទល្មើសនោះទេ បើទោះបីជាមានគម្លាតរយៈពេលយូរយ៉ាងណារវាងអំពើទីមួយ និងអំពើទីពីរក៏ដោយ។ **ឧទាហរណ៍៖** ឈ្មោះ ក បានគំរាមកំហែងជនរងគ្រោះតាមទូរស័ព្ទជាលើកទី ១ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២០ និងជាលើកទី ២ នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ

[53] ណែនាំដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង**, ដកស្រង់ចេញពីសារណាបញ្ចប់ការសិក្សាប្រធានបទ បទល្មើសព្រហ្មទណ្ឌ ឆ្នាំ២០២២។

២០២១។ ចិរវេលានៃអាជ្ញាយុកាលត្រូវចាប់ផ្ដើមគិតពីថ្ងៃទី០៥ ខែមេសា ឆ្នាំ ២០២១ តែមិនមែនចាប់គិតពីថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០២០ ឡើយ ពីព្រោះថាបទល្មើសបានកើតឡើងនៅថ្ងៃទី០៥ ខែមេ សា ឆ្នាំ២០២១ ដែលជាអំពើចុងក្រោយនៃធាតុផ្សំបទគំរាមកំហែង។[54]

## ២. ផលប្រយោជន៍ទាក់ទងនឹងតុលាការមានសមត្ថកិច្ច

តុលាការច្រើនអាចមានសមត្ថកិច្ចក្នុងការជំនុំជម្រះបទល្មើស នៅពេលដែលអំពើជាធាតុផ្សំសត្យានុម័តនៃបទល្មើសត្រូវបានប្រព្រឹត្តនៅទីកន្លែងខុសៗគ្នា។ **ឧទាហរណ៍៖** ជនល្មើស បានគំរាមកំហែងជនរងគ្រោះលើកទី១នៅរាជធានីភ្នំពេញ លើកទី២នៅខេត្តកណ្ដាល និងលើកទី៣នៅខេត្តកំពង់ស្ពឺ។ ក្នុងករណីបែបនេះ តុលាការមានសមត្ថកិច្ចអាចជាសាលាដំបូងរាជធានីភ្នំពេញ សាលាដំបូងខេត្តកណ្ដាល និងសាលាដំបូងខេត្តកំពង់ស្ពឺ។

## ឃ. ចំណាត់ថ្នាក់ទៅតាមលទ្ធផលនៃបទល្មើស

លទ្ធផលនៃបទល្មើស សំដៅទៅលើព្យសនកម្មដែលជាផលវិបាកនៃអំពើសត្យានុម័តរបស់ចារី។ លទ្ធផលនៃអំពើល្មើសគឺជាព្យសនកម្ម ឬជាការនាំឱ្យអន្តរាយដល់សង្គមមានដូចជា ព្យសនកម្មសម្ភារៈ ព្យសនកម្មផ្លូវកាយ និងព្យសនកម្មផ្លូវចិត្ត។ ដោយយោងទៅលើលទ្ធផលនៃបទល្មើស បទល្មើសត្រូវបានបែងចែកជាពីរប្រភេទ គឺ បទល្មើសសម្ភារៈ និងបទល្មើសទម្រង់ ឬហៅម្យ៉ាងទៀតថា បទល្មើសរូបភាព។

### ឃ.១ បទល្មើសសម្ភារៈ

បទល្មើសមួយគឺជាបទល្មើសសម្ភារៈ នៅពេលដែលច្បាប់តម្រូវឱ្យមានភស្តុតាងអំពីលទ្ធផលណាមួយជាកំណត់ដើម្បីអាចឱ្យចាត់ទុកថាជាបទល្មើសបានសម្រេចផល។ ដូច្នេះ លទ្ធផលនៃអំពើល្មើសជាធាតុផ្សំមួយនៃបទល្មើស ហើយបទល្មើសអាចបានផល នៅពេលដែលលទ្ធផលបានទទួល ឬនិយាយម្យ៉ាងទៀតថា ជនរងគ្រោះបានទទួលរងនូវព្យសនកម្មពិតប្រាកដ ដែលចារីបានគ្រោងទុកជាមុន។[55] **ឧទាហរណ៍៖** បទឃាតកម្ម បានសម្រេចនៅពេលដែលជនរងគ្រោះបានស្លាប់បាត់បង់ជីវិត។ មរណភាព របស់ជនរងគ្រោះត្រូវតែមានហេតុនៅក្នុងអំពើរបស់ចារី ដែលអាចជាអំពើចាក់នឹងកាំបិត ឬបាញ់នឹងកាំភ្លើងជាដើម ហើយក៏ដោយសារតែអំពើចាក់ ឬអំពើបាញ់ពីសំណាក់ចារីនេះឯង ទើបបណ្ដាលឱ្យជនរងគ្រោះបាត់បង់ជីវិត។

### ឃ.២ បទល្មើសទម្រង់ ឬបទល្មើសរូបភាព

បទល្មើសនេះផ្ទុយពីបទល្មើសសម្ភារៈ បទល្មើសរូបភាពក៏អាចត្រូវផ្ដន្ទាទោសបានផងដែរ ដោយមិនអាស្រ័យទៅលើលទ្ធផលនៃបទល្មើសឡើយ ពោលគឺចាត់ទុកថាជាបទល្មើសបានសម្រេច ទោះបីជាលទ្ធផលដែលជនល្មើស ប្រាថ្នាចង់បានបែរជាមិនបានទទួលក៏ដោយ។ **ឧទាហរណ៍៖** បទសម្លុតកុំឱ្យដាក់ពាក្យបណ្ដឹង

[54] ណែនាំដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង**, ដកស្រង់ចេញពីសារណាបញ្ចប់ការសិក្សាប្រធានបទ បទល្មើសព្រហ្មទណ្ឌ ឆ្នាំ២០២២។
[55] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង សាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០២២។

កើតឡើងនៅពេលដែលជនល្មើសបានគំរាមកំហែង ដើម្បីញុះញង់ឱ្យជនរងគ្រោះកុំឱ្យដាក់ពាក្យបណ្ដឹង ឬដកពាក្យបណ្ដឹងរបស់ខ្លួន។ លទ្ធផលដែលចារីចង់បានពីបទល្មើសនេះ គឺធ្វើយ៉ាងណាឱ្យជនរងគ្រោះភ័យខ្លាចហើយមិនដាក់ពាក្យបណ្ដឹង ឬដកពាក្យបណ្ដឹងដែលបានដាក់រួចហើយ។ ក៏ប៉ុន្តែមាត្រា ៥២៧ នៃក្រមព្រហ្មទណ្ឌចាត់ទុកថាជាបទល្មើស ទោះបីជាជនរងគ្រោះធ្វើតាមបំណងប្រាថ្នារបស់ជនល្មើស ឬក៏មិនធ្វើតាមក៏ដោយ។

**ង. ការចាត់ថ្នាក់ទៅតាមបទល្មើសជាក់ស្ដែង និងមិនជាក់ស្ដែង**

ពេលដែលយើងដឹងវាថា គឺជាបទល្មើសដែលបានកើតឡើងនៅកន្លែងណាមួយ យើងមិនទាន់អាចកំណត់បានថាជាបទល្មើសជាក់ស្ដែង រឺមិនមែនជាបទល្មើសជាក់ស្ដែងឡើយ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើនៅថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ បានកំណត់នូវសញ្ញាណពីរទាក់ទងនឹងបទល្មើសគឺ បទល្មើសជាក់ស្ដែង (**ង.១**) និងបទល្មើសមិនជាក់ស្ដែង (**ង.២**)។

**ង.១ បទល្មើសជាក់ស្ដែង**

បទល្មើសជាក់ស្ដែង គឺជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលបច្ចុប្បន្នកំពុងប្រព្រឹត្ត ឬដែលទើបនឹងប្រព្រឹត្ត ឬជន សង្ស័យត្រូវបានសាក្សី ឬជនរងគ្រោះចង្អុលបង្ហាញនូវនឹងកន្លែងដែលប្រព្រឹត្តបទល្មើស។ **ឧទាហរណ៍៖** លោក ខ បានកាន់កូនកាំបិតដើរសំដៅទៅចាក់ លោក ក ដោយហេតុថាលោក ក បានប៉ះពាល់មិត្តស្រី នៅក្នុងកម្មវិធីមួយកន្លែង កំឡុងពេលប្រព្រឹត្តអំពើរបស់លោក ខ នោះផងដែរ ម្ចាស់កម្មវិធីក៏បានរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់ការរឿងនេះតាមនីតិវិធី។

**ង.២ បទល្មើសមិនជាក់ស្ដែង**

សកម្មភាពមួយដែលអាចកំណត់ថាជាបទល្មើសមិនជាក់ស្ដែង ពោលគឺជាបទល្មើសទាំងឡាយណាដែលការប្រព្រឹត្តបានចប់សព្វគ្រប់ទៅហើយផ្ទុយនឹងបទល្មើសជាក់ស្ដែង។ **ឧទាហរណ៍៖** ការប្រទះឃើញដោយចៃដន្យរបស់បុរសម្នាក់ដោយឃើញមានសាកសពមនុស្សស្រីម្នាក់ដេកស្លាប់នៅក្នុងព្រៃ។ ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការស៊ើបអង្កេតបឋម ស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

**៣.២ ការចាត់ថ្នាក់ផ្អែកលើបែបបទធាតុអត្តនោម័ត**

យោងទៅលើធាតុផ្សំអត្តនោម័តនៃបទល្មើសមួយ គេអាចបែងចែកបទល្មើសជាបទល្មើសចេតនា(**ក**) និងបទល្មើសអចេតនា(**ខ**)។

**ក. បទល្មើសចេតនា**

បទល្មើសចេតនា គឺជាបទល្មើសទាំងឡាយណា ដែលចារីមានចេតនាប្រព្រឹត្តយ៉ាងពិតប្រាកដ។ **ឧទាហរណ៍៖** អំពើលួច គឺចារីមានចេតនាទុច្ចរិតចង់ដកហូតយកវត្ថុរបស់អ្នកដទៃ បានន័យថា ជនល្មើសបានប្រព្រឹត្តអំពើដកហូតដោយចេតនា និងមានបំណងយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

### ខ. បទល្មើសអចេតនា

បទល្មើសអចេតនា គឺជាបទល្មើសទាំងឡាយណាដែលជនល្មើសគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែបទល្មើស នៅតែបានកើតឡើង ពីព្រោះថាបទល្មើសកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្វះខ្វា ការធ្វេសប្រហែស ឬការមិន គោរពកាតព្វកិច្ចដោយទ្បែកណាមួយ។ **ឧទាហរណ៍៖** បទបង្ករបួសស្នាមដោយអចេតនា គឺជាអំពើដែលបណ្តា លឱ្យមានរបួសដល់អ្នកដទៃ ដោយការ ធនប្រុងប្រយ័ត្នរបស់ចារី។

### ៤. បទល្មើសដែលគ្មានអាជ្ញាយុកាល

ស្ទើរតែគ្រប់បទល្មើសទាំងអស់ សុទ្ធសឹងតែមានកំណត់យ៉ាងច្បាស់លាស់អំពីអាជ្ញាយុកាលនៃបទ ល្មើសទាំងនោះ ដែលជាការកំណត់ពេលវេលាសម្រាប់ជនរងគ្រោះអាចដាក់ពាក្យប្តឹងដល់ជនល្មើសដែលបាន បង្កព្យសនកម្មមកលើខ្លួន ហើយផុតពីនោះមិនអាចដាក់ពាក្យប្តឹងបានឡើយ។ ក៏ប៉ុន្តែនៅតែមានករណីពិសេស ទៅលើបទឧក្រិដ្ឋមួយចំនួនដែលច្បាប់មិនបានកំណត់ពីអាជ្ញាយុកាលទេ ជាក់ស្តែងយោងតាមស្មារតីនៃក្រមនីតិ វិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើនៅថ្ងៃទី ១០ ខែសីហា ២០០៧ ត្រង់មាត្រា ៩ បានកំណត់អំពីប្រភេទនៃបទ ល្មើសធំៗមួយចំនួនដែលគ្មានអាជ្ញាយុកាលរួមមាន បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្ស ជាតិ និងបទឧក្រិដ្ឋសង្គ្រាម ដោយហេតុថាបទល្មើសទាំងនេះ មានចរិតលក្ខណៈបង្កគ្រោះថ្នាក់ដល់សង្គមនិង មនុស្សជាតិយ៉ាងធ្ងន់ធ្ងរហើយមិនអាចលើកលែងទោសបានឡើយ។ មានន័យថា ទោះបីជានៅក្រោយពេល ប្រព្រឹត្តអំពើល្មើសប៉ុន្មានឆ្នាំក៏ដោយ ក៏ស្ថាប័នដែលមានសមត្ថកិច្ចអាចធ្វើការចោទប្រកាន់ និងអាចយកជន ល្មើសមកកាត់ទោសតាមនីតិវិធីច្បាប់បានដដែល។[56]

[56] ណែនាំដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង**, ដកស្រង់ចេញពីសារណាបញ្ចប់ការសិក្សាប្រធានបទ បទល្មើសព្រហ្មទណ្ឌ ឆ្នាំ២០២២។

# ជំពូកទី ២
# ការទទួលខុសត្រូវ
# និង
# ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

# ជំពូកទី ២

# ការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

នៅក្នុងជំពូកនេះយើងនឹងធ្វើការសិក្សាទៅលើចំណុចសំខាន់ៗមួយចំនួនដែលទាក់ទងទៅនឹង ជនល្មើស និងការទទួលខុសត្រូវព្រហ្មទណ្ឌ (**ផ្នែកទី១**) និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ (**ផ្នែកទី២**)។ ដូចនេះ ថាតើជនល្មើសគឺជានរណា? ហើយត្រូវទទួលខុសត្រូវព្រហ្មទណ្ឌបែបណា? ហើយចុះបើមិនទទួលខុសត្រូវវិញ តើមានលក្ខខណ្ឌណាខ្លះដែលនាំឱ្យជនល្មើស ឬអ្នកប្រព្រឹត្តបទល្មើសនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌ? អាស្រ័យដូចនេះ ដើម្បីឱ្យកាន់តែច្បាស់សូមមកឈ្វេងយល់នៅចំណុចបកស្រាយខាងក្រោមនេះ។

## ផ្នែកទី១៖ ជនល្មើស និងការទទួលខុសត្រូវព្រហ្មទណ្ឌ

នៅត្រង់ផ្នែកនេះ មុនឈានដល់ការបកស្រាយអំពី ការទទួលខុសត្រូវព្រហ្មទណ្ឌ យើងក៏បានលើកយកអំពីជនល្មើស (១) មកធ្វើការសិក្សាផងដែរ ព្រោះថាដើម្បីឱ្យបុគ្គលមួយអាចទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាតែបុគ្គលនោះមានលក្ខខណ្ឌគ្រប់គ្រាន់ជាមុនសិន។ ហើយក្រោយពេលដែលយើងបានឈ្វេងយល់អំពីជនល្មើសរួចរាល់ នោះយើងនឹងឈានដល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនល្មើសនោះ (២)។

### ១. ជនល្មើស

ចំពោះជនល្មើស គឺជាបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តអំពើល្មើស ដែលអំពើល្មើសនោះគឺផ្ទុយពីច្បាប់បានហាមឃាត់។ ការប្រព្រឹត្តអំពើល្មើសរបស់បុគ្គលណាម្នាក់ គឺចាំបាច់ទាមទារឲ្យមានលក្ខខណ្ឌមួយចំនួន ដើម្បីអាចធ្វើជាមូលដ្ឋានក្នុងការវិនិច្ឆ័យ វែកញែក ព្រមទាំងឈានដល់ការកំណត់អំពីអត្ថិភាពនៃជនល្មើស ព្រោះថាមានអំពើល្មើសមួយចំនួនដែលបានប្រព្រឹត្តហើយ តែបែរជាមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌទៅវិញ អំពើល្មើសទាំងនោះអាចមានដូចជា ច្បាប់អនុញ្ញាត ឬការការពារស្របច្បាប់ ឬវិបល្លាសស្មារតីជាដើម។ ករណីនេះគឺមិនត្រូវចាត់ទុកថាមានទោស ឬមិនត្រូវចាត់ទុកថាជាជនល្មើសឡើយ។ ដូច្នេះត្រង់ចំណុចនេះយើងនឹងធ្វើការឈ្វេងយល់អំពីជនល្មើស ឬសញ្ញាណនៃជនល្មើស (១.១) និងលក្ខខណ្ឌនៃជនល្មើស (១.២)។

#### ១.១ សញ្ញាណនៃជនល្មើស

ជនល្មើស គឺជាជនទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មានន័យថា ជនល្មើសត្រូវបានគេប្រើប្រាស់ជាទូទៅសម្គាល់លើជនដែលបានប្រព្រឹត្តបទល្មើស។ ជនល្មើស គឺជាជនដែលបានប្រព្រឹត្តសកម្មភាពបង្កជាព្យសនកម្មដល់សណ្តាប់ធ្នាប់សាធារណៈ ឬប៉ះពាល់ដល់បុគ្គលដទៃ ហើយអំពើនោះជាអំពើខុសទៅនឹងច្បាប់ព្រហ្មទណ្ឌ។ គេហៅម្យ៉ាងទៀតថា ជនល្មើស គឺជាជនដែលបានចូលរួមប្រព្រឹត្តដោយចេតនាក្តី អចេតនាក្តី ទោះបីជាដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ជននោះនឹងត្រូវមានទោស។ ជនដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ (ក) ហៅថា **ចារី** ហើយអ្នកចូលរួមប្រព្រឹត្តដោយផ្ទាល់គេហៅថា **សហចារី** ឯការចូលរួមប្រព្រឹត្ត

ដោយប្រយោល(ខ) ហៅថា **អ្នកសមគំនិត** ឯអ្នកញុះញុងអោយមានបទល្មើសកើតឡើងហៅថា **អ្នកផ្តើមគំនិត**។

**ក. ជនល្មើសដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ (ចារី និងសហចារី)**

ចំពោះជនល្មើស ដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ អាចមានចាប់ពីម្នាក់ ឬច្រើននាក់។ ជនល្មើសដែលប្រព្រឹត្តល្មើសដោយផ្ទាល់តែម្នាក់ ឬច្រើននាក់ ត្រូវបានបែងចែកជា ២ ប្រភេទដូចជា ចារី **(ក.១)** ចារីក្នុងបទល្មើសសកម្ម **(ក.១.១)** ចារីក្នុងបទល្មើសអសកម្ម **(ក.១.២)** និងសហចារី **(ក.២)**។

**ក.១ ចារី**

ចារី គឺសំដៅដល់ជនដែលបានប្រព្រឹត្ត ឬបានប៉ុនប៉ងប្រព្រឹត្តបទល្មើស។ ដោយផ្អែកតាមមាត្រា ២៥ នៃក្រមព្រហ្មទណ្ឌបានចែងថា ត្រូវចាត់ទុកថាជាចារី ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។ ត្រូវចាត់ទុកថាជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម។ ចារីនៃបទល្មើស គឺជាជនដៃដល់ហើយជាអ្នកដែលប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ ឬជាជនដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ។ ចារី ត្រូវបានគេចាត់ទុកថា មានតួនាទីសំខាន់ណាស់ ព្រោះប្រសិនបើគ្មានអំពើល្មើសរបស់ចារីទេនោះ ក៏គ្មានបទល្មើសកើតឡើងដែរ។ **ឧទាហរណ៍ៈ** ឈ្មោះ **ក** បានដកកាំភ្លើងបាញ់សំដៅទៅរកក្បាលឈ្មោះ **ខ** បណ្តាលឱ្យស្លាប់ ដូចនេះឈ្មោះ **ក** ជាចារី។ ករណីមួយទៀត លោក **ខ** យកកាំបិតទៅចាក់លោក **ក** បណ្តាលឱ្យលោក **ក** ស្លាប់ ដូចនេះលោក **ខ** ជាចារី។

**ក.១.១ ចារីក្នុងបទល្មើសសកម្ម(ចេតនា)**

ចារីក្នុងបទល្មើសសកម្ម គឺជាអំពើដែលប្រព្រឹត្តដោយផ្ទាល់របស់ចារី ដូចជាការដែលជនល្មើសយកកាំបិតទៅចាក់លើជនរងគ្រោះឱ្យស្លាប់ ឬជនចូលទៅលួចលុយគេក្នុងផ្សារជាដើម។ ជាក់ស្តែងករណីមួយដែលមានបុរសម្នាក់បានប្រើកាំបិតចាក់ទៅលើនារីម្នាក់ ដោយសារទាស់ពាក្យសម្តីគ្នាបណ្តាលឱ្យនារីរងគ្រោះស្លាប់។ ចំពោះសកម្មភាពបែបនេះ គឺជាការប្រព្រឹត្តផ្ទាល់របស់ចារី ហើយចារីនឹងត្រូវចោទប្រកាន់ពីបទឃាតកម្មដោយចេតនា និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ មាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០១០[57]។

**ក.១.២ ចារីក្នុងបទល្មើសអសកម្ម(អចេតនា)**

ចារីក្នុងបទល្មើសអកម្ម គឺជាកាតព្វកិច្ចរបស់ចារីផ្ទាល់ដែលច្បាប់បានកំណត់ ដោយតម្រូវឲ្យចារីធ្វើនូវសកម្មភាពជាកំណត់ណាមួយ ប៉ុន្តែដោយការមិនយកចិត្តទុកដាក់ និងភ័យខ្លាចចារីពុំបានបំពេញ ឬបំពេញមិនបានគ្រប់លក្ខខណ្ឌ នោះនឹងនាំឲ្យចារីត្រូវទទួលខុសត្រូវចំពោះការមិនបំពេញកាតព្វកិច្ច ដែលច្បាប់ព្រហ្មទណ្ឌបានតម្រូវនោះ។ ជាក់ស្តែងដូចករណីដែល ឈ្មោះ **សុខ** បានដឹងថាឈ្មោះ សៅរ៍ បានធ្វើបាប និង បៀតបៀនខាង

[57] នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោក សាស្ត្រាចារ្យ **ហ៊ាង ឡេង**។

ផ្លូវភេទលើក្មេងស្រីឈ្មោះ **សុខនី** ដែលជាអនីតិជនអាយុក្រោម ១៥ឆ្នាំ ហើយមិនបានប្ដឹងបរិហារដល់មន្ត្រីមូលដ្ឋាន ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតនោះទេ។ ដោយការមិនបំពេញកាតព្វកិច្ចចំពោះការមិនប្ដឹងបរិហារអំពីការធ្វើបាបអនីតិជនយ៉ាងនេះ ជាហេតុនាំឱ្យឈ្មោះ **សុខ** នឹងត្រូវទទួលរងនូវការផ្ដន្ទាទោស ពីព្រោះច្បាប់បានកំណត់ថា រាល់បុគ្គលទាំងអស់ដែលបានដឹងពីការធ្វើបាបអនីតិជនអាយុក្រោម១៥ឆ្នាំ គឺមានកាតព្វកិច្ចប្ដឹងបរិហារពីការធ្វើបាបអនីតិជននោះទៅកាន់អាជ្ញាធរតុលាការ ឬអាជ្ញាធរសមត្ថកិច្ចផ្សេងទៀត[58] ដូច្នេះប្រសិនជាដឹងថាមានការធ្វើបាបអនីតិជនអាយុក្រោម១៥ឆ្នាំហើយ តែឈ្មោះ **សុខ** ដែលជាចារីមិនបានបំពេញកាតព្វកិច្ចប្ដឹងបរិហារ នោះនាំឱ្យចារីនឹងត្រូវទទួលរងនូវការផ្ដន្ទាទោសព្រហ្មទណ្ឌចំពោះអំពើអកម្មរបស់ខ្លួនជាពុំខាន។

**ក.២ សហចារី**

សហចារី គឺសំដៅលើជនល្មើសដែលបានចូលរួមដោយផ្ទាល់ក្នុងការប្រព្រឹត្តបទល្មើស មានន័យថាដើម្បីអាចចាត់ទុកថាជា សហចារីបានលុះត្រាតែជនល្មើសនោះបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់។ ជាក់ស្ដែងក្រមព្រហ្មទណ្ឌក៏បានធ្វើការកំណត់ចំពោះជនល្មើសច្រើនរូបដែលបានប្រព្រឹត្តបទល្មើសរួមគ្នាដែរថា ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀង ប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ យ៉ាងណាមិញការព្រមព្រៀងដែលមានបុគ្គលច្រើននាក់ ដើម្បីប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ក្នុងករណីដែលច្បាប់បានចែងទុក ក៏ត្រូវចាត់ទុកថាជាសហចារីផងដែរ[59]។

ដូចឧទាហរណ៍ករណី ឈ្មោះ **ក** និងឈ្មោះ **ខ** ជាមិត្តភក្ដិនឹងគ្នាដោយសារដាច់លុយចាយពួកគេបានព្រមព្រៀងបបួលគ្នាចូលទៅលួចទាក់ឆ្កែ អ្នកនៅក្នុងភូមិវេលាយប់ ដោយបានរៀបចំនូវឧបករណ៍មានខ្សែលួសសម្រាប់ទាក់កឆ្កែ។ ឈ្មោះ **ក** និងឈ្មោះ **ខ** បានលបចូលទៅក្នុងផ្ទះរបស់អ្នកភូមិដោយបម្រុងនឹងធ្វើសកម្មភាពបម្រុងទាក់ឆ្កែ ស្រាប់តែម្ចាស់ផ្ទះមកទាន់ ហើយចាប់ឈ្មោះ **ក** និងឈ្មោះ **ខ** ប្រគល់ឲ្យសមត្ថកិច្ចមូលដ្ឋាន ដើម្បីធ្វើការសាកសួរ។ ចំពោះករណីនេះ បើទោះបីជាឈ្មោះ **ក** និងឈ្មោះ **ខ** មិនទាន់បានទាក់ឆ្កែអ្នកភូមិក៏ពិតមែនប៉ុន្តែការព្រមព្រៀងក្នុងបំណងដើម្បីធ្វើសកម្មភាពល្មើស និងការត្រៀមរៀបចំជាឧបករណ៍របស់ពួកគេទាំងពីរ គឺបានស្ដែងឡើងនូវគំនិតទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសរបស់ពួកគេទាំងពីរយ៉ាងពិតប្រាកដមែន ហើយម្យ៉ាងវិញទៀត ពួកគេទាំងពីរក៏មិនបានបញ្ឈប់សកម្មភាពដោយស្ម័គ្រចិត្តនោះទេ គឺដោយសារការអាក់ខានដោយកាលៈទេសៈក្រៅឆន្ទៈ របស់ពួកគេទាំងពីរ គឺដោយសារតែម្ចាស់ផ្ទះបានតាមទាន់។

ហើយម្យ៉ាងទៀត ការធ្វើឱ្យស្លាប់អ្នកដទៃដោយសារអចេតនាបង្កឡើងដោយរថយន្តច្រើនគ្រឿង គឺគេក៏អាចចាត់ទុកអ្នកបើកបរយានយន្តទាំងអស់នោះថាជាសហចារីបានដែរ។ **ឧទាហរណ៍៖** រថយន្តបីគ្រឿងបានបើក

[58] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥៣០។

[59] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៦។

បរប្រណាំងគ្នា ហើយរថយន្តទី១ក៏បានប៉ះនឹងនារីម្នាក់កំពុងដើរឆ្លងផ្លូវ បណ្តាលឱ្យដួល ហើយរថយន្តទី២ និងទី៣ បានកិនពីលើខ្លួននារីនោះបន្ថែមបណ្តាលឱ្យនារីនោះស្លាប់បាត់បង់ជីវិត។ ជាក់ស្តែងមិនមានភស្តុតាងណាមួយអាចបញ្ជាក់ថានារីនោះស្លាប់ដោយសាររថយន្តមួយណាទេ តែទោះជាយ៉ាងណា ចំពោះករណីនេះ អ្នកបើកបរទាំងបីខាងលើត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌពីបទ បើកបរបង្កឱ្យស្លាប់អ្នកដទៃដោយអចេតនា។[60]

### ខ. ជនល្មើសដែលបានប្រព្រឹត្តបទល្មើសដោយប្រយោល

ជនមួយចំនួនជាអ្នករៀបចំគម្រោង ឬផ្តើមគំនិតមិនបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់នោះទេ ប៉ុន្តែពួកគេបានចូលរួមប្រព្រឹត្តបទល្មើសដោយប្រយោល តាមរយៈសកម្មភាពផ្សេងៗដូចជា ការបញ្ជាក្នុងគោលបំណងចង់ឲ្យជនណាម្នាក់ប្រព្រឹត្តនូវបទល្មើសណាមួយ ឬជួយសម្រួល និងផ្តល់ជាមធ្យោបាយ ដើម្បីឲ្យបទល្មើសកើតឡើងដោយអ្នកទាំងអស់នោះរួមមានដូចជា អ្នកបញ្ជា ឱ្យរៀបចំគម្រោង ការផ្តល់ជាគំនិតហៅថា អ្នកផ្តើមគំនិត(**ខ.១**) និងអ្នកដែលផ្តល់ជាសម្ភារៈហៅថា អ្នកសមគំនិត(**ខ.២**)។

#### ខ.១ អ្នកផ្តើមគំនិត

ដើម្បីអាចចាត់ទុកជាជនល្មើស ឬចារីបាន លុះត្រាតែជននោះបានប្រព្រឹត្តអំពើល្មើសដោយផ្ទាល់ ក៏ប៉ុន្តែចំពោះជនមួយជំពូកទៀត មិនបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសដោយផ្ទាល់នោះទេ ពោលគ្រាន់តែជាអ្នកមានគំនិតយោបល់រៀបចំផ្តើមនូវឧបាយកល និងគម្រោងធ្វើសកម្មភាពតែប៉ុណ្ណោះ នេះគេហៅថាជា អ្នកផ្តើមគំនិត។ អ្នកផ្តើមគំនិតនេះ អាចជាអ្នកចូលរួមប្រព្រឹត្ត និងបញ្ជាដោយផ្ទាល់ខ្លួន ជួនកាលគេមិនបានចូលរួមទេដោយគ្រាន់តែបញ្ជាតាមរយៈទូរស័ព្ទ ឬក៏មធ្យោបាយផ្សេងទៀតតែប៉ុណ្ណោះ[61]។

ក្រមព្រហ្មទណ្ឌក៏បានបញ្ញត្តិទុកជាមុនអំពីការផ្តើមគំនិត ដើម្បីបង្កើតជាបទល្មើសផងដែរ ដោយមាត្រា ២៨ បានចែងថា ត្រូវចាត់ទុកថាជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែល៖

- ជម្រុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយការណែនាំ ឬការបញ្ជា។

- បង្កឲ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជាអំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា(ដូចករណីមន្ត្រីនគរបាលយុត្តិធម៌ បានបញ្ជាឱ្យភ្នាក់ងាររបស់ខ្លួន ធ្វើទារុណកម្មលើជនសង្ស័យដែលត្រូវបានឃាត់ខ្លួន) ឬអំណាចរបស់ខ្លួន។

អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬ បទមជ្ឈិមត្រូវបាន សម្រេច ឬបានប៉ុនប៉ង។ អ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។ ធាតុផ្សំនៃការផ្តើមគំនិតមាន៖

**សត្យានុម័តនៃការផ្តើមគំនិត៖** សំដៅលើការជម្រុញតាមការណែនាំ ឬបញ្ជា ការផ្តល់ជាអំណោយដោយ

---

[60] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង សាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០២២។

[61] នីតិព្រហ្មទណ្ឌទូទៅ រៀបចំដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង។**

ការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។

**អន្តនោម័តនៃការផ្តើមគំនិត៖** អ្នកផ្តើមគំនិតត្រូវមានបំណងប្រព្រឹត្តអំពើផ្តើមគំនិត មានន័យថាអ្នកផ្តើមគំនិតបានដឹងថា អំពើរបស់ចារីជាបទល្មើសព្រហ្មទណ្ឌ ហើយខ្លួននៅតែមានចេតនាផ្តើមគំនិតចង់ឲ្យបទល្មើសនេះកើតឡើង។

ដើម្បីឲ្យអ្នកផ្តើមគំនិតមានទោសលុះត្រាតែ៖ **អំពើចម្បងជាបទល្មើស៖** ហេតុដូចនេះ ដើម្បីឲ្យមានការផ្តន្ទាទោសបាន លុះត្រាតែមានករណីដូចជា លោក **ណាក់** បានបញ្ជាឲ្យលោក **នួន** ទៅសម្លាប់លោក **ណា**។ តែប្រសិនបើលោក **នួន** ពុំបានទៅសម្លាប់លោក **ណា** នោះទេ មានន័យថា លោក **នួន** ពុំមានទោសទេ ព្រោះពុំទាន់មានបទល្មើសកើតឡើងនៅឡើយទេ។ ដូច្នេះ អ្នកផ្តើមគំនិតក៏ពុំមានទោសដែរ ករណីនេះ អំពើរបស់លោក **ណាក់** ពុំមែនជាការផ្តើមគំនិតដែលអាចត្រូវផ្តន្ទាទោសបានទេ តែអំពើនេះ អាចត្រូវផ្តន្ទាទោសក្រោមឈ្មោះបទល្មើសមួយផ្សេងទៀត ពោលគឺ បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍[62] ដែលជាបទល្មើសដាច់ដោយឡែក។

**ខ.២ អ្នកសមគំនិត**

ចំពោះអ្នកសមគំនិត គឺសំដៅលើបុគ្គលណាមួយដែលបានជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយតាមរយៈការផ្តល់ជាជំនួយសម្ភារៈ និងការឧបត្ថម្ភ[63]។ មានន័យថា អ្នកសមគំនិត សំដៅដល់បុគ្គលដែលបានជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយផ្តល់នូវជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន ពោលគឺជាជនដែលផ្តល់ជាមធ្យោបាយ តាមរយៈណាក៏ដោយ ដើម្បីសម្រួលដល់ការប្រព្រឹត្តបទល្មើសអនុវត្តទៅដោយរលូន។ **ឧទាហរណ៍៖** នៅក្នុងបទល្មើសលួចមានបុគ្គលពីរនាក់ ឈ្មោះ **ក** និង **ខ** បានធ្វើសកម្មភាពលួចឡានរបស់លោក **គ** ដោយម្នាក់ឈ្មោះ **ក** ជាអ្នកមើលផ្លូវជុំវិញ ដើម្បីឱ្យឈ្មោះ **ខ** ធ្វើសកម្មភាពលួចឡាន នៅពេលដែលគ្មានមនុស្សនៅទីនោះ។ ករណីនេះ ឈ្មោះ **ក** នឹងត្រូវបានចាត់ទុកជាអ្នកសមគំនិត ព្រោះថាសកម្មភាពបែបនេះ ជាអំពើដែលជួយសម្រួលឱ្យការប្រព្រឹត្តបទល្មើសបានសម្រេច ហើយឈ្មោះ **ខ** គឺជាចារី។ អ្នកសមគំនិត គឺមានការចូលរួមដោយប្រយោល ដោយការផ្តល់ជាមធ្យោបាយ ការបង្គាប់បញ្ជា ការផ្តល់ព័ត៌មាន និងជួយបង្កលក្ខណៈងាយស្រួល។ ទោះបីជាអ្នកសមគំនិតមិនបានចូលរួមប្រព្រឹត្តដោយផ្ទាល់ក៏ដោយ ប៉ុន្តែអ្នកសមគំនិតត្រូវទទួលទោសដូចគ្នាទៅនឹងចារីផងដែរ ដោយផ្អែកតាមមាត្រា ២៩ កថាខណ្ឌទី៣ ក្រមព្រហ្មទណ្ឌ។ ការសមគំនិតត្រូវបំពេញលក្ខខណ្ឌ ៣ ដើម្បីឲ្យមានទោសគឺ ៖

**អំពើចម្បងជាបទល្មើស៖** អំពើដែលចារីប្រព្រឹត្តត្រូវតែជាអំពើល្មើសក្នុងបទឧក្រិដ្ឋ ឬមជ្ឈិម។ **ឧទាហរណ៍** លោក **ក** បានជួយសម្រួលឱ្យលោក **ខ** ប្រព្រឹត្តបទល្មើសឃាតកម្ម ឬបទហិង្សា បើបទល្មើសបានសម្រេច ឬមិន

[62] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៩៤ និង៤៩៥។

[63] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៩ កថាខណ្ឌទី១។

បានសម្រេចចូលដល់ការប៉ុនប៉ង នោះលោក **ក** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ សូមបញ្ជាក់ថាតាមរយៈការលើឡើងខាងលើ ចំពោះអំពើល្មើសជាបទលហុ គឺមិនត្រូវឲ្យទទួលទោសនោះទេ។

**ធាតុផ្សំសត្យានុម័តនៃការសមគំនិត៖**ការផ្តល់ជាជំនួយ ឬការឧបត្ថម្ភ។**ឧទាហរណ៍៖** ដូចករណីលោក **ក** បានផ្តល់ជាទីកន្លែង និងជួយមើលផ្លូវឲ្យឧក្រិដ្ឋជនមួយក្រុមដែលជាគ្នីគ្នារបស់ខ្លួនក្នុងការធ្វើសកម្មភាពចាប់ជំរិតក្មេងៗដើម្បីទារប្រាក់ពីឪពុកម្តាយរបស់ក្មេងៗទាំងនោះ។

**ធាតុផ្សំអត្តនោម័តនៃការសមគំនិត៖** ចេតនានៃការសមគំនិត គឺការធ្វើសកម្មភាពដោយមានគម្រោងការ ឬជាការដែលមានបំណងចូលរួមក្នុងការប្រព្រឹត្តបទល្មើសដោយប្រយោលជាមួយអ្នកដទៃ។ ឬម្យ៉ាងទៀតគឺថា ការសមគំនិត ត្រូវតែកើតចេញពីចេតនាទុច្ចរិតរបស់អ្នកសមគំនិតក្នុងការ ជំរុញ ឬបង្កឱ្យបទល្មើសកើតឡើង។ និយាយជារួម អ្នកសមគំនិតគឺជាជនដែលមានបំណងប្រព្រឹត្តអំពើសមគំនិត ឬឱ្យច្បាស់ជាងនេះទៅទៀតគឺថា អ្នកសមគំនិតបានដឹងថា អំពើរបស់ចារី ជាបទល្មើសហើយខ្លួននៅតែមានបំណងចង់ចូលរួមជាមួយចារីទៀត។ ចំពោះចេតនា ឬបំណងនៃបទសមគំនិតជានិច្ចកាលនៅតែជាកត្តាចាំបាច់ សម្រាប់បទសមគំនិត។

ហេតុដូចនេះ ប្រសិនបើការផ្តល់មធ្យោបាយ ដោយសុទ្ធចិត្តទៅឱ្យជនម្នាក់ ដែលក្រោយមកបានយកមធ្យោបាយនោះទៅប្រព្រឹត្តបទល្មើស គឺពុំអាចចាត់ទុកថាជាការសមគំនិតដែលត្រូវទទួលការផ្តន្ទាទោសឡើយ។ **ឧទាហរណ៍៖** បុគ្គលម្នាក់បានឱ្យរថយន្តរបស់ខ្លួនទៅមិត្តភក្តិខ្ចីប្រើប្រាស់ ប៉ុន្តែមិត្តភក្តិបែរ ជាឆ្លៀតយករថយន្តនោះ ទៅធ្វើជាមធ្យោបាយ ដើម្បីបើកបុកសម្លាប់គូសត្រូវរបស់ខ្លួនទៅវិញ ។[64]

គោលការណ៍សំខាន់មួយក្នុងការពិចារណាគឺ ចារី និងសហចារី ដែលបានប្រព្រឹត្តបទល្មើសណាមួយ ឬច្រើន ត្រូវតែមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់។ ចំណែកឯបទសមគំនិតវិញ គឺមិនចាំបាច់មានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ទេ ប៉ុន្តែត្រូវមានធាតុពិតពិសេស៣គឺ : អំពើចម្បងដែលត្រូវផ្តន្ទាទោស(បទឧក្រិដ្ឋ ឬបទមជ្ឈិមបានសម្រេច ឬត្រូវបានប៉ុនប៉ង) អំពើប្រព្រឹត្តជាក់ស្តែងនៃបទល្មើសសមគំនិត និងចេតនានៃបទសមគំនិត[65]។

**សូមបន្ថែមថា** ដើម្បីធ្វើឱ្យការផ្តើមគំនិត និងការសមគំនិតមានទោស ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត និងការសមគំនិត ត្រូវមានមុន ឬស្របពេលជាមួយនឹងអំពើចម្បង។ ក៏ប៉ុន្តែ ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត និងការសមគំនិតអាចកើតឡើងនៅក្រោយអំពើល្មើសបាន បើសិនបើអ្នកផ្តើមគំនិត ឬអ្នកសមគំនិត និងចារីបានព្រមព្រៀងគ្នាជាមុន។ ក្នុងករណីនេះ ត្រូវរកភស្តុតាងមកបញ្ជាក់ពីការឃុបឃិតព្រមព្រៀងគ្នាជាមុន រវាងអ្នកផ្តើមគំនិត ឬអ្នកសមគំនិត និងចារី។ **ឧទាហរណ៍** ៖ លោក **ក** និងលោក **ខ** បានព្រមព្រៀងគ្នាថា លោក ក នឹងរង់ចាំជូន លោក **ខ**(ចារី) រត់គេចខ្លួនចេញពីកន្លែងកើតហេតុ នៅពេលដែលលោក **ខ** បានប្រព្រឹត្តបទល្មើសរួច

[64] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង សាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០២២។

[65] សៀវភៅនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង**។

ហើយភ្លាម ។ ប្រសិនបើពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ អំពីការឃុបឃិតព្រមព្រៀងគ្នាជាមុនទេ អំពើរបស់ជនដែលបានសម្រួលដល់បទល្មើសក្រោយពេលបានប្រព្រឹត្តបទល្មើសរួចហើយ អាចចាត់ចូលជាបទល្មើសដោយឡែកទៅវិញ។[66]

មួយវិញទៀត តាមរយៈមាត្រា ២៨ កថាខណ្ឌទី២ និងមាត្រា២៩ កថាខណ្ឌទី២ នៃក្រម ព្រហ្មទណ្ឌ បានកំណត់នូវលក្ខខណ្ឌនៃការផ្ដើមគំនិត និងការសមគំនិតដែលអាចត្រូវទទួលទោសបាន លុះត្រាតែ **បទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង**។ ត្រង់នេះមានន័យថា ដើម្បីឱ្យការផ្ដើមគំនិត និងការសមគំនិតអាចទទួលការផ្តន្ទាទោសបាន លុះត្រាតែអំពើចម្បងជាបទល្មើស ទោះបានសម្រេច ឬត្រឹមការប៉ុនប៉ងក៏ ដោយ។ ដូចនេះការសមគំនិត និងការផ្ដើមគំនិតឱ្យប្រព្រឹត្តអំពើដែលច្បាប់មិនបានចាត់ទុកជាបទល្មើស គឺមិនមានទោសទេ។ **ឧទាហរណ៍៖** លោក **ខា** បានញុះញង់ឱ្យលោកស្រី **ខុំ** សម្លាប់ខ្លួន ដូចនេះពុំអាចត្រូវបានផ្តន្ទាទោសទេ ព្រោះការធ្វើអត្តឃាតមិនមែនជាបទល្មើសឡើយ តាមច្បាប់កម្ពុជាបច្ចុប្បន្ន។

## ១.២ លក្ខខណ្ឌនៃជនល្មើស

ក្នុងការវិនិច្ឆ័យជនណាម្នាក់ ឬក៏ក្នុងការសន្មតថាបុគ្គលណាម្នាក់ជាជនល្មើស ពោលគឺត្រូវគោរពតាមលក្ខខណ្ឌដែលច្បាប់កំណត់ជាមុនសិន។ ជាការពិតណាស់ ដើម្បីធ្វើការសន្មតថាបុគ្គលណាមួយជាជនល្មើស ចាំបាច់ត្រូវគោរពនូវលក្ខខណ្ឌដែលច្បាប់បានកំណត់មួយចំនួនដូចជា ជនល្មើសជាមនុស្ស**(ក)** កំពុងរស់រានមានជីវិត**(ខ)** មានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ**(គ)** និងមានអាយុតាមការកំណត់របស់នីតិព្រហ្មទណ្ឌ**(ឃ)**។

### ក. ជនល្មើសជាមនុស្ស

ជនល្មើសជាមនុស្សដែលជារូបវ័ន្តបុគ្គល គឺមានន័យថាមានតែមនុស្សប៉ុណ្ណោះ ដែលជាកម្មវត្ថុតាមច្បាប់ព្រហ្មទណ្ឌបានកំណត់ថាជាជនល្មើស ហើយមានតែមនុស្សប៉ុណ្ណោះ ដែលត្រូវទទួលខុសត្រូវនូវអំពើល្មើសដែលខ្លួនបានប្រព្រឹត្ត។ មានន័យថា គេមិនអាចយកសត្វមកធ្វើជាជនល្មើសទេ ឬក៏គេមិនយកសត្វមកដាក់ទោសព្រហ្មទណ្ឌបានឡើយ ពោលតាមច្បាប់ព្រហ្មទណ្ឌគឺមានតែមនុស្សប៉ុណ្ណោះដែលអាចកំណត់ថាជាជនល្មើស។

### ខ. កំពុងរស់នៅមានជីវិត

ក្នុងបទល្មើសព្រហ្មទណ្ឌគ្មានច្បាប់មួយណាដែលចែងកំណត់ថាត្រូវដាស់សាកសព ដែលបានស្លាប់ទៅហើយ ឱ្យមកទទួលខុសត្រូវចំពោះអំពើដែលគាត់បានប្រព្រឹត្តនៅពេលដែលគាត់នៅរស់នោះទេ។ ហេតុនេះបានជាស្មារតីច្បាប់កំណត់ថាមានតែបុគ្គលដែលមានជីវិតប៉ុណ្ណោះ ទើបកំណត់ថាត្រូវតែទទួលខុសត្រូវចំពោះអំពើល្មើសផ្ទាល់ខ្លួនដែលបានប្រព្រឹត្ត។

[66] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង សាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០២២។

ចំណែកឯបុគ្គលដែលបានបាត់បង់ជីវិត បើទោះបីជាបុគ្គលនោះបានប្រព្រឹត្តសកម្មភាពល្មើសយ៉ាងណាក្តីក៏មិនមានការចោទប្រកាន់ណាមួយអាចកើតឡើងឡើយ ពីព្រោះថា ជនរងគ្រោះដែលបានរងព្យសនកម្មមិនអាចប្តឹងជនល្មើសបានទេឡើយ ដោយហេតុថា បណ្តឹងអាជ្ញាត្រូវផុតរលត់ដោយ សារមរណភាពនៃជនល្មើសគឺជនដែលប្រព្រឹត្តបានស្លាប់បាត់បង់ជីវិតទៅហើយ នេះដោយផ្អែកតាមមាត្រា ៧ ចំណុចទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ឧទាហរណ៍៖ លោក ខា បានប្រព្រឹត្តបទល្មើស បន្ទាប់មកលោក ខា ក៏បានស្លាប់ ដូចនេះបណ្តឹងអាជ្ញាត្រូវបានផុតរលត់។

**គ. មានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ**

សូមបញ្ជាក់ថា មិនមែនគ្រប់បុគ្គលទាំងអស់ដែលមានជីវិតរស់នៅសុទ្ធសឹង តែត្រូវទទួលខុសត្រូវចំពោះអំពើល្មើសដែលខ្លួនបានធ្វើនោះទេ។ ដោយច្បាប់ព្រហ្មទណ្ឌបានបញ្ញត្តិយ៉ាងជាក់ច្បាស់ទាក់ទងទៅនឹងអត្ថិភាព និងនត្ថិភាពនៃសមត្ថភាពបុគ្គលក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ព្រមទាំងបានកំណត់នូវលក្ខខណ្ឌអាយុរបស់ជនល្មើស និងបុគ្គលិកលក្ខណៈ ព្រមទាំងកម្រិតនៃការយល់ដឹងខុសត្រូវរបស់ជនល្មើស ដែលបានប្រព្រឹត្តបទល្មើស ក្នុងគោលបំណងជៀសវាងការផ្តន្ទាទោសទៅលើជនណាម្នាក់ ដោយពុំត្រឹមត្រូវតាមយុត្តាធិការ ឬក៏ផ្ទុយពីគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌជាដើម។ **ឧទាហរណ៍៖** ជនវិបល្លាសស្មារតី ឬជនដែលមានអាយុក្រោម ១៤ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ឬមិនត្រូវបានចាត់ទុកជាជនល្មើសនោះទេ។

**ឃ. មានអាយុតាមការកំណត់របស់នីតិព្រហ្មទណ្ឌ**

គ្រប់នីតិជនទាំងអស់ត្រូវមានការទទួលខុសត្រូវព្រហ្មទណ្ឌដែលក្រមព្រហ្មទណ្ឌបានកំណត់ថានីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី១៨ឆ្នាំឡើងទៅ។ តែសម្រាប់អនីតិជនវិញ តុលាការអាចប្រកាសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌបានទៅលើអនីតិជនអាយុចាប់ពី១៤ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈ របស់អនីតិជនតម្រូវ គឺមានន័យថាអនីតិជនដែលបានប្រព្រឹត្តបទល្មើសមានកាយសម្បទាធំដំបង និងមានការយល់ដឹងពីសកម្មភាពដែលខ្លួនបានប្រព្រឹត្ត ហើយយល់ដឹងពីទំហំព្យសនកម្មដែលខ្លួនបង្កផងដែរ។

ហេតុនេះហើយ លក្ខខណ្ឌអាយុរបស់ជនល្មើសដែលជានីតិជនក្តី និងជាអនីតិជនក្តីគឺជារឿងសំខាន់ដើម្បីឈានដល់ការកំណត់ឲ្យបានច្បាស់លាស់ថា តើជនល្មើសអាយុចាប់ពីប៉ុន្មានឆ្នាំឡើងទៅដែលអាចឃាត់ខ្លួន និងជាកម្មវត្ថុនៃការផ្តន្ទាទោស ចំពោះការប្រព្រឹត្តបទល្មើសបាន។

## ២. ការទទួលខុសត្រូវព្រហ្មទណ្ឌ

តាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌបានចែងថា បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ ដោយបញ្ញត្តក្នុងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។ នៅ

ត្រង់នេះមានន័យថាកាលណាជនណាម្នាក់បានប្រព្រឹត្តបទល្មើស ឬបានប្រព្រឹត្តអំពើល្មើស ជនម្នាក់នោះនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ពោលគឺពុំអាចឱ្យអ្នកដទៃមកទទួលខុសត្រូវជំនួសខ្លួនបានឡើយ។ ចំពោះមូលហេតុដែលពុំអាចឱ្យអ្នកដទៃមកទទួលខុសត្រូវជំនួសខ្លួន ដោយសារតែគោលដៅនៃការដាក់ទណ្ឌកម្ម គឺដើម្បីធ្វើការកែប្រែជនដែលបានប្រព្រឹត្តបទល្មើស ឱ្យបានដឹងអំពីកំហុសរបស់ខ្លួន ហើយនឹងធ្វើឱ្យជននោះមិនចង់ប្រព្រឹត្តម្តងទៀត។ ផ្ទុយទៅវិញ ច្បាប់អាចអនុញ្ញាតឲ្យមានការទទួលខុសត្រូវរដ្ឋប្បវេណីចំពោះអំពើរបស់អ្នកដទៃដូចជា ការទទួលខុសត្រូវរបស់ឪពុកម្តាយ ចំពោះកូនដែលជាអនីតិជន និងការទទួលខុសត្រូវរបស់និយោជក ពីអំពើរបស់និយោជិកជាដើម។

ម្យ៉ាងទៀតគេអាចនិយាយបានថា ការទទួលខុសត្រូវព្រហ្មទណ្ឌជាកាតព្វកិច្ចដើម្បីឆ្លើយតបទៅនឹងអំពើប្រព្រឹត្តនៃបទល្មើស។[67] ការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានចែកចេញជា ២ ប្រភេទដូចជា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនល្មើសជារូបវន្តបុគ្គល **(២.១)** និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល **(២.២)** ។

## ២.១ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនល្មើសជារូបវន្តបុគ្គល

រូបវន្តបុគ្គល គឺជាបុគ្គលដែលមានរូបពិតៗ ឬជាមនុស្សពិតៗ ផ្ទុយពីនីតិបុគ្គលដែលជាមនុស្សសន្មត់តាមរបៀបច្បាប់។ ចំពោះជនល្មើសជារូបវន្តបុគ្គល ដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌត្រូវចែកចេញជា ២ មានដូចជា ជនល្មើសជានីតិជន **(ក)** និងជនល្មើសជាអនីតិជន **(ខ)**។

### ក. ជនល្មើសជានីតិជន

ដោយគោរពតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា២០០៩ បានចែងថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។ តាមសន្ធានុក្រមផ្នែករដ្ឋប្បវេណីកម្ពុជា២០០៧ បានឱ្យនិយមន័យនៃនីតិជនថា នីតិជនសំដៅទៅលើជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។ ត្រង់នេះមានន័យថា ជនណាដែលមានអាយុ ១៨ ឆ្នាំឡើង ហើយបានប្រព្រឹត្តបទល្មើស ជននោះត្រូវទទួលខុសត្រូវយ៉ាងពេញលេញចំពោះអំពើល្មើសរបស់ខ្លួន។

### ខ. ជនល្មើសជាអនីតិជន

ជាគោលការណ៍ គេមិនអាចឲ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួន ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ តាមធម្មតាបុគ្គលណាបានធ្វើឱ្យអ្នកដទៃស្លាប់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តែប្រសិនបើក្មេងមានអាយុ ១០ ឆ្នាំ ម្នាក់បានចាក់សម្លាប់ក្មេងម្នាក់ទៀត ក្មេងដែលបានប្រព្រឹត្តអំពើល្មើសមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ដោយសារតែក្មេង ១០ ឆ្នាំ នោះមិនមានសមត្ថភាពដឹងខុសត្រូវអំពើរបស់ខ្លួនឡើយ។

---

[67] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់ឆ្នាំទី២។

ដោយគោរពតាមមាត្រា ៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ ២០១៦ អំពីការកំណត់អាយុ បានចែងថា អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្ត បទល្មើស។ ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀត ដែលអាចបញ្ជាក់បានអំពីកំណើត។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាព ច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន។ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ មាត្រា ៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

តាមសន្ធានុក្រមផ្នែករដ្ឋប្បវេណីកម្ពុជា២០០៧ បានឱ្យនិយមន័យនៃ អនីតិជន[68]ថា អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ឆ្នាំ។ ចំពោះការទទួលខុសត្រូវរបស់ព្រហ្មទណ្ឌរបស់អនីតិជននេះ អនីតិជនត្រូវបានចែកចេញជា ២ ប្រភេទដូចជា អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ **(ខ.១)** និងអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ **(ខ.២)**។

**ខ.១ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ**

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ មិនអាចត្រូវទទួលរងនូវការផ្តន្ទាទោសណាមួយឡើយ ទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយ។ ដូច្នេះនៅពេលដែលអនីតិជនមានអាយុក្រោម ១៤ ឆ្នាំ បានប្រព្រឹត្តបទល្មើសណាមួយ អនីតិជននោះពុំទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ អនីតិជនអាយុតិចជាង ១៤ ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះទៅឱ្យ ឪពុកម្តាយ អ្នកអាណាព្យាបាល ឬបើគ្មាន ត្រូវប្រគល់ទៅឱ្យមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ[69]។ គ្រប់អំពើដែលជាបទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអនីតិជនអាយុក្រោម ១៤ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។[70]អនីតិជនមានអាយុក្រោម ១៤ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់។[71]ក្នុងករណីអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញា ត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវ

[68] សន្ធានុក្រមផ្នែករដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, លេខរៀង ១៨៧។

[69] ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧, មាត្រា ២១២។

[70] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ កក្កដា ២០១៦ មាត្រា ១៤។

[71] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ កក្កដា ២០១៦ មាត្រា ១៤។

ប្រគល់អនីតិជនទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម។[72]

**ខ.២ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ**

សម្រាប់អនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ តុលាការអាចប្រកាសទណ្ឌកម្មបាន ចំពោះទណ្ឌកម្មដែលក្រមព្រហ្មទណ្ឌសំដៅដល់នោះគឺ ទោស។ ដោយគោរពតាមមាត្រា ៣៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានចែងថា តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ[73]។ មានន័យថា តុលាការត្រូវថ្លឹងថ្លែងពាក់ព័ន្ធនឹងកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ឬបុគ្គលលក្ខណៈរបស់អនីតិជនដែលប្រព្រឹត្តល្មើសនោះ មុនឈានដល់ការសម្រេចផ្តន្ទាទោស ឬក៏មិនផ្តន្ទាទោស ព្រោះដោយមូលហេតុថា អនីតិជនដែលបានប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ[74]។ ចំពោះប្រភេទនៃវិធានការខាងលើមានចែងក្នុងមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ដែលមានដូចជា៖

- ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។
- ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។
- ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។
- ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។
- ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។[75]

បើនៅក្នុងករណីដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ពត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ។[76] ការទទួលខុសត្រូវរបស់អនីតិជន ដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ គឺនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល គ្រាន់តែការទទួលមានកម្រិតស្រាលជាងនីតិជន។

ដោយផ្អែកតាមមាត្រា ១៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦ បានចែងថា នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ តែក្នុងករណីដែលអនីតិជនប្រព្រឹត្តបទ

[72] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ កក្កដា ២០១៦ មាត្រា ២៧។

[73] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៩ កថាខណ្ឌទី ២។

[74] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៩ កថាខណ្ឌទី ១។

[75] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤០។

[76] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤១។

មជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ការចាប់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា។ រាល់ការចាប់ខ្លួនអនីតិជនត្រូវរាយការណ៍ជូន ព្រះរាជអាជ្ញាភ្លាម។ ការអនុវត្តការចាប់ខ្លួន នគរបាលយុត្តិធម៌ ត្រូវចៀសវាងការធ្វើឲ្យអាម៉ាស់មុខនិងបាត់បង់សេចក្តី ថ្លៃថ្នូររបស់អនីតិជន និងត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញ ទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត។

**២.២ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

ចំពោះនីតិបុគ្គល គឺសំដៅលើក្រុមមនុស្ស ឬ មូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។[77] ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានចែកចេញជា ២ មាន នីតិបុគ្គលជារដ្ឋ(នីតិបុគ្គលសាធារណៈ) **(ក)** និងនីតិបុគ្គលមិនមែនជារដ្ឋ(នីតិបុគ្គលឯកជន) **(ខ)**។

**ក. នីតិបុគ្គលជារដ្ឋ ឬនីតិបុគ្គលសាធារណៈ**

យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ត្រង់មាត្រា ៤២ បានកំណត់យ៉ាងជាក់លាក់ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលថា នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ ដូច្នេះ រដ្ឋគឺជានីតិបុគ្គលមួយដែលច្បាប់មិនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ព្រោះថាច្បាប់ព្រហ្មទណ្ឌនៅក្នុងទោសបន្ថែម គឺអាចរំលាយនីតិបុគ្គលមួយចោលបាន។ ដូចនេះ ប្រសិនបើជាឱ្យរំលាយនីតិបុគ្គលដែលជារដ្ឋ ឬប្រទេសមួយចោលបានដូចជា ប្រទេសកម្ពុជាយើងជាដើម ពេលនោះវានឹងប៉ះពាល់ដល់អធិបតេយ្យជាតិយើង ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញជាក់ជាមិនខានឡើយ[78]។ ចំណែកឯនៅក្នុងមូលទោសវិញនោះ គឺមានទោសមួយប្រភេទហៅថាទោសពិន័យជាប្រាក់ ហើយរាល់ទោសពិន័យជាប្រាក់ សុទ្ធតែត្រូវបង់ចូលថវិការដ្ឋ។

ដូចនេះហើយ ទើបបានជារដ្ឋមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ លើកលែងតែបទល្មើស ៤ ប្រភេទ ដែលស្ថិតក្នុងសមត្ថកិច្ចនៃយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ដែលជាបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុតរវាងរដ្ឋ និងប្រជាពលរដ្ឋ។ បទល្មើសព្រហ្មទណ្ឌ ដែលជាបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរបំផុតត្រូវបានជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC) មានចំនួន ៤ ដូចខាងក្រោមនេះ៖

១-បទឧក្រិដ្ឋប្រល័យពូជសាសន៍

២-បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

[77] សន្ធានុក្រមផ្នែករដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, លេខរៀង ៧១។

[78] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០១២។

៣-បទឧក្រិដ្ឋកម្មសង្គ្រាម

៤-បទឧក្រិដ្ឋកម្មឈ្លានពាន។

**ខ. នីតិបុគ្គលមិនមែនរដ្ឋ ឬនីតិបុគ្គលឯកជន**

នីតិបុគ្គលឯកជន គឺសំដៅទៅលើ ក្រុមហ៊ុន ឬសមាគមន៍ជាដើម។ ដោយយោងតាមមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ នីតិបុគ្គលគ្រប់ប្រភេទសុទ្ធតែអាចទទួលខុសត្រូវព្រហ្មទណ្ឌ លើកលែងតែរដ្ឋចេញ។ ដូច្នេះ នីតិបុគ្គលឯកជន អាចទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាណាតែមានលក្ខខណ្ឌគ្រប់គ្រាន់ជាមុនសិនដូចជា មានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗចែងទុកជាមុន(**ខ.១**) បទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់នីតិបុគ្គល(**ខ.២**) និងការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គលនោះ (**ខ.៣**)។ ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ កថាខណ្ឌទី២ មាត្រា៤២ នៃក្រមព្រហ្មទណ្ឌ។ ហើយការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល[79]។

**ខ.១ មានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗចែងទុកជាមុន**

នីតិបុគ្គលមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈទូទៅទេ បានសេចក្តីថា នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ កាលបើច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានចែងយ៉ាងជាក់លាក់ថា "នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសណាមួយជាកំណត់។ ហេតុដូច្នេះ ចំពោះបទល្មើសដែលមានចែងនៅមាត្រា ១៩៩ អំពីបទឃាតកម្ម ក្រមព្រហ្មទណ្ឌពុំបានចែងបញ្ជាក់បន្ថែមពីការទទួលខុសត្រូវពហ្មទណ្ឌរបស់នីតិបុគ្គលទេ ដូចនេះហើយ នីតិបុគ្គលមិនអាចត្រូវបានប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌពីបទឃាតកម្មបានឡើយ។

**ឧទាហរណ៍៖** ប្រធានក្រុមហ៊ុន **ក** បានធ្វើឃាតប្រធានក្រុមហ៊ុន **ខ** ព្រោះតែការបក្ខតប្រជែងគ្នាផ្នែកពាណិជ្ជកម្ម។ តុលាការបានសម្រេចផ្តន្ទាទោសប្រធានក្រុមហ៊ុន **ក** ពីបទឃាតកម្ម ក្នុងនាមជារូបវន្តបុគ្គល តែតុលាការមិនអាចដាក់ទោសក្រុមហ៊ុន **ក** ពីបទឃាតកម្មឡើយ ព្រោះតែពុំមានច្បាប់ចែងថា នីតិបុគ្គលត្រូវទទួលខុសត្រូវពហ្មទណ្ឌពីបទឃាតកម្មឡើយ។

ផ្ទុយទៅវិញ ទាក់ទងនឹង បទមនុស្សឃាតដោយអចេតនា ដែលមានចែងនៅមាត្រា ២០៧ និងមាត្រា ២០៩ នៃក្រមព្រហ្មទណ្ឌបានចែងពីការទទួលខុសត្រូវពហ្មទណ្ឌរបស់នីតិបុគ្គលដែរ។ ការចែងយ៉ាងដូច្នេះ មានន័យថា នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពី បទមនុស្សឃាតដោយអចេតនាបាន កាលបើលក្ខខណ្ឌផ្សេងទៀតត្រូវបានបំពេញ។[80]

---

[79] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៨។

[80] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

### ខ.២ បទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់នីតិបុគ្គល

នីតិបុគ្គល គឺជាបុគ្គលដែលកើតឡើងពីការសន្មតរបស់ច្បាប់។ នីតិបុគ្គល រមែងមានអង្គការតំណាងក្រោមរូបភាពជាក្រុមប្រឹក្សា ឬអ្នកតំណាងជារូបវន្តបុគ្គល ដែលធ្វើសកម្មភាពតំណាងឱ្យនីតិបុគ្គលជានិច្ច។

អង្គភាពតំណាង ឬអ្នកតំណាងនៃនីតិបុគ្គល គឺជាជន ឬអង្គភាពដែលច្បាប់ ឬលក្ខន្តិកៈផ្តល់នូវមុខងារជាអ្នកដឹកនាំគ្រប់គ្រង ហើយមាននីតិសម្បទាគ្រប់គ្រាន់( មានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់ ) ក្នុងការសម្រេចសេចក្តីដែលអាច ធ្វើឱ្យនីតិបុគ្គលទទួលខុសត្រូវបាន ឬនិយាយម្យ៉ាងទៀតថា គឺជាអង្គភាព ឬជាអ្នកតំណាងដែលមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការប្រព្រឹត្តសកម្មភាពណាមួយក្នុងនាមនីតិបុគ្គល។ **ឧទាហរណ៍៖** អង្គភាពដែលតំណាងឱ្យនីតិបុគ្គលមានដូចជា៖ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន សន្និបាតរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាឃុំសង្កាត់។ អ្នកតំណាងឱ្យនីតិបុគ្គលរួមមានដូចជា៖ ប្រធានសមាគម អភិបាល(អ្នកគ្រប់គ្រង) មេឃុំ ចៅសង្កាត់។[81]

### ខ.៣ ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គល

ចំពោះលក្ខខណ្ឌនេះ គឺថាដើម្បីឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាណាតែការប្រព្រឹត្តបទល្មើសក្នុងគោលបំណងផ្តល់ជាប្រយោជន៍ដល់នីតិបុគ្គលនោះតែប៉ុណ្ណោះ ពីព្រោះថា នីតិបុគ្គលដែលទទួលប្រយោជន៍ពីការប្រព្រឹត្តបទល្មើសនេះ ត្រូវតែទទួលយកផលវិបាកនៃបទល្មើសនេះផងដែរ។ **ឧទាហរណ៍៖** ក្រុមហ៊ុនដឹកជញ្ជូនមួយ ដោយមានបំណងចង់បង្កើនចំណូលសម្រាប់ក្រុមហ៊ុន អ្នកគ្រប់គ្រងក្រុមហ៊ុនបានលួចដាក់ថ្នាំញៀនដែលជាសារធាតុច្បាប់ហាមឃាត់ ដើម្បីនាំចេញទៅក្រៅប្រទេស។ សកម្មភាពនេះ ធ្វើឡើងដោយអ្នកតំណាងក្រុមហ៊ុន ហើយក្នុងគោលបំណងជាប្រយោជន៍ដល់ក្រុមហ៊ុន ពោលគឺដើម្បីបង្កើនចំណូលឱ្យក្រុមហ៊ុន។

ផ្ទុយទៅវិញ បទល្មើសដែលប្រព្រឹត្តដោយតំណាងរបស់នីតិបុគ្គល ក៏ប៉ុន្តែការធ្វើឡើងគឺដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកតំណាង ករណីនេះនីតិបុគ្គលមិនអាចត្រូវបានចោទប្រកាន់ ឬទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ព្រោះថាទោះបីជាធ្វើដោយអ្នកតំណាងក្រុមហ៊ុនក៏ដោយ តែគោលបំណងមិនមែនជាផលប្រយោជន៍ដល់ក្រុមហ៊ុននោះទេ ពោលគឺធ្វើដើម្បីយកផលប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ។ **ឧទាហរណ៍៖** ដូចករណីខាងលើដែរ ក្រុមហ៊ុនដឹកជញ្ជូនមួយ អ្នកគ្រប់គ្រងក្រុមហ៊ុនបានលួចបង្កប់សារធាតុញៀនដែលច្បាប់ហាមឃាត់ ដើម្បីចែកចាយ ឬលក់បន្ត ក្នុងគោលបំណងប្រមូលប្រាក់ដែលបានមកពីអំពើល្មើសនោះមកទុកខ្លួនឯង។ អំពើនេះមិនទាក់ទងក្រុមហ៊ុនឡើយ គឺអ្នកគ្រប់គ្រងនេះឯងដែលជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើផ្ទាល់ខ្លួន។

---

[81] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

## ផ្នែកទី២៖ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺបានបកស្រាយនៅចំណុចខាងលើរួចរាល់មកហើយ ពោល បុគ្គលណាម្នាក់បានប្រព្រឹត្តអំពើល្មើសដែលបង្កចលាចល ឬគ្រោះថ្នាក់ដល់សង្គម គឺត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ក៏ប៉ុន្តែមានករណីខ្លះ បុគ្គលម្នាក់បានប្រព្រឹត្តអំពើដែលចែងទុកថាជាបទល្មើសក្នុងច្បាប់ជាធរមាន បុគ្គលនោះក៏អាចរួចផុតពីការទទួលខុសត្រូវចំពោះអំពើនោះបានដែរ ព្រោះថាការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌខ្លះ អាចបណ្តាលមកពីមូលហេតុណាមួយ ដែលច្បាប់បានចាត់ទុកថាជាមូលហេតុត្រឹមត្រូវ ដូចនេះច្បាប់មិនតម្រូវឱ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ចំពោះមូលហេតុដែលនាំឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយពិនិត្យទៅតាមក្រមព្រហ្មទណ្ឌអាចមានមូលហេតុចំនួន ២ ធំៗគឺ មូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬមិនអាចទម្លាក់កំហុសបាន(១) និងមូលហេតុសត្យានុម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬអំពើយុត្តិកម្ម(២)។

### ១. មូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ (ទាក់ទងនឹងចារីផ្ទាល់)

ចំពោះមូលហេតុអត្តនោម័តនេះ សំដៅទៅលើបុគ្គលដែលជាជនប្រព្រឹត្តបទល្មើស ឬជាមូលហេតុដែលទាក់ទងនឹងស្ថានភាពរបស់ចារីផ្ទាល់ ពោលគឺការប៉ះពាល់ដោយផ្ទាល់ទៅនឹងសតិបញ្ញាស្មារតីរបស់ជននោះ ឬប៉ះពាល់ដល់ការសម្រេចចិត្តដោយឯករាជ្យរបស់ចារីនៃបទល្មើស។ មូលហេតុនេះ គឺជាឧបសគ្គដល់ការទម្លាក់កំហុសគ្រប់បែបយ៉ាងទៅលើចារី ដែលអាចនាំឱ្យចារីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ឬទទួលបានស្ថានសម្រាលនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ក្នុងន័យនេះ សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតរបស់ចារីពុំអាចលើកសំអាងពីមូលហេតុខាងលើដើម្បីឱ្យខ្លួនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ពីព្រោះថា ស្ថានភាពទាំងនោះ ពុំមានការពាក់ព័ន្ធជាមួយសហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតទេ[82]។

ចំពោះមូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌមានដូចជា មូលហេតុវិបល្លាសស្មារតី (១.១) និងមូលហេតុដោយអានុភាពនៃកម្លាំង ឬការបង្ខំ (១.២)។

#### ១.១ មូលហេតុវិបល្លាសស្មារតី

វិបល្លាសស្មារតី គឺចង់សំដៅទៅលើវិបត្តិដែលធ្វើឱ្យមានភាពរឹករវដល់សកម្មភាពនៃសរសៃប្រសាទរបស់មនុស្ស ដែលធ្វើឱ្យមនុស្សបាត់បង់នូវការដឹងខុសត្រូវលើរាល់សកម្មភាពរបស់ខ្លួន។ ជាក់ស្តែង វិបល្លាសស្មារតីអាចមានប្រភពមកពីភាពចាស់ជរា មកពីគ្រោះថ្នាក់ណាមួយ ឬមកពីជម្ងឺផ្សេងៗជាដើម។ ដោយគោរពតាមមាត្រា ៣១នៃក្រមព្រហ្មទណ្ឌកម្ពុជា បានចែងអំពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយសារមូលហេតុវិបល្លាសស្មារតី ដោយមាត្រានេះបានចែងថា កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតមាន

[82] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

វិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ដូច្នេះ ដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ គេត្រូវតែរកភស្តុតាងមកបញ្ជាក់ពីអត្ថិភាពនៃវិបល្លាសស្មារតី ដែលបានកើតមានចំពោះចារីនៅពេលចារីប្រព្រឹត្តបទល្មើស។ ជាទូទៅ ភស្តុតាងនៃវិបល្លាសស្មារតីត្រូវបញ្ជាក់ ដោយវេជ្ជបណ្ឌិតជំនាញ ក៏ប៉ុន្តែយោបល់ទាំងនោះពុំមានអានុភាពចងជាកាតព្វកិច្ច ឱ្យចៅក្រមត្រូវតែជឿតាមនោះទេ ពោលចៅក្រមជឿក៏បាន មិនជឿក៏បានដែរ។

**ក. ការបាត់បង់នូវការដឹងខុសត្រូវ**

ចំពោះវិបល្លាសស្មារតី ដែលជាមូលហេតុរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ គឺត្រូវតែជាវិបល្លាសស្មារតីដែលត្រូវបានបំផ្លាញចោលទាំងស្រុង នូវសមត្ថភាពនៃការយល់ដឹងខុសត្រូវរបស់ចារី។ ស្ថានភាពនេះ បើចារីជាជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ(ជនវិកលចរិត ឬឆ្កួតជានិរន្តន៍) ហើយបានទៅប្រព្រឹត្តអំពើណាមួយ ទាំងដែលមិនអាចដឹងថាអំពើនោះខុស ឬក៏ត្រូវផងនោះ ធ្វើឱ្យជននោះរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ ប៉ុន្តែ ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ គេត្រូវតែរកភស្តុតាងមកបញ្ជាក់ ថាជននោះពិតជាកើតវិបល្លាសស្មារតីពិតប្រាកដមែន។ **ឧទាហរណ៍៖** ជនវិកលចរិតមិនទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលគាត់បានប្រព្រឹត្តទេ កាលបើមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជននោះពិតជាវិបល្លាសស្មារតីពិតប្រាកដមែន។

**ខ. ការបន្ថយការដឹងខុសត្រូវ**

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស។[83] ត្រង់ចំណុចនេះមានន័យថា ប្រសិនបើចារីមានវិបល្លាសស្មារតី ដែលមានអានុភាពត្រឹមតែបន្ថយនូវការយល់ដឹងខុសត្រូវរបស់គាត់តែប៉ុណ្ណោះ (ជនស្ថិតក្រោមហិតូបត្ថម្ភ ឬឆ្កួតជ្រូក ឬឆ្កួតម្តងម្កាល) ចារីនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ក៏ប៉ុន្តែអាចទទួលនូវស្ថានសម្រាលទោសពីតុលាការ។[84]

**គ. វិបល្លាសស្មារតីដោយសារគ្រឿងស្រវឹង ឬសារធាតុដែលច្បាប់ហាមឃាត់**

ការប្រើប្រាស់សារធាតុញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ ដែលអាចមានឥទ្ធិពលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ ដូចជា គ្រឿងញៀន គ្រឿងស្រវឹង ឬថ្នាំផ្សេងៗទៀតជាដើម ហើយបានទៅប្រព្រឹត្តបទល្មើស គឺមិនអាចយកលេសថាកើតវិបល្លាសស្មារតី ដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

ដូចនេះហើយទើបមាត្រា ៣១ កថាខណ្ឌទី ៣ នៃក្រមព្រហ្មទណ្ឌបានចែងថា កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន

[83] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣១ កថាខណ្ឌទី ២ ។

[84] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ៣ ។

ឬ សារជាតិដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។ ក្រមព្រហ្មទណ្ឌក៏មិនបានចាត់ទុកវិបល្លាសស្មារតីនេះជាមូលហេតុនៃការបន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌទេ។ **ឧទាហរណ៍៖** ជនម្នាក់បានប្រើប្រាស់គ្រឿងញៀន ឬថ្នាំសម្រើបបណ្តាលឱ្យមានការលំបាកក្នុងការទប់ស្កាត់កាមតណ្ហារបស់ខ្លួន ហើយក៏បានទៅរំលោភសេពសន្ថវៈនារីម្នាក់ដែលនៅក្បែរនោះ។ ក្នុងករណីបែបនេះ ជនល្មើសមិនអាចលើកសំអាងពីការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសម្រើបធ្វើឱ្យគាត់មិនអាចគ្រប់គ្រងខ្លួនឯងបាន ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។[85]

## ១.២ មូលហេតុដោយអានុភាពនៃកម្លាំង ឬការបង្ខំ

អានុភាពនៃកម្លាំង ឬការបង្ខំ គឺជាមូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ។ វិបល្លាសស្មារតីបានធ្វើឱ្យខូចខាតការយល់ដឹងរបស់ចារី ឯកម្លាំង ឬការបង្ខំវិញ បានលុបចោលនូវឆន្ទៈរបស់ចារីតែម្តង។ ការបង្ខំ ជាភាពលុបបំបាត់ចោលនូវសេរីភាពរបស់ជនល្មើស មានន័យថា ជនល្មើសមិនអាចធ្វើអ្វីក្រៅពី ប្រព្រឹត្តបទល្មើសឡើយ គឺជនល្មើសស្ថិតនៅក្រោមការគាបសង្កត់ ឬការបង្ខំណាមួយដែលមិនអាចទប់ទល់បាន។[86]

ជាក់ស្តែងក្រមព្រហ្មទណ្ឌក៏បានចែង អំពីអានុភាពនៃកម្លាំង ឬការបង្ខំ ដែរថា បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនោះមិនអាចទប់ទល់បាន បុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ (មាត្រា ៣៦ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ)។ កម្លាំង ឬការបង្ខំអាចមាន ២ ប្រភេទ **(ក)** ហើយត្រូវមានលក្ខណៈ ២ យ៉ាង **(ខ)** ដើម្បីឱ្យក្លាយជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។

### ក. ប្រភេទនៃកម្លាំង ឬការបង្ខំ

ប្រភេទនៃកម្លាំង ឬការបង្ខំមាន២ ប្រភេទដូចជា ការបង្ខំលើរូបកាយ**(ក.១)** និងការបង្ខំលើផ្លូវចិត្ត**(ក.២)**។

#### ក.១ ការបង្ខំលើរូបកាយ

ការបង្ខំលើរូបកាយ សំដៅទៅលើវត្តមាននៃកម្លាំងណាមួយលើរូបកាយរបស់ចារីដែលជាហេតុធ្វើឱ្យចារីត្រូវតែប្រព្រឹត្តអំពើ ដោយខ្លួនពុំអាចឃាត់ឃាំងអំពើនោះបាន។ កម្លាំងបង្ខំអាចជាកម្លាំងបង្ខំមកពីខាងក្រៅ ដូចជាកម្លាំងបង្ខំមកពីព្រឹត្តការណ៍ធម្មជាតិ ឬមកពីតតិយជនណាមួយ។

**ឧទាហរណ៍៖** នៅពេលកំពុងបើកបរ មានភ្លៀងយ៉ាងខ្លាំង រួមមកជាមួយរន្ទះបាញ់ដែលធ្វើឱ្យឡានបែកកង់ ដោយអ្នកបើកបរមិនអាចទប់ចង្កូតបានក៏បណ្តាលឱ្យបុកផ្ទះនៅក្បែរនោះ ធ្វើឱ្យស្លាប់មនុស្សម្នាក់។ ចំពោះក្នុងស្ថានភាពបែបនេះ អ្នកបើកបរមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ព្រោះបណ្តាលមកពីព្រឹត្តការណ៍ធម្មជាតិដែលពុំអាចរារាំងបាន។

[85] សាស្ត្រាចារ្យ **នុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[86] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់ឆ្នាំទី២។

**ក.២ ការបង្ខំលើផ្លូវចិត្ត**

ការបង្ខំលើផ្លូវចិត្តសំដៅទៅលើកម្លាំងដែលបង្ខំឆន្ទៈរបស់ជនល្មើស។ ការបង្ខំផ្លូវចិត្តក៏អាចជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ តែក្នុងករណីដែលការបង្ខំនោះ មានប្រភពមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់ជនល្មើសតែប៉ុណ្ណោះ ពោលគឺជាការគាបសង្កត់ខាងក្រៅ ដែលជម្រុញឲ្យជន ល្មើសមិនអាចជៀសវាងបានក្នុងការប្រព្រឹត្តបទល្មើស។[87]**ឧទាហរណ៍៖** ការគំរាមកំហែងថានឹងសម្លាប់ជនល្មើស ឬសម្លាប់សាច់ញាតិរបស់ជនល្មើស ដើម្បីធ្វើឱ្យជនល្មើសប្រព្រឹត្តបទល្មើសណាមួយដូចជា ការសម្លាប់នរណាម្នាក់ ឬឱ្យធ្វើអ្វីមួយតាមគោលបំណងរបស់តតិយជននោះជាដើម។

**ខ. លក្ខណៈនៃកម្លាំង ឬការបង្ខំ**

ក្នុងលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងករណីប្រធានសក្តិ នៅក្នុងរឿងរដ្ឋប្បវេណីដែរ មាត្រា ៣៦ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌតម្រូវឲ្យកម្លាំង និងការបង្ខំមានលក្ខណៈ ២ យ៉ាង ដើម្បីឲ្យកម្លាំង ឬការបង្ខំនេះ ក្លាយជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌបាន ពោលគឺ កម្លាំង ឬការបង្ខំដែលមិនអាចមើលឃើញជាមុនបាន(**ខ.១**) និងកម្លាំង ឬការបង្ខំមិនអាចជៀសវាងបាន(**ខ.២**)។

**ខ.១ កម្លាំង ឬការបង្ខំដែលមិនអាចមើលឃើញជាមុនបាន**

កម្លាំង និងការបង្ខំត្រូវតែជាស្ថានភាពដែលមិនអាចមើលឃើញជាមុនបាន ពោលគឺជនល្មើសមិនអាចប៉ាន់ស្មានដឹងជាមុនបានឡើយ ហើយក៏ពុំមែនកើតចេញពីកំហុសណាមួយរបស់ជនល្មើសផងដែរ។ ក្នុងន័យនេះ ជនដែលខ្វះការប្រុងប្រយ័ត្ន ក្នុងការទប់ស្កាត់អំពើដែលអាចបង្ខំខ្លួនឯងផ្ទាល់ឲ្យប្រព្រឹត្តបទល្មើសមិនអាចលើកសំអាងពីកម្លាំង ឬការបង្ខំ ដើម្បីឲ្យខ្លួនបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ។[88]

**ឧទាហរណ៍៖** អ្នកបើកបរមិនអាចលើកសំអាងថា ដោយសារតែការបើកបររថយន្ត រយៈពេលវែង និងមិនបានបរិភោគអាហារគ្រប់គ្រាន់ បណ្តាលឱ្យសុខភាពផ្លូវកាយរបសគាត់ទុឌទ្រោម ទើបបានបង្កជាគ្រោះថ្នាក់ចរាចរណ៍ ពីព្រោះថា ជាទូទៅ គេអាចដឹងជាមុនបានថា នៅពេលដែលបើកបររយៈពេលវែង និងបរិភោគអាហារមិនគ្រប់គ្រាន់ រមែងធ្វើឱ្យរូបកាយចុះទន់ខ្សោយ។

**ខ.២ កម្លាំង ឬការបង្ខំត្រូវតែជៀសមិនបាន**

កម្លាំង និងការបង្ខំដែលមិនអាចជៀសវាងបាន គឺជាកម្លាំង និងការបង្ខំដែលលុបបំបាត់ចោលទាំងស្រុងនូវសេរីភាពក្នុងការប្រព្រឹត្តអំពើ។ ចារីត្រូវស្ថិតក្នុងស្ថានភាពមិនអាចទប់ទល់នឹងកម្លាំងបង្ខំខាងលើ ហើយមិនអាចជ្រើសរើសអំពើណាមួយផ្សេងទៀត ក្រៅតែពីការប្រព្រឹត្តបទល្មើសឡើយ ។ ការវាយតែម្លពីលក្ខណៈមិនអាច

[87] សាស្ត្រាចារ្យ **នុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, នីតិព្រហ្មទណ្ឌទូទៅ និងនីតិគ្រួសារ បោះពុម្ពឆ្នាំ២០១៧។

[88] សាស្ត្រាចារ្យ **នុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

ជៀសវាងបាននៃកម្លាំង និងការបង្ខំ គឺអាស្រ័យទៅតាមករណីនីមួយៗ ទៅតាមសម្បទារបស់ជនម្នាក់ៗក្នុងការទប់ទល់នឹងកម្លាំងឬការបង្ខំនោះ។

ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវមានភស្តុតាងមកបញ្ជាក់ឱ្យបានច្បាស់លាស់ថា ជនប្រព្រឹត្តអំពើស្ថិតក្នុងស្ថានភាពមួយដែលខ្លួនមិនអាចជៀសវាងពីការប្រព្រឹត្តបទល្មើសបានទាល់តែសោះឬនិយាយម្យ៉ាងទៀតថា ចារីស្ថិតក្នុងស្ថានភាពអលទ្ធភាពដាច់ខាតក្នុងការគោរពច្បាប់។ ប្រសិនបើជាក់ស្តែង ចារីនៅមានលទ្ធភាពអាចជៀសវាងបានខ្លះដែរ ក៏ប៉ុន្តែចារីបែរជានៅតែប្រព្រឹត្តបទល្មើសទៀត ជននេះមិនអាចលើកសំអាងពីកម្លាំង ឬការបង្ខំ ដើម្បីឱ្យបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។[89]

**ឧទាហរណ៍ ៖** ជនម្នាក់មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយសំអាងថា ក្រុមចោរបង្ខំឱ្យរូបគាត់ទិញវត្ថុដែលពួកគេលួចបាន ក្រោមការគំរាមកំហែងថា បើមិនទិញទេថ្ងៃក្រោយពួកគេនឹងដុតផ្ទះរបស់គាត់ចោលជាក់ជាមិនខាន ។ ក្នុងករណីយ៉ាងនេះ អំពើរបស់ក្រុមចោរគឺជាការបង្ខំក៏ពិតមែន ក៏ប៉ុន្តែការបង្ខំនេះអាចឱ្យទប់ទល់បាន តាមរយៈការប្តឹងទប់ស្កាត់ទៅអាជ្ញាធរមានសមត្ថកិច្ចឱ្យធ្វើអន្តរាគមន៍ជាដើម។ ដូច្នេះ ជនខាងលើនៅតែទទួលខុសត្រូវពហ្មទណ្ឌពី បទទទួលផលចោរកម្មដដែល។

**១.៣ មូលហេតុទាក់ទងនឹងអនីតិភាព**

ដោយគោរពតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា២០០៩ បានចែងថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។ មានន័យថា ជនណាដែលមានអាយុ ១៨ ឆ្នាំឡើងហើយបានប្រព្រឹត្តបទល្មើស ជននោះត្រូវទទួលខុសត្រូវយ៉ាងពេញលេញចំពោះអំពើល្មើសរបស់ខ្លួន។

ជាគោលការណ៍ គេមិនអាចឲ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួន ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ តាមធម្មតាបុគ្គលណាបានធ្វើឱ្យអ្នកដទៃស្លាប់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តែប្រសិនបើក្មេងមានអាយុ ១០ ឆ្នាំ ម្នាក់បានចាក់សម្លាប់ក្មេងម្នាក់ទៀត ក្មេងដែលបានប្រព្រឹត្តអំពើល្មើសមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ដោយសារតែក្មេង ១០ ឆ្នាំ នោះមិនមានសមត្ថភាពដឹងខុសត្រូវអំពើរបស់ខ្លួនឡើយ។

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ មិនអាចត្រូវទទួលរងនូវការផ្តន្ទាទោសណាមួយឡើយ ទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយ។ ដូច្នេះនៅពេលដែលអនីតិជនមានអាយុក្រោម ១៤ ឆ្នាំបានប្រព្រឹត្តបទល្មើសណាមួយ អនីតិជននោះពុំទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

សម្រាប់អនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ តុលាការអាចប្រកាសទណ្ឌកម្មបាន ដោយគោរពតាមមាត្រា ៣៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានចែងថា តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌ

[89] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២ ដកស្រង់ចេញទាំងស្រុងនៅចំណុច ២.២ កម្លាំង ឬការបង្ខំត្រូវតែមិនអាចជៀសវាងបាន។

ទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ មានន័យថា តុលាការត្រូវថ្លឹងថ្លែងពាក់ព័ន្ធនឹងកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ឬបុគ្គលលក្ខណៈរបស់អនីតិជនដែលប្រព្រឹត្តល្មើសនោះ មុនឈានដល់ការសម្រេចផ្តន្ទាទោស ឬក៏មិនផ្តន្ទាទោស។

**២. មូលហេតុសត្យានុម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ (យុត្តិកម្មនៃបទល្មើស)**

យុត្តិកម្មនៃបទល្មើស គឺជាអំពើដែលមានផ្ទុកចរិតគ្រោះថ្នាក់ដល់សង្គម ជាទូទៅ គេចាត់ទុកអំពើនេះថាល្មើសច្បាប់ និងគួរផ្តន្ទាទោសដោយច្បាប់ ប៉ុន្តែបែរជាចាត់ទុកថាត្រឹមត្រូវទៅវិញនៅពេលដែលអំពើនោះ បង្ហាញពីការអនុវត្តសិទ្ធ ឬការបំពេញកាតព្វកិច្ច បានសេចក្តីថា អំពើនោះត្រូវបានធ្វើឡើងដើម្បីប្រយោជន៍ស្របច្បាប់ ហើយប្រយោជន៍នោះមានសារៈសំខាន់ជាងចាត់ទុកអំពើនោះជាបទល្មើស។ យុត្តិកម្មនៃបទល្មើសអាចកើតមានក្នុងករណី ៣ យ៉ាងដូចជា ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ **(២.១)** ការការពារស្របច្បាប់ **(២.២)** និងស្ថានភាពចាំបាច់**(២.៣)**។ ហើយក៏អាចលេចចេញនូវមូលហេតុផ្សេងៗទៀត **(២.៤)** ដូចជា អភ័យឯកសិទ្ធិគ្រួសារ និងករណីប្រធានសក្តិជាដើម។

**២.១ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ**

ប្រសិនបើច្បាប់អនុញ្ញាតឱ្យធ្វើ ការធ្វើសកម្មភាពសមស្របតាមច្បាប់អនុញ្ញាតនោះ មិនត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនោះទេ។ ដូចនេះហើយទើបមាត្រា ៣២ នៃក្រមព្រហ្មទណ្ឌបានចែងថា បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទ។ បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។ ដោយយោងតាមមាត្រាដែលបានលើកឡើងខាងលើនេះ អ្នកនីតិបញ្ញត្តិមានបំណងបង្កើតជាយុត្តិកម្មនូវអំពើដែលតាមធម្មតាជាបទល្មើស តែបែរជាមិនត្រូវចាត់ទុកជាបទល្មើសទៅវិញ ដោយសារការអនុញ្ញាតដោយច្បាប់ **(ក)** និងការអនុញ្ញាតដោយអាជ្ញាធរ ឬបញ្ជាដោយអាជ្ញាធរ **(ខ)**។

**ក. ការអនុញ្ញាតដោយច្បាប់**

នៅក្នុងករណីច្បាប់អនុញ្ញាតឱ្យប្រព្រឹត្តអំពើណាមួយ ច្បាប់មិនអាចផ្តន្ទាទោសលើអំពើដែលកើតចេញពីការបំពេញកាតព្វកិច្ច ឬការអនុវត្តសិទ្ធិដែលច្បាប់បានអនុញ្ញាតនោះឡើយ។ មានន័យថា ប្រសិនបើមាន ច្បាប់អនុញ្ញាត ជនដែលធ្វើសកម្មភាពសមស្របតាមការអនុញ្ញាតនោះ គឺមិនអាចចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនឹងទទួលការផ្តន្ទាទោសបានឡើយ។ **ឧទាហរណ៍៖** ដូចមាត្រា ៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងអំពីបទល្មើសជាក់ស្តែង គឺច្បាប់បានអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចចាប់ខ្លួនជនល្មើសបាន។ ដូចនេះ ការចាប់ខ្លួនជនល្មើស មិនមែនជាការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទេ ទោះបីអ្នកចាប់មិនមែនជាមន្ត្រីមានសមត្ថកិច្ចក៏ដោយ។

ទោះបីជាច្បាប់បានអនុញ្ញាតឱ្យចាប់ខ្លួនជនល្មើសដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែងក៏ដោយ តែច្បាប់

តម្រូវឱ្យយកជនល្មើសនោះទៅប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត។ ប្រសិនបើបុគ្គលម្នាក់បានចាប់ជនល្មើស ហើយបែរជាបង្ខាំងជននេះទុកនៅក្នុងផ្ទះរបស់ខ្លួនវិញ អំពើនេះគឺបានប្រព្រឹត្តហួសពីការអនុញ្ញាតរបស់ច្បាប់ ដូច្នេះមិនមែនជាមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

នៅត្រង់មាត្រា ៣២ កថាខណ្ឌទី ៣ បានចែងអញ្ញត្រកម្មទៅនឹងគោលការណ៍ខាងលើ ដោយមាត្រានោះបានចែងថា ប៉ុន្តែ ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុថា ជនល្មើសនោះ បានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ ដោយច្បាប់ជាធរមានក៏ដោយ។ **ឧទាហរណ៍៖** ទោះជាមានច្បាប់ជាធរមាន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានអនុញ្ញាតឱ្យមានការសម្លាប់មនុស្ស ក៏ជនទាំងឡាយណាដែលធ្វើតាមការអនុញ្ញាតដោយច្បាប់នេះ នឹងមិនអាចឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន ដោយលើកសំអាងពីការអនុញ្ញាតដោយច្បាប់នោះឡើយ ពីព្រោះថា បទល្មើសដែលបានប្រព្រឹត្តត្រូវបានចាត់បញ្ចូល ជាប្រភេទនៃបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈធ្ងន់ធ្ងរ និងមិនអាចឱ្យអនុគ្រោះបាន។ ហេតុដូច្នេះ ជនដែលបានប្រព្រឹត្តបទល្មើសទាំងនេះ ទោះបីជាមានច្បាប់អនុញ្ញាតឱ្យធ្វើក៏ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ។[90]

### ខ. ការអនុញ្ញាតដោយអាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់[91]។ ចំពោះខ្លឹមសារនៃមាត្រាខាងលើនេះ មានន័យថា ការអនុញ្ញាតដោយអាជ្ញាធរជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ លុះត្រាតែអាជ្ញាធរនោះ គឺជាអាជ្ញាធរស្របច្បាប់ និងជាអ្នកចេញបញ្ជាស្របច្បាប់។

**អាជ្ញាធរស្របច្បាប់ ៖** គឺសំដៅទៅលើអាជ្ញាធរសាធារណៈ ដែលមានអំណាចតាមផ្លូវច្បាប់ក្នុងការបញ្ជាឱ្យអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ អាជ្ញាធរទាំងនោះមានដូចជា តុលាការ រដ្ឋបាល ឬយោធា។ យើងអាចនិយាយបានថា អាជ្ញាធរស្របច្បាប់ គឺជាអាជ្ញាធរដែលមានអំណាចតាមផ្លូវច្បាប់ តាមតួនាទីរបស់ខ្លួន នៅក្នុងកិច្ចការមួយដែលច្បាប់កំណត់ជាក់លាក់។

**បញ្ជាស្របច្បាប់ ៖** តាមរយៈមាត្រា ៣២ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ មិនអនុញ្ញាតឱ្យជនដែលបានប្រព្រឹត្តបទល្មើសតាមបញ្ជាស្របច្បាប់ រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប្រសិនបើអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។ ដូចឧទាហរណ៍ ករណីមន្ត្រីយោធាបញ្ជាអ្នកក្រោមឱវាទទៅសម្លាប់មនុស្ស ចំពោះ

[90] សាស្ត្រាចារ្យ **នុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[91] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣២ កថាខណ្ឌទី ២។

ការបញ្ជាបែបនេះ គឺជាការបញ្ជាដែលខុសច្បាប់យ៉ាងជាក់ច្បាស់។

ក្រមព្រហ្មទណ្ឌនៅត្រង់មាត្រា ៣២ កថាខណ្ឌទី ៣ មិនអនុញ្ញាតឱ្យលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ កាលបើអំពើប្រព្រឹត្តជាបទល្មើសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា ៣២ នេះ។ ដោយមាត្រានេះបានចែងថា ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុថា បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ក៏ដោយ។

**២.២ ការការពារស្របច្បាប់**

យោងតាមមាត្រា ៣៣ កថាខណ្ឌទី ១ នៃក្រមព្រហ្មទណ្ឌ បានចែងថា បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ នៅក្នុងខ្លឹមសារនៃមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌមានន័យថា ការការពារស្របច្បាប់ ជាស្ថានភាពមួយដែលមិនឲ្យបុគ្គលដែលបានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពនៃការពារស្របច្បាប់ទទួលខុសត្រូវព្រហ្មទណ្ឌទេ។

យើងអាចនិយាយម្យ៉ាងទៀតថា នៅក្នុងករណីការការពារស្របច្បាប់ បើទោះបីជាបានប្រព្រឹត្តបទល្មើសក៏ដោយ ក៏មិនទទួលខុសត្រូវព្រហ្មទណ្ឌដែរ។ អាស្រ័យបែបនេះដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយលើកសំអាងពីការការពារស្របច្បាប់ បុគ្គលដែលបានប្រព្រឹត្តបទល្មើស ត្រូវតែបង្ហាញឱ្យឃើញអំពីលក្ខខណ្ឌនៃការការពារស្របច្បាប់ (**ក**) និងបង្ហាញដោយភស្តុតាងនៃការការពារស្របច្បាប់ (**ខ**)។

**ក. លក្ខខណ្ឌនៃការការពារស្របច្បាប់**

នៅត្រង់មាត្រា ៣៣ កថាខណ្ឌទី ២ បានចែងអំពីលក្ខខណ្ឌនៃការការពារស្របច្បាប់ ត្រង់នោះចែងថា ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ

- **បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ៖** ពោលការឈ្លានពានត្រូវតែកើតឡើងមុនពេលមានការការពារ ព្រោះថាអំពើការពារធ្វើឡើងដើម្បីទប់ទល់នឹងការឈ្លានពាននោះ។ ហើយបទល្មើសដែលបានប្រព្រឹត្តដើម្បីទប់ទល់ទៅនឹងការឈ្លានពាននោះត្រូវតែចាំបាច់ មានន័យថា ការការពារត្រូវតែចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ។ យើងអាចនិយាយបានថា គឺមានតែផ្លូវមួយគត់ដើម្បីប្រព្រឹត្តបទល្មើសតទល់នឹងការឈ្លានពាននោះ ពោលគឺគ្មានជម្រើសឡើយ។ **ឧទាហរណ៍៖** លោក **ក** ក្រោយពីបានគេចផុតពីការឈ្លានពានពីលោក **ខ** រួចមក ក្រោយមកលោក **ក** ក៏បានទៅយកកាំបិតកាប់ទៅលើលោក **ខ** ដែលជាអ្នកបានឈ្លានពានមកលើខ្លួន។ ករណីនេះមិនមែនជាការចាំបាច់សម្រាប់ការពារខ្លួនឡើយ ព្រោះលោក **ក** គេចផុតពីការឈ្លានពានហើយ គាត់អាចមានជម្រើសផ្សេងៗ ដើម្បីតទល់ជាមួយលោក **ខ** ។

- **បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា៖** មានន័យថា ការការពារត្រូវតែធ្វើឡើងភ្លាមៗ ដើម្បីតទល់ទៅនឹងការឈ្លានពាននោះ។ ដូចករណីការចាំបាច់ខាងលើដែរ ប្រសិនបើការឈ្លានពានចប់រួចរាល់ហើយ ទើបចាប់ផ្តើមធ្វើការតបតជាក្រោយ នោះមិនមែនជាការការពារស្របច្បាប់ទេ គឺចូលក្នុងករណីនៃការសងសឹកទៅវិញទេ។ **ឧទាហរណ៍៖** ដូចករណីខាងលើ ដោយលោក **ក** បានយកកាំបិតទៅកាប់លោក **ខ** ក្រោយពេលលោក **ខ** បានឈ្លានពានមកលើខ្លួនរួច អំពើនេះមិនត្រូវចាត់ទុកជាការការពារស្របច្បាប់ឡើយ។

- **គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ៖** ពេលការប្រើប្រាស់នូវមធ្យោបាយការពារ ត្រូវសមាមាត្រទៅតាមទំហំគ្រោះថ្នាក់នៃការឈ្លានពាន។ ដូចនេះ ប្រសិនបើគ្រាន់តែការពារទ្រព្យសម្បត្តិ អ្នកការពារពុំគួរឈានដល់ទៅសម្លាប់អ្នកឈ្លានពានឡើយ គឺមានន័យថាជីវិតមនុស្សមិនអាចប្រៀបនឹងទ្រព្យសម្បត្តិបានទេ ពោលទ្រព្យមិនសមាមាត្រនឹងជីវិតមនុស្សនោះទេ។ **ឧទាហរណ៍៖** ចោរម្នាក់បានចូលទៅលួចកង់នៅមុខផ្ទះ ពេលនោះម្ចាស់ផ្ទះតាមទាន់ក៏យកកាំបិតទៅកាប់ចោររហូតដល់ដាច់ដៃម្ខាង។ ក្នុងករណីនេះ ការការពារគឺមានវិសមាមាត្រ ឬក៏មានភាពមិនសមហេតុផល ដែលការការពារនោះវាលើសទៅនឹងអំពើដែលបានឈ្លានពាន ពោលគឺពុំមែនជាការការស្របច្បាប់ឡើយ។ ដូចនេះ ម្ចាស់ផ្ទះដែលយកកាំបិតកាប់នោះ គឺត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។

សរុបជារួមមក លក្ខខណ្ឌដែលបានលើកឡើងខាងលើទាំងបីនេះ ត្រូវតែបំពេញឱ្យគ្រប់ទាំងអស់ ដើម្បីអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយសំអាងលើការការពារស្របច្បាប់នេះ។ **សូមបញ្ជាក់ផងដែរថា៖** កាលបើអំពើមួយត្រូវបានចាត់ទុកថាជាការការពារស្របច្បាប់ហើយ ចារី ឬជនដែលបានប្រព្រឹត្តបទល្មើសមិនត្រឹមតែមិនទទួលខុសត្រូវប៉ុណ្ណោះទេ គឺថែមទាំងមិនត្រូវទទួលខុសត្រូវរដ្ឋប្បវេណីទៀតផង។ ការលើកឡើងនេះផ្អែកតាមមាត្រា ៧៥៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី បានចែងថា អ្នកប្រព្រឹត្តអំពើការពារជាធម្មានុរូបមិនទទួលខុសត្រូវចំពោះការខូចខាតដែលបានកើតឡើងឡើយ[92]។

## ខ. ភស្តុតាងនៃការការពារស្របច្បាប់

ចំពោះការការពារស្របច្បាប់ ក៏មិនខុសពីយុត្តិកម្មនៃបទល្មើសដទៃទៀតនោះទេ ជនជាប់ចោទដែលលើកសំអាងពីការការពារស្របច្បាប់ ត្រូវតែរកភស្តុតាងមកបញ្ជាក់ពីអត្ថិភាពនៃការការពារស្របច្បាប់។ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌបានសន្មតទុកនូវករណី ២ យ៉ាងថាជាការការពារស្របច្បាប់ ពោលជនជាប់ចោទ ដែលជាអ្នកសំអាងពីការការពារស្របច្បាប់ មិនចាំបាច់ស្វែងរកភស្តុតាងពីលក្ខខណ្ឌនៃការការពារស្របច្បាប់ឡើយ ដោយក្រមព្រហ្មទណ្ឌសន្មតថា ជននេះបានធ្វើការការពារស្របច្បាប់តែម្តង។[93]

[92] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[93] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

ដោយផ្អែកតាមមាត្រា ៣៤ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ បានចែងថា ត្រូវសន្មតថាជាការការពារស្របច្បាប់នៅក្នុងករណីដូចតទៅ៖

**១- បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ៖** មានន័យថា ការចូលនៅក្នុងពេលយប់ទៅកន្លែងដែលមានមនុស្សរស់នៅ តាមរយៈការប្រើប្រាស់សោរក្លែង ឬក៏ការកាប់គាស់ទម្លុះទម្លាយ ច្បាប់អនុញ្ញាតឱ្យម្ចាស់ទីកន្លែងប្រើប្រាស់មធ្យោបាយ ទប់ទល់ដើម្បីរុញច្រានជននោះឱ្យចេញវិញបាន។

**២- បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា៖** ការណ៍ដែលយើងស្ថិតនៅក្នុងស្ថានភាពដែលមានចោរប្លន់ដោយប្រើហិង្សា ឬដោយប្រើប្រាស់អាវុធ គឺយើងអាចប្រើប្រាស់មធ្យោបាយដើម្បីទប់ទល់តបទៅវិញបាន។

ចំពោះខ្លឹមសារនៃមាត្រានេះមានន័យថា ចារីដែលបានប្រព្រឹត្តបទល្មើសគ្រាន់តែបង្ហាញភស្តុតាងអំពីស្ថានភាពដូចមានចែងក្នុងមាត្រា ៣៤ នេះគឺគ្រប់គ្រាន់ហើយ ដោយមិនចាំបាច់បង្ហាញភស្តុតាងពីលក្ខខណ្ឌនៃការការពារស្របច្បាប់ដូចមានចែងនៅមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌឡើយ។ ប៉ុន្តែសច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ។ សច្ចធារណ៍នេះ អាចត្រូវរំលាយដោយភស្តុតាងផ្ទុយ។ មានន័យថា តំណាងអយ្យការអាចរកភស្តុតាងផ្ទុយមករំលាយសច្ចធារណ៍នេះបាន ដោយលើកចំណុចខ្វះខាតនៃលក្ខខណ្ឌនៃការការពារស្របច្បាប់ ដែលមានចែងនៅមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌដូចជា៖ ពុំមានការឈ្លានពានឡើយ ពុំមានភាពចាំបាច់ក្នុងការការពារខ្លួនទេ(ចាក់សម្លាប់ចោរនៅពេលដែលចោរកំពុងរត់គេចខ្លួន) និងមានវិសមាមាត្ររវាងមធ្យោបាយការពារដែលបានប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។

## ២.៣ ស្ថានភាពចាំបាច់

ស្ថានភាពចាំបាច់ គឺជាស្ថានភាពរបស់បុគ្គលម្នាក់ដែលឈានទៅដល់ការប្រព្រឹត្តបទល្មើសណាមួយដោយសារតែមានបំណងចង់ជួយស្តារនូវផលប្រយោជន៍មួយផ្សេងទៀត ដែលត្រូវបានគំរាមកំហែងដោយគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។[94]មានន័យថា ស្ថានភាពចាំបាច់ សំដៅលើស្ថានភាពទាំងឡាយណាដែលបុគ្គលម្នាក់ សម្រេចចិត្តប្រព្រឹត្តបទល្មើស ដើម្បីគេចផុតពីមហន្តរាយដែលហៀបនឹងកើតឡើងចំពោះខ្លួនឯង ឬអ្នកដទៃ។ ចំពោះស្ថានភាពចាំបាច់ ចារីមានជម្រើស ២ យ៉ាងគឺ៖

១. ទទួលយកការខូចខាតដែលនឹងត្រូវកើតមានឡើង ដោយសុខចិត្តបដិសេធ មិនព្រមប្រព្រឹត្តបទល្មើស។

២. ត្រូវតែប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសការខូចខាត។

---

[94] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

ស្ថានភាពចាំបាច់ ធ្វើឲ្យកើតឡើងនូវវិវាទផលប្រយោជន៍ដែលតម្រូវឲ្យបុគ្គលម្នាក់ធ្វើការជ្រើសរើសជាចាំបាច់ ដើម្បីការពារផលប្រយោជន៍ណាមួយដោយខានមិនបាន។ **សូមបញ្ជាក់ថា៖**

**ស្ថានភាពចាំបាច់ មានលក្ខណៈខុសពីកម្លាំង និងការបង្ខំ** ត្រង់ថាកម្លាំង និងការបង្ខំ គឺជំរុញឱ្យចារីប្រព្រឹត្តបទល្មើស ពីព្រោះតែខ្លួនមិនអាចទប់ទល់បាន ដោយគ្មានជម្រើសអ្វីដែលល្អទាល់តែសោះ តែស្ថានភាពចាំបាច់វិញ គឺចារីមានជម្រើសថា ចង់ទទួលយកការខូតខាត ឬក៏ប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសការខូចខាត។

**ស្ថានភាពចាំបាច់ មានលក្ខណៈខុសពីការការពារស្របច្បាប់** ត្រង់ថាស្ថានភាពចាំបាច់ពុំមានការឈ្លានពានដែលមិនត្រឹមត្រូវនោះទេ ពោលស្ថានភាពចាំបាច់គឺសំដៅទៅលើបុគ្គលម្នាក់មានជម្រើស ចង់ទទួលយកការខូតខាត ឬក៏ប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសការខូចខាត។

ស្ថានភាពចាំបាច់ត្រូវបានចាត់ទុកថាជាយុត្តិកម្មនៃបទល្មើស ផ្អែកតាមមាត្រា ៣៥ នៃក្រមព្រហ្មទណ្ឌដែលបានចែងថា បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ

- បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង
- គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។

ដើម្បីលើកសំអាងថា ការប្រព្រឹត្តបទល្មើសនេះគឺស្ថិតក្នុងស្ថានភាពចាំបាច់ ជនដែលបានប្រព្រឹត្តបទល្មើសមានករណីយកិច្ចត្រូវតែបង្ហាញភស្តុតាងពីលក្ខខណ្ឌតម្រូវសម្រាប់បង្កើតជាស្ថានភាពចាំបាច់។ ជាដំបូងត្រូវតែបង្ហាញភស្តុតាងអំពីអត្ថិភាពនៃគ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន (**ក**) ដែលជាមូលហេតុនាំឱ្យមានការការពារជាចាំបាច់ (**ខ**) ហើយត្រូវបញ្ជាក់ឱ្យឃើញថា ការការពារនេះពិតជាគ្មានវិសមាមាត្រជាមួយនឹងទម្ងន់នៃគ្រោះថ្នាក់ប្រាកដមែន (**គ**)។

### ក. គ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន

អ្នកដែលបានប្រព្រឹត្តបទល្មើសដោយស្ថានភាពចាំបាច់ ត្រូវរកភស្តុតាងអំពីគ្រោះថ្នាក់ ដែលជម្រុញឲ្យខ្លួនប្រព្រឹត្តបទល្មើស។ ចំពោះគ្រោះថ្នាក់នេះអាចជាគ្រោះថ្នាក់ដែលគំរាមកំហែងជននោះផ្ទាល់តែម្តង ឬគំរាមកំហែងតតិយជន ឬមួយក៏គ្រាន់តែគំរាមកំហែងលើទ្រព្យសម្បត្តិណាមួយក៏បានដែរ។ ដូចករណី ស្ត្រីម្នាក់ដោយមិនចង់ឱ្យកូនខ្លួនអត់អាហារស្លាប់ ស្ត្រីម្នាក់នោះក៏បានសម្រេចចិត្តលួចអាហារក្នុងហាងមួយកន្លែង ចំពោះសកម្មភាពនេះគឺជាការបញ្ចៀសពីគ្រោះថ្នាក់ដល់អាយុជីវិតកូន ទើបស្ត្រីរូបនេះសម្រេចចិត្តប្រព្រឹត្តបទល្មើស។

### ខ. ការការពារជាចាំបាច់

ដើម្បីឲ្យមានយុត្តិកម្មបាន បទល្មើសដែលប្រព្រឹត្តដោយចារីត្រូវតែជាអំពើចាំបាច់ដើម្បីការពារខ្លួនឯងការ

ពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ។ ត្រង់នេះមានន័យថា ការប្រព្រឹត្តបទល្មើសជា ជម្រើសដ៏ប្រសើរបំផុត និងជាជម្រើសតែមួយគត់ដើម្បីបញ្ចៀសគ្រោះថ្នាក់បាន។ ចំពោះការវាយតម្លៃការការពារតាមរយៈការប្រព្រឹត្តបទល្មើសជាការការពារចាំបាច់ ឬអត់នោះ គឺអាស្រ័យទៅលើអង្គហេតុនៃករណីនីមួយៗ។[95] ដូចឧទាហរណ៍ករណីមួយថា លោក ក បានសម្រេចចិត្តលួចសាច់គោរបស់អ្នកលក់ ដើម្បីយកឱ្យប្រពន្ធរបស់គាត់ធ្វើម្ហូបឱ្យឆ្ងាញ់ជាងធម្មតា ចំពោះករណីនេះ លោក ក មិនអាចលើកសំអាងពីស្ថានភាពចាំបាច់ឡើយ ព្រោះថា ការធ្វើបែបនេះមិនមែនជាស្ថានភាពចាំបាច់ឡើយ ដូចនេះគាត់នៅតែទទួលខុសត្រូវដដែល។

**គ. ការការពារដែលគ្មានវិសមាមាត្រជាមួយនឹងទម្ងន់គ្រោះថ្នាក់**

ជនដែលប្រព្រឹត្តបទល្មើសត្រូវរកភស្តុតាងមកបង្ហាញថា បទល្មើសដែលខ្លួនបានប្រព្រឹត្តមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃគ្រោះថ្នាក់។ ផលវិបាក នៃបទល្មើសត្រូវតែមានតម្លៃតិចជាង ឬស្មើនឹងតម្លៃដែលចារីមានបំណងចង់ជួយស្រោចស្រង់សង្គ្រោះ។ ភាពសមាមាត្រនៃមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់ត្រូវវាយតម្លៃទៅតាមស្ថានភាពនៃករណីនីមួយៗ។ **ឧទាហរណ៍៖** ដើម្បីបញ្ចៀសការប៉ះទង្គិចអ្នកថ្មើរជើងដែលកំពុងដើរឆ្លងផ្លូវអ្នកបើកបររថយន្តម្នាក់បានបង្ខំចិត្តត្រូវបត់រថយន្តរបស់ខ្លួនទៅខាងឆ្វេងដៃ ដែលមានស្លាកសញ្ញាហាមបត់ឆ្វេង ករណីនេះ អ្នកបើកបររថយន្តមិនត្រូវឱ្យទទួលខុសត្រូវពីការមិនគោរពស្លាកសញ្ញាហាមឃាត់នោះទេ។[96]

ជាចុងក្រោយ ដោយផ្អែកតាមមាត្រា ៧៥៥ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីបានកំណត់និយមន័យអំពីស្ថានភាពចាំបាច់ ហើយដោយយោងតាមខ្លឹមសារនៃមាត្រានេះ ពិនិត្យឃើញថានិយមន័យតាមក្រមរដ្ឋប្បវេណី ក៏មិនខុសពីនិយមន័យស្ថានភាពចាំបាច់តាមក្រមព្រហ្មទណ្ឌឡើយ។ ដោយយោងតាមមាត្រា ៧៥៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី បានកំណត់ពីបញ្ហាសំណងនៃការខូចខាតថា ចំពោះការខូចខាតដែលកើតឡើងដោយសារស្ថានភាពចាំបាច់ អ្នកដែលប្រព្រឹត្តអំពើដោយសារស្ថានភាពចាំបាច់ពុំទទួលខុសត្រូវឡើយ។ ដូចនេះ តាមក្រមរដ្ឋប្បវេណី បុគ្គលដែលបានប្រព្រឹត្តបទល្មើសដោយសារស្ថានភាពចាំបាច់ មិនទទួលខុសត្រូវក្នុងការសងការខូចខាតឡើយ ក៏ប៉ុន្តែជនដែលបានបង្កឱ្យមានការប្រព្រឹត្តបទល្មើសគឺជាអ្នកទទួលខុសត្រូវសងការខូចខាតទៅវិញ។

**ឧទាហរណ៍៖** លោក **ក** កំពុងបើកបរលើផ្លូវជាធម្មតា ពេលនោះមានឡានមួយបានបើកដោយមិនគោរពច្បាប់ចរាចរណ៍មកពីមុខឡានរបស់លោក **ក** ពេលនោះដោយឃើញក្នុងឡានមានក្មេងៗ លោក **ក** ក៏សម្រេចចិត្តថានឹងគេចឡាននោះ។ ការគេចរបស់គាត់ក៏បានទៅបុកផ្ទះរបស់ប្រជាពលរដ្ឋនៅជាប់ផ្លូវនោះ ករណីនេះលោក **ក** បានធ្វើឱ្យខូចខាតផ្ទះអ្នកដទៃដោយចេតនា ក៏ប៉ុន្តែអំពើនោះគឺស្ថិតក្នុងស្ថានភាពចាំបាច់។ ដូចនេះ លោក **ក** មិន

[95] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[96] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

ទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ហើយក៏មិនទទួលខុសត្រូវសំណងដែរ។ តាមក្រមរដ្ឋប្បវេណី អ្នកដែលបើកបរមិនប្រុងប្រយ័ត្ន ឬមិនគោរពច្បាប់នោះទេ ដែលជាអ្នកទទួលខុសត្រូវក្នុងការចេញសំណងខូចខាត។

## ២.៤ មូលហេតុផ្សេងៗនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

ចំពោះការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬក៏ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលជាមូលហេតុយុត្តិកម្មនៃបទល្មើស ឬជាមូលហេតុសត្យានុម័តនៃការមិនទទួលខុសត្រូវ យើងពិនិត្យឃើញមានមូលហេតុផ្សេងៗបន្ថែមទៀតដែលអាចឱ្យបុគ្គលដែលប្រព្រឹត្តបទល្មើសរួចផុតពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ ចំពោះមូលហេតុទាំងនោះមានដូចជា អភ័យឯកសិទ្ធិគ្រួសារ **(ក)** និងករណីប្រធានសក្តិ **(ខ)**។

### ក. អភ័យឯកសិទ្ធិគ្រួសារ

អភ័យឯកសិទ្ធិគ្រួសារ គឺមានចែងក្នុងមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចំពោះខ្លឹមសារមាត្រានេះចង់សំដៅទៅលើភាពមិនអាចផ្តន្ទាទោសព្រហ្មទណ្ឌបាន ចំពោះជនដែលបានប្រព្រឹត្តបទល្មើសលួច បើជននោះលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ និងទ្រព្យសម្បត្តិរបស់សហព័ទ្ធរបស់ខ្លួន។ ដូច្នេះ បើមានករណីលួចទ្រព្យសម្បត្តិនៅក្នុងរង្វង់គ្រួសារដែលប្រព្រឹត្តឡើងដោយបុព្វញាតិ ឬបច្ឆាញាតិ ក៏ដូចជាសហព័ទ្ធពិតមែននោះមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌមានអានុភាពអនុវត្តចំពោះករណីនេះ។

**ឧទាហរណ៍៖** លោក **ក** បានលួចទូរស័ព្ទរបស់លោក **ខ** ដែលត្រូវជាជីតារបស់ខ្លួនទៅលក់ ចំពោះករណីនេះ តុលាការមិនអាចផ្តន្ទាទោសលោក **ក** បានឡើយ ព្រោះលោក **ក** ត្រូវជាចៅ(បច្ឆាញាតិ) របស់លោក **ខ** ដែលត្រូវបានផ្តល់អភ័យឯកសិទ្ធិគ្រួសារតាមមាត្រា ៣៥៥ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

### ខ. ករណីប្រធានសក្តិ

ប្រធានសក្តិ សំដៅដល់ព្រឹត្តិការណ៍កើតឡើងក្រៅឆន្ទៈ ដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុន និងមិនអាចជំនះបានដូចជា គ្រោះធម្មជាតិ(ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម អគ្គិភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ។ ដូចករណី រន្ទះបាញ់បានបាញ់ឡានមួយគ្រឿងដែលកំពុងបើកបរនៅលើផ្លូវធ្វើឱ្យបែកកង់ឡាន ហើយឡានក៏បានជ្រុលទៅបុកហាងមួយកន្លែង បណ្តាលឱ្យខូចខាតសម្ភារៈ និងរបួសអ្នកនៅអង្គុយជិតនោះ។ ចំពោះករណីនេះ ច្បាប់មិនបុគ្គលដែលប្រព្រឹត្តបទល្មើស ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលកើតឡើងដោយករណីប្រធានសក្តិនេះឡើយ។

ការមិនទទួលខុសត្រូវព្រហ្មទណ្ឌក៏មានការរំលត់បណ្តឹងអាជ្ញាចូលរួមផងដែរ (សូមអានមាត្រា ៧ និងមាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ សរុបជារួមមក ដោយផ្អែកតាមមាត្រា ៣៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ បានចែងអំពី ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដោយខ្លឹមសារនៃមាត្រានេះបានចែងថា បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយឡើយ។

# ជំពូកទី ៣
# ការអនុវត្តទោសព្រហ្មទណ្ឌ

# ជំពូកទី ៣
# ការអនុវត្តទោសព្រហ្មទណ្ឌ

ចំពោះទោស គឺជាដំណាក់កាលចុងក្រោយក្នុងសម្រេចចិត្តរបស់ចៅក្រម ក្នុងការផ្តន្ទាទោសទៅលើជនល្មើស ពេលបន្ទាប់ពីបានកំណត់អំពើណាមួយជាបទល្មើស ដែលមានពិរុទ្ធភាពរួចមក ចៅក្រមនឹងពិចារណាអំពីការផ្តន្ទាទោស ចំពោះជនល្មើសដែលបានប្រព្រឹត្តបទល្មើស។

ទោសត្រូវបានគេបែងចែកដាច់ពីសំណងរដ្ឋប្បវេណី និងទណ្ឌកម្មវិន័យ ព្រោះថាទោសមានគោលបំណងការពារផលប្រយោជន៍សាធារណៈ មានន័យថាបម្រើឱ្យផលប្រយោជន៍សង្គមជាតិទាំងមូល។ ចំណែកសំណងរដ្ឋប្បវេណី និងទណ្ឌកម្មវិន័យវិញ គឺដើម្បីការពារផលប្រយោជន៍របស់ក្រុមណាមួយ ទោះបីក្រុមនោះជាបុគ្គលក្តី ជាសមូហភាពក្តី[97]។

អាស្រ័យដូចនេះ ជាដំបូងយើងត្រូវឈ្វេងយល់អំពីសញ្ញាណនៃទោស **(ផ្នែកទី១)** ជាមុនសិន ហើយដំណាក់កាលបន្តត្រូវសិក្សាពីទោសដែលត្រូវអនុវត្តចំពោះជនល្មើសជារូបវន្តបុគ្គល **(ផ្នែកទី២)** និងទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល **(ផ្នែកទី៣)**។

## ផ្នែកទី១៖ សញ្ញាណនៃទោស

ការប្រព្រឹត្តផ្ទុយពីការហាមឃាត់របស់ច្បាប់ព្រហ្មទណ្ឌជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវទទួលទោសព្រហ្មទណ្ឌទៅតាមច្បាប់កំណត់។ ចំពោះទស្សនៈផ្នែកច្បាប់ ទោសព្រហ្មទណ្ឌ គឺជាទោសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ[98]។ ដូច្នេះ តើអ្វីជាទោសព្រហ្មទណ្ឌ?

ដើម្បីយល់កាន់តែច្បាស់អំពីទោសព្រហ្មទណ្ឌ គប្បីត្រូវឈ្វេងយល់នូវចំណុចមួយចំនួនដូចជា និយមន័យនៃទោស (១) គោលបំណងនៃទោស (២) និងចុងក្រោយគឺ ចរិតលក្ខណៈនៃទោស (៣)។

### ១. និយមន័យនៃទោស

ទោស គឺជាទណ្ឌកម្មដែលត្រូវបានផ្តន្ទាដោយសង្គម តាមរយៈច្បាប់រាល់បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើស។[99] ហើយទោស ក៏ជាទណ្ឌកម្មដែលត្រូវបានកំណត់ដោយសង្គម ដើម្បីទុកផ្តន្ទាទោសទៅលើជនល្មើស ដែលបានប្រព្រឹត្តបទល្មើស។

ជារួមទោស ជាវិធានខាងផ្នែកយុត្តាធិការដែលត្រូវបានអនុវត្តតឹងរឹងបំផុតរបស់រដ្ឋ ដែលត្រូវបានចែងទុកនៅក្នុងច្បាប់ជាធរមាន នឹងត្រូវបានប្រកាសដោយស្ថាប័នតុលាការជាអ្នកសម្រេចផ្តន្ទាទោសជនល្មើស។

[97] សៀវភៅនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ **ហ៊ាង ឡេង**។

[98] ប្រសាសន៍របស់ឯកឧត្តម **ផូវ សំភី** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា និងជាអគ្គនាយកកិច្ចការរដ្ឋបាលតុលាការ ក្រសួងយុត្តិធម៌។

[99] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

## ២. គោលបំណងនៃទោស

ប្រសិនបើយើងចង់កែប្រែទង្វើបុគ្គលណាម្នាក់ ដែលធ្លាប់ប្រព្រឹត្តអំពើទុច្ចរិត ដែលបង្កព្យសនកម្មដល់សង្គម ឬដល់អ្នកដទៃ ឱ្យមកក្លាយជាមនុស្សល្អវិញ ជាការចំបាច់ណាស់ត្រូវដាក់ទណ្ឌកម្មដល់ពួកគេ ដើម្បីឱ្យមានភាពរាងចាល និងលែងចង់ប្រព្រឹត្តអំពើនោះបន្តទៀត។ អាស្រ័យហេតុនេះ ជម្រើសក្នុងការដាក់ទោសទៅលើជនទាំងនេះ គឺក្នុងគោលបំណងពុំមែនត្រឹមតែបង្ក្រាបជនល្មើសតែប៉ុណ្ណោះទេ ពោលគឺនៅមានគោលបំណងអប់រំកែប្រែបុគ្គលទាំងនោះឱ្យមកក្លាយទៅជាមនុស្សមានផលប្រយោជន៍សម្រាប់ប្រទេសជាតិ ឬសង្គមវិញ និងរាំងស្កាត់បទល្មើសថ្មីៗមិនឱ្យកើតមានឡើងជាបន្តទៀត។

ចំពោះគោលបំណងនៃការដាក់ទោសនេះ គឺយើងអាចពិនិត្យឃើញមានចំណុចបីធំៗ ដែលមានដូចជា គោលបំណងការការពារទុកជាមុន (២.១) គោលបំណងនៃការធ្វើសំណងជាប្រាក់ (២.២) និងគោលបំណងនៃការអប់រំកែប្រែ (២.៣)។

### ២.១ គោលបំណងនៃការការពារទុកជាមុន(បំភិតបំភ័យ)

ចំពោះគោលបំណងនៃការការពារទុកជាមុន គឺមានន័យថាជាការដាក់ទណ្ឌកម្មទៅលើជនដែលបានប្រព្រឹត្តអំពើល្មើសម្នាក់ ដើម្បីគំរាមដល់ជនទូទៅកុំឱ្យប្រព្រឹត្តល្មើសតាមជននោះ។ ការការពារទុកជាមុននេះ មានគោលបំណងសំខាន់ៗពីរគឺ ធ្វើឱ្យរុញរាចំពោះបុគ្គលណាមួយ(ការភ័យខ្លាចចំពោះការផ្តន្ទាទោស) និងធ្វើឱ្យរាង៉េកក្នុងការចង់ប្រព្រឹត្តបទល្មើស តួយ៉ាងដូចជា ជនប្រព្រឹត្តបទល្មើសដែលត្រូវបានគេដាក់ទោសនោះជាស្ថាពរហើយ គឺជាឧទាហរណ៍ដ៏សំខាន់ក្នុងការផ្តល់ជាគតិមួយសម្រាប់ឱ្យអ្នកដទៃធ្វើការពិចារណា។ ពោលគឺការបង្អាក់គំនិតព្រមទាំងការគិតរបស់ពួកគេដែលចង់ប្រព្រឹត្តបទល្មើស ឱ្យងាកមកគិតពិចារណាបានវែងឆ្ងាយ មុននឹងប្រព្រឹត្តបទល្មើសណាមួយ។

សរុបជារួមមក ការដាក់ទោសលើជនល្មើសបណ្តាលឲ្យជនដ៏ទៃទៀត ដែលមានបំណងប្រព្រឹត្តបទល្មើស ខ្លាចលែងហ៊ានប្រព្រឹត្តទៀត ចំណែកឯជនមិនទាន់បានប្រព្រឹត្តបទល្មើសក៏មានការភ័យខ្លាចនឹងមិនហ៊ានប្រព្រឹត្តបទល្មើសឡើយ ពោលព្រោះខ្លាចជាប់ទោស ឬទណ្ឌកម្មព្រហ្មទណ្ឌណាមួយ។

### ២.២ គោលបំណងនៃការធ្វើសំណងជាប្រាក់

គោលបំណងនៃការធ្វើសំណងជាប្រាក់ គឺជាការដាក់បន្ទុកទៅលើជនល្មើស ដែលជាបុគ្គលអ្នកបង្កនូវព្យសនកម្ម ដែលបានធ្វើឱ្យប៉ះពាល់ព្រមទាំងខូចខាតដល់ជនដទៃ ឬក៏សណ្តាបធ្នាប់សង្គមជាតិជាដើម។ ហើយចំពោះការដាក់ទោសលើការធ្វើសំណងជាប្រាក់ គឺត្រូវបានកម្រិតលើមូលដ្ឋាននៃពិរុទ្ធភាពរបស់ជនល្មើស និងលើមូលដ្ឋាននៃការខូចខាតដែលសង្គមបានទទួលរងគ្រោះ គឺបានសេចក្តីថា ការដាក់ទោសលើជនល្មើសត្រូវផ្អែកលើភាពមានទោសរបស់ជនល្មើស និងព្យសនកម្មទាំងឡាយដែលកើតឡើងដោយអំពើរបស់ជនល្មើស។

ការធ្វើយ៉ាងនេះ គឺក្នុងគោលបំណង ធ្វើឱ្យរំងាប់ការឈឺចាប់របស់ជនរងគ្រោះ និងមតិសាធារណៈបាន រំងាប់ស្ងប់ស្ងាត់ទៅវិញ។ ចំណុចនេះមានន័យថា អំពើដែលជនល្មើសបានប្រព្រឹត្តបង្កព្យសនកម្ម នោះជនដែលបង្កនោះត្រូវទទួលសងសំណងជាប្រាក់ដល់ជនរងគ្រោះ ឬក៏ត្រូវសងទៅរដ្ឋ ដើម្បីរៀបចំជួសជួលសណ្តាប់ធ្នាប់សាធារណៈ ដែលជននោះបានបង្កឱ្យមានរបៀបរៀបរយឡើងវិញ។

## ២.៣ គោលបំណងនៃការអប់រំកែប្រែ

គោលបំណងនៃការអបរំនេះមិនខុសច្រើនពីគោលបំណងទី១ខាងលើទេ គឺមានគោលបំណងរួមមួយក្នុងការធ្វើសមាហរណកម្មជនល្មើសដែលបានប្រព្រឹត្តបទល្មើសឱ្យត្រឡប់ចូលក្នុងសង្គមវិញ។

ចំពោះគោលបំណងនៃការដាក់ទោសនេះ មិនមែនសំដៅទៅលើការធ្វើទារុណកម្មលើរូបរាងកាយជនល្មើសនោះទេ គោលបំណងចំបងបំផុត គឺសំដៅទៅលើការអប់រំកែប្រែជនល្មើស ឱ្យកែប្រែអត្តចរិតពីមនុស្សកោងកាច ឃោឃៅ ឱ្យទៅជាមនុស្សមានផលប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល។ ក្នុងចំណុចនេះមានន័យថា បុគ្គលដែលធ្លាប់ប្រព្រឹត្តអំពើទុច្ចរិត ឬអំពើល្មើស ហើយក្រោយមកបានកែប្រែអត្តចរិតអប់រំចិត្តគំនិតខ្លួន និងអាចត្រឡប់មកប្រព្រឹត្តអំពើត្រឹមត្រូវវិញក្នុងសង្គម ក៏ត្រូវមានឈ្មោះជាមនុស្សល្អផងដែរ។

## ៣. ចរិតលក្ខណៈនៃទោសព្រហ្មទណ្ឌ

យើងពិនិត្យឃើញថា ចំពោះទោសព្រហ្មទណ្ឌមានចរិតលក្ខណៈ ៣ ប្រភេទ ដែលមានដូចតទៅ ចរិតលក្ខណៈនីត្យានុកូលនៃទោស **(៣.១)** ចរិតលក្ខណៈសមភាព **(៣.២)** និងចរិតលក្ខណៈឯកត្តជន **(៣.៣)**។

### ៣.១ ចរិតលក្ខណៈនីត្យានុកូលនៃទោស

ចរិតលក្ខណៈនីត្យានុកូលនៃទោស គឺចង់សំដៅដល់ចរិតលក្ខណៈផ្អែកលើច្បាប់បានន័យថា ទោសទាំងអស់ត្រូវតែមាននៅក្នុងច្បាប់ ហើយកំពុងតែស្ថិតនៅជាធរមានទៀតផង បើគ្មានច្បាប់ចែងទេនោះ ចៅក្រមមិនអាចយកទោសនោះមកធ្វើការប្រកាសបានឡើយ។

យោងតាមក្រមព្រហ្មទណ្ឌ គ្រប់ទោសទាំងអស់ត្រូវតែមានចែងយ៉ាងច្បាស់ដោយច្បាប់ ផ្ទុយមកវិញប្រសិនបើពុំមានច្បាប់ចែងទេ ទោសក៏ពុំអាចយកមកអនុវត្តបានដែរ នេះគឺជាអ្វីដែលគេតែងតែហៅថា គោលការណ៍នីត្យានុកូលភាពនៃទោស។

សរុបជារួមមកថា ដើម្បីធ្វើការផ្តន្ទាទោសចំពោះអំពើណាមួយបាន គឺទាមទារឱ្យមានច្បាប់ចែងទុក ទើបអាចធ្វើការចោទប្រកាន់ និងដាក់ទោសចំពោះអំពើនោះបាន។ ហេតុនេះ ទោសទាំងអស់ត្រូវតែមានចែងនៅក្នុងច្បាប់ ប៉ុន្តែច្បាប់មិនបានចែងទោសបញ្ញត្តដោយរបៀបតឹងរ៉ឹងពេកទេ ពោលគឺជានិច្ចកាលតែងតែទុកចន្លោះ ដើម្បីឱ្យចៅក្រមធ្វើការពិចារណា ដោយផ្អែកលើស្ថានភាពទម្ងន់ទោស ឬស្ថានភាពសម្រាលទោស ក្នុងការកំណត់

ទណ្ឌកម្មឱ្យបានសមស្របទៅនឹងអំពើប្រព្រឹត្តរបស់ជនល្មើស[100]។ មានន័យថា ការកំណត់របស់ចៅក្រម គឺគិតពីស្ថានសម្រាល ឬក៏ស្ថានទម្ងន់ វាអាស្រ័យទៅលើសភាពព្យសនកម្មរបស់ជនល្មើសដែលបានបង្កឡើង។

**ឧទាហរណ៍៖**

- ❖ បទឃាតកម្ម មាត្រា១៩៩ ក្នុងក្រមព្រហ្មទណ្ឌ២០០៩ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ ទៅ ១៥ ឆ្នាំ។
- ❖ បទល្មើសហិង្សា មាត្រា២១៧ ក្នុងក្រមព្រហ្មទណ្ឌ២០០៩ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ ទៅ ៦.០០០.០០០ រៀល។
- ❖ បទឆបោក មាត្រា៣៧៧ និងទោសដែលត្រូវអនុវត្ត មាត្រា៣៧៨ ក្នុងក្រមព្រហ្មទណ្ឌ២០០៩ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ ទៅ ៦.០០០.០០០ រៀល។

### ៣.២ ចរិតលក្ខណៈសមភាពនៃទោស

ចំពោះការដាក់ទោស គឺមិនត្រូវគិតអំពីតួនាទី ឬឋានៈ នៅក្នុងសង្គមរបស់អ្នកត្រូវបានផ្តន្ទាទោសនោះទេ ពោលគឺប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដូចមានចែងក្នុង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៣១ និងមាត្រាបន្តបន្ទាប់។ ចរិតលក្ខណៈសមភាពនៃទោស ទាញចេញពីការអនុវត្តនូវគោលការណ៍សមភាពរវាងពលរដ្ឋគ្រប់រូប។

**ឧទាហរណ៍៖**

មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌបានកំណត់ទោសដាក់ពន្ធនាគារពី០៥ឆ្នាំ ទៅ១០ឆ្នាំ សម្រាប់បទរំលោភសេពសន្ថវៈ ដោយមិនបានធ្វើការគូសបញ្ជាក់ថា ទោសនេះត្រូវអនុវត្តតែទៅលើបុរស ឬស្ត្រី អ្នកមាន ឬអ្នកក្រីក្រ អ្នកមានតួនាទីក្នុងសង្គម ឬក៏មន្ត្រីរាជការឡើយ។

### ៣.៣ ចរិតលក្ខណៈឯកត្តជននៃទោស

ចរិតលក្ខណៈឯកត្តជននៃទោស គឺជាប្រភពនៃគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ យោងតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បានចែងថា បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។

នៅត្រង់ចំណុចខាងលើនេះមានន័យថា ទោសមានចរិតលក្ខណៈជាឯកត្តជនគឺទោសត្រូវតែផ្តន្ទាទៅលើបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ បានសេចក្តីថា មានតែបុគ្គលដែលបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់(ចារី និងសហចារី) ឬដោយប្រយោល(អ្នកផ្តើមគំនិត និងអ្នកសមគំនិត)នោះទេ ដែលត្រូវបានចាត់ទុកថាជាជនល្មើស ហើយនឹងត្រូវបានផ្តន្ទាទោស។ អាចនិយាយបានថា គឺហាមឃាត់ដាច់ខាតការទទួលខុសត្រូវចំពោះអំពើរបស់អ្នកដទៃ មានន័យថា អ្នកណាធ្វើ អ្នកនោះជាអ្នកទទួល មិនអាចឱ្យអ្នក

[100] ក្រមនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោក សាស្ត្រាចារ្យ **ហ៊ាង ឡេង**។

ដទៃមកទទួលជំនួសឡើយ។ តាមគោលការណ៍ខាងលើនេះ ចៅក្រមមិនអាចធ្វើការប្រកាសទោសទៅលើជនដែលមិនពាក់ព័ន្ធបានឡើយ។

**ឧទាហរណ៍**៖ ឈ្មោះ **សុខៈ** បានយកកាំបិតចាក់សម្លាប់ឈ្មោះ **ពិសី** ដោយសារតែមានទំនាស់រឿងដីចំការជាមួយនឹងក្រុមគ្រួសាររបស់គាត់។ ក្នុងករណីនេះ មានតែឈ្មោះ **សុខៈ** ទេដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំណែកឯឪពុកម្តាយរបស់ឈ្មោះ **សុខៈ** មិនបានដឹងពីរឿងនេះទេ ហើយក៏មិនបានចូលរួមក្នុងការប្រព្រឹត្តសកម្មភាពល្មើសច្បាប់នេះដែរ។ ហេតុនេះឪពុកម្តាយរបស់ឈ្មោះ **សុខៈ** មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាមួយនឹង **សុខៈ** ឡើយ មានតែឈ្មោះ **សុខៈ** ម្នាក់ឯងគត់ដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ និងទទួលការផ្តន្ទាទោស។

## ផ្នែកទី២៖ ទោសដែលត្រូវអនុវត្តចំពោះជនល្មើសជារូបវន្តបុគ្គល

ចំពោះបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តអំពើល្មើស ដែលអំពើល្មើសនោះគឺផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌ បុគ្គលនោះនឹងត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។ យោងតាម**គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ** បានចែងថា បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។ នៅត្រង់ចំណុចនេះមានន័យថា ទោសមានចរិតលក្ខណៈជាឯកត្តជន ពោលដូចបានបកស្រាយខាងលើរួចមកហើយថា ទោសត្រូវតែផ្តន្ទាទៅលើបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ បានសេចក្តីថា មានតែបុគ្គលដែលបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់(ចារី និងសហចារី) ឬដោយប្រយោល (អ្នកផ្តើមគំនិត និងអ្នកសមគំនិត)នោះទេ ដែលត្រូវបានចាត់ទុកថាជាជនល្មើស ហើយនឹងត្រូវបានផ្តន្ទាទោស។

យើងអាចនិយាយឱ្យខ្លីបានថា គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ គឺចង់សំដៅថា បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ ពោលគឺហាមឃាត់ដាច់ខាត ការទទួលខុសត្រូវចំពោះអំពើរបស់អ្នកដទៃ (អ្នកណាធ្វើ អ្នកនោះជាអ្នកទទួល មិនអាចឱ្យអ្នកដទៃមកទទួលជំនួសឡើយ)។

**ឧទាហរណ៍**៖ លោក **ពិសិដ្ឋ** និងលោក **ភារម្យ** បានព្រមព្រៀងគ្នាថានឹងរំលោភសេពសន្ថវៈទៅលើនារីម្នាក់ឈ្មោះ **ខ** នៅពេលយប់ស្ងាត់ ដោយពេលវេលាល្អ លោកទាំងពីរនេះក៏បានរំលោភនារីឈ្មោះ **ខ** នោះបានសម្រេច។ ក្នុងករណីនេះ មានតែលោក **ពិសិដ្ឋ** និងលោក **ភារម្យ** តែប៉ុណ្ណោះ ដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំណែកឯលោក **មករា** ដែលត្រូវជាមិត្តរបស់លោកទាំងពីរនោះ មិនបានដឹងពីរឿងនេះទេ ហើយក៏មិនបានចូលរួមប្រព្រឹត្តសកម្មភាពល្មើសច្បាប់នេះដែរ។ អាស្រ័យដូចនេះ លោក **មករា** មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាមួយនឹងលោក **ពិសិដ្ឋ** និងលោក **ភារម្យ** ឡើយ ពោលគឺមានតែលោកទាំងពីរនេះទេដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ហើយនឹងត្រូវទទួលនូវការផ្តន្ទាទោស (ផ្អែកតាមមាត្រា ២៣៩ និងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌកម្ពុជា)។

ចំពោះការប្រកាសទោសរបស់តុលាការ គឺផ្អែកតាមមាត្រា ៩៦ **គោលការណ៍ឯកត្តកម្មនៃទោស** ខ្លឹមសារនៃមាត្រានេះបានចែងថា តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស

ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុក ទៅលើមូលហេតុ ព្រម ទាំងទៅលើកិរិយាមាយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ។ តាមខ្លឹម សារនៃមាត្រានេះ គឺជាគោលការណ៍មូលដ្ឋានដែលមានបញ្ញាតិក្នុងក្រមព្រហ្មទណ្ឌ សម្រាប់ចៅក្រមយកមក ពិចារណាអំពីស្ថានភាពរបស់ជនល្មើស ក្នុងពេលប្រព្រឹត្តបទល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ពិចារណាអំពី ចរិតលក្ខណៈ ឬសភាពផ្លូវចិត្តរបស់ជនជាប់ចោទ និងទំហំព្យសនកម្មបង្កដល់ជនរងគ្រោះ និងសង្គមជាតិជា ដើម មុននឹងធ្វើការប្រកាសទោសព្រហ្មទណ្ឌ។

សរុបជារួមមក ក្រមព្រហ្មទណ្ឌកម្ពុជា បានចែងនូវគោលការណ៍សំខាន់ៗចំនួន ០២ ប្រភេទ មានដូចជា

**គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ៖** គឺចង់សំដៅដល់ការទទួលខុសត្រូវព្រហ្មទណ្ឌ តែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ។[101]

**ចំណែកគោលការណ៍ឯកត្តកម្មនៃទោសវិញ៖** គឺជាគោលការណ៍ដែលត្រូវបានបង្កើតឡើងទុកជាមូល ដ្ឋានគ្រឹះដល់ចៅក្រមជំនុំជម្រះពិចារណាទៅតាមស្ថានភាពរបស់បុគ្គលម្នាក់ៗដែលបានប្រព្រឹត្តបទល្មើស ដើម្បី ឈានទៅដល់ការប្រកាសទោសព្រហ្មទណ្ឌ។

នៅក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្ន បានចែកទោសព្រហ្មទណ្ឌជា ៣ ប្រភេទ មានដូចជា **មូលទោស(១) ទោសបន្ថែម (២) និងទោសជំនួស (៣)** ទោសទាំងបីនេះត្រូវបានតុលាការយកមកពិចារណាក្នុងការអនុវត្តចំពោះ ជនទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើស ឬអាចហៅបុគ្គលនោះថាជា ជនល្មើស។ អាស្រ័យដូចនេះ ចំណុចបន្ទាប់យើងខ្ញុំនឹងធ្វើការសិក្សាស្រាវជ្រាវ ថាតើតុលាការដាក់ទោស ឬប្រកាសទោសទាំងបីខាងលើឱ្យអនុ វត្តទៅលើជនល្មើសដោយបែបណាខ្លះ?

### ១. មូលទោស

តើមូលទោសជាអ្វី? **មូលទោស** សំដៅទៅលើទោសសំខាន់ចម្បងជាងគេ ដែលតុលាការអាចប្រកាស ទោសតែឯង ដើម្បីផ្តន្ទាទោសចំពោះបទល្មើសណាមួយ[102]។ **មូលទោស** ជាទោសដែលអាចយកទៅសម្រេចផ្ត ន្ទាដាច់តែឯងបាន ដោយអាចរួមបញ្ចូលទាំងទោសបន្ថែមក៏បាន ឬមិនបញ្ចូលទោសបន្ថែមក៏បានដែរ[103]។ **មូល ទោស** គឺជាទោសដែលត្រូវយកមកផ្តន្ទាចំពោះគ្រប់បទល្មើសទាំងអស់។

ដោយផ្អែកតាមក្រមព្រហ្មទណ្ឌមាត្រា ៤៣ មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ដោយឡែកទោសប្រហារជីវិតត្រូវបានលុបចោល តាមមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៨៩ និងគូសបញ្ជាក់សា

---

[101] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៤។

[102] ប្រសាសន៍របស់ឯកឧត្តម **កើត រិទ្ធិ** តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

[103] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០១២។

ជាថ្មីនៅក្នុងមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន។

- **ទោសដាក់ពន្ធនាគារៈ** ទោសដាក់ពន្ធនាគារ គឺជាទោសដែលលុបបំបាត់ទាំងអស់ នូវសិទ្ធិសេរីភាពជាមូលដ្ឋាន ឬហៅជាសាមញ្ញថា ជាប់គុក។ ក្នុងការកំណត់ទោសដាក់ពន្ធនាគារ ច្បាប់កម្ពុជាបានកំណត់ អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ[104]។

យោងតាមក្រមព្រហ្មទណ្ឌ ទោសដាក់ពន្ធនាគារអាចជាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬជាទោសដាក់ពន្ធនាគារមានរយៈពេល ពោលទោសដាក់ពន្ធនាគារមានរយៈពេលអាចជាទោសដាក់ពន្ធនាគារមានរយៈពេលចាប់ពី ១ថ្ងៃ រហូតដល់ ៣០ឆ្នាំ ផ្អែកតាមមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ។

ចំពោះទោសដាក់ពន្ធនាគារ គឺការអនុវត្តត្រូវធ្វើនៅពន្ធនាគារ គឺមានន័យថា គេយកជនល្មើសទៅដាក់គុក។ ក្រមព្រហ្មទណ្ឌក៏បានកំណត់អំពីការគណនាអំពីចិរវេលានៃទោសដាក់ពន្ធនាគារ ដែលបានកំណត់ដូចខាងក្រោម[105]៖

- បើទោសដាក់ពន្ធនាគារដាក់រយៈពេល ១ថ្ងៃ ច្បាប់កំណត់ថា ១ថ្ងៃនេះត្រូវគិត ២៤ ម៉ោង។
- បើទោសដាក់ពន្ធនាគារ ១ខែ ច្បាប់កំណត់ថាត្រូវគិត ៣០ថ្ងៃ។ ទោសដាក់ពន្ធនាគារលើសពី ១ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ។
- បើសិនទោសដាក់ពន្ធនាគារ ១ឆ្នាំ ច្បាប់កំណត់ថាត្រូវគិត ១២ខែ។

បើទណ្ឌិតបានទទួលរងទោសនៅក្នុងពន្ធនាគារចប់សព្វគ្រប់ តាមចិរវេលាដូចបានកំណត់នៅក្នុងសេចក្តីសម្រេចផ្តន្ទាទោសហើយ ទណ្ឌិតនឹងត្រូវដោះលែងឱ្យមានសេរីភាពវិញ ប៉ុន្តែទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ត្រូវតែដោះលែងឱ្យមានសេរីភាពវិញនៅមុន ថ្ងៃឈប់សម្រាកនោះ (មាត្រា ៥០)។

**ឧទាហរណ៍៖**

លោក **ក** ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៦ខែ ឧបមាថា លោក **ក** ត្រូវបានចាប់ខ្លួន និងឃុំខ្លួនតាមអំណាចសាលក្រមផ្តន្ទាទោសនៅថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២១។ ហេតុនេះ ការគណនាចិរវេលា ៦ខែ ត្រូវធ្វើដូចតទៅ ៖ គិតពីថ្ងៃទី ២៥ ខែមករា រហូតដល់ថ្ងៃទី ២៥ ខែកុម្ភៈ មានចិរវេលា ១ខែ បើរហូត ដល់ថ្ងៃទី ២៥ ខែមីនា មានចំនួន ២ខែ ដូច្នេះ រហូតដល់ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០២១ គឺមានចិរវេលា ៦ខែ ។ ក្នុងន័យនេះ លោក **ក** ត្រូវតែដោះលែងឱ្យមាន សេរីភាពនៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០២១ ក៏ប៉ុន្តែដោយហេតុថា ថ្ងៃទី ២៥ កក្កដា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃសៅរ៍ ហេតុដូច្នេះ

[104] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៥។

[105] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៩។

លោក **ក** ត្រូវតែដោះលែងឱ្យមានសេរីភាពនៅថ្ងៃសុក្រ ទី២៤ ខែកក្កដា ឆ្នាំ២០២១ ពោលគឺមុនមួយថ្ងៃនៃថ្ងៃឈប់សម្រាក។[106]

ថិរវេលានៃការឃុំខ្លួនជាបណ្ដោះអាសន្ន ត្រូវយកមកបញ្ចូលនឹងរយៈពេលនៃទោសដែរ។ ជាក់ស្ដែងមាត្រា ៥១ នៃក្រមព្រហ្មទណ្ឌ តម្រូវឱ្យគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល។

**ឧទាហរណ៍៖**

លោក **ក** ត្រូវបានតុលាការសម្រេចដាក់ទោសពន្ធនាគារចំនួន ១ឆ្នាំ។ ជាក់ស្ដែង សាលក្រមដែលបានសម្រេចផ្ដន្ទាទោសបានប្រកាសនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ ប៉ុន្តែលោក **ក** ត្រូវបានចៅក្រមស៊ើបសួរសម្រេចឱ្យឃុំខ្លួន ជាបណ្ដោះអាសន្ន តាំងពីថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២១។ ហេតុដូច្នេះ រយៈពេល ១ឆ្នាំ ត្រូវគិតចាប់ពីថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២១ មិនមែនគិតពីថ្ងៃប្រកាសសាលក្រមនៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២១ ទេ ព្រោះរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ដាច់ខាតត្រូវតែរាប់បញ្ចូលទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារ (សៀវភៅនីតិព្រហ្មទណ្ឌទូទៅឆ្នាំ២០២២ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**)។

- ❖ **ទោសពិន័យ៖** ការពិន័យត្រូវគិតជាប្រាក់រៀល[107] ហើយផលដែលបានចេញពីការពិន័យជាប្រាក់នេះ ត្រូវបង់ចូលទៅក្នុងថវិការដ្ឋ[108]។ ទោសពិន័យជាប្រាក់នេះ ខុសពីទោសសងជម្ងឺចិត្ត ពោលទោសពិន័យ ជាប្រភេទនៃទោសព្រហ្មទណ្ឌ គឺខុសពីទោសទណ្ឌកម្មផ្សេងទៀត។ ចំពោះសំណងជម្ងឺចិត្ត ត្រូវបង់ទៅឱ្យជនរងគ្រោះ និងត្រូវគិតគូរទៅតាមទំហំនៃព្យសនកម្ម ប៉ុន្តែប្រាក់ពិន័យ គឺចៅក្រមមិនអាចធ្វើអ្វីខុសពីការកំណត់របស់ច្បាប់ទេ ពោលច្បាប់បានកំណត់ជាស្រេចអំពីអប្បបរមា និងអតិបរមាដែលត្រូវពិន័យ។

ដើម្បីកំណត់ទោសទៅលើបទល្មើសណាមួយបាន លុះត្រាតែយើងមើលទៅលើលក្ខណៈសម្គាល់នៃបទល្មើសនីមួយៗ។ ដើម្បីអាចសម្គាល់ថាបទល្មើសមួយជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុនោះ យើងត្រូវពិនិត្យទៅលើអតិបរមានៃទោសដាក់ពន្ធនាគារ។តាមក្រមព្រហ្មទណ្ឌ មាត្រា ៤៦, ៤៧ និង៤៨ បានកំណត់អំពីរបៀបក្នុងការសម្គាល់ថា បទល្មើសមួយជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុបាន តាមរយៈទោសដាក់ពន្ធនាគារក្នុងករណីដូចខាងក្រោម៖

---

[106] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០១២។

[107] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៣។

[108] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥២។

- ទោសដាក់ពន្ធនាគារនោះជាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬជាទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ ប៉ុន្តែលើសពី ៥ឆ្នាំឡើងទៅ ដល់ក្រោម ឬស្មើនឹង ៣០ឆ្នាំ នៅក្នុងករណីនេះ ច្បាប់បានកំណត់ថាជាបទឧក្រិដ្ឋ។

- ទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ថ្ងៃ ដល់ក្រោម ឬស្មើនឹង ៥ឆ្នាំ ក្រមព្រហ្មទណ្ឌចាត់ទុកថាបទល្មើសនោះជាបទមជ្ឈិម។

- ចំពោះបទលហុ ត្រូវវិនិច្ឆ័យនៅក្នុងករណីពីរគឺ ការមើលទៅលើទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានរយៈពេលក្រោម ឬស្មើនឹង ៦ថ្ងៃ និងទោសត្រឹមតែពិន័យជាប្រាក់។

អាស្រ័យដូចបានរៀបរាប់ខាងលើអំពីមូលទោសរួចមក ដូចនេះខាងក្រោមនេះគឺឈានដល់ការបកស្រាយអំពីការយកមូលទោសទៅអនុវត្តចំពោះជនល្មើសវិញម្តង មូលទោសដែលអនុវត្តចំពោះជនល្មើសជានីតិជន (១.១) និងមូលទោសដែលអនុវត្តចំពោះជនល្មើសជាអនីតិជន (១.២)។

### ១.១ មូលទោសដែលអនុវត្តចំពោះជនល្មើសជានីតិជន

នីតិជន សំដៅដល់ជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដោយផ្អែកតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌបានចែងថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី ១៨ឆ្នាំឡើងទៅ។ ចំពោះគោលបំណងនៃមាត្រានេះ មានន័យថាជនដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ គឺត្រូវទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងពេញលេញ ដូចនេះនីតិជនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងពេញលេញទៅតាមច្បាប់កំណត់។

សូមបញ្ជាក់ថា ទោះបីជាទទួលខុសត្រូវពេញលេញក៏ដោយ ហើយបើទោះបីបទល្មើសខ្លះ តម្រូវឱ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារផង និងទោសពិន័យផងក៏ដោយ ក៏មិនមានន័យថា តុលាការមានកាតព្វកិច្ចត្រូវតែប្រកាសទោសទាំងពីរនេះជាមួយគ្នាទេ។ ករណីនេះគឺផ្អែកតាមមាត្រា **៩៧** នៃក្រមព្រហ្មទណ្ឌ ស្តីពីការប្រកាសមូលទោស ពោលមាត្រានេះបានចែងថា នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាសៈ

- ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ
- ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ
- ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។

### ១.២ មូលទោសដែលអនុវត្តចំពោះជនល្មើសជាអនីតិជន

អនីតិជនដែលមានអាយុតិចជាង ១៤ឆ្នាំ តុលាការមិនអាចប្រកាសទោសចំពោះអំពើរបស់អនីតិជននោះបានទេ។ ចំណែកឯអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ តុលាការអាចប្រកាសទណ្ឌកម្មបាន ចំពោះទណ្ឌកម្មដែលក្រមព្រហ្មទណ្ឌសំដៅដល់នោះគឺ ទោស។ ដោយគោរពតាមមាត្រា ៣៩ កថាខណ្ឌទី២ នៃក្រម

ព្រហ្មទណ្ឌឆ្នាំ២០០៩ បានចែងថា តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ មានន័យថា តុលាការត្រូវថ្លឹងថ្លែងពាក់ព័ន្ធនឹងកាលៈទេសៈនៃបទល្មើស ឬបុគ្គលលក្ខណៈរបស់អនីតិជនដែលប្រព្រឹត្តល្មើសនោះ មុនឈានដល់ការសម្រេចផ្តន្ទាទោស ឬក៏មិនផ្តន្ទាទោស ព្រោះដោយមូលហេតុថា អនីតិជនដែលបានប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ[109]។

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ៖

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។

អនីតិជន មិនអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាលឡើយ[110]។ អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន។ អនីស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែងសម្រាប់អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។[111]

## ២. ទោសបន្ថែម

តើទោសបន្ថែមជាអ្វី? ទោសបន្ថែម គឺជាទោសមួយប្រភេទដែលបន្ថែមទៅលើមូលទោស ពេលតុលាការអាចប្រកាសទោសបន្ថែមបាន លុះត្រាតែបានសម្រេចផ្តន្ទានូវមូលទោសណាមួយជាមុនសិន។ ចំពោះការលើកឡើងខាងលើនេះ មានន័យថា ជាទូទៅ ក្រោយពេលចៅក្រមប្រកាសមូលទោសហើយ ទើបទោសបន្ថែមអាចត្រូវបានប្រកាស ផ្អែកតាមមាត្រា ៩៩ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែទោសបន្ថែមអាចត្រូវអនុញ្ញាតឱ្យប្រកាសជំនួសមូលទោសបាន ផ្អែកតាមលក្ខខណ្ឌមាត្រា ១០០ នៃក្រមព្រហ្មទណ្ឌ។

[109] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៩ កថាខណ្ឌទី ១។

[110] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦៣។

[111] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦៦ ។

### ២.១ ទោសបន្ថែមសម្រាប់អនុវត្តចំពោះជនល្មើសជានីតិជន

ចៅក្រមអាចប្រកាសទោសបន្ថែមទៅលើជនដែលប្រព្រឹត្តបទល្មើស ដែលជានីតិជនមួយ ឬច្រើនបាន។ ចំពោះទោសបន្ថែមដែលអាចអនុវត្តចំពោះនីតិជន មានដូចតទៅ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ (ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៥៥)។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ (ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៥៦)។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ (ក្រមព្រហ្មទណ្ឌមាត្រា ៥៧)។

៤-ការព្យួរលិខិតបើកបរ (ក្រមព្រហ្មទណ្ឌមាត្រា ៥៨)។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ (ក្រមព្រហ្មទណ្ឌមាត្រា ៥៩)។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា (ក្រមព្រហ្មទណ្ឌមាត្រា៦០)។

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស (ក្រមព្រហ្មទណ្ឌមាត្រា ៦១)។

៨-ការរឹបអូសឧបករណ៍សម្ភារៈបទល្មើស ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្ត ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។[112]

៩-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។[113]

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស។[114]

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន។[115]

[112] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៦២។

[113] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៦៥។

[114] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៦៦។

[115] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៦៧។

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។[116]

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។[117]

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។[118]

ចំពោះបទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត។

ចំពោះពេលនៃការអនុវត្តទោសបន្ថែមវិញ ត្រង់មាត្រា ៧១ បានចែងថា ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១,២,៣,៤,៥,៦ និង៧ នៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ ត្រូវអនុវត្តនៅពេលផុតទោសពន្ធនាគារ លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់តុលាការ។

យោងតាមមាត្រា **៥៤** នៃក្រមព្រហ្មទណ្ឌ ទោសបន្ថែមអាចនឹងប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងយ៉ាងជាក់លាក់ ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុដែលត្រូវបានចោទប្រកាន់។ ហេតុដូច្នេះប្រសិនបើច្បាប់ពុំបានចែងសោះថា ចំពោះបទល្មើសណាមួយ អាចត្រូវប្រកាសទោសបន្ថែមណាមួយឱ្យជាក់លាក់ទេ តុលាការក៏មិនអាចប្រកាសនូវទោសបន្ថែមណាមួយបានឡើយ។

**ឧទាហរណ៍ ៖** សម្រាប់ បទទ្វេពន្ធភាព ដែលមានចែងនៅក្នុងមាត្រា ៣៥០ នៃកមព្រហ្មទណ្ឌ គេពុំឃើញមានបទប្បញ្ញត្តិណាមួយនៃក្រមដែលចែងពីទោសបន្ថែម ចំពោះបទល្មើសនេះឡើយ ។ ហេតុនេះ ចំពោះបទល្មើសនេះ តុលាការមិនអាចប្រកាសនូវទោសបន្ថែមណាមួយបានជាដាច់ខាត។[119]

## ២.២ ទោសបន្ថែមសម្រាប់អនុវត្តចំពោះជនល្មើសជាអនីតិជន

ចំពោះទោសបន្ថែមដែលអនុវត្តចំពោះអនីតិជន មានលក្ខណៈខុសពីទោសបន្ថែមដែលអនុវត្តចំពោះអនីតិជន។ យោងតាមក្រមព្រហ្មទណ្ឌ មាត្រា ១៦១ បានចែងថា មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន៖

១- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។

២- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

៣- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៤- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

---

[116] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៦៨។

[117] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៦៩។

[118] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧០។

[119] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០១២។

៥- ការហាមឃាត់ការកាន់កាប់ ឬការយកមកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

**កំណត់សម្គាល់៖** ដូចការប្រកាសទោសបន្ថែមនៅចំណុច (ទោសបន្ថែមសម្រាប់អនុវត្តចំពោះជនល្មើសជានីតិជន) ខាងលើដែរ ដោយយោងតាមមាត្រា **៥៤** នៃក្រមព្រហ្មទណ្ឌ ទោសបន្ថែមអាចនឹងប្រកាសទៅបានលុះត្រាតែទោសនេះត្រូវបានចែងយ៉ាងជាក់លាក់ ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវបានចោទប្រកាន់។ ហេតុដូច្នេះ ប្រសិនបើច្បាប់ពុំបានចែងសោះថា ចំពោះបទល្មើសណាមួយ អាចត្រូវប្រកាសទោសបន្ថែមណាមួយឱ្យជាក់លាក់ទេ តុលាការក៏មិនអាចប្រកាសនូវទោសបន្ថែមណាមួយបានឡើយ។

ជាទូទៅ តុលាការអាចប្រកាសទោសបន្ថែមក៏បាន មិនប្រកាសក៏បាន តែលើកលែងករណីច្បាប់ចែងថាទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់[120]។ ករណីបែបនេះតុលាការត្រូវតែប្រកាសជាដាច់ខាតបន្ថែមលើមូលទោស។ **ឧទាហរណ៍៖** មាត្រា ៨ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ការផលិត ការនាំចេញ ដើម្បីធ្វើអាជីវកម្ម ការលក់ឧបករណ៍ល្បែងស៊ីសងគ្រប់ប្រភេទ ដោយខុសច្បាប់ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពី ៥សែនរៀល ដល់ ៥លានរៀល និងដាក់គុកពី ១ខែ ដល់ ១ឆ្នាំ។ ឧបករណ៍ជាវត្ថុតាងខាងលើនេះត្រូវតែរឹបអូស ដូច្នេះ អនុលោមតាមបញ្ញត្តិនេះ តុលការដាច់ខាតត្រូវតែប្រកាសការរឹបអូសឧបករណ៍ដែលជាវត្ថុតាងខាងលើនេះដោយខានមិនបាន[121]។

គួរកត់សម្គាល់ថា មាត្រា ១០០ នៃក្រមព្រហ្មទណ្ឌបានចែងអំពីការជំនួសមូលទោសដោយទោសបន្ថែម ត្រង់មាត្រានេះបានចែងថា តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោមៈ

១- **កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់។** **ឧទាហរណ៍៖** លោកស្រី **ក** បានជេរប្រមាថជាសាធារណៈទៅលើលោកស្រី **ខ** ដោយមានគ្រប់ពាក្យមើលងាយ ឬពាក្យប្រមាថ។ អំពើនេះត្រូវផ្តន្ទាទោសតាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ពោលត្រូវពិន័យជាប្រាក់ពី ១សែនរៀល ទៅ ១០ លានរៀល។ ករណីបែបនេះ តុលាការអាចប្រកាសទោសបន្ថែមជំនួសមូលទោសបាន ព្រោះបទល្មើសខាងលើត្រូវផ្តន្ទាទោសជាទោសពិន័យតែមួយប៉ុណ្ណោះ ហើយបទល្មើសខាងលើក៏បានចែងអំពីការប្រកាសទោសបន្ថែមផងដែរ។ ដូចនេះ បើតុលាការប្រកាសទោសបន្ថែមជំនួសឱ្យមូលទោស តុលាការមិនអាចបង្គាប់ឱ្យលោកស្រី **ក** បង់ប្រាក់ពិន័យតាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌឡើយ។

២- **កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣(បី) ឆ្នាំ។** **ឧទាហរណ៍៖** លោកស្រី **គ** បានប្រព្រឹត្តបទល្មើសគំរាមកំហែងទៅលើលោកស្រី **ឃ** ក្នុងបទល្មើសនេះត្រូវទទួល

[120] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥៤ កថាខណ្ឌទី២។

[121] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០១២។

ទោសតាមមាត្រា ២៣១ នៃក្រមព្រហ្មទណ្ឌ ពោលគឺដាក់ពន្ធនាគារពី ១ខែ ទៅ ៦ខែ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ ១លានរៀល។ ករណីបែបនេះ តុលាការអាចប្រកាសទោសបន្ថែមជំនួសមូលទោសបាន ព្រោះបទល្មើសខាងលើត្រូវផ្តន្ទាទោសជាទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ៣ឆ្នាំ ហើយបទល្មើសខាងលើក៏បានចែងអំពីការប្រកាសទោសបន្ថែមផងដែរ។ ដូចនេះ បើតុលាការប្រកាសទោសបន្ថែមជំនួសឱ្យមូលទោស តុលាការមិនអាចប្រកាសទោសពន្ធនាគារ ឬទោសពិន័យជាប្រាក់លើលោកស្រី **គ** បានឡើយ នេះដោយផ្អែកតាមមាត្រា ១០០ នៃក្រមព្រមទណ្ឌ។

ជាចុងក្រោយ ការមិនគោរពតាមទោសបន្ថែមដែលប្រកាសដោយតុលាការ ត្រូវបានក្រមព្រហ្មទណ្ឌចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌដាច់ដោយឡែកមួយផ្សេងទៀត។

**៣. ទោសជំនួស**

ទោសជំនួស គឺជាទោសដែលតុលាការយកមកប្រើប្រាស់ ដើម្បីជំនួសឱ្យមូលទោស។ ក្នុងករណីតុលាការប្រើប្រាស់ទោសជំនួសនេះ គឺតុលាការមិនអាចប្រកាសមូលទោសដែលមាន ទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បាននោះទេ (មាត្រា ៩៨ នៃក្រមព្រហ្មទណ្ឌ)។ តាមក្រមព្រហ្មទណ្ឌទោសជំនួសមានពីរប្រភេទ ដូចជា ទោសការងារសហគមន៍ និងទោសស្តីបន្ទោស។

- **ទោសការងារសហគមន៍៖** តាមក្រមព្រហ្មទណ្ឌមាត្រា ៧២ កថាខណ្ឌទី២ ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ម៉ោង ទៅ ២០០ម៉ោង នូវការងារគ្មានកម្រៃ ជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល។

  តាមខ្លឹមសារនៃក្រម ទោសការងារសហគមន៍ គឺសំដៅដល់កាតព្វកិច្ចដែលត្រូវបំពេញការងារដោយមិនទទួលបានប្រាក់កម្រៃ ឬប្រាក់ខែ ហើយការធ្វើនេះជាប្រយោជន៍ដល់រដ្ឋ ឬក្រុមផ្សេងៗដែលមានចែងក្នុងមាត្រា ៧២ ប៉ុន្តែករណីលើកលែង ត្រង់មាត្រា ៧៣ បានចែងថា នៅគ្រប់ករណីទាំងអស់ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលបានទេ។

- **ទោសស្តីបន្ទោស៖** គឺជាទោសដែលប្រើប្រាស់សម្រាប់បទល្មើសស្រាល ដោយចៅក្រមមិនប្រកាសមូលទោសនោះទេ ពោលគឺចៅក្រមប្រកាសទោសស្តីបន្ទោសជំនួសឱ្យការប្រកាសមូលទោស។ ការប្រកាសទោសស្តីបន្ទោសនេះ ដើម្បីទុកជាការព្រមានអំពីកំហុសឆ្គងដែលជនជាប់ចោទបានប្រព្រឹត្ត និងបង្ការកុំឱ្យមានការប្រព្រឹត្តបន្តទៀត។

ទោសជំនួសដែលអនុវត្តចំពោះជនល្មើស ដោយផ្អែកតាមក្រមព្រហ្មទណ្ឌគឺមានចំនួន ២ប្រភេទ ដូចទៅនឹងមូលទោស ឬទោសបន្ថែមដែលត្រូវអនុវត្តចំពោះជនល្មើសដែរ។ ទោសជំនួសដែលត្រូវអនុវត្តចំពោះជន

ល្មើសទាំងពីរនោះ មានដូចជា ទោសជំនួសដែលត្រូវអនុវត្តចំពោះជនល្មើសជានីតិជន (**៣.១**) និងទោសជំនួសដែលត្រូវអនុវត្តចំពោះជនល្មើសជាអនីតិជន (**៣.២**)។

### ៣.១ ទោសជំនួសដែលត្រូវអនុវត្តចំពោះជនល្មើសជានីតិជន

ទោសជំនួសដែលត្រូវប្រកាសទៅលើជនល្មើសជានីតិជនមាន ២ ប្រភេទដូចខាងក្រោមនេះ៖

**ក. ទោសការងារសហគមន៍**

តាមក្រមព្រហ្មទណ្ឌមាត្រា ៧២ កថាខណ្ឌទី១ បានចែងថា កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍បាន។ ករណីនេះ ត្រូវពិនិត្យមើលទៅលើអតិបរមានៃទោសដែលច្បាប់កំណត់ សម្រាប់បទល្មើសដែលជាកម្មវត្ថុនៃការផ្តន្ទាទោស ពោលមិនមែនមើលលើទោសដែលប្រកាសដោយតុលាការនោះទេ។

ហើយដើម្បីឱ្យទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមាន វត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ។ ជាមួយគ្នានេះដែរ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះបាន ហើយចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា។[122] លើសពីនេះទៀត តុលាការត្រូវតែកំណត់អំពីថិរវេលា និងអំឡុងពេលនៃការងារសហគមន៍ដែលត្រូវបំពេញឱ្យបានច្បាស់លាស់ ពោលតុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីថិរវេលានៃការងារ និងរយៈពេលដែលត្រូវបំពេញ។ ហើយរយៈពេលនេះមិនអាចលើសពី ១ឆ្នាំទេ។[123]ចំណែកឯបែបបទនៃការអនុវត្តទោសការងារសហគមន៍វិញ ត្រូវកំណត់ដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាត្រូវចង្អុលប្រាប់ឈ្មោះនីតិបុគ្គល ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ។ ហើយទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា។[124]

**ឧទាហរណ៍៖** លោក **ក** ត្រូវបានផ្តន្ទាទោសពី បទល្មើសលួច ដែលត្រូវផ្តន្ទាទោស តាមមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌឱ្យជាប់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លាន ទៅ ៦លានរៀល។ ចំពោះករណីនេះអតិបរមានៃទោសដាក់ពន្ធនាគារគឺ ៣ឆ្នាំ ដូច្នេះ តុលាការអាចប្រកាសទោសការងារសហគមន៍ ជំនួសឱ្យមូលទោសនៅមាត្រា ៣៥៦ បាន។ ដូចនេះ តុលាការអាចសម្រេចសេចក្តីតម្រូវឱ្យលោក **ក** ធ្វើការងារសហគមន៍ចំនួន ៩០ម៉ោង(ថិរវេលា) អំឡុងពេល ៣ខែ(រយៈពេល) នៅសាលាឃុំជិតលំនៅឋានរបស់លោក **ក** ហើយដោយមិនឱ្យលោក **ក** ទទួលការផ្តន្ទាទោសដាក់ពន្ធនាគារ ឬទោសពិន័យចំពោះបទលួចដែលបានប្រព្រឹត្តឡើយ។

[122] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០១។

[123] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០២។

[124] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៣។

បើតុលាការប្រកាសទោសការងារសហគមន៍ ដោយមានការយល់ព្រមពីជនជាប់ចោទនៅក្នុងសវនាការរួចហើយ ទណ្ឌិតត្រូវតែគោរពកាតព្វកិច្ចធ្វើការងារដែលកើតចេញពីទោសការងារសហគមន៍នេះ។ ម្យ៉ាងទៀត អំពើបំពានដោយទណ្ឌិតលើកាតព្វកិច្ច ដែលជាលទ្ធផលនៃទោសការងារសហគមន៍ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ២លាន ទៅ ៤លានរៀល មាត្រា ៥៨៣ នៃក្រមព្រហ្មទណ្ឌ។

**ឧទាហរណ៍** ៖ លោក **ក** ត្រូវបានតុលាការសម្រេចដាក់ទោសការងារសហគមន៍ជំនួសឱ្យមូលទោស ដោយតម្រូវឱ្យធ្វើការងារសហគមន៍នៅសាលាឃុំចំនួន ១១០ម៉ោង ដោយធ្វើការក្នុងមួយថ្ងៃចំនួន ៤ម៉ោង និង៥ថ្ងៃក្នុងមួយសប្តាហ៍ សម្រាប់រយៈពេល ៥សប្តាហ៍។ ក៏ប៉ុន្តែជាក់ស្តែង លោក **ក** ខកខានមិនបានទៅបំពេញការងារសហគមន៍រយៈពេល ៣សប្តាហ៍ ជាបន្តបន្ទាប់ ។ នៅក្នុងករណីបែបនេះ លោក **ក** បានប្រព្រឹត្តបទបំពានលើកាតព្វកិច្ចការងារសហគមន៍[125]។

## ខ. ទោសស្តីបន្ទោស

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ។[126]

**ឧទាហរណ៍**៖ លោក **ក** បានប្រព្រឹត្ត បទល្មើសធ្វើឱ្យខូចខាតដោយចេតនា ដែលមានចែងនៅមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ។ ក្រោយពីបានប្រព្រឹត្តបទល្មើសរួចលោក **ក** ក៏បានដឹងកំហុសរបស់ខ្លួន ហើយក៏បានចេញថ្លៃការខូចខាតដល់ជនរងគ្រោះ ហើយព្រមទាំងសម្តែងនូវការសោកស្តាយពីអំពើដែលខ្លួនបានធ្វើ។ ចំពោះករណីនេះ តុលាការអាចប្រកាសត្រឹមតែ ការស្តីបន្ទោស ជំនួសឱ្យមូលទោសបាន ដោយមិនតម្រូវឱ្យលោក **ក** ទទួលរងមូលទោសដែលមានចែងក្នុងមាត្រា ៤១០ ឡើយ។

## ៣.២ ទោសជំនួសដែលត្រូវអនុវត្តចំពោះជនល្មើសជាអនីតិជន

ទោសជំនួសដែលត្រូវប្រកាសទៅលើជនល្មើសជាអនីតិជនមាន ២ ប្រភេទដូចខាងក្រោមនេះ៖

## ក. ទោសការងារសហគមន៍

តុលាការអាចប្រកាសទោសការងារសហគមន៍ ទៅលើជនល្មើសដែលជាអនីតិជនបាន តែត្រូវបំពេញលក្ខខណ្ឌមួយចំនួន។ ដោយផ្អែកតាមមាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌបានចែងថា ទោសដែលជាការងារសហ

---

[125] សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

[126] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧៦។

គមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ឆ្នាំ មានន័យថា តុលាការមិនអាចប្រកាសទោសការងារសហគមន៍ទៅលើអនីតិជនដែលមានអាយុតិចជាង ១៦ឆ្នាំ បានឡើយ។ ហើយចំពោះថិរវេលានៃការងារវិញ គឺមិនអាចលើសពី ១០០ម៉ោងឡើយ។ ចំពោះទោសការងារសហគមន៍ ត្រូវតែសម្របសម្រួលទៅលើអនីតិជន ដែលមានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

**ខ. ទោសស្តីបន្ទោស**

ចំពោះទោសស្តីបន្ទោស ទាក់ទងនឹងលក្ខខណ្ឌនៃការប្រកាសទោសស្តីបន្ទោស គឺបានកំណត់នៅចំណុចការអនុវត្តទោសជំនួសចំពោះជនល្មើសជានីតិជនរួចមកហើយ។[127]

សូមបញ្ជាក់ផងដែរថា ដោយផ្អែកតាមមាត្រា ៩៨ នៃក្រមព្រហ្មទណ្ឌ បានចែងថា ទោសការងារសហគមន៍ និងទោសស្តីបន្ទោស ដែលប្រកាសជំនួសឱ្យមូលទោស ប្រសិនបើតុលាការយកទោសការងារសហគមន៍ ឬទោសស្តីបន្ទោសមកប្រកាស គឺតុលាការមិនអាចប្រកាសមូលទោស ពោលគឺទោសដាក់ពន្ធនាគារ និងពិន័យបានឡើយ ដោយមូលហេតុថាតុលាការយកទោសជំនួសទាំងពីរ មកជំនួសមូលទោសហើយ។

**ផ្នែកទី៣៖ ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល**

តាមក្រមព្រហ្មទណ្ឌ មាត្រា ៤២ បានចែងអំពីការទទួលខុសត្រូវរបស់នីតិបុគ្គល ដោយមាត្រានោះបានចែងថា នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ មានន័យថា នីតិបុគ្គលដែលជារដ្ឋ មិនត្រូវបានប្រកាសថា ទទួលទោសចំពោះអំពើណាមួយឡើយ **ព្រោះរដ្ឋមានសិទ្ធិអំណាចផ្តាច់មុខក្នុងការដាក់ទណ្ឌកម្ម ហើយរដ្ឋមិនអាចដាក់ទណ្ឌកម្មខ្លួនឯងបានទេ** ប៉ុន្តែនីតិបុគ្គលដែលមិនមែនជារដ្ឋ ត្រូវទទួលខុសត្រូវចំពោះអំពើណាមួយ ហើយក៏មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ។

យោងតាមមាត្រា ១៦៧ នៃក្រមព្រហ្មទណ្ឌបានចែងអំពីទោសដែលត្រូវរងដោយនីតិបុគ្គល ចំពោះទោសដែលនីតិបុគ្គលអាចត្រូវបានប្រកាសមាន ទោសពិន័យក្នុងឋានៈជាមូលទោស (១) និងទោសបន្ថែម (២)។

**១. ទោសពិន័យក្នុងឋានៈជាមូលទោស**

នីតិបុគ្គល ចំពោះទោសដែលត្រូវទទួលរង គឺត្រឹមតែជាទោសពិន័យតែប៉ុណ្ណោះ ព្រោះថា តុលាការមិនអាចយកនីតិបុគ្គលទៅដាក់ពន្ធនាគារបាននោះទេ។ អាស្រ័យហេតុនេះ ទោសពិន័យក្នុងឋានៈជាមូលទោសនេះ នីតិបុគ្គលត្រូវអនុវត្តទៅតាមបទល្មើសនីមួយៗដែលក្រមព្រហ្មទណ្ឌបានកំណត់ ឬបានចែង។

[127] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧៦។

## ២. ទោសបន្ថែមដែលអនុវត្តចំពោះនីតិបុគ្គល

យោងតាមមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានចំនួន ១៤ ប្រភេទដូចបានរៀបរាបនៅខាងក្រោមនេះៈ

១.ការរំលាយចោល (មាត្រា ១៧០ នៃក្រមព្រហ្មទណ្ឌ)។

២.ការដាក់នៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ (មាត្រា ១៧១ នៃក្រមព្រហ្មទណ្ឌ)។

៣.ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន (មាត្រា ១៧២ នៃក្រមព្រហ្មទណ្ឌ)។

៤.ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ (មាត្រា ១៧៣ នៃក្រមព្រហ្មទណ្ឌ)។

៥.ការហាមឃាត់ការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ (មាត្រា ១៧៤ នៃក្រមព្រហ្មទណ្ឌ)។

៦.ការហាមឃាត់ចំពោះឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូបានដែល កំណត់ដោយធនាគារ (មាត្រា ១៧៥ នៃក្រមព្រហ្មទណ្ឌ)។

៧.ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់ (មាត្រា ១៧៥ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ)។

៨.ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស(មាត្រា១៧៦ នៃក្រមព្រហ្មទណ្ឌ)។

៩.ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណៈជន ឬដែលបានប្រើប្រាស់ដោយសាធារណៈជន (មាត្រា ១៧៧ នៃក្រមព្រហ្មទណ្ឌ)។

១០.ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស (មាត្រា ១៧៩ កថាខណ្ឌទី ១ នៃក្រមព្រហ្មទណ្ឌ)។

១១.ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស (មាត្រា ១៧៩ កថាខណ្ឌទី ២ )។

១២.ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស(មាត្រា១៧៩ កថាខណ្ឌ៣)។

១៣.ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុក្នុងទីកន្លែង ដែលបទល្មើសបានប្រព្រឹត្ត (មាត្រា ១៧៩ )។ ការរឹបអូសមិនអាចប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន។

១៤.ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមទូរគមនាគមន៍សោតទស្សន៍ (មាត្រា ១៨០ នៃក្រមព្រហ្មទណ្ឌ)។

ចំពោះទោសបន្ថែមសម្រាប់នីតិបុគ្គលដែលបានលើកឡើងខាងលើនេះ អាចត្រូវប្រកាសដោយតុលាការប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់(យោងមាត្រា១៦៩)។ មានន័យថា បទប្បញ្ញត្តិពិសេសសម្រាប់បទល្មើសនីមួយៗ នឹងកំណត់ពីទោសបន្ថែមដែលតុលាការអាចប្រកាសសម្រាប់បទល្មើសនោះ។ ករណីនេះ តុលាការមិនអាចប្រកាសទោសបន្ថែមណាផ្សេងបានឡើយ[128]។

[128] សាស្ត្រាចារ្យ **នុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០២២។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទ **បទល្មើសព្រហ្មទណ្ឌ** រួចមក យើងអាចពិចារណាឃើញថា បទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់ព្រោះថា អំពើទាំងនោះបង្កចលាចលដល់សង្គម ឬប៉ះពាល់សេរីភាពរបស់ប្រជាពលរដ្ឋ ការប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌហាមឃាត់នេះត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ។ ដោយផ្អែកតាមក្រមព្រហ្មទណ្ឌ បានចែងថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស គឺមានន័យថា បទល្មើសជាអំពើទាំងឡាយណាដែលបានប្រព្រឹត្តដោយបុគ្គលណាម្នាក់ ឬច្រើននាក់ ហើយអំពើនោះបានបង្កចលាចលដល់សង្គម ឬក៏ប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋជាដើម។ ចំពោះការលើកឡើងខាងលើនេះ បើតាមការពិនិត្យជាក់ស្តែង មានអំពើមួយចំនួនក៏បង្កជាអំពើល្មើសដែរ ក៏ប៉ុន្តែមិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនោះទេ ដែលអំពើទាំងនោះមានដូចជា អំពើល្មើសផ្នែករដ្ឋប្បវេណី និងអំពើល្មើសផ្នែកវិន័យ។ ចំពោះអំពើល្មើសផ្នែករដ្ឋប្បវេណី មានប្រភពមកពីក្រមរដ្ឋប្បវេណី ដែលបានចែងថាបុគ្គលដែលបានបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃដោយកំហុសចេតនា ឬដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាតដែលកើតឡើងដោយអំពើនោះ។ ចំណែកឯអំពើល្មើសផ្នែកវិន័យ គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ជា សមូហភាពនៃក្រុម ឬសង្គមណាមួយ ដែលមានដូចជា មេធាវី ពេទ្យ និងនិស្សិតជាដើម។ ប៉ុន្តែបទល្មើសព្រហ្មទណ្ឌវិញ គឺជាអំពើដែលប៉ះពាល់សង្គមទូទៅ ឬក៏ប៉ះពាល់ធំធេងជាងអំពើល្មើសផ្នែកវិន័យ និងអំពើល្មើសផ្នែករដ្ឋប្បវេណី មានន័យថា បទល្មើសព្រហ្មទណ្ឌ គឺមានព្យសនកម្មជាច្រើនដល់មនុស្ស និងសង្គមដូចជាប៉ះពាល់ដល់អាយុជីវិត ទ្រព្យសម្បត្តិ និងជាពិសេសនោះបង្កឱ្យមានអនាធិបតេយ្យ និងសង្គមគ្មានសណ្តាប់ធ្នាប់ជាដើម។

ហើយក្នុងការកំណត់អំពើណាមួយជាបទល្មើសបាន លុះត្រាតែអំពើនោះបានបំពេញធាតុផ្សំទាំងបីជាមុនសិន ដែលធាតុផ្សំទាំងបីនោះមានដូចជា ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។ ចំពោះធាតុនីត្យានុកូល គឺជាធាតុដែលទាក់ទងនឹងច្បាប់ ព្រោះដើម្បីធ្វើការចោទប្រកាន់ និងផ្តន្ទាទោសបាន គឺត្រូវមានច្បាប់ចែងទុកជាមុនសិន។ ចំពោះធាតុផ្សំសត្យានុម័តវិញ សំដៅទៅលើអំពើដែលជនល្មើសបានប្រព្រឹត្តស្តែងចេញមកខាងក្រៅមិនថាដោយអំពើសកម្ម ឬអកម្មក្តី ដែលអំពើនោះធ្វើឱ្យមានព្យសនកម្ម ដែលព្យសនកម្មនោះមានដូចជាការប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពបុគ្គល ទ្រព្យសម្បត្តិសាធារណៈ ឬឯកជនជាដើម។ ចំណែកឯធាតុអត្តនោម័តវិញ ជាចិត្តគំនិតខាងក្នុងរបស់ជនល្មើស ដែលស្តែងមកខាងក្រៅតាមរយៈ ធាតុសត្យានុម័ត ដូចជាកាយវិការ ឬអំពើប្រព្រឹត្តរបស់ជនល្មើស។

បន្ទាប់ពីកំណត់បទល្មើសបានហើយ ក្នុងក្រមព្រហ្មទណ្ឌក៏បានចាត់ថ្នាក់បទល្មើសជាបីផងដែរ ដែលមានដូចជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ ចំពោះបទឧក្រិដ្ឋ គឺជាបទល្មើសទាំងឡាយណាដែលជនល្មើស

បានប្រព្រឹត្តនឹងបង្កព្យសនកម្មដ៏គ្រោះថ្នាក់ដល់សង្គមយ៉ាងធ្ងន់ធ្ងរ ហើយទោសដែលត្រូវទទួលក៏មានលក្ខណៈជាស្ថានទម្ងន់ផងដែរ។ ចំពោះបទមជ្ឈិម គឺជាបទល្មើសទាំងឡាយណាដែលពុំសូវបង្កព្យសនកម្មខ្លាំងខ្លាពេកទេ វាស្ថិតនៅចន្លោះបទឧក្រិដ្ឋ និងបទលហុ ហើយកម្រិតគ្រោះថ្នាក់ដល់សង្គមនោះមិនធ្ងន់ធ្ងរពេក ក៏មិនស្រាលដែរ ចំណែកទោសដែលត្រូវទទួលក៏មានកម្រិតមធ្យម និងមិនស្រាលពេកដែរ ។ ចំណែកបទលហុវិញ គឺជាបទល្មើសដែលជនល្មើសបានប្រព្រឹត្តអំពើដែលនាំឱ្យប៉ះពាល់ដល់ សិទ្ធិសេរីភាពបុគ្គល ឬសណ្តាប់ធ្នាប់សាធារណៈយ៉ាងតិចតួច ហើយទណ្ឌកម្មដែលត្រូវផ្តន្ទាទោសទៅលើជនល្មើស ក៏មិនមានស្ថានទម្ងន់ផងដែរ។ សូមបញ្ជាក់ផងដែរថា ការចាត់ថ្នាក់បទល្មើស មានការចាត់ថ្នាក់បែបផ្សេងៗជាច្រើនទៀត ដែលការចាត់ថ្នាក់ទាំងនោះមានគោលបំណងផ្តល់ភាពងាយស្រួលដល់មន្ត្រីមានសមត្ថកិច្ចក្នុងការអនុវត្តន៍ការងារ។

បើទោះបីជាកំណត់អំពើណាមួយជាបទល្មើសបានហើយក៏ដោយ តុលាការក៏ត្រូវពិនិត្យមើលលើបុគ្គលដែលបានប្រព្រឹត្តបទល្មើសដែរថា គួរឱ្យបុគ្គលនោះទទួលខុសត្រូវ ឬមិនទទួលខុសត្រូវ ព្រោះថាមានអំពើខ្លះជាបទល្មើសក៏ពិតមែន ប៉ុន្តែផ្អែកតាមជនដែលប្រព្រឹត្តផ្ទាល់ គឺមិនអាចទម្លាក់កំហុសទៅលើជននោះបានទេ ឬក៏ថាអំពើរបស់ជននោះជាអំពើយុត្តិកម្មនៃបទល្មើសជាដើម។ ក្នុងករណីថា បើជននោះរួចផុតពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ជននោះគឺមិនទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយឡើយ។ ហើយបើតុលាការរកឃើញថា ជននោះបានប្រព្រឹត្តអំពើដែលជាបទល្មើស តុលាការត្រូវតែផ្តន្ទាទោសជននោះ តុលាការក៏ត្រូវពិនិត្យមើលលើស្ថានភាពរបស់ជននោះដែរ ពោលគឺពិនិត្យមើលថា ជននោះជាជនគ្រប់អាយុ ឬមិនទាន់គ្រប់អាយុក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។ បើរកឃើញថា ជននោះមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ គឺតុលាការត្រូវពិចារណាក្នុងការប្រកាសទោសលើជននោះ ដោយផ្អែកតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវ។

ចំពោះទោស គឺជាដំណាក់កាលចុងក្រោយក្នុងសម្រេចចិត្តរបស់ចៅក្រម ក្នុងការផ្តន្ទាទោសទៅលើជនល្មើស ពោលបន្ទាប់ពីបានកំណត់អំពើណាមួយជាបទល្មើស ដែលមានពិរុទ្ធភាពរួចមក ចៅក្រមនឹងពិចារណាអំពីការផ្តន្ទាទោស ចំពោះជនល្មើសដែលបានប្រព្រឹត្តបទល្មើស។ ក្នុងការប្រកាសទោស តុលាការត្រូវគោរពនូវគោលការណ៍ឯកត្តកម្មនៃទោស ព្រោះគោលការណ៍នេះ គឺជាគោលការណ៍ដែលត្រូវបានបង្កើតឡើងទុកជាមូលដ្ឋានគ្រឹះដល់ចៅក្រមជំនុំជម្រះពិចារណាទៅតាមស្ថានភាពរបស់បុគ្គលម្នាក់ៗដែលបានប្រព្រឹត្តបទល្មើស ដើម្បីឈានទៅដល់ការប្រកាសទោសព្រហ្មទណ្ឌ។ នៅក្នុងការប្រកាសទោស ចៅក្រមត្រូវយកទោសដែលមានចែងក្នុងច្បាប់មកធ្វើការផ្តន្ទាទោស ពោលក្រមព្រហ្មទណ្ឌបច្ចុប្បន្ន បានចែកទោសជាបីប្រភេទ មានដូចជា មូលទោស ទោសបន្ថែម និងទោសជំនួស ទោសទាំងបីនេះត្រូវបានតុលាការយកមកពិចារណាក្នុងការអនុវត្តចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើស ឬអាចហៅជនល្មើស។ចំពោះប្រធានបទនេះពិតជាមានសារៈសំខាន់ណាស់ ព្រោះថាបានចូលរួមក្នុងការរក្សាសន្តិសុខសង្គម និងរក្សាយុត្តិធម៌សម្រាប់ជូនជនរងគ្រោះពិតប្រាកដ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់តាមរយៈការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទ **បទល្មើសព្រហ្មទណ្ឌ** រួចជាស្ថាពរមក យើងខ្ញុំបានពិនិត្យឃើញថា ប្រធានបទមួយនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការចូលរួមស្វែងរកយុត្តិធម៌ជូនជនដែលរងគ្រោះពិតប្រាកដ ហើយជាពិសេសនោះ គឺបានជួយថែរក្សាសន្តិសុខសុវត្ថិភាពទូទាំងប្រទេសផងដែរ។ មូលហេតុដែលយើងខ្ញុំលើកឡើងខាងលើបែបនេះ ព្រោះថា ការកំណត់បទល្មើសមួយបានច្បាស់លាស់ដោយផ្អែកតាមនីតិវិធី ឬពិចារណាលើចំណុចនីមួយៗដែលបានបកស្រាយខាងលើ គឺនាំឱ្យមានការអនុវត្តន៍ច្បាប់យ៉ាងត្រឹមត្រូវពិតប្រាកដសម្រាប់ជនរងគ្រោះ និងប្រទេសជាតិទាំងមូល។

យើងខ្ញុំសូមរំលឹកឡើងវិញថា ចំពោះទោសព្រហ្មទណ្ឌ នៅពេលដែលតុលាការយកទៅប្រកាសផ្តន្ទាទោសទៅលើជនណាម្នាក់ នោះវាពិតជាមានផលវិបាកជាច្រើនបានកើតឡើងទៅលើជននោះ។ ចំពោះផលវិបាកទាំងនោះមានដូចជា **ការលំបាក** (ទាំងផ្លូវកាយ និងផ្លូវចិត្ត) **ការបន្ទោស** (គឺជាការស្អប់ខ្ពើមពីសាធារណៈជនពោលសាធារណៈជនមានទស្សនៈថា អ្នកធ្លាប់ជាប់ពន្ធនាគារ គឺសុទ្ធតែជាមនុស្សមិនល្អ មនុស្សដែលបំពានច្បាប់ជាដើម) **ការបាត់បង់សិទ្ធិសេរីភាព** (ត្រូវជាប់ពន្ធនាគារ ឬគុកមិនអាចចេញក្រៅបាន) **ការខាតបង់ប្រាក់ ឬធ្វើឱ្យសេដ្ឋកិច្ចគ្រួសារធ្លាក់ចុះ** (ព្រោះពេលខ្លះអ្នករកចំណូលចូលគ្រួសារត្រូវបានជាប់ពន្ធនាគារ ហើយត្រូវបង់ប្រាក់ពិន័យ ឬពេលខ្លះត្រូវបង់ប្រាក់សំណងទៅជនរងគ្រោះជាដើម) ហើយជាពិសេសនោះ គឺប៉ះពាល់ដល់កិត្តិយសដល់ជនដែលត្រូវបានផ្តន្ទាទោស និងក្រុមគ្រួសាររបស់ជននោះ។

អាស្រ័យដូចបានរៀបរាប់ខាងលើនេះ មិនថាឡើយអ្នកអនុវត្តច្បាប់ អ្នកសិក្សាស្រាវជ្រាវ ឬក៏ប្រជាពលរដ្ឋទូទៅនោះទេ ជាចាំបាច់បំផុតត្រូវមានការចូលរួមជាមួយគ្នា ក្នុងការកាត់បន្ថយ ឬការលំបំបាត់កុំឱ្យមានបទល្មើសកើតឡើងជាបន្តបន្ទាប់ទៀត។ បើក្នុងករណីមានបទល្មើសកើតឡើងហើយ មន្ត្រីមានសមត្ថកិច្ចគួរគប្បីពិនិត្យពិចារណា ដោយឈរលើគោលការណ៍មួយចំនួនដូចបានបកស្រាយខាងលើនេះ ដើម្បីសម្រេចឱ្យបានយុត្តិធម៌ជូនជនរងគ្រោះ ព្រោះបានដឹងមកហើយថាបើក្នុងករណីតុលាការ ឬចៅក្រមវិនិច្ឆ័យសេចក្តីមានការខុសឆ្គងត្រង់ប្រការណាមួយ គឺធ្វើឱ្យមានការចោទប្រកាន់ និងផ្តន្ទាទោសខុស នាំឱ្យប៉ះពាល់ដល់ជននោះជាច្រើនដូចបានរៀបរាប់អំពីផលវិបាកនៃការទោសព្រហ្មទណ្ឌខាងលើ។ ដូច្នេះ មានវិធានការមួយចំនួន ដើម្បីកាតបន្ថយកុំឱ្យមានបទល្មើសកើតឡើងច្រើន ហើយបើបទល្មើសបានកើតឡើងហើយ មន្ត្រីមានសមត្ថកិច្ច ត្រូវវិនិច្ឆ័យសេចក្តីដោយផ្អែកតាមគោលការច្បាប់ឱ្យបានត្រឹមត្រូវ។ ចំពោះវិធានការទាំងនោះយើងនឹងរៀបរាប់នៅខាងក្រោមនេះ៖

**ការរៀបចំការផ្សព្វផ្សាយ** ៖ តាមរយៈការផ្សព្វផ្សាយនេះ គឺបានជួយឱ្យអ្នកអនុវត្តច្បាប់ទាំងឡាយ រួមទាំងប្រជាពលរដ្ឋទូទៅ មានការយល់ដឹងឱ្យបានកាន់តែច្បាស់អំពីផ្លូវច្បាប់។ ទាក់ទងចំណុចនេះ គឺមានសារៈសំខាន់ណាស់ ព្រោះថាបើមន្ត្រីអ្នកអនុវត្តច្បាប់មានការយល់ដឹងច្បាស់លាស់អំពីច្បាប់នាំឱ្យការអនុវត្តមានភាពត្រឹមត្រូវ

ពោលគឺមានយុត្តិធម៌យ៉ាងពិតប្រាកដដល់ជនរងគ្រោះ ហើយបើប្រជាពលរដ្ឋបានយល់ដឹងអំពីច្បាប់កាន់តែច្រើន នាំឱ្យមិនសូវមានបទល្មើស ឬអំពើល្មើសផ្សេងៗកើតឡើងឡើយ។

**ការបណ្តុះបណ្តាល** ៖ ចំពោះការបណ្តុះបណ្តាល គឺសំដៅទៅលើការពង្រឹងគុណភាពមន្ត្រី គឺមន្ត្រីត្រូវតែមានសមត្ថភាព ចំណេះ និងជំនាញយ៉ាងពិតប្រាកដ ទើបការពង្រីក និងពង្រឹងការអនុវត្តច្បាប់មានភាពរីកចម្រើន ពោលបើមន្ត្រីមានចំណេះ និងជំនាញពិតប្រាកដនោះការវិនិច្ឆ័យក្តីគឺប្រកបដោយ ព្យាក្រឹតិ និងយុត្តិធម៌។ អាស្រ័យដូចបានរៀបរាប់ខាងលើនេះហើយ គឺត្រូវទាមទារចាំបាច់មានការចូលរួមជាមួយគ្នា ក្នុងគោលបំណងជាប្រយោជន៍រួមរបស់ប្រទេសជាតិរបស់យើងទាំងមូល។

សរុបជារួមមក និងជាចុងក្រោយ យើងខ្ញុំមិនចង់ឃើញប្រទេសដែលមានច្បាប់ល្អ តែការអនុវត្តច្បាប់មិនបានល្អ ឬប្រទេសដែលមានច្បាប់ល្អហើយ តែនៅតែមានបទល្មើសជាច្រើនបានកើតឡើងនោះទេ។ ដូចនេះហើយសូមឱ្យអ្នកអនុវត្តច្បាប់ សិស្ស និស្សិត ឬប្រជាពលរដ្ឋទូទាំងប្រទេស ខិតខំ និងព្យាយាមសិក្សាស្រាវជ្រាវអំពីច្បាប់បន្ថែម(ច្បាប់ព្រហ្មទណ្ឌ ឬច្បាប់ដទៃទៀត) ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនផង និងជាប្រយោជន៍រួមផង។ ហើយជាពិសេសចូលរួមអនុវត្ត ឬគោរពច្បាប់ឱ្យបានខ្ជាប់ខ្ជួនជានិច្ច ដើម្បីជៀសវាងកុំឱ្យធ្លាក់ខ្លួនទៅប្រព្រឹត្តបទល្មើសដែលច្បាប់បានហាមឃាត់ នាំឱ្យមានការផ្តន្ទាទោសពីតុលាការ ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជាច្រើនដល់ខ្លួន ដល់គ្រួសារ និងសង្គមជាតិទាំងមូល។

# ឯកសារយោង

# ឯកសារយោង


- **លិខិតបទដ្ឋានគតិយុត្តជាតិ**

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣

២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

៣. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៤. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

៥. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២

៦. ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧

៧. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

៨. ច្បាប់ស្តីពីឯកពន្ធភាព ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ ២០០៦

- **លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ**

១. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨

២. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦

- **វចនានុក្រម និងសទ្ទានុក្រម**

១. វចនានុក្រមខ្មែរសម្តេចសង្ឃរាជ **ជួន ណាត**

២. វចនានុក្រមខ្មែរ-អង់គ្លេស អងគ្លេស-ខ្មែរ បោះពុម្ពលើទី១ ឆ្នាំ២០១២

៣. វចនានុក្រមបារាំង - ខ្មែរ

៤. សទ្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌចេញផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី

៥. សទ្ទានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីចេញផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី

- **ឯកសារជាសៀវភៅ និងឯកសារផ្សេងៗ**

១.សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ **ហ៊ាង ឡេង**

២.សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ២០២២

៣.សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ **កៅ សីហា** ឆ្នាំ២០១៣

៤.សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ **មីន សំអុល**

៥.សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ **សាឡេះ សុវណ្ណារ៉ា** និងសាស្ត្រាចារ្យ **ស៊ុយ ទិត្យ**

៦.ការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌ តាមរយៈទូរទស្សន៍ជាតិ ឆ្នាំ២០១០ និង

៧.ឯកសារផ្សេងៗទៀត។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី ១** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ១៩៩៣។
- **ឧបសម្ព័ន្ធទី ២** ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០៩។
- **ឧបសម្ព័ន្ធទី ៣** ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០០៧។
- **ឧបសម្ព័ន្ធទី ៤** ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០៩។

# ឧបសម្ព័ន្ធទី ១
# រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

**ព្រះរាជក្រម**

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

*យោងតាមមាត្រា១៣៥ និង១៣៦ នៃជំពូកទី១៤ ស្តីពី អន្តរប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា អនុម័តដោយសភាធម្មនុញ្ញ នៅថ្ងៃទី ២១ ខែ កញ្ញា គ.ស ១៩៩៣ ។*

**ត្រាស់បង្គាប់**

**មាត្រា ១ :**

*ប្រកាសឱ្យប្រើជាផ្លូវការភ្លាមនូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលសភាធម្មនុញ្ញបានអនុម័ត នៅថ្ងៃ ទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៣ ។*

**មាត្រា ២ :**

*សភាធម្មនុញ្ញបានត្រឡប់ទៅជារដ្ឋសភានៃកម្ពុជា ចាប់ពីពេលនេះតទៅ ។*

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កញ្ញា គ.ស ១៩៩៣*

**នរោត្តម សីហនុ**

# ជំពូកទី ៣
# អំពី សិទ្ធិ និងករណីយកិច្ច របស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១.-**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពនិងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ការប្រើសិទ្ធិ សេរីភាពផ្ទាល់ ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២.-**

ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**មាត្រា ៣៣.-**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបាន រដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៨.-**

ច្បាប់ហាមឃាត់មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដែលដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

# ជំពូកទី ១១ ថ្មី
# អំពីអំណាចតុលាការ

**មាត្រា ១២៨.- ថ្មី ( មាត្រា ១០៩ ចាស់ )**

*អំណាចតុលាការជាអំណាចឯករាជ្យ ។*

*អំណាចតុលាការ ធានារក្សាអនាគត និងការពារសិទ្ធិ សេរីភាព របស់ប្រជាពលរដ្ឋ ។*

*អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។*

*អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តី គ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។*

**មាត្រា ១២៩.- ថ្មី ( មាត្រា ១១០ ចាស់ )**

*ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។*

*មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញការកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។*

**មាត្រា ១៣០.- ថ្មី ( មាត្រា ១១១ ចាស់ )**

*គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។*

**មាត្រា ១៣១.- ថ្មី ( មាត្រា ១១២ ចាស់ )**

*មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។*

**មាត្រា ១៣២.- ថ្មី ( មាត្រា ១១៣ ចាស់ )**

*ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។*

**មាត្រា ១៣៣.- ថ្មី ( មាត្រា ១១៤ ចាស់ )**

*ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់វិន័យលើចៅក្រម ដែលបានប្រព្រឹត្តខុស ។*

**មាត្រា ១៣៤.- ថ្មី ( មាត្រា ១១៥ ចាស់ )**

*ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយ ដែលនឹងកំណត់សមាសភាព និងមុខងារ។*

*ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតី នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមនេះ ។*

*ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយ ព្រះ-មហាក្សត្រ អំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់ ។*

*ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យ ចំពោះចៅក្រម និងព្រះរាជអាជ្ញាត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា ។*

**មាត្រា ១៣៥.- ថ្មី ( មាត្រា ១១៦ ចាស់ )**

*លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការ នឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា ។*

# ឧបសម្ព័ន្ធទី ២

# ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

**នស/រកម/១១០៩/០២២**

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# គន្ថីទី ១

# បទប្បញ្ញត្តិទូទៅ

## មាតិកាទី ១

## ច្បាប់ព្រហ្មទណ្ឌ

### ជំពូកទី ១

### គោលការណ៍ទូទៅ

**មាត្រា ១.-** ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ

ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថា ជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ ។

នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។

**មាត្រា ២.-** និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស

ច្បាប់បញ្ញត្តថា អំពើខុសរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស ។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ ។

**មាត្រា ៣.-** គោលការណ៍នីត្យានុកូលភាព

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។

មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន ។

**មាត្រា ៤.-** ចេតនាប្រព្រឹត្តបទល្មើស

ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។

ប៉ុន្តែ ក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។

**មាត្រា ៥.-** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ ។

**មាត្រា ៦.-** ការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ ។

**មាត្រា ៧.-** លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ដែនអនុវត្តច្បាប់កម្ពុជាក្នុងលំហ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៨.-** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ

បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ ។

## ជំពូកទី ២

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

**មាត្រា ៩.-** ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស

បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ ត្រូវបញ្ចប់ ។

**មាត្រា ១០.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬធ្ងន់ជាង

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម ។ ប៉ុន្តែ ការផ្តន្ទាទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ។

**មាត្រា ១១.-** សុពលភាពនៃកិច្ចនីតិវិធី

ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធីដែលបានបំពេញស្របតាមបទប្បញ្ញត្តិចាស់ឡើយ ។

# ជំពូកទី ៣
# ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ
## ផ្នែកទី ១
## បទល្មើសដែលបានប្រព្រឹត្ត ឬចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១២.-** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៣.-** ទីកន្លែងប្រព្រឹត្តបទល្មើស

បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៤.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៥.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ ។

**មាត្រា ១៦.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៧.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្តើមប្រព្រឹត្តនៅកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមនេះត្រូវបានបំពេញ :

-បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង និង

-អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស ។

**មាត្រា ១៨.-** ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល

ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល ។

## ផ្នែកទី ២

## បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៩.-** បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ នៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ។

បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ ។

**មាត្រា ២០.-** ជនរងគ្រោះជាជនជាតិខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេស ទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

**មាត្រា ២១.-** ការផ្ញើបណ្តឹងចោទប្រកាន់

នៅក្នុងករណីដែលមានចែងនៅក្នុងមាត្រា ១៩ (បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្ត ដោយពលរដ្ឋខ្មែរ) និងមាត្រា ២០ (ជនរងគ្រោះជាជនជាតិខ្មែរ) នៃក្រមនេះ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អយ្យការតែប៉ុណ្ណោះ ។ ការចោទប្រកាន់ត្រូវតែមានបណ្តឹងពីជនរងគ្រោះ ឬពីសិទ្ធិវន្ត ឬបណ្តឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត ។

**មាត្រា ២២.-** សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបើបទល្មើសនោះជា :

១-បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ។

២-បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ។

៣-បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

៤-បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

៥-បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៣.-** ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។

## មាតិកាទី ២

## ការទទួលខុសត្រូវព្រហ្មទណ្ឌ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

**មាត្រា ២៥.-** **និយមន័យនៃចារី**

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។

ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ។

**មាត្រា ២៦.-** **និយមន័យនៃសហចារី**

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ។

ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ។

**មាត្រា ២៧.-** **និយមន័យនៃការប៉ុនប៉ង**

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង

-ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬរាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស មិនមែនជាការចាប់ផ្តើមអនុវត្តទេ ។

ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ ។

**មាត្រា ២៨.-** **និយមន័យនៃអ្នកផ្តើមគំនិត**

ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែល :

១-ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ តាមការណែនាំ ឬការបញ្ជា។

២-បង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន ។

អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ។

អ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ ។

**មាត្រា ២៩.-** និយមន័យនៃអ្នកសមគំនិត

ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួល ដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន ។

អ្នកសមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ។

អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ ។

**មាត្រា ៣០.-** និយមន័យនៃអ្នករាជការសាធារណៈ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត

១-អ្នករាជការសាធារណៈ មានន័យថា :

ក/ បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពី ឋានៈ អាយុរបស់បុគ្គលនោះឡើយ ។

ខ/ បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

២-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថា ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

## ជំពូកទី ២
## មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

**មាត្រា ៣១.-** ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**មាត្រា ៣២.-** ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះ មិនប្រព្រឹត្តបទល្មើសទេ ។

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

**មាត្រា ៣៣.-** ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

**មាត្រា ៣៤.-** សច្ចធារណីនៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណីនៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណីនេះ អាចត្រូវរំលាយដោយភស្តុតាងផ្ទុយ ។

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

**មាត្រា ៣៩.-** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។

**មាត្រា ៤០.-** ប្រភេទនៃវិធានការ

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្ដីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្ដល់ព័ត៌មាន ដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

## ជំពូកទី ៤
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

## មាតិកាទី ៣
## ទោស
## ជំពូកទី ១
## ប្រភេទនៃទោស
## ផ្នែកទី ១
## មូលទោស

**មាត្រា ៤៣.-** មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

**មាត្រា ៤៤.-** អប្បបរមា និងអតិបរមានៃមូលទោស

កាលបើបទល្មើសត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពី អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្ដន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។

**មាត្រា ៤៥.-** ការទម្ងន់ទោស និងការសម្រាលទោស

អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ អាចបន្ថែម ឬបន្ថយនៅក្នុងលក្ខខណ្ឌដែលចែងដោយក្រមនេះ ។

**មាត្រា ៤៦.-** និយមន័យនៃបទឧក្រិដ្ឋ

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ :

១-ជាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

២-ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៤៧.-** និយមន័យនៃបទមជ្ឈិម

បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវវងនោះ មានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៤៨.-** និយមន័យនៃបទលហុ

បទល្មើសជាបទលហុ នៅក្នុងករណីដែល :

១-អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវវងនោះ មានរយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

២-បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។

**មាត្រា ៤៩.-** ការគណនាអំពីចិរវេលានៃទោសដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារ ១ (មួយ) ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ ។

**មាត្រា ៥០.-** លក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស

ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឱ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ ។

**មាត្រា ៥១.-** ការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងចិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល ។

**មាត្រា ៥២.-** ផលនៃទោសពិន័យ

ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលថវិការដ្ឋ ។

## ផ្នែកទី ២
## ទោសបន្ថែម

**មាត្រា ៥៣.-** ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការល្បូវលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត ។

**មាត្រា ៥៤.-** លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម

ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែង

ដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់ ។

ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន ។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ ។

**មាត្រា ៥៥.–** សិទ្ធិពលរដ្ឋដែលអាចដកបាន

សិទ្ធិពលរដ្ឋដែលអាចដកបានដូចមានចែងក្នុងចំណុច ១ នៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ រួមមាន :

១-សិទ្ធិបោះឆ្នោត ។

២-សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ។

៣-សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ ។

៤-សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្ដាល ឬជាអាណត្តិគាហករបស់តុលាការ ។

៥-សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់ ។

៦-សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការ ។

ទោសនេះអាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

**មាត្រា ៥៦.–** ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ

ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ មិនអនុវត្តទៅលើការបំពេញអាណត្តិដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ ឬការទទួលខុសត្រូវខាងសហជីពទេ ។ ការហាមឃាត់នេះ មិនអាចអនុវត្តចំពោះបទល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មានទេ ។

ទោសនេះអាចជាស្ថាពរ ឬក៏ជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

តុលាការត្រូវបញ្ជាក់មុខរបរដែលត្រូវហាមឃាត់ ។

**មាត្រា ៥៧.–** ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ

ការហាមឃាត់ចំពោះការបើកបរយានយន្ត មិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ទេ។

**មាត្រា ៥៨.–** ការព្យួរលិខិតបើកបរ

ទោសព្យួរលិខិតបើកបរ មិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ។ ទណ្ឌិតត្រូវប្រគល់លិខិតបើកបររបស់ខ្លួនទៅក្រឡាបញ្ជីតុលាការ ។ លិខិតបើកបរត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៥៩.-** ការហាមឃាត់ចំពោះការស្នាក់នៅទីកន្លែងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា

ទោសហាមឃាត់ការស្នាក់នៅ គឺជាការហាមឃាត់ដល់ទណ្ឌិត ចំពោះការមានមុខនៅទីកន្លែងខ្លះលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ទោសនេះមិនអាចលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម ។

តុលាការកំណត់បញ្ជីនៃទីកន្លែងដែលហាមឃាត់ និងកំណត់ថិរវេលានៃការហាមឃាត់ ។

ការហាមឃាត់ការស្នាក់នៅ រួមមានវិធានការតាមដាន ។

ទណ្ឌិតត្រូវតែ :

១-ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាលដែលតុលាការបានចាត់តាំង ។

២-ចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬកងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ ។

តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន ។

សេចក្តីសម្រេចរបស់តុលាការ ត្រូវជូនដំណឹងដោយព្រះរាជអាជ្ញាដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**មាត្រា ៦០.-** ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា មិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ។

ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការ ។ លិខិតឆ្លងដែននេះ ត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនបានទេ ក្នុងរយៈពេលដែលកំពុងទទួលទោសនោះ ។

**មាត្រា ៦១.-** ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដល់ទណ្ឌិតដែលជាជនបរទេស

ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល និងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។ ការហាមឃាត់នេះ នាំឱ្យមានការបណ្តេញទណ្ឌិតឱ្យចេញដោយពេញច្បាប់នៅពេលបញ្ចប់ទោសដាក់ពន្ធនាគារ ។

**មាត្រា ៦២.-** ការរឹបអូស

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចតទៅ :

១-ឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើស ។

២-វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុ នៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

ប៉ុន្តែ ការរឹបអូសមិនអាចប្រកាសបានទេ ប្រសិនបើមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។

**មាត្រា ៦៣.-** ការចាត់ចែងទ្រព្យសម្បត្តិរឹបអូស

កាលបើការរឹបអូសបានក្លាយទៅជាស្ថាពរ ទ្រព្យសម្បត្តិរឹបអូសក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដែលចែងអំពីការប្រគល់ផ្សេងពីនេះ ។

រដ្ឋអាចលក់ ឬបំផ្លាញទ្រព្យរឹបអូស តាមនីតិវិធីស្តីពីការលក់ទ្រព្យសម្បត្តិរដ្ឋ ។

**មាត្រា ៦៤.-** ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ

ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។ ការហាមឃាត់នេះត្រូវអនុវត្តទៅលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦៥.-** ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ

ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងលទ្ធកម្មសាធារណៈទាំងឡាយដែលរៀបចំដោយ :

១-រដ្ឋ ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទោសបណ្តេញចេញនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៦៦.-** ការបិទត្រឹះស្ថាន

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថានដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង ។

ទោសបិទគ្រឹះស្ថាននេះអាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៦៧.-** ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលត្រូវប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៦៨.-** ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស

ទោសបិទផ្សាយសេចក្ដីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ ទេ ។ ការបិទផ្សាយអាចធ្វើទាំងស្រុង ឬតាមសម្រង់ ឬតាមនិទ្ទេសធម្មតា ។ សោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ។

ក្នុងករណីមានការបំបាត់ចោល ការលាក់បំបាំង ឬការហែកចោលសេចក្ដីប្រកាសនេះ ត្រូវតែធ្វើការបិទផ្សាយជាថ្មី ។ ការបិទផ្សាយនេះ ត្រូវចេញសោហ៊ុយដោយអ្នកបំបាត់ចោល លាក់បំបាំង ឬអ្នកហែកចោលសេចក្ដីប្រកាសនេះ ។

**មាត្រា ៦៩.-** ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ

ទោសផ្សាយសេចក្ដីសម្រេចរបស់តុលាការ ត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ ។

សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់ទណ្ឌិត ។ ក្នុងករណីមិនគោរពតាមទណ្ឌិតអាចត្រូវបង្ខំដល់រូបកាយ ។

បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្ដីសម្រេច សារព័ត៌មានមិនអាចបដិសេធការផ្សព្វផ្សាយនេះបានទេ ។

**មាត្រា ៧០.-** ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍

ទោសផ្សាយជាសាធារណៈនូវសេចក្ដីសម្រេចតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយតុលាការ ។ ការផ្សាយនេះមិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ ទេ ។ ការផ្សាយអាចផ្សាយទាំងស្រុង តាមសម្រង់ ឬតាមនិទ្ទេស ។ សោហ៊ុយនៃការផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ។

**មាត្រា ៧១.-** ពេលនៃការអនុវត្តទោសបន្ថែម

ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦ និង ៧ នៃមាត្រា ៩៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ ត្រូវអនុវត្តនៅពេលផុតទោសពន្ធនាគារ លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់តុលាការ។

## ផ្នែកទី ៣

## ទោសជំនួស

## កថាភាគទី ១

## ការងារសហគមន៍

**មាត្រា ៧២.-** និយមន័យនៃការងារសហគមន៍

កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍ ។

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកម្រៃ ជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល ។

**មាត្រា ៧៣.-** អ្នកមិនទទួលប្រយោជន៍នៃការងារសហគមន៍

នៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ ។

**មាត្រា ៧៤.-** របបគតិយុត្តនៃការងារសហគមន៍

ការងារសហគមន៍ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាអាទិ៍ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី ។

ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ ។

**មាត្រា ៧៥.-** គោលការណ៍ផ្សងផុលការខូចខាតដល់អ្នកដទៃ

រដ្ឋត្រូវតែចេញសោហ៊ុយផ្សងផុលការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍ ។ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ ទៅក្នុងសិទ្ធិជនរងគ្រោះ ។

## កថាភាគទី ២
## ការស្ដីបន្ទោស

**មាត្រា ៧៦.-** របបគតិយុត្តនៃការស្ដីបន្ទោស

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្ដីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ :

-ភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈដែលបណ្ដាលមកពីបទល្មើសបានបញ្ចប់

-ការខូចខាតត្រូវបានជួសជុលរួចហើយ និង

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ ។

## ជំពូកទី ៣
## របបនៃការប្រកាសទោស
## ផ្នែកទី ១
## របបទូទៅ

**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស

តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ ។

**មាត្រា ៩៧.-** ការប្រកាសមូលទោស

នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស :

-ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ

-ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

-ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

**មាត្រា ៩៨.-** ការប្រកាសទោសជំនួស

ទោសការងារសហគមន៍ជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

ការស្ដីបន្ទោសជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសការស្ដីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស

កាលណាបទល្មើសមួយត្រូវផ្ដន្ទាទោសដោយទោសបន្ថែមមួយឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះ ចេញ ។

**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម

តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោម :

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ ។

**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ ។ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា ។

**មាត្រា ១០២.-** ចិរវេលា និងអំឡុងពេលនៃការងារសហគមន៍

តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីចិរវេលានៃការងារ និងរយៈពេលដែលត្រូវបំពេញ ។ រយៈពេលនេះមិនអាចលើសពី ១ (មួយ) ឆ្នាំ ទេ ។

**មាត្រា ១០៣.-** បែបបទនៃការអនុវត្តទោសការងារសហគមន៍

បែបបទនៃការអនុវត្តទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គល ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ ។

ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។

## ជំពូកទី ៦
## ទោសដែលអាចអនុវត្តចំពោះអនីតិជន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែ ចិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល

បទប្បញ្ញត្តិស្តីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

## ផ្នែកទី ២

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែងសម្រាប់អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ។

# ជំពូកទី ៧

# ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល

## ផ្នែកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦៧.-** ទោសដែលត្រូវរងដោយនីតិបុគ្គល

ទោសជាយថាប្រភេទដែលត្រូវរងដោយនីតិបុគ្គលមានដូចតទៅ :

១-ទោសពិន័យក្នុងឋានៈជាមូលទោស ។

២-ទោសបន្ថែមដែលរៀបរាប់នៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមនេះ ។

## ផ្នែកទី ២

## ទោសបន្ថែម

**មាត្រា ១៦៨.-** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានដូចតទៅ :

១-ការរំលាយចោល ។

២-ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

៣-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ។

៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជូញដូរបាន ក្រៅពីឧបករណ៍អាចជូញដូរបាន ដែលកំណត់ដោយធនាគារ ។

៧-ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់ ។

៨-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស ។

៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន ។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

១១-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

១២-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន ។

**មាត្រា ១៦៩.-** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម

ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់ ។

**មាត្រា ១៧០.-** ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល

សេចក្ដីសម្រេចដែលបង្គាប់ឱ្យរំលាយនីតិបុគ្គល នាំឱ្យមានការបញ្ជូននីតិបុគ្គលនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី ។

**មាត្រា ១៧១.-** ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការមិនអាចលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ។ សេចក្ដីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឱ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម ។ ជារៀងរាល់ ៦ (ប្រាំមួយ) ខែ យ៉ាងតិច អាណត្តិគាហកតុលាការធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន ។

ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការ ព្រះរាជអាជ្ញាអាចប្តឹងទៅតុលាការដែលបានប្រកាសឱ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ ។

តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់តំណាងអយ្យការ អាណត្តិគាហកតុលាការ និងជាយថាហេតុ មេធាវីរបស់នីតិបុគ្គលនោះ ។

**មាត្រា ១៧២.-** ការហាមឃាត់ចំពោះការធ្វើសកម្មភាព

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់ចិរវេលា ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់ ។

**មាត្រា ១៧៣.-** ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ

ទោសបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួម ដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំ ដោយ :

១-រដ្ឋ ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោសនេះ អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់ចិរវេលាមួយមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

**មាត្រា ១៧៤.-** ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ

ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ឱ្យធ្វើការដាក់ប្រាក់សន្សំ អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ការហាមឃាត់នេះ នាំឱ្យមានការហាមឃាត់ដល់នីតិបុគ្គលចំពោះការអំពាវនាវដើម្បីឱ្យដាក់ឧបករណ៍អាចជួញដូរបានរបស់ខ្លួនទៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬក្រុមហ៊ុនមូលបត្រ ។

ការហាមឃាត់នេះនាំឱ្យមានការហាមឃាត់ចំពោះការផ្សព្វផ្សាយជាសាធារណៈដែរ ។

**មាត្រា ១៧៥.-** ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន

ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន អាចជាស្ថាពរ ឬជាបណ្ដោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ចំពោះការហាមឃាត់ប្រើប្រាស់បណ្ណទូទាត់ ក៏ដូចគ្នាដែរ ។

**មាត្រា ១៧៦.-** ការបិទគ្រឹះស្ថាន

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះ នូវសកម្មភាពដែលបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ។

ទោសនេះអាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ

យ៉ាងច្រើន ។

**មាត្រា ១៧៧.-** ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានមួយ ដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬជាបណ្ដោះអាសន្នក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ១៧៨.-** ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស

កាលបើការរឹបអូសក្លាយជាស្ថាពរ វត្ថុរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែបទប្បញ្ញត្តិដោយឡែកបានចែងអំពីការប្រគល់ផ្សេងទៀត ។

រដ្ឋអាចលក់ ឬបំផ្លាញចោលវត្ថុរឹបអូសនៅក្នុងទម្រង់ដែលមានចែងសម្រាប់ការលក់ទ្រព្យសម្បត្តិរបស់រដ្ឋ ។ ច្បាប់អាចចែងអំពីការបំផ្លាញចោលនូវវត្ថុខ្លះផងដែរ ។

កាលបើវត្ថុរឹបអូសមិនត្រូវបានចាប់យកទេ ហើយនិងមិនអាចប្រគល់ឱ្យបានទេនោះ ទណ្ឌិតត្រូវចេញសងតម្លៃនៃវត្ថុរឹបអូសនេះ ។ តម្លៃនេះត្រូវបានកំណត់ដោយតុលាការ ។ វិធានការដើម្បីប្រមូលប្រាក់នេះ ត្រូវធ្វើឡើងដូចក្នុងរឿងបង្ខំដល់រូបកាយដែរ ។

**មាត្រា ១៧៩.-** ការរឹបអូស និងសិទ្ធិតតិយជន

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចខាងក្រោមនេះ :

១-ឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

២-វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

៤-ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើតឡើង ។

ក៏ប៉ុន្តែ ការរឹបអូសមិនអាចត្រូវប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។

**មាត្រា ១៨០.-** ការបិទផ្សាយសេចក្តីសម្រេច

ការបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលប្រាប់ដោយតុលាការ និងសម្រាប់រយៈពេលមួយដែលកំណត់ឡើងដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ ។ ការបិទផ្សាយ អាចទាំងស្រុងតាមសម្រង់ ឬតាមនិទ្ទេសធម្មតា ។ សោហ៊ុយនៃការបិទផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ក្នុងករណីដែលដកបំបាត់ចេញ លាក់បំបាំង ឬហែកចោលសេចក្តីប្រកាសបិទផ្សាយនោះ ត្រូវធ្វើការបិទផ្សាយជាថ្មីម្តងទៀត ។ សោហ៊ុយនៃការបិទផ្សាយនេះត្រូវចេញដោយជនល្មើសដែលជាអ្នកដកបំបាត់ចោល លាក់បំបាំង ឬហែកចោល ។

**មាត្រា ១៨១.-** ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍

ទោសផ្សាយសេចក្តីសម្រេច តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ឡើងដោយតុលាការ ។ ការផ្សាយនេះ មិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ ។ ការផ្សាយនេះ អាចផ្សាយទាំងស្រុង តាមសម្រង់ ឬតាមនិទ្ទេស ។ សោហ៊ុយនៃការផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ទោសផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់នីតិបុគ្គល ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារព័ត៌មានមិនអាចបដិសេធការចុះផ្សាយនេះបានទេ ។

**មាត្រា ១៨២.-** ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងរូបវន្តបុគ្គល និងនីតិបុគ្គល

បទប្បញ្ញត្តិនៃមាតិកាទី ១ មាតិកាទី ២ និងមាតិកាទី ៣ នៃគន្ថីទី ១ នៃក្រមនេះ ដែលទាក់ទងនឹងរូបវន្តបុគ្គល ត្រូវអនុវត្តទៅលើនីតិបុគ្គលក្នុងកម្រិតដែលបទប្បញ្ញត្តិនេះ មិនផ្ទុយជាមួយនឹងបទប្បញ្ញត្តិនៃជំពូកនេះ ។

# ឧបសម្ព័ន្ធទី ៣
# ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

នស/រកម/០៨០៧/០២៤

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# គន្ថីទី ១

# បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

## មាតិកាទី ១

## គោលការណ៍ទូទៅ

### ជំពូកតោល

### គោលការណ៍ទូទៅ

**មាត្រា ១.** – គោលបំណងនៃក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនីតិវិធីព្រហ្មទណ្ឌ មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ។

បទប្បញ្ញត្តិនៃក្រមនេះត្រូវយកទៅអនុវត្តចំពោះរឿងព្រហ្មទណ្ឌ កាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេសទេនោះ ។

**មាត្រា ២.** – បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងពីរផ្សេងគ្នា ។

បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់ ។

បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តចួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល ។

## មាតិកាទី ២

## បណ្តឹងអាជ្ញា

### ជំពូកតោល

### បណ្តឹងអាជ្ញា

**មាត្រា ៣.** – កម្មវត្ថុនៃបណ្តឹងអាជ្ញា

បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។

**មាត្រា ៤.** – ការចាប់ផ្តើមដំណើរការនៃបណ្តឹងអាជ្ញាដោយអយ្យការ

បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ ។

អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ។

**មាត្រា ៥.** – ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ។ ពាក្យប្តឹងដោយមានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបញ្ញត្តដោយមាត្រា ១៣៨ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ ។

យុត្តាធិការព្រហ្មទណ្ឌក៏អាចទទួលបណ្ដឹងពីមន្ត្រីរាជការ ឬភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកបានប្រគល់អំណាចឱ្យផងដែរ ។

**មាត្រា ៦.** – ការដាក់ពាក្យប្ដឹងទាមទារដោយជនរងគ្រោះ

បុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើស អាចដាក់ពាក្យប្ដឹងបាន ។ ពាក្យប្ដឹងសាមញ្ញ គ្មានអានុភាពនាំឱ្យធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ ។

នៅក្នុងករណីដែលពាក្យប្ដឹងស្ថិតនៅដោយគ្មានចម្លើយ ឬត្រូវបានតម្កល់ទុកឥតចាត់ការ ដោយព្រះរាជអាជ្ញា ជនរងគ្រោះអាចប្ដឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទៅតាមរបៀប ដូចដែលមានចែងទុកដោយមាត្រា ៤១ (ការតម្កល់រឿងទុកឥតចាត់ការ) នៃក្រមនេះ ។

**មាត្រា ៧.** – ការរលត់នៃបណ្ដឹងអាជ្ញា

មូលហេតុនៃការរលត់បណ្ដឹងអាជ្ញាមានដូចតទៅគឺ :

១-មរណភាពនៃជនល្មើស ។

២-ការផុតអាជ្ញាយុកាល ។

៣-ការលើកលែងទោសជាទូទៅ ។

៤-និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ។

៥-អាជ្ញាអស់ជំនុំ ។

កាលណាបណ្ដឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្ដើមបានទៀតទេ ឬត្រូវតែបញ្ឈប់ ។

**មាត្រា ៨.** – មូលហេតុផ្សេងទៀតនៃការរលត់បណ្ដឹងអាជ្ញា

កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្ដឹងអាជ្ញាក៏អាចផុតរលត់បានដែរ :

១-ដោយការសម្របសម្រួលជាមួយរដ្ឋ ។

២-ដោយការដកពាក្យប្ដឹង នៅក្នុងករណីដែលពាក្យប្ដឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ។

៣-ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល ។

**មាត្រា ៩.** – ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់

បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតអាជ្ញាយុកាលបានទេ ។

**មាត្រា ១០.** – អាជ្ញាយុកាលនៃបទល្មើស

លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនេះចេញ ថិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាមានដូចតទៅគឺ :

-១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

-៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម

-១ (មួយ) ឆ្នាំ ចំពោះបទលហុ

**មាត្រា ១១.** – ការផ្តាច់រយៈពេលនៃអាជ្ញាយុកាល

ថិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស ។ អាជ្ញាយុកាលត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ ។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗ នាំឱ្យចាប់ផ្តើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាល តាមការវែកញែកនៃមាត្រា ១០ (អាជ្ញាយុកាលនៃបទល្មើស) នៃក្រមនេះ ។ ថិរវេលាថ្មីអាចយកទៅជំទាស់បានចំពោះជនគ្រប់រូបដែលទាក់ទិននៅក្នុងរឿងនេះ ។

**មាត្រា ១២.** – អាជ្ញាអស់ជំនុំ

ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ ។

## គន្ថីទី ២

## អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ស៊ើបសួរ និងស៊ើបអង្កេត

## មាតិកាទី ១

## អង្គការអយ្យការ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៧.** – តួនាទីរបស់អង្គការអយ្យការ

អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ ។ អង្គការអយ្យការធានាភ័ប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន ។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ ។

ចៅក្រមអយ្យការត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ ។

**មាត្រា ២៨.** – ចៅក្រមអយ្យការ

ចៅក្រមអយ្យការមាន :

១-អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។

២-អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

៣-ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ។

## ជំពូកទី ២

## ការអនុវត្តបណ្តឹងអាជ្ញា

**មាត្រា ៤០.** – ជម្រើសនៃការចោទប្រកាន់

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ។

ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើស

ព្រហ្មទណ្ឌ ។ មុននឹងសម្រេចព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម ។

ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៤១.** – ការតម្កល់រឿងទុកឥតចាត់ការ

កាលណាបណ្តឹងណាមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្តឹង អំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីដែលមានចែងក្នុងមាត្រា ៤០ (បញ្ជីនៃពាក្យប្តឹង) នៃក្រមនេះ ។

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងច្បាប់ និងសំអាងហេតុ ។ ការតម្កល់ទុកឥតចាត់ការនេះគ្មានអាជ្ញាអស់ជំនុំទេ ។

ព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញ ក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ ។

ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ។

ការតវ៉ានេះត្រូវធ្វើនៅក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ការតវ៉ានេះត្រូវធ្វើតាមបណ្តឹងសាមញ្ញ នៅអង្គការអយ្យការដែលពាក់ព័ន្ធ ។ បន្ទាប់មក សំណុំរឿងត្រូវបានបញ្ជូនភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដោយតំណាងអយ្យការអមសាលាដំបូង ។

ប្រសិនបើយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូង ឱ្យធ្វើការចោទប្រកាន់ ។ អគ្គព្រះរាជអាជ្ញាធ្វើអធិបញ្ញា តាមការណែនាំជាលាយលក្ខណ៍អក្សរ ។ នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ទុកជាបានការ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវឱ្យដំណឹងអំពីសេចក្តីសម្រេចនេះដល់អ្នកប្តឹងតវ៉ា ។

**មាត្រា ៤២.** – កាតព្វកិច្ចធ្វើបណ្តឹងបរិហារចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

អាជ្ញាធរសាធារណៈ ឬមន្ត្រីគ្រប់រូបដែលនៅក្នុងការបំពេញមុខងាររបស់ខ្លួន បានដឹងអំពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬដល់មន្ត្រីនគរបាលយុត្តិធម៌ ដោយត្រូវបញ្ជូនឲ្យព័ត៌មាន កំណត់ហេតុ លិខិត និងវត្ថុតាងទាំងអស់ ដែលទាក់ទងនឹងបទល្មើសនោះ ភ្ជាប់ជាមួយផង ។

មិនអាចមានការលើកលែងផ្សេងណា ក្រៅពីការលើកលែងស្តីអំពីអាថ៌កំបាំងខាងវិជ្ជាជីវៈ ក្នុងករណីដែលច្បាប់បានចែងយ៉ាងជាក់លាក់នោះទេ ។

**មាត្រា ៤៣.-** ការចោទប្រកាន់

ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាម :

-ការបើកធ្វើការស៊ើបសួរ

-ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ

-តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

**មាត្រា ៤៤.-** ការបើកការស៊ើបសួរ

ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ។

ការស៊ើបសួរត្រូវបានបើក តាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវផ្ញើទៅចៅក្រមស៊ើបសួរ ។ ការស៊ើបសួរ អាចបើកប្រឆាំងលើ បុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន :

-សេចក្ដីសង្ខេបនៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

-ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះ ត្រូវទុកជាមោឃៈ ។

**មាត្រា ៤៥.-** ការចោទប្រកាន់ក្នុងករណីបទមជ្ឈិម

ក្នុងករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាច :

-បើកការស៊ើបសួរដោយធ្វើដូចដែលបានចែងដោយមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ

-បញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់នៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចបានចែងនៅក្នុងមាត្រា ៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ឬ

-បង្គាប់ឱ្យនាំជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចដែលបានចែងក្នុងមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) និងមាត្រា ៤៨ (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ ។

**មាត្រា ៤៦.-** ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន :

-អត្តសញ្ញាណនៃជនជាប់ចោទ

-សេចក្ដីសង្ខេបនៃអង្គហេតុ

-ឈ្មោះបទល្មើស

-អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ។

ដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ។ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន ។

**មាត្រា ៤៧.– ការបង្ហាញខ្លួនភ្លាម**

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅ ៖

-បទល្មើសជាបទល្មើសជាក់ស្តែង តាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ

-ជនជាប់ចោទជានីតិជន

-រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

**មាត្រា ៤៨.– នីតិវិធីនៃការបង្ហាញខ្លួនភ្លាម**

កាលណាសម្រេចថា ត្រូវប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ ៖

-ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន

-ឱ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស

-ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ

-ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

មេធាវីជ្រើសរើស ឬចាត់តាំង ត្រូវបានទទួលដំណឹងភ្លាម ។ មេធាវីអាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន ។

និទ្ទេសនៃទម្រង់ការទាំងនេះ ត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូច្នោះទេ នីតិវិធីត្រូវទុកជាមោឃៈ ។

តុលាការជាន់ដំបូង ត្រូវបានទទួលបណ្តឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

ជនជាប់ចោទត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង ។

នៅពេលបង្ហាញខ្លួននេះ តុលាការក្រោយពីបានផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ ត្រូវប្រាប់ដល់ជនជាប់ចោទថា សាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួន ។

ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅពេលសវនាការក្រោយ ។

តុលាការអាចបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន ដោយសាលក្រមដែលមានបញ្ជាក់ពីសំអាងហេតុ ។ នៅក្នុងសាលក្រមនោះ តុលាការត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ ។ តុលាការចេញដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួន ។

សាលក្រមលើអង្គសេចក្តី ត្រូវតែប្រកាសក្នុងរយៈពេលដែលមិនអាចលើសពី ២ (ពីរ) សប្តាហ៍ គិតពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការ ។ ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ ក្រោយពីផុតរយៈពេល ២ (ពីរ) សប្តាហ៍ ។

ប្រសិនបើតុលាការដែលបានទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម យល់ឃើញថា លក្ខខណ្ឌនៃមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ មិនបានបំពេញទេ ឬក៏ដោយភាពសាំញ៉ាំនៃសំណុំរឿង តម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ ។ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង ។

**មាត្រា ៤៩.** – ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក្នុងករណីបទលហុ

ប្រសិនបើរឿងនោះជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះជនជាប់ចោទឱ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់ ដូចបានចែងនៅក្នុងមាត្រា ៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ។

**មាត្រា ៥០.** – បញ្ជីនៃពាក្យប្តឹង

នៅតាមតុលាការជាន់ដំបូងនីមួយៗ ត្រូវបង្កើតឱ្យមានបញ្ជីអយ្យការមួយសម្រាប់ចុះបណ្តឹងដែលប្តឹងដោយផ្ទាល់ដល់ព្រះរាជអាជ្ញា ឬដែលបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ។

គ្រប់បណ្តឹងទាំងអស់ត្រូវតែចុះក្នុងបញ្ជីដោយមានខ្លឹមសារដូចតទៅ :

-អត្តសញ្ញាណរបស់អ្នកប្តឹង

-កាលបរិច្ឆេទដែលអយ្យការបានទទួលពាក្យប្តឹង

-ប្រភពនៃបណ្តឹង : បណ្តឹងធ្វើមកផ្ទាល់ចំពោះព្រះរាជអាជ្ញា ឬក៏បញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌

-ប្រភេទនៃរឿងហេតុដែលអ្នកប្តឹងបានរាយការណ៍

-ចំណាត់ការលើពាក្យប្តឹង : ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។

បញ្ជីនៃពាក្យប្តឹងត្រូវកាន់កាប់ដោយលេខាធិការរបស់អយ្យការ ក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។ បញ្ជីអាចត្រូវបានបើកមើលដោយអាជ្ញាធរតុលាការទាំងអស់ ជាអាទិ៍គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

**មាត្រា ៨៦.** – និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺ :

-បទល្មើសដែលកំពុងប្រព្រឹត្ត

-បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ។

ត្រូវចាត់ទុកថា ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក :

-ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រផាប់ចាប់ប្រកីង

-បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។

**មាត្រា ៨៧.** – ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើសហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

**មាត្រា ៨៨.** – ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ ។

# ឧបសម្ព័ន្ធទី ៤
# ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

## មាត្រា ១.– គោលបំណង

ច្បាប់នេះមានគោលបំណង៖

- ធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស
- គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍
- ធានាការពារផលប្រយោជន៍សង្គមនិងសហគមន៍ ។

## មាត្រា ២.– គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន ។

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងច្បាប់ដោយឡែកផ្សេងទៀត ត្រូវយកមកអនុវត្ត លើកលែងតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់នេះ ។

## មាត្រា ៣.– វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើករណីអនីតិជនប្រព្រឹត្តបទល្មើស ។

## មាត្រា ៤.– និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

១- យុត្តិធម៌អនីតិជន សំដៅដល់ការការពារសិទ្ធិអនីតិជនតាមរយៈយន្តការ វិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងអនុវត្តដោយហ្មត់ចត់ ព្រមទាំងវិធាននៃការកំណត់ទោសក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស ។

២- អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់បុគ្គល ឬស្ថាប័នដែលអនុវត្តដោយស្របច្បាប់នូវមុខងាររបស់ខ្លួនដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជន ។

៣- អនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ។

៤- **អនីតិជនត្រូវការកិច្ចការពារ និងថែទាំ** សំដៅដល់អនីតិជនដែលត្រូវការកិច្ចការពារ និងថែទាំ ដោយមូលហេតុអនីតិជននោះគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬគ្មានការថែទាំ និងគ្រប់គ្រងត្រឹមត្រូវពីសំណាក់អ្នកតំណាងដែលច្បាប់បានកំណត់ ហើយកំពុងប្រឈមនឹងសភាពគ្រោះថ្នាក់ ឬរងការរំលោភបំពាន ឬបង្ហាញការគំរាមកំហែងដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន ។

៥- **អ្នកតំណាងដែលច្បាប់បានកំណត់** សំដៅដល់អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ ។

៦- **អ្នកទំនុកបម្រុង** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវបានជ្រើសរើសដោយអនីតិជន ឬដោយអាជ្ញាធរមានសមត្ថកិច្ច និងមានការយល់ព្រមពីអនីតិជនឲ្យទទួលខុសត្រូវក្នុងការទំនុកបម្រុងខ្លួនក្នុងអំឡុងពេលអនុវត្តនីតិវិធីដែលមានចែងក្នុងច្បាប់នេះ ។

៧- **នីតិវិធីកុមារមេត្រី** សំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ព័ន្ធនឹងការលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្តី តាមរយៈការប្រើប្រាស់ភាសានិងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និងក្នុងបរិយាកាសដែលផ្តល់ឲ្យអនីតិជននូវសុវត្ថិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន ។

៨- **របាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន** សំដៅដល់របាយការណ៍ស្តីពីស្ថានភាពទូទៅរបស់អនីតិជន និងការផ្តល់យោបល់វាយតម្លៃផ្សេងៗដែលធ្វើឡើងដោយភ្នាក់ងារសង្គមកិច្ច ។

៩- **ភ្នាក់ងារសង្គមកិច្ច** សំដៅដល់មន្ត្រីរបស់ក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាលជំនាញផ្នែកកុមារ និងច្បាប់ពាក់ព័ន្ធនឹងអនីតិជន ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១០- **មណ្ឌលយុវនីតិសម្បទា** សំដៅដល់មណ្ឌលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ផ្តល់សេវាការពារ ថែទាំ អប់រំ ស្តារនីតិសម្បទា និងសមាហរណកម្មដល់អនីតិជន ។

# ជំពូកទី ២
# គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន

## មាត្រា ៥.- គោលការណ៍ជាមូលដ្ឋាន

គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឲ្យមានការគោរពគោលការណ៍ដូចតទៅ ៖

- ត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា
- ត្រូវប្រព្រឹត្តប្រកបដោយមនុស្សធម៌ និងសេចក្ដីថ្លៃថ្នូរទៅលើអនីតិជន
- ត្រូវផ្ដល់ឱកាសឲ្យអនីតិជនសម្ដែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន
- ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្ដន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន
- មិនត្រូវរើសអើងចំពោះអនីតិជន មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ឋានៈសង្គម ធនធាន ដើមកំណើតជាតិ និន្នាការនយោបាយ ឬស្ថានភាពឯទៀត
- មិនត្រូវប្រើខ្នោះ និងឧបករណ៍ផ្សេងៗទៀតដែលប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់អនីតិជន លើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះដែលវិធានការទាំងឡាយមិនអាចអនុវត្តបាន ឬគ្មានប្រសិទ្ធភាព
- មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក តាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជន
- មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អនីតិជន និងដែលនាំឲ្យបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព ។ ការផ្សព្វផ្សាយរឿងក្ដីអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជ-អាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ
- សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

## មាត្រា ៦._ សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ។

# ជំពូកទី ៣

# ការទទួលខុសត្រូវព្រហ្មទណ្ឌ និងវដ្តប្បវេណីរបស់អនីតិជន

## មាត្រា ៧._ ការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

## មាត្រា ៨.- ការទទួលខុសត្រូវរដ្ឋប្បវេណី

បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៧៤៥ (អសមត្ថភាពក្នុងការទទួលខុសត្រូវ) និងមាត្រា ៧៤៦ (ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ) នៃជំពូកទី ១៦ (អំពើអនីត្យានុកូល) ក្នុងគន្ថីទី ៥ (កិច្ចសន្យាសំខាន់ៗ និងអំពើអនីត្យានុកូល)នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការទទួលខុសត្រូវរដ្ឋប្បវេណីរបស់អនីតិជន ។

## មាត្រា ៩.- ការកំណត់អាយុ

អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ។

ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត ។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន ។

ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ ។

# ជំពូកទី ៤

# ជំនួយផ្នែកសេវាសង្គមកិច្ច

## មាត្រា ១០.- ការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច

ការតែងតាំង ការទទួលស្គាល់ និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ចជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

បែបបទនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។

## មាត្រា ១១.- ភ្នាក់ងារសង្គមកិច្ច

ភ្នាក់ងារសង្គមកិច្ចមានភារកិច្ចជាអាទិ៍ ៖

- ជួបអនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី ជាពិសេស នៅដំណាក់កាលដំបូងនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ និងនៅក្នុងពន្ធនាគារ ដើម្បីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាបន្ទាន់ដល់អនីតិជន

- ប្រមូលព័ត៌មានស្តីពីស្ថានភាពគ្រួសារ អាកប្បកិរិយា ប្រវត្តិអប់រំ ការសិក្សា លក្ខខណ្ឌដែលទាក់ទងនឹងការរស់នៅ ការរីកលូតលាស់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលទាក់ទងនឹងកម្រិតយល់ដឹង បញ្ញាអារម្មណ៍ ផ្លូវចិត្ត សង្គមរបស់អនីតិជន ដើម្បីរៀបចំ និងផ្តល់របាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនជូនចៅក្រម អយ្យការ និងតុលាការ
- ផ្តល់ការគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី
- រៀបចំ និងផ្តល់ផែនការបង្វែរជូនអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យ និងសម្រេច
- ផ្តល់សេវាស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអនីតិជន
- ភារកិច្ចចាំបាច់ផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

## ជំពូកទី ៥
## នគរបាលយុត្តិធម៌ និងការស៊ើបអង្កេត

### មាត្រា ១២.- សមត្ថកិច្ចនគរបាលយុត្តិធម៌ក្នុងការពិនិត្យបទឧក្រិដ្ឋ និងបទមជ្ឈិម

នគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម កំណត់អត្តសញ្ញាណ និងចាប់អនីតិជន ព្រមទាំងប្រមូលភស្តុតាង ។

នគរបាលយុត្តិធម៌ដែលចាប់ខ្លួន ឬមន្ត្រីនគរបាលយុត្តិធម៌ដែលឃាត់ខ្លួនអនីតិជន ត្រូវប្រគល់របាយការណ៍ និងកំណត់ហេតុលម្អិតស្តីពីការចាប់ ឬឃាត់ខ្លួន និងប្រគល់អនីតិជននោះទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន ។

### មាត្រា ១៣.- អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការពិនិត្យ និងដោះស្រាយបទលហុ

អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទលហុ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអប់រំណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ រួចហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ជាបន្ទាន់ ។

ក្នុងករណីអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស ហើយបទល្មើសនោះជាបទលហុ នគរបាលយុត្តិធម៌អាចធ្វើការសម្រុះសម្រួលរវាងភាគីពាក់ព័ន្ធដើម្បីបញ្ចប់វិវាទ ។

ករណីដែលមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ នគរបាលយុត្តិធម៌ត្រូវធ្វើរបាយការណ៍ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នក តំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

## មាត្រា ១៤.- នីតិវិធីទាក់ទងនឹងអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ

អនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

គ្រប់អំពើដែលជាបទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ក្នុងករណីមានវិវាទទាក់ទងនឹងអាយុរបស់អនីតិជននៅពេលប្រព្រឹត្តបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងនេះទៅព្រះរាជអាជ្ញាជាបន្ទាន់ ។

## មាត្រា ១៥.- ការចាប់ខ្លួន

នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ តែក្នុងករណីដែលអនីតិជនប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការចាប់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការចាប់ខ្លួនអនីតិជនត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។

ការអនុវត្តការចាប់ខ្លួន នគរបាលយុត្តិធម៌ត្រូវចៀសវាងការធ្វើឲ្យអាម៉ាស់មុខនិងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន និងត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត ។

## មាត្រា ១៦.- ការឆែកឆេរលើខ្លួនបុគ្គល

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរលើខ្លួនបុគ្គលដែលជាអនីតិជនបាន ។ ការឆែកឆេរខ្លួនបុគ្គលត្រូវធ្វើឡើងដោយបុគ្គលដែលមានភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយអនីតិជននោះឡើយ លើកលែងតែក្នុងករណីមិនអាចចៀសវាងបាន ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុនិងចុះនិទ្ទេសអំពីបញ្ហានេះ ។

## មាត្រា ១៧.- ការឃាត់ខ្លួនអនីតិជនប្រព្រឹត្តបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំបាន ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ជឿជាក់ថាអនីតិជនអាចរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ ។ ប៉ុន្តែ អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃាត់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជន នោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការឃាត់ខ្លួនអនីតិជន ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម ។ ការឃាត់ខ្លួននេះ សម្រាប់តែជាវិធានការចុងក្រោយប៉ុណ្ណោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ចប់ដំណើរការស៊ើបអង្កេតឲ្យបានលឿនបំផុតដែលអាចធ្វើទៅបាន ។

## មាត្រា ១៨.- ការជូនដំណឹងបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជននោះ ។ ក្នុងករណីមិនអាចផ្តល់ដំណឹងនេះជាបន្ទាន់ ត្រូវជូនដំណឹងដល់អ្នកតំណាងដែលច្បាប់បានកំណត់ក្នុងរយៈពេលយ៉ាងខ្លីបំផុតដែលអាចធ្វើ ទៅបាន អំពី ៖

- មូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន និងប្រភេទនៃបទល្មើស
- ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ
- សិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់នៅអង្គភាពនគរបាល ។

ក្នុងករណីមិនអាចទាក់ទងអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនបាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រឹងប្រែងទាក់ទងអ្នកទំនុកបម្រុងដែលជ្រើសរើសដោយអនីតិជន ឬដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយមានការយល់ព្រមពីអនីតិជននោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងភ្លាមផងដែរទៅភ្នាក់ងារសង្គមកិច្ច បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីផ្តល់សេវាគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងភ្លាមទៅមេធាវីរបស់អនីតិជន ប្រសិនបើមាន ។ ក្នុងករណីដែលគ្មានការជ្រើសរើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានបញ្ជីឈ្មោះមេធាវីសម្រាប់ឲ្យអនីតិជនធ្វើការជ្រើសរើស ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែភាសាដោយមិនយកកម្រៃឲ្យអនីតិជន ក្នុងករណីដែលអនីតិជននោះពុំមានអ្នកបកប្រែភាសាផ្ទាល់ខ្លួន ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុដោយឡែកអំពីការជូនដំណឹង ឬការព្យាយាមជូនដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវីរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច និងស្វែងរកមេធាវីនិងអ្នកទំនុកបម្រុង ទោះបីជាការជូនដំណឹង ឬការព្យាយាមជូនដំណឹងនោះមិនបានទទួលលទ្ធផលក្តី។

## មាត្រា ១៩.- ការពិនិត្យសុខភាពផ្លូវកាយ ឬសុខភាពផ្លូវចិត្ត

ក្នុងករណីអនីតិជនមានរបួស ឬមានបញ្ហាសុខភាពហើយត្រូវការការព្យាបាល នគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជនទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតបំផុត ដើម្បីធ្វើការពិនិត្យព្យាបាល ។

រាល់ការចំណាយលើការពិនិត្យនិងព្យាបាលជាបន្ទុករបស់រដ្ឋ ក្នុងករណីដែលឪពុកម្តាយ ឬអ្នកអាណាព្យាបាលគ្មានលទ្ធភាព ។

កំណត់ហេតុ ឬរបាយការណ៍ពាក់ព័ន្ធនឹងសុខភាព ត្រូវបញ្ចូលទៅក្នុងសំណុំរឿង ។

## មាត្រា ២០.- កំណត់ហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន

ច្បាប់ចម្លងនៃកំណត់ហេតុស្ដីពីការចាប់ខ្លួននិងកំណត់ហេតុសរុបនៃការឃាត់ខ្លួនអនីតិជនត្រូវផ្ដល់ឲ្យមេធាវីតាមការស្នើសុំ ។

នៅតាមអង្គភាពដែលមាននគរបាលយុត្តិធម៌នីមួយៗ ត្រូវមានបញ្ជីដោយឡែកស្ដីពីការឃាត់ខ្លួនអនីតិជន ។

## មាត្រា ២១.- នីតិវិធីមុនការស្តាប់ចម្លើយ

អនីតិជនត្រូវទទួលបានឱកាសសន្ទនា ឬទំនាក់ទំនងជាមួយអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច និងមេធាវីជាលក្ខណៈឯកជននិងជាសម្ងាត់ ប្រសិនបើមានការស្នើសុំ លើកលែងតែជនទាំងនេះមានការទាក់ទិនក្នុងរឿងជាមួយ ។ ការជួបសន្ទនាឬទាក់ទងគ្នាមានរយៈពេល ៣០ (សាមសិប) នាទី និងត្រូវធ្វើមុនពេលស្តាប់ចម្លើយ ប្រសិនបើអាចធ្វើទៅបាន ។

## មាត្រា ២២.- ការស្តាប់ចម្លើយ

មុនពេលផ្ដើមស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់អនីតិជនអំពីសិទ្ធិជាមូលដ្ឋានជាពិសេស គឺសិទ្ធិមិនផ្ដល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី ។

ការស្តាប់ចម្លើយត្រូវប្រព្រឹត្តដោយមានវត្តមានរបស់មេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រីមានលក្ខណៈជាឯកជននិងជាការសម្ងាត់ ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចដែលមានសិទ្ធិ ហើយអាចផ្ដល់ជំនួយដល់អនីតិជន មានសិទ្ធិចូលរួមក្នុងការស្តាប់ចម្លើយអនីតិជនបាន ។

មន្ត្រីនគរបាលយុត្តិធម៌អាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយ ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះ ត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។ ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់មិនអាចចូលរួមបាន ត្រូវអនុញ្ញាតឲ្យអ្នកទំនុកបម្រុងអនីតិជនចូលរួមជំនួសប្រសិនបើមាន ។

ក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬមេធាវីរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ចក្នុងពេលស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយបញ្ជាក់ពីមូលហេតុនៃអវត្តមាននោះ ហើយបញ្ចូលក្នុងសំណុំរឿងរបស់អនីតិជន ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានបាន មន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុញ្ញាតឲ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយ ។

អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុនោះ ដោយត្រូវចុះនិទ្ទេស ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចដែលមានវត្តមានត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ។ ក្នុងករណីអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស នៅក្នុងកំណត់ហេតុនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ២៣.- ការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាផ្លូវឡើយ ក្នុងករណីគ្មានការយល់ព្រមជាមុនពីអនីតិជន ដោយមានការពិគ្រោះយោបល់ជាមួយមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ។ ក្នុងករណីអនីតិជនយល់ព្រម ត្រូវមានកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងផ្តិតម្រាមដៃ ។

អនីតិជនដែលត្រូវឃាត់ខ្លួន ត្រូវដាក់ដាច់ដោយឡែកពីនីតិជន និងទៅតាមភេទ ។

អនីតិជនមិនត្រូវបានទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុតបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬទទួលរងអំពើអមនុស្សធម៌ណាមួយឡើយ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL •

# ជំពូកទី ៦
## ការចោទប្រកាន់

### មាត្រា ២៤.- សមត្ថកិច្ចរបស់អង្គការអយ្យការ

បណ្ដឹងអាជ្ញាត្រូវអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ ។ អយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអនីតិជន ។

ការចោទប្រកាន់ករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជន ត្រូវឲ្យតំណាងអយ្យការដែលទទួលបានការចាត់តាំងពិសេសឲ្យកាន់រឿងក្ដីអនីតិជន ទោះជាការចាត់តាំងនោះឲ្យធ្វើតែរឿងអនីតិជនដាច់ខាតឬមិនដាច់ខាតក្ដី ។ តំណាងអយ្យការដែលនឹងត្រូវចាត់ឲ្យកាន់រឿងក្ដីអនីតិជន ត្រូវទទួលបានការបណ្ដុះបណ្ដាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងយុត្តិធម៌អនីតិជន ។

### មាត្រា ២៥.- ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន

ព្រះរាជអាជ្ញាត្រូវពិនិត្យសំណុំឯកសារ និងពាក្យប្ដឹងដែលខ្លួនបានទទួល ដើម្បីផ្ទៀងផ្ទាត់អាយុរបស់អនីតិជន ។

ក្នុងករណីមានវិមតិសង្ស័យអំពីអាយុរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីស្វែងរកឲ្យឃើញអាយុពិតប្រាកដរបស់អនីតិជននោះ ។

ក្នុងករណីការស៊ើបអង្កេតបឋមនោះមិនអាចឈានដល់ការសន្និដ្ឋានអំពីអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ ។

### មាត្រា ២៦.- ការស្ដាប់ចម្លើយ

ព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមស្ដាប់ចម្លើយអំពីសិទ្ធិដែលមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ ដោយប្រើភាសានិងអាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជនមុនពេលធ្វើការស្ដាប់ចម្លើយ ។ ក្នុងករណីដែលគ្មានការជ្រើសរើសព្រះរាជ-អាជ្ញាត្រូវចាត់តាំងមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះ ។

ការស្ដាប់ចម្លើយអនីតិជនត្រូវធ្វើជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ។ ការស្ដាប់ចម្លើយនេះត្រូវមានវត្តមានមេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ។ ព្រះរាជអាជ្ញាអាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្ដាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។

ក្នុងករណីអវត្តមានជនណាមួយខាងលើ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុ ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ ។

ព្រះរាជអាជ្ញាត្រូវអនុញ្ញាតឲ្យមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយបាន ។

មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខាឬផ្តិតម្រាមដៃលើកំណត់ហេតុ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខាឬផ្តិតម្រាមដៃលើកំណត់ហេតុ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ២៧.- ការតម្កល់រឿងទុកឥតចាត់ការចំពោះអនីតិជនអាយុក្រោម ១៤ (ដប់បួន)ឆ្នាំ

ក្នុងករណីអនីតិជនមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ព្រះរាជអាជ្ញាត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ។

ក្រោយពីបានទទួលអនីតិជនពីព្រះរាជអាជ្ញាហើយ ប្រសិនបើមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត យល់ឃើញថាអនីតិជននោះចាំបាច់ត្រូវមានកិច្ចការពារនិងថែទាំ នោះមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បាន

កំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ២៨.- អំណាចរបស់តំណាងអយ្យការក្នុងការបង្វែរ

ករណីអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។

ករណីព្រះរាជអាជ្ញាសម្រេចបង្វែរ បទប្បញ្ញត្តិនៃជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ។

ប្រសិនបើការរៀបចំផែនការបង្វែរត្រូវការពេលវេលា ព្រះរាជអាជ្ញាត្រូវផ្អាកនីតិវិធីចោទប្រកាន់ និងបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ។

ព្រះរាជអាជ្ញាជូនដំណឹងដល់ជនរងគ្រោះឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីចោទប្រកាន់ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ២៩.- ការឲ្យដំណឹងអំពីការចោទប្រកាន់

ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងភ្លាមដោយផ្ទាល់និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្រប ត្រូវឲ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ឬអ្នកទំនុកបម្រុងនិងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •